# 法輪功
# ហ្វាលុនគង់

**(Khmer Version)**

**李洪志**

**លីហុងជី**

# មាតិកា

**ជំពូកទី១ • មុំពូកថា** ........................................ 1

**I. ប្រភពដើមរបស់ឈើគង់** ........................................ 3

**II. `ឈើ´ និង `គង់´** ........................................ 6

**III. `អំណាចគង់´ និង `សីលគង់´** ........................................ 8

១. អំណាចគង់គឺពឹងផ្អែកលើការបួសចិត្តគំនិតចេញមក ........................................ 8

២. សីលគង់មិនមែនជាការស្វែងរករបស់មនុស្សហាត់គង់ ........................................ 9

៣. កាន់ជាប់អំណាចគង់ ........................................ 13

**IV. បញ្ញាញាណ** ........................................ 15

១. បើកបញ្ញាញាណ ........................................ 15

២. ជាន់ថ្នាក់របស់បញ្ញាញាណ ........................................ 19

៣. ទូរនេត្រ ........................................ 23

៤. អវកាស ........................................ 24

**V. ព្យាបាលជំងឺដោយឈើគង់និងព្យាបាលជំងឺនៅមន្ទីរពេទ្យ** ........................................ 27

**VI. ឈើគង់ពុទ្ធវង្សនិងពុទ្ធសាសនា** ........................................ 32

១. ឈើគង់ពុទ្ធវង្ស ........................................ 32

២. ពុទ្ធសាសនា ........................................ 34

**VII. សុចរិតធម៌និងទុចរិតធម៌** ........................................ 36

១. ទ្វារចំហៀងផ្លូវឆ្វេង ........................................ 36

២. ឈើគង់សិល្បៈក្បាច់គុន ........................................ 38

៣. បួសបញ្ឆោសនិងកម្មីគង់ ........................................ 39

៤. ភាសាចក្រវាល ........................................ 41

៥. ព័ត៌មានរាងកាយភ្ជាប់ ........................................ 43

៦. គង់ហ្វាសុចរិតក៏អាចហាត់ចេញទុចរិតធម៌ ............................45
**ជំពូកទី២ • ហ្វាលូនគង់ ..................................................46**
**I. តួនាទីរបស់ហ្វាលូន ..................................................46**
**II. រូបសណ្ឋានរបស់ហ្វាលូន ..................................................50**
**III. លក្ខណៈបួសហាត់របស់ហ្វាលូនគង់ ..................................................51**
១. ធម៌ហាត់មនុស្ស ..................................................51
២. បួសហាត់សតិម្ចាស់ ..................................................54
៣. ហាត់គង់មិនសម្តែងទិសដៅ, ពេលវេលា ..................................................57
**IV. ចិត្តជីវិតបួសទាំងទ្វេ ..................................................58**
១. ផ្លាស់ប្រែរាងកាយ ..................................................58
២. វង់សកលហ្វាលូន ..................................................61
៣. បើកស្រឡះខ្សែវណ្ណ ..................................................64
**V. គំនិត ..................................................65**
**VI. ជាន់ថ្នាក់បួសហាត់របស់ហ្វាលូនគង់ ..................................................68**
១. បួសហាត់ជាន់ថ្នាក់ខ្ពស់ ..................................................68
២. ទម្រង់បង្ហាញរបស់គង់ ..................................................69
៣. បួសហាត់ផុតពីលោកីយ៍ធម៌ ..................................................71
**ជំពូកទី៣ • បួសហាត់ចិត្តគំនិត ..................................................73**
**I. អត្ថន័យរបស់ចិត្តគំនិត ..................................................74**
**II. បាត់និងបាន ..................................................76**
**III. "សច្ចៈ-ករុណា-ខន្តី" បួសដំណាលគ្នា ..................................................82**
**IV. កម្ចាត់ចិត្តច្រណែន ..................................................85**
**V. កម្ចាត់ចិត្តប្រកាន់ ..................................................88**

VI. អំណាចកម្ម ....................................................92
១. ការបង្កើតនៃអំណាចកម្ម ....................................92
២. រំលាយកម្ម ....................................................96
VII. អន្ទងខ្មោច ....................................................102
VIII. និស្ស័យនិងភ្ញាក់ដឹង ....................................105
IX. ចិត្តស្ងប់ស្ងាត់ ....................................................109

**ជំពូកទី៤ • លំហាត់ហ្វាលូនគង់** ..............................113

I. លំហាត់ព្រះពុទ្ធបង្ហាញដៃមួយពាន់ ..............................114
II. លំហាត់ឈរឱបហ្វាលូន ....................................125
III. លំហាត់ស្រោចស្រឡះពីរប៉ូល ..............................129
IV. លំហាត់វង់សកលហ្វាលូន ....................................135
V. លំហាត់ពង្រឹងទេពអំណាច ....................................141
តម្រូវការនិងការប្រុងប្រយ័ត្នជាមូលដ្ឋានមួយចំនួននៃការបួសហាត់ហ្វាលូនគង់ ....................................152

**ជំពូកទី៥ • ឆ្លើយសំណួរ** ............................................155

I. ហ្វាលូននិងហ្វាលូនគង់ ....................................155
II. គោលសីលធម៌និងលំហាត់ ....................................162
III. បួសហាត់ចិត្តគំនិត ....................................199
IV. បញ្ញាញាណ ....................................................209
V. ទុក្ខវេទនា ....................................................222
VI. អវកាសនិងមនុស្សជាតិ ....................................226

# ជំពូកទី១ • បុព្វកថា

ឈីគង់នៅប្រទេសយើងមានប្រភពយូរលង់, មានប្រវត្តិសាស្ត្រដ៏វែង, ហេតុនោះ, ប្រជាជនប្រទេសយើងបួសហាត់ឈីគង់មានលក្ខខណ្ឌងាយស្រួលដោយបានព្រះប្រទាន។ អំពីបួសហាត់ឈីគង់សុចរិតធម៌នៃទាំងពីរវង្សធំពុទ្ធវង្សនិងតាវវង្ស, ធ្លាប់បានផ្សព្វផ្សាយជាសាធារណៈជាច្រើនមហាធម៌បង្រៀនសម្ងាត់។ វិធីសាស្ត្របួសហាត់របស់តាវវង្សគឺពិសេសណាស់; ពុទ្ធវង្សក៏មានវិធីសាស្ត្របួសហាត់រៀងខ្លួនផងដែរ។ ហ្វាលូនគង់ជាក់ស្ដែងគឺជាមហាធម៌បួសហាត់ជាន់ថ្នាក់ខ្ពស់នៃឈីគង់ពុទ្ធវង្ស។ នៅលើថ្នាក់បង្រៀន, ខ្ញុំមុនដំបូងត្រូវតែកែសំរួលរាងកាយរបស់អ្នករាល់គ្នារហូតដល់សមស្របនឹងស្ថានភាពនៃការបួសហាត់លើជាន់ថ្នាក់ខ្ពស់, បន្ទាប់មកនៅត្រូវតែដំឡើងហ្វាលូននិងយន្តការឈីលើរាងកាយឱ្យអ្នករាល់គ្នា, ហើយបង្រៀនគង់ហ្វាឱ្យអ្នករាល់គ្នាទៀត។ ក្រៅពីនេះ, ខ្ញុំនៅមានបរមីការពារលោកអ្នក។ ប៉ុន្តែ, ទាំងនេះនៅមិនទាន់គ្រប់គ្រាន់ទេ, នៅពុំអាចសម្រេចបានគោលបំណងបង្កើនគង់, នៅតម្រូវអ្នករាល់គ្នាត្រូវតែយល់ដឹងពីគោលសីលធម៌នៃការបួសហាត់លើជាន់ថ្នាក់ខ្ពស់។ នេះជាក់ស្ដែងគឺជាខ្លឹមសារដែលសៀវភៅនេះចាំបាច់សម្ដែង។

ខ្ញុំនៅលើជាន់ថ្នាក់ខ្ពស់សម្ដែងគង់, ដូច្នេះខ្ញុំមិនមែនសម្ដែងបួសខ្សែវណ្ណណាមួយ, ចំណុចចាក់ម្ជុលវិទ្យាសាស្ត្រណាមួយ, ផ្លូវថាមពលណាមួយ; ខ្ញុំគឺសម្ដែងបួសហាត់មហាធម៌, គឺជាមហាធម៌

ដែលឫសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់ពិតប្រាកដ។ ដំបូងស្តាប់ទៅអាចមានអារម្មណ៍ដូចជាអាថ៌កំបាំង, ប៉ុន្តែសម្រាប់អ្នកឫសហាត់ឈីគង់ដែលមានឆន្ទៈ, ដរាបណាពិសោធនិងយល់ដោយយកចិត្តទុកដាក់, អាថ៌កំបាំងទាំងអស់ស្ថិតនៅក្នុងនោះ។

# I. ប្រភពដើមរបស់ឈីគង់

`ឈីគង់´ ដែលពួកយើងបច្ចុប្បន្នកំពុងនិយាយ, តាមពិតទៅមិនត្រូវបានហៅថា `ឈីគង់´។ វាមកពីប្រភពបួសដោយឯកតានៃមនុស្សបុរាណប្រទេសចិនឬក៏មកពីការបួសហាត់នៃសាសនា។ បើកអស់ (សៀវភៅ) `គម្ពីរតាន´, `តាវចាង´, បើកអស់ `គម្ពីរតាចាង´, ក៏រកមិនឃើញ២អក្សរ "ឈីគង់" ផងដែរ។ នៅក្នុងការអភិវឌ្ឍន៍នៃដំណាក់កាលនេះរបស់អរិយធម៌មនុស្សជាតិដែលពួកយើងកំពុងមាន, វាបានឆ្លងកាត់រយៈពេលក្មេងខ្ចីរបស់សាសនា។ នៅមុនពេលដែលសាសនាបានបង្កើត, ឈីគង់បានស្ថិតនៅរួចមកហើយ។ បន្ទាប់ពីមានសាសនារួចហើយ, វានាំតាមឱជារសជាក់លាក់របស់សាសនា។ ឈ្មោះដើមរបស់វាត្រូវបានហៅថា `មហាធម៌បួសពុទ្ធ´, `មហាធម៌បួសតាវ´; នៅមានអានប្រភេទឈ្មោះដូចជា `ជីវជួនជីនតានស៊ូ´, `លោរហន្តធម៌´, `ជីនកាងសមាធិ´។ ពួកយើងបច្ចុប្បន្នយកវាហៅថា "ឈីគង់", គឺដើម្បីកាន់តែសមស្របសតិអារម្មណ៍របស់មនុស្សសម័យទំនើបពួកយើង, គឺដើម្បីកាន់តែងាយស្រួលជាសកលនៅក្នុងសង្គម។ តាមពិតទៅគឺជាអ្វីដែលបួសហាត់រាងកាយមនុស្សសុទ្ធសាធនៃប្រទេសចិនពួកយើង។

ឈីគង់មិនមែនជាអ្វីដែលមនុស្សជាតិសម័យនេះពួកយើងប្រឌិតឡើងទេ, វាមានប្រវត្តិសាស្ត្រយូរណាស់មកហើយ។ ដូច្នេះតើឈីគង់បានផលិតនៅពេលណា? មនុស្សខ្លះសម្តែងថាឈីគង់មានប្រវត្តិ៣ពាន់ឆ្នាំរួចហើយ, ពេញនិយមសម័យរាជវង្សថាង។

មនុស្សខ្លះសម្តែងថាឈីគង់មានប្រវត្តិ៥ពាន់ឆ្នាំ, វែងដូចគ្នានឹងវប្បធម៌ជនជាតិចិន។ មនុស្សខ្លះសម្តែង, សង្កេតពីកំណាយវត្ថុបុរាណវប្បធម៌, បានមានប្រវត្តិ៧ពាន់ឆ្នាំរួចហើយ។ ខ្ញុំសង្កេតឃើញថាឈីគង់មិនមែនជាការបង្កើតរបស់មនុស្សជាតិសម័យទំនើបទេ, វាគឺជាវប្បធម៌បុរេប្រវត្តិ។ យោងតាមមនុស្សដែលមានសីលគង់ពិនិត្យមើល, ចក្រវាលនេះដែលពួកយើងរស់នៅគឺជាការរួមបញ្ចូលគ្នាបន្ទាប់ពីធ្លាប់បានផ្ទុះបែកចំនួន៩ដងរួចហើយ។ ភពផែនដីនេះដែលពួកយើងរស់នៅធ្លាប់បានបំផ្លាញច្រើនដងរួចហើយ។ រាល់ដងបន្ទាប់ពីភពផែនដីបានរួមបញ្ចូលបង្កើតឡើងសាជាថ្មី, មនុស្សជាតិបានបង្កើនចំនួនសាជាថ្មីម្តងទៀត។ បច្ចុប្បន្ន, ពួកយើងបានរកឃើញថាពិភពលោកមានរបស់ជាច្រើនដែលលើសពីអរិយធម៌សម័យទំនើប។ យោងតាមទ្រឹស្តីនៃការវិវត្តន៍របស់ Darwin, មនុស្សជាតិគឺវិវត្តមកពីសត្វស្វា, អរិយធម៌ក៏មិនលើសពី១ម៉ឺនឆ្នាំ។ ប៉ុន្តែពីកំណាយវត្ថុបុរាណវប្បធម៌រកឃើញថា, នៅអឺរ៉ុបជួរភ្នំអាល់ប៊ីក្នុងរូងភ្នំមានផ្ទាំងគំនូរតាំងពី ២៥ម៉ឺនឆ្នាំមុន, មានគុណតម្លៃសិល្បៈដ៏ខ្ពស់, ដែលមនុស្សសម័យទំនើបតាមមិនទាន់។ នៅក្នុងសារមន្ទីរនៃសាកលវិទ្យាល័យជាតិ ប៉េរូមានដុំថ្មធំមួយ, ខាងលើឆ្លាក់រូបមនុស្សម្នាក់, កាន់កែវយឹតតារាសាស្រ្តសង្កេតមើលរាងកាយលោកធាតុ។ រូបមនុស្សមួយនេះមានប្រវត្តិជាង៣ម៉ឺនឆ្នាំរួចហើយ។ អ្នករាល់គ្នាដឹងថា, Galileo គាត់បានបង្កើតកែវយឹតតារាសាស្រ្ត៣០គុណក្នុងឆ្នាំ១៦០៩, រហូតមកដល់ពេលនេះ

ប្រវត្តិក៏មិនច្រើនជាង៣០០ឆ្នាំ, តើ៣ម៉ឺនឆ្នាំមុនឯណាទៅមានកែរឃើត? ឥណ្ឌាមានដំបងដែកមួយ, ភាពបរិសុទ្ធដែលផ្ទុកជាតិដែកឈានដល់កម្រិត៩៩%។ យោងទៅតាមបច្ចេកទេសស្លដែកបច្ចុប្បន្នក៏មិនអាចស្លចេញបានដែកដែលមានភាពបរិសុទ្ធបែបនេះ, បានលើសពីកម្រិតនៃបច្ចេកវិទ្យាទំនើប។ តើអ្នកណាបង្កើតអរិយធម៌នេះ? នៅពេលនោះមនុស្សជាតិប្រហែលនៅជាអតិសុខុមប្រាណ, តើធ្វើដូចម្ដេចអាចបង្កើតរបស់ទាំងនេះបានទៅ? ការប្រឌិតរបស់ទាំងនេះ, បានទាក់ទាញចំណាប់អារម្មណ៍របស់អ្នកវិទ្យាសាស្ត្រមកពីទូទាំងពិភពលោក។ ដោយសារតែពន្យល់មិនបាន, គ្រាន់តែហៅវាថា "វប្បធម៌បុរេប្រវត្តិ"។

កម្រិតវិទ្យាសាស្ត្រគឺខុសគ្នាក្នុងរយៈពេលនីមួយៗ, មានរយៈពេលខ្លះខ្ពស់ណាស់, លើសពីកម្រិតមនុស្សជាតិសម័យទំនើបរបស់ពួកយើងនេះ។ ប៉ុន្តែអរិយធម៌នោះត្រូវបានបំផ្លាញ, ដូច្នេះខ្ញុំនិយាយ, ឈីគង់មិនត្រូវបានបង្កើតដោយពួកយើងជាមនុស្សសម័យទំនើបទេ, មិនត្រូវបានបង្កើតឡើងដោយមនុស្សសម័យទំនើប, ប៉ុន្តែបានមនុស្សសម័យទំនើបរកឃើញនិងបំពេញ, វាគឺជាវប្បធម៌បុរេប្រវត្តិ។

ឈីគង់មិនមែនជាផលិតផលប្លែករបស់ប្រទេសយើង, បរទេសក៏មានផងដែរ។ ប៉ុន្តែពួកគេមិនហៅថា 'ឈីគង់', ប្រទេសលោកខាងលិចហៅថា 'មន្តអាគម', នៅសហរដ្ឋអាមេរិច, ចក្រភពអង់គ្លេសនិងប្រទេសដទៃទៀតគឺហៅយ៉ាងនេះឯង។ សហរដ្ឋអា

មេរិចមានគ្រូមន្តអាគមម្នាក់, តាមពិតគាត់គឺជាគ្រូធំមានសីលគង់ពិសេស, សម្តែងការឆ្លងកាត់ជញ្ជាំងមហាកំផែង។ នៅពេលដែលគាត់ឆ្លងកាត់គឺបានប្រើក្រណាត់សគ្របខ្លួនវិញ, ផ្ដិតខ្លួនលើជញ្ជាំង, បន្ទាប់មកគាត់បានឆ្លងកាត់ទៅ។ ហេតុអ្វីបានជាគាត់ធ្វើបែបនេះ? តាមរយៈការធ្វើបែបនេះ, មនុស្សជាច្រើននឹងមើល, គឺជាការបង្ហាញមន្តអាគម។ ដោយសារតែគាត់មិនធ្វើបែបនេះគឺមិនបាន។ គាត់ដឹងថាប្រទេសចិនពួកយើងមានអធិជនជាច្រើន, គាត់ខ្លាចត្រូវទទួលនូវការជ្រៀតជ្រែកនេះ, ដូច្នេះគាត់បានគ្របខ្លួនរួចហើយចូលទៅ។ នៅពេលចេញមក, លាតដៃមួយចេញ, លើកក្រណាត់ឡើងមនុស្សក៏ដើរចេញមក។ "ក្នុងវិជ្ជាជីវៈមើលបច្ចេកទេស, ក្រៅវិជ្ជាជីវៈមើលភាពរំភើប", បែបនេះទស្សនិកជនសន្មតថាវាជាការបង្ហាញមន្តអាគម។ ពួកគេបានហៅសីលគង់ទាំងនេះថាមន្តអាគម, គឺដោយសារតែពួកគេមិនបានប្រើរឿងនេះដើម្បីបួសហាត់រាងកាយទេ, ប៉ុន្តែត្រូវបានប្រើសម្តែងនៅលើឆាកដើម្បីបង្ហាញពីភាពអស្ចារ្យនិងភាពសប្បាយរីករាយ។ ដូច្នេះ, សម្តែងពីជាន់ថ្នាក់ទាប, ឈីគង់គឺផ្លាស់ប្តូរស្ថានភាពរាងកាយរបស់មនុស្ស, ឈានដល់គោលបំណងព្យាបាលជំងឺកាយសម្បទា; សម្តែងពីជាន់ថ្នាក់ខ្ពស់, ឈីគង់គឺសំដៅទៅលើការបួសហាត់រាងកាយ។

## II. 'ឈី' និង 'គង់'

ឈី "氣" ដែលពួកយើងកំពុងនិយាយឥឡូវនេះ, មនុស្សបុរាណហៅថាឈី "炁", ខ្លឹមសារគឺដូចគ្នា, ទាំងអស់សំដៅទៅលើឈីនៃ

ចក្រវាល, គឺសំដៅទៅលើមួយប្រភេទសារធាតុដែលគ្មានរូបគ្មានរាងនៅក្នុងចក្រវាល។ វាមិនសំដៅទៅលើឧស្ម័ននៃខ្យល់អាកាស។ រាងកាយមនុស្សតាមរយៈការបួសហាត់, ប្រមូលផ្តុំថាមពលនៃប្រភេទសារធាតុនេះ, អាចផ្លាស់ប្តូរស្ថានភាពរាងកាយមនុស្ស, ដើរតួនាទីក្នុងការកម្ចាត់ជំងឺនិងពង្រឹងរាងកាយ។ ប៉ុន្តែ, ឈីគឺជាឈី, លោកអ្នកក៏មានឈី, គាត់ក៏មានឈី, រវាងឈីនិងឈីគ្មានប្រសិទ្ធភាពរឹតត្បិត។ មនុស្សខ្លះសម្តែងថា, ឈីអាចព្យាបាលជំងឺ; ឬក៏និយាយថា ‛លោកអ្នកបញ្ចេញបន្តិចឈីឱ្យនរណា, ព្យាបាលជំងឺឱ្យគាត់សាកមើល′។ ការអះអាងទាំងនេះគឺរឹតតែគ្មានវិទ្យាសាស្ត្រ, ដោយសារតែឈីមិនអាចព្យាបាលជំងឺបាន។ មនុស្សហាត់គង់នៅពេលលើខ្លួនរបស់គាត់នៅមានឈី, គឺពន្យល់ថារាងកាយរបស់គាត់នៅមិនទាន់ជារាងកាយ ‛សដូចទឹកដោះ′, ពន្យល់ថាគាត់នៅមានជំងឺ។

មនុស្សដែលហាត់ដល់ភាពជំនាញការខ្ពស់, ដែលគាត់បញ្ចេញមកគឺមិនមែនឈី, ប៉ុន្តែគឺជាក្រុមថាមពលខ្ពស់, គឺជាសារធាតុដែលមានថាមពលខ្ពស់បង្ហាញក្នុងទម្រង់ជាពន្លឺ, ភាគល្អិតម៉ដ្ឋណាស់, ដង់ស៊ីតេធំណាស់, នេះហើយគឺជា ‛គង់′, នៅពេលនេះទើបអាចមានប្រសិទ្ធភាពរឹតត្បិតសម្រាប់មនុស្សសាមញ្ញ, ទើបអាចពិនិត្យជំងឺឱ្យមនុស្ស។ មានពាក្យមួយឃ្លាដែលគេហៅថា៖ ‛ពន្លឺព្រះពុទ្ធចែងចាំង, សុជីវធម៌មូលភ្លឺថ្លា′។ គឺមានន័យថាសម្រាប់អ្នកបួសហាត់សុចរិតធម៌, ថាមពលដែលរាងកាយរបស់គាត់យក

តាមធំណាស់, នៅកន្លែងដែលគាត់បានឆ្លងកាត់, នៅក្នុងវិសាលភាពដែលថាមពលរបស់គាត់គ្របដណ្ដប់, អាចកែតម្រូវទាំងអស់ស្ថានភាពមិនប្រក្រតី, ធ្វើឱ្យប្រែជាស្ថានភាពប្រក្រតីវិញ។ ឧទាហរណ៍រាងកាយរបស់មនុស្សមានជំងឺ, ជាក់ស្ដែងគឺលើរាងកាយមានស្ថានភាពមិនប្រក្រតី, កែតម្រូវប្រភេទស្ថានភាពនេះរួចហើយជំងឺក៏ត្រូវបានលុបចោល។ និយាយងាយយល់បន្តិច, ‵គង់′ ជាក់ស្ដែងគឺជាថាមពល។ ‵គង់′ មានលក្ខណៈនៃសារធាតុ, មនុស្សហាត់គង់តាមរយៈការបួសហាត់, អាចពិនិត្យបានការស្ថិតនៅដោយធម្មជាតិរបស់វា។

## III. ‵អំណាចគង់′ និង ‵សីលគង់′

### ១. អំណាចគង់គឺពឹងផ្អែកលើការបួសចិត្តគំនិតចេញមក

‵គង់′ ពិតប្រាកដដែលកំណត់ជាន់ថ្នាក់អំណាចគង់របស់មនុស្សមិនមែន[ហាត់]ចេញមកទេ, វាគឺពឹងផ្អែកលើប្រភេទសារធាតុ "គុណធម៌" នេះផ្លាស់ប្ដូរចេញមក, ពឹងផ្អែកលើការបួសចិត្តគំនិតបួសចេញមក។ ដំណើរការផ្លាស់ប្ដូរនេះក៏មិនត្រូវបានហាត់ចេញប្រដូច ‵រៀបស្លុកបង្កើតឡ, ជ្រើសឱសថស្លតាន′ ដែលមនុស្សសាមញ្ញធ្លាប់ស្រមៃផងដែរ។ គង់ដែលពួកយើងនិយាយគឺបង្កើតនៅខាងក្រៅរាងកាយ, ចាប់ផ្ដើមពីពាក់កណ្ដាលខាងក្រោមនៃរាងកាយមនុស្ស, ជាមួយនឹងការលើកកម្ពស់នៃចិត្តគំនិតហើយកើនឡើងលើក្នុងទម្រង់គួទខ្យង, បង្កើតឡើងទាំងស្រុងខាងក្រៅរាងកាយ, បន្ទាប់មកនៅលើកំពូលក្បាលបង្កើតឡើងសសរគង់។

សសរគង់ខ្ពស់ប៉ុណ្ណា, គឺកំណត់ថាមនុស្សម្នាក់នេះមានគង់ខ្ពស់ប៉ុណ្ណោះ។ សសរគង់នៅក្នុងអវកាសលាក់ខ្លួនយ៉ាងខ្លាំង, មនុស្សធម្មតាមិនងាយមើលឃើញបាន។

‵សីលគង់′ ពឹងផ្អែកលើការពង្រឹងនៃអំណាចគង់, មនុស្សមានអំណាចគង់ខ្ពស់, ជាន់ថ្នាក់ខ្ពស់សីលគង់ក៏ធំផងដែរ, អនុវត្តក៏បានដូចចិត្ត; មនុស្សមានអំណាចគង់តូចសីលគង់ក៏តូចផងដែរ, អនុវត្តក៏មិនបានដូចចិត្ត, សូម្បីតែអនុវត្តមិនបានផង។ សីលគង់ខ្លួនវាមិនអាចតំណាងឱ្យអំណាចគង់ធំឬតូច, ជាន់ថ្នាក់ខ្ពស់ឬទាបរបស់មនុស្សម្នាក់។ កំណត់ជាន់ថ្នាក់ខ្ពស់ឬទាបរបស់មនុស្សម្នាក់គឺជាអំណាចគង់ប៉ុន្តែមិនមែនជាសីលគង់។ មនុស្សខ្លះគឺហាត់ដោយបាន ‶ចាក់សោរ″, អំណាចគង់របស់គាត់ខ្ពស់ណាស់, ប៉ុន្តែមិនប្រាកដថាមានសីលគង់ប៉ុន្មានទេ។ អំណាចគង់គឺមានតួនាទីសម្រេចចិត្ត, គឺពឹងផ្អែកលើចិត្តគំនិតបួសចេញមក, នេះគឺជារឿងសំខាន់បំផុត។

## ២. សីលគង់មិនមែនជាការស្វែងរករបស់មនុស្សហាត់គង់

មនុស្សហាត់គង់ទាំងអស់សុទ្ធតែចាប់អារម្មណ៍លើសីលគង់, ទេពអំណាចមានកម្លាំងទាក់ទាញចិត្តយ៉ាងខ្លាំងនៅក្នុងសង្គម, មនុស្សជាច្រើនសុទ្ធតែចង់បានសីលគង់មួយចំនួន។ ប៉ុន្តែ, ចិត្តគំនិតមិនល្អ, គឺនឹងគ្មានសីលគង់ទាំងនេះ។

មានសីលគង់មួយចំនួនគឺមនុស្សសាមញ្ញអាចមាន, ដូចជាសីលគង់បើកបញ្ញាញាណ, ត្រចៀកទិព្វ, ទូរវេទន៍, ព្យាករណ៍ជា

ដើម។ ប៉ុន្តែសីលគង់ទាំងនេះខុសគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់, នៅក្នុងស្ថានភាព `ត្រាស់ដឹងបន្តិចម្តងៗ´ នឹងមិនមានទាំងស្រុងនោះទេ។ មានសីលគង់មួយចំនួនគឺមនុស្សសាមញ្ញមិនអាចមាន, ឧបមាប្រែក្លាយមួយប្រភេទវត្ថុនៃអវកាសប្រាកដនិយមទៅជាមួយប្រភេទវត្ថុផ្សេងទៀត, នេះគឺមនុស្សសាមញ្ញមិនអាចមាន។ សីលគង់ដ៏ធំគឺត្រូវបានហាត់ចេញដោយពឹងផ្អែកទៅថ្ងៃអនាគត។ ហ្វាលូនគង់គឺបានវិវត្តយោងតាមគោលការណ៍របស់ចក្រវាល, ក្នុងហ្វាលូនគង់មានទាំងអស់សីលគង់ដែលស្ថិតនៅក្នុងចក្រវាល, ជាក់ស្តែងសង្កេតមើលមនុស្សហាត់គង់បួសហាត់ដូចម្តេច។ គំនិតចង់បានសីលគង់មួយចំនួនក៏មិនគិតថាខុស, ប៉ុន្តែ, ចំណង់ខ្លាំងក្លាពេក, គឺលែងនៅជាគំនិតប្រក្រតីទៀតហើយ, គឺនឹងកើតមានផលវិបាកមិនល្អ។ នៅជាន់ថ្នាក់ទាបបានមានសីលគង់បន្តិចបន្តួចគ្មានបានផលប្រយោជន៍ប៉ុន្មានទេ, គ្រាន់តែចង់ប្រើសាកមើល, នៅចំពោះមុខមនុស្សសាមញ្ញបង្ហាញសមត្ថភាពបន្តិចបន្តួច, ធ្វើជា `បុរសខ្លាំង´ នៃមនុស្សសាមញ្ញ។ ប្រសិនបើបែបនេះ, ពន្យល់ត្រង់ថាចិត្តគំនិតមិនខ្ពស់, មិនផ្តល់សីលគង់ឱ្យគឺត្រឹមត្រូវ។ មានសីលគង់មួយចំនួន, ប្រសិនបើផ្តល់ឱ្យមនុស្សដែលមានចិត្តគំនិតមិនល្អគឺអាចយកមកប្រើដើម្បីធ្វើរឿងអាក្រក់, ដោយសារតែចិត្តគំនិតមិនគួរឱ្យទុកចិត្តនឹងគ្មានវិធីធានាថាគាត់មិនប្រព្រឹត្តរឿងអាក្រក់។

ម្យ៉ាងវិញទៀត, ដោយទាក់ទងជាមួយសីលគង់អាចយកចេញមកសម្តែង, សុទ្ធតែមិនអាចប្រើដើម្បីផ្លាស់ប្តូរសង្គមមនុស្សជាតិ,

ផ្លាស់ប្តូរមិនបានជីវិតសង្គមធម្មតា។ សីលគង់ខ្ពស់ពិតប្រាកដគឺមិនអនុញ្ញាតយកចេញមកសម្តែង, ដោយសារតែមានឥទ្ធិពលនិងគ្រោះថ្នាក់របស់វាធំណាស់។ រួមដូចជាមិនអាចសម្តែងក្រឡាប់ផ្ទាអាគារមួយធំបាន។ សម្រាប់សីលគង់ដ៏ធំ, លើកលែងតែមនុស្សដែលមានបន្ទុកបេសកកម្មពិសេសទើបអនុញ្ញាតប្រើការ, បើមិនដូច្នេះទេគឺមិនអនុញ្ញាតឱ្យប្រើ, ក៏មិនអាចយកចេញបានផងដែរ, ដោយសារតែត្រូវទទួលនូវការឃុំគ្រងរបស់គ្រូខាងលើនៅទីនោះ។

ប៉ុន្តែជាធម្មតាមានមនុស្សសាមញ្ញមួយចំនួននៅតែចង់ឱ្យគ្រូឈីគង់សម្តែងសាកមើល, បង្ខំឱ្យគាត់យកចេញមកមើលសាកមើល។ មនុស្សដែលមានសីលគង់ទាំងអស់មិនស្ម័គ្រចិត្តយកសីលគង់ចេញមកសម្តែង, ដោយសារតែនោះគឺមិនអនុញ្ញាតយកចេញមក, យកចេញមកនឹងមានឥទ្ធិពលដល់ស្ថានភាពនៃសង្គមទាំងមូល។ មនុស្សដែលមានគុណធម៌ធំពិតប្រាកដ, សីលគង់របស់គាត់គឺមិនអនុញ្ញាតយកចេញទេ។ គ្រូឈីគង់ខ្លះមានអារម្មណ៍មិនល្អនៅពេលសម្តែង, បន្ទាប់ពីគាត់បានត្រឡប់មកវិញ, ស្អប់ដែលមិនអាចយំឱ្យធំបានម្តង។ កុំបង្ខំគាត់ឱ្យសម្តែង! គឺមិនស្រួលសម្រាប់គាត់ក្នុងការយករបស់នោះចេញមក។ មានសិក្ខាកាមម្នាក់បានយកមកទស្សនាវដ្តីមួយក្បាល, ខ្ញុំខ្ពើមរអើមណាស់ពេលឃើញរបស់នោះ។ មានន័យថា៖ បើកសន្និសីទឈីគង់អន្តរជាតិ, (មនុស្ស)ដែលមានសីលគង់អាចយកសីលគង់មកចូលរួមប្រកួត, អ្នកណាមានសីលគង់ខ្លាំងអ្នកនោះចូលទៅក្នុង។ បន្ទាប់ពីខ្ញុំបាន

មើលចប់, ចិត្តខ្ញុំមិនស្រួលប៉ុន្មានថ្ងៃ។ រឿងនេះគឺមិនអាចយកចេញមកប្រកួត, យកចេញមកគឺនឹងស្តាយក្រោយ។ មនុស្សសាមញ្ញនោះ, គាត់យកចិត្តទុកដាក់តែរឿងជាក់ស្តែងនៅក្នុងលោកីយ៍, ប៉ុន្តែគ្រូឈីគង់ត្រូវតែគោរពខ្លួនឯង។

តើគោលបំណងចង់បានសីលគង់គឺជាហេតុអ្វី? វាឆ្លុះបញ្ចាំងវិស័យមនោគតិនិងការស្វែងរករបស់មនុស្សហាត់គង់, មនោគតិចំណង់មិនបរិសុទ្ធ, មិនគួរឱ្យទុកចិត្ត, មិនអាចទទួលបានសីលគង់ខ្ពស់ទេ។ ក្នុងនេះមានមូលហេតុមួយ, ជាក់ស្តែងមុនពេលដែលលោកអ្នកនៅមិនទាន់ត្រាស់ដឹង, រឿងរ៉ាវល្អឬក៏អាក្រក់ដែលលោកអ្នកមើលឃើញ, គឺគ្រាន់តែយោងតាមបរមាណីយខុសឬក៏ត្រូវនៃលោកីយ៍ធម៌ប៉ុណ្ណោះ, លោកអ្នកមិនអាចមើលឃើញសេចក្តីពិតនៃបញ្ហា, មិនអាចមើលឃើញទំនាក់ទំនងកម្មផលនៃបញ្ហា។ ការវាយស្តីបន្ទោស, ការសម្លុតធ្វើបាបរវាងមនុស្សត្រូវតែមានកម្មផល, លោកអ្នកមិនអាចមើលធ្លុះធ្លាយកាន់តែជួយឱ្យមានថែមបញ្ហាប៉ុណ្ណោះ។ ការដឹងគុណនិងតូចចិត្ត, ការត្រូវនិងខុសទីមនុស្សសាមញ្ញ, មានលោកីយ៍ធម៌គ្រប់គ្រងដោយខ្លួនឯង, មនុស្សហាត់គង់មិនចាំបាច់គ្រប់គ្រង។ ដោយសារតែនៅមុនពេលដែលលោកអ្នកមិនទាន់បានត្រាស់ដឹង, សេចក្តីពិតនៃបញ្ហាដែលលោកអ្នកមើលឃើញនៅចំពោះមុខគឺមិនប្រាកដដូចបែបនោះដែលលោកអ្នកបានមើលឃើញនោះទេ។ នរណាវាយនរណាមួយដៃ, អាចជាពួកគាត់កំពុងសង "កម្ម", លោកអ្នកចូលទៅគ្រប់គ្រងអាចនឹងរារាំង

ដល់ការសង "កម្ម" រវាងពួកគាត់។ "កម្ម"គឺជាមួយប្រភេទសារធាតុខ្មៅៗនៅជុំវិញរាងកាយមនុស្ស, វាគឺជាអត្ថិភាពនៃសារធាតុនៅក្នុងអវកាសមួយផ្សេងទៀត, របស់នេះអាចផ្លាស់ប្តូរទៅជាជំងឺឬក៏គ្រោះកាច។

មនុស្សគ្រប់គ្នាសុទ្ធតែមានសីលគង់, បញ្ហាគឺត្រូវឆ្លងកាត់ការប្តូសហាត់ជាបន្តបន្ទាប់ដើម្បីអភិវឌ្ឍនិងពង្រឹងបន្ថែម។ ធ្វើជាមនុស្សហាត់គង់, ប្រសិនបើគ្រាន់តែស្វែងរកទទួលបានសីលគង់, គឺចក្ខុវិស័យខ្លីរាក់, មនោគតិមិនបរិសុទ្ធ, មិនថាគាត់ចង់បានសីលគង់ធ្វើអ្វី, ក្នុងនោះសុទ្ធតែមានផ្ទុកនូវចិត្តអាត្មានិយម, ជៀសមិនរួចរារាំងការហាត់គង់, ហើយលទ្ធផលជាក់ស្តែងគឺមិនអាចទទួលបានសីលគង់។

## ៣. កាន់ជាប់អំណាចគង់

មនុស្សហាត់គង់ខ្លះរយៈពេលហាត់គង់មិនយូរ, គឺចង់ព្យាបាលជំងឺឱ្យមនុស្ស, មើលថាតើវាដំណើរការឬអត់។ សម្រាប់មនុស្សដែលអំណាចគង់មិនខ្ពស់, លោកអ្នកឈានដល់សាកល្បងភ្លាម, នឹងស្រូបយកឈីខ្មៅ, ឈីជំងឺ, ឈីកខ្វក់មួយចំនួនធំនៅក្នុងរាងកាយអ្នកជំងឺចូលមកលើរាងកាយខ្លួនឯង។ ដោយសារតែលោកអ្នកមិនទាន់មានសមត្ថភាពការពារ(ទល់នឹង)ឈីជំងឺ, លើខ្លួននៅមិនទាន់មានគម្របការពារ, ជាមួយនឹងអ្នកជំងឺបង្កើតជាវាលមួយ, អំណាចគង់មិនខ្ពស់គឺបង្ការមិនបាន, ខ្លួនឯងនឹងមានអារម្មណ៍ពិបាកទ្រាំ។ ប្រសិនបើគ្មានមនុស្សគ្រប់គ្រងលោកអ្នកទេ, ពេល

វេលាយូរទៅ, នឹងធ្វើឱ្យរាងកាយទាំងមូលគឺជាជំងឺ។ ហេតុនោះ, មនុស្សដែលអំណាចគង់មិនខ្ពស់, មិនអាចពិនិត្យជំងឺឱ្យមនុស្សដទៃ។ លើកលែងតែលោកអ្នកបញ្ចេញសីលគង់រួចហើយ, និងមានអំណាចគង់ជាក់លាក់, ទើបអាចប្រើឈីគង់ពិនិត្យជំងឺបាន។ មានមនុស្សមួយចំនួនទោះបីបញ្ចេញសីលគង់រួចហើយក៏ដោយ, អាចពិនិត្យជំងឺបាន, ប៉ុន្តែនៅពេលជាន់ថ្នាក់ទាបពេក, ការពិតគឺប្រើអំណាចគង់ដែលស្តុកទុកដើម្បីពិនិត្យជំងឺ, ប្រើថាមពលខ្លួនឯងដើម្បីពិនិត្យជំងឺ។ ដោយសារតែគង់គឺជាថាមពល, គឺជារាងកាយវិញ្ញាណ, គឺមិនងាយស្រួលស្តុកទុកមកបាន, យកគង់នេះវាយចេញទៅជាក់ស្តែងគឺកំពុងធ្វើអោយហិនខ្លួនឯង។ ជាមួយនឹងការលោកអ្នកធ្វើគង់ទៅខាងក្រៅ, កម្ពស់សសរគង់នៅលើក្បាលបានកំពុងខ្លីមកវិញ, កំពុងធ្វើអោយហិន, រឿងនេះរឹតតែមិនស័ក្តិសម។ ដូច្នេះ, ខ្ញុំមិនផ្តល់នូវការគាំទ្រនៅពេលអំណាចគង់មិនខ្ពស់ហើយទៅពិនិត្យជំងឺឱ្យមនុស្ស។ មិនថាវិធីរបស់លោកអ្នកខ្ពស់ប៉ុណ្ណា, ក៏នៅតែបានកំពុងធ្វើអោយហិនថាមពលរបស់ខ្លួនឯង។

អំណាចគង់ឈានដល់កម្រិតជាក់លាក់រួចហើយ, ជាក់ស្តែងនឹងលេចឡើងបណ្តាប្រភេទសីលគង់, ប្រើការចំនួនសីលគង់ទាំងនេះដូចម្តេច, ក៏ចាំបាច់ត្រូវមានការប្រុងប្រយ័ត្នខ្ពស់បំផុតផងដែរ។ ឧទាហរណ៍បញ្ញាញាណបើករួចហើយ, មិនមើលក៏មិនបាន, ពីព្រោះតែងតែមិនប្រើគឺងាយស្រួលបិទមកវិញ។ មើលក៏មិនអាចមើលជាញឹកញាប់បានដែរ, មើលច្រើនពេកថាមពលលេចធ្លាយក៏

ច្រើនផងដែរ។ ដូច្នេះ, តើចង់ឱ្យអ្នករាល់គ្នាមិនប្រើជារៀងរហូតឬ? ពិតណាស់មិនត្រូវទេ។ ប្រសិនបើមិនប្រើជារៀងរហូតតើនៅឬស ហាត់ធ្វើអ្វីទៀត? បញ្ហាគឺប្រើនៅពេលណា។ មានតែឬសហាត់ ដល់កម្រិតជាក់លាក់, ពេលដែលមានសមត្ថភាពបំពេញបន្ថែម ដោយខ្លួនឯង, គឺអាចប្រើបាន។ ឬសហាត់ហ្វាលូនគង់ដល់កម្រិត ជាក់លាក់, បញ្ចេញមកក្រៅប៉ុន្មានគង់, ហ្វាលូនអាចវិវត្តនិងបំពេញ បន្ថែមដោយស្វ័យប្រវត្តិ, រក្សាកម្រិតអំណាចគង់របស់អ្នកហាត់គង់ ដោយស្វ័យប្រវត្តិ, នឹងមិនថយចុះសូម្បីតែមួយភ្លែត, នេះគឺជា លក្ខណៈរបស់ហ្វាលូនគង់។ មានតែពេលនេះទេ, ទើបអាចប្រើ សីលគង់បាន។

# IV. បញ្ញាញាណ

## ១. បើកបញ្ញាញាណ

ផ្លូវរន្ធសំខាន់របស់បញ្ញាញាណនៅពាក់កណ្ដាលខាងមុខថ្ងាស់ ដល់ទីតាំងសានកិន។ មនុស្សសាមញ្ញប្រើភ្នែកទទេមើលឃើញអ្វីៗ ជាក់ស្ដែងដូចជាគោលការណ៍របស់កាមេរ៉ា, ជាមួយនឹងចម្ងាយ ឆ្ងាយឬជិតនិងពន្លឺខ្លាំងឬខ្សោយ, តាមរយៈការកែសំរួលទំហំរបស់ កែវភ្នែកឬក៏រន្ធប្រស្រី, បណ្ដាលឱ្យរូបភាពតាមរយៈណឺរ៉ូនបង្កជារូប ភាពនៅលើក្រពេញស្រល់នៃពាក់កណ្ដាលខាងក្រោយខួរធំ។ សីលគង់ពិសេស 'មើលធ្លុះ' ជាក់ស្ដែងគឺតាមរយៈបញ្ញាញាណ បណ្ដាលឱ្យក្រពេញស្រល់មើលចេញក្រៅដោយផ្ទាល់។ មនុស្ស ធម្មតាម្នាក់បញ្ញាញាណមិនបើកស្រឡះ, នៅទីតាំងនៃផ្លូវរន្ធចម្បង

គម្លាតតូចចង្អៀតណាស់, ខ្មៅណាស់, ខាងក្នុងគ្មានឫទ្ធានុភាព, មិនថែងចាំង។ មនុស្សមួយចំនួនគឺត្រូវរាំងស្ទះជិតឈឹង, ដូច្នេះ មើលមិនឃើញ។

ពួកយើងបើកបញ្ញាញាណ, ទីមួយគឺតាមរយៈកម្លាំងខាងក្រៅ ឬក៏បួសហាត់ដោយខ្លួនឯងវាយបើកផ្លូវរន្ធ។ ផ្លូវរន្ធរបស់មនុស្ស ម្នាក់ៗមានរូបរាងមិនដូចគ្នា, មានរូបពងក្រពើ, រូបមូល, រូបបួនជ្រុង ញាយ, រូបត្រីកោណ, ហាត់បានកាន់តែល្អអាចបួសបានកាន់តែ មូល។ ទីពីរគឺដោយសារតែលោកគ្រូផ្តល់ឱ្យលោកអ្នកកែវភ្នែកមួយ , ប្រសិនបើខ្លួនឯងបួសហាត់ជាក់ស្តែងត្រូវតែបួសដោយខ្លួនឯង។ ទីបីគឺនៅទីតាំងបញ្ញាញាណត្រូវតែមាន ‘ឈើសម្រាំង’។

ជាធម្មតាពួកយើងមើលអ្វីៗគឺតាមរយៈភ្នែកទាំងពីរដើម្បីមើល , វាច្បាស់ណាស់ជាក់ស្តែងគឺភ្នែកទាំងពីរនេះបានរារាំងពួកយើង ឆ្លងទៅផ្លូវរន្ធនៃអវកាសផ្សេងទៀត, វាដើរតួនាទីជារបាំង, ពួកយើង គ្រាន់តែអាចមើលឃើញអ្វីៗនៃអវកាសសារធាតុនេះរបស់ពួក យើងប៉ុណ្ណោះ។ បើកបញ្ញាញាណជាក់ស្តែងគឺជៀសវាងបើកភ្នែក ទាំងពីរនេះដើម្បីមើល។ បន្ទាប់ពីដល់ជាន់ថ្នាក់ដ៏ខ្ពស់រួចហើយ, ក៏ អាចបួសចេញបាន ‘សច្ចៈនេត្រ’, ជាក់ស្តែងអាចប្រើសច្ចៈនេត្រ របស់បញ្ញាញាណដើម្បីមើលឬក៏ប្រើសច្ចៈនេត្រទីតាំងសានកិន ដើម្បីមើល។ យោងតាមពុទ្ធវង្សបានសម្តែង៖ រន្ធរោមនីមួយៗ សុទ្ធតែជាភ្នែក, រាងកាយទាំងមូលសុទ្ធតែជាភ្នែក។ យោងតាមតាវ វង្សបានសម្តែង៖ ចំណុចចាក់ម្ជុលវិទ្យាសាស្ត្រនីមួយៗសុទ្ធតែជា

ភ្នែក។ ប៉ុន្តែផ្លូវរន្ធចម្បងនៅបញ្ញាញាណ, ត្រូវការវាយបើកមុនដំបូង។ នៅក្នុងថ្នាក់បង្រៀន, ខ្ញុំផ្តល់ឱ្យមនុស្សម្នាក់ៗសុទ្ធតែដំឡើងនូវអ្វីដែលបើកបញ្ញាញាណ។ ដោយសារតែគុណសម្បត្តិរាងកាយរបស់មនុស្សម្នាក់ៗមិនដូចគ្នា, លទ្ធផលលេចឡើងក៏មិនដូចគ្នាផងដែរ។ មនុស្សខ្លះមើលឃើញប្រហោងខ្មៅមួយប្រៀបដូចអណ្តូងជ្រៅ, នេះជាក់ស្តែងគឺផ្លូវរន្ធនៃបញ្ញាញាណគឺជាពណ៌ខ្មៅ។ មនុស្សខ្លះមើលឃើញគឺផ្លូវរន្ធពណ៌ស, ប្រសិនបើអាចមើលឃើញអ្វីនៅខាងមុខជាក់ស្តែងគឺជិតនឹងបើកហើយ។ មនុស្សខ្លះមើលឃើញមានអ្វីកំពុងវិល, នេះជាក់ស្តែងគឺជាលោកគ្រូដំឡើងនូវអ្វីដែលបើកបញ្ញាញាណ, បន្ទាប់ពីក្ឋចស្រឡះបញ្ញាញាណជាក់ស្តែងអាចមើលបានហើយ។ មនុស្សខ្លះបញ្ញាញាណអាចមើលឃើញភ្នែកធំមួយ, គិតថាគឺជា 'ពុទ្ធនេត្រ', តែការពិតទៅគឺជាភ្នែករបស់ខ្លួនគាត់ផ្ទាល់, ជាធម្មតានេះគឺជាមនុស្សដែលមាននិស្ស័យពីកំណើតដ៏ល្អ។

យោងតាមស្ថិតិរបស់ពួកយើង, រាល់លើកថ្នាក់បង្រៀនមនុស្សដែលបើកបញ្ញាញាណសុទ្ធតែជាងពាក់កណ្តាល។ ដោយសារតែបន្ទាប់ពីបញ្ញាញាណបានវាយបើកនឹងពាក់ព័ន្ធដល់បញ្ហាមួយ៖ មនុស្សដែលចិត្តគំនិតមិនខ្ពស់គាត់ងាយស្រួលនឹងប្រើវាដើម្បីធ្វើរឿងអាក្រក់។ ដើម្បីបង្ការបញ្ហាមួយនេះ, ខ្ញុំយកបញ្ញាញាណរបស់លោកអ្នកវាយបើកដោយផ្ទាល់ដល់ជាន់ថ្នាក់ 'បញ្ញាចក្ខុវិស័យ', ក៏ដូចជានិយាយថាវាយបើកដល់ជាន់ថ្នាក់ខ្ពស់ជាង, អនុញ្ញាតឱ្យលោកអ្នកមើលឃើញដោយផ្ទាល់ទស្សនីយភាពនៃអវកាសផ្សេង,

អនុញ្ញាតឱ្យលោកអ្នកមើលឃើញអ្វីៗលេចឡើងក្នុងការហាត់គង់, ធ្វើឱ្យលោកអ្នកជឿវា, នឹងបង្កើនទំនុកចិត្តរបស់លោកអ្នកក្នុងការហាត់គង់។ មនុស្សដែលទើបតែចាប់ផ្ដើមហាត់គង់, ចិត្តគំនិតនៅមិនទាន់អាចឈានដល់កម្ពស់លើសពីមនុស្សសាមញ្ញ, នៅពេលណាមានអ្វីលើសពីមនុស្សសាមញ្ញរួចហើយ, នឹងងាយស្រួលទៅធ្វើរឿងមិនល្អមួយចំនួន។ លើកឧទាហរណ៍និយាយរឿងកំប្លែងមួយ, ប្រសិនបើលោកអ្នកដើរនៅតាមផ្លូវដឹងថាមានលក់សំបុត្រឆ្នោត, ប្រហែលជាឆ្នោតលេខមួយនោះសុទ្ធតែត្រូវបានលោកអ្នកប៉ះត្រូវ, ជាក់ស្ដែងសម្ដែងអត្ថន័យមួយនេះ, គឺមិនអនុញ្ញាតធ្វើបែបនេះឡើយ។ មូលហេតុមួយទៀត, ពួកយើងនៅទីនេះក៏ស្ថិតក្នុងនឹងការបើកបញ្ញាញាណនៃទ្រង់ទ្រាយធំ, ឧបមាថាសុទ្ធតែបើកនៅជាន់ថ្នាក់ទាប, អ្នករាល់គ្នាគិតសាកមើល, ប្រសិនបើមនុស្សម្នាក់ៗសុទ្ធតែ 'មើលឃើញផ្ទះរាងកាយមនុស្ស', សុទ្ធតែអាច 'បាំងជញ្ជាំងមើលឃើញវត្ថុ', ខ្ញុំនិយាយថាតើនោះគឺជាសង្គមមនុស្សជាតិឬ? ជ្រៀតជ្រែកធ្ងន់ធ្ងរដល់ស្ថានភាពសង្គមមនុស្សសាមញ្ញ, ដូច្នេះគឺមិនអនុញ្ញាត, ក៏មិនអាចធ្វើបែបនេះផងដែរ, ថែមទៀតសម្រាប់មនុស្សហាត់គង់ក៏គ្មានកន្លែងល្អ, ជំរុញឱ្យចំរើនឡើងចិត្តប្រកាន់នៃមនុស្សហាត់គង់ថែមទៀត។ ដូច្នោះមិនវាយ(បើក)ឱ្យលោកអ្នកដល់ជាន់ថ្នាក់ទាប, ប៉ុន្តែវាយ(បើក)ឱ្យលោកអ្នកដោយផ្ទាល់ដល់ជាន់ថ្នាក់ខ្ពស់ឡើងទៅ។

## ២. ជាន់ថ្នាក់របស់បញ្ញាញាណ

បញ្ញាញាណមានច្រើនប្រភេទជាន់ថ្នាក់។ ជាន់ថ្នាក់មិនដូចគ្នា, អវកាសមើលឃើញក៏មិនដូចគ្នា។ យោងតាមពុទ្ធសាសនាសម្ដែងមាន "ប្រាំចក្ខុវិស័យ", មានន័យថាសាច់ចក្ខុវិស័យ, ទិព្វចក្ខុវិស័យ, បញ្ញាចក្ខុវិស័យ, ធម៌ចក្ខុវិស័យ, ពុទ្ធចក្ខុវិស័យ។ ជាន់ថ្នាក់នីមួយៗនៅមានបែងចែកលើ, កណ្ដាល, ក្រោម។ នៅជាន់ថ្នាក់ទិព្វចក្ខុវិស័យចុះក្រោម, គ្រាន់តែអាចមើលឃើញពិភពសារធាតុរបស់ពួកយើងនេះ។ នៅជាន់ថ្នាក់បញ្ញាចក្ខុវិស័យឡើងទៅ, ទើបអាចមើលឃើញអវកាសដទៃទៀតបាន។ មានមនុស្សមួយចំនួនមានសីលគង់ 'មើលធ្លុះ', ថែមទាំងមើលឃើញត្រឹមត្រូវណាស់, ប្រៀបនឹងការស្កេន "CT" នៅច្បាស់ជាង។ ប៉ុន្តែដែលគាត់បានមើលឃើញនៅតែជាពិភពសារធាតុពួកយើងនេះ, នៅមិនទាន់ចេញផុតពីអវកាសដែលពួកយើងស្ថិតនៅ, នៅមិនទាន់បានចាត់ទុកជាជាន់ថ្នាក់ខ្ពស់នៃបញ្ញាញាណ។

កំណត់ជាន់ថ្នាក់បញ្ញាញាណរបស់មនុស្សម្នាក់ខ្ពស់ប៉ុណ្ណាគឺដោយសារតែបរិមាណនៃឈីសម្រាំងនិងទទឹងនៃផ្លូវរន្ធចម្បង, កម្រិតពន្លឺក៏ដូចជាកម្រិតរាំងស្ទះរបស់ផ្លូវរន្ធរបស់មនុស្សម្នាក់នេះ។ បញ្ញាញាណបើកធ្លាយស្រឡះឬក៏មិនធ្លាយស្រឡះ, ឈីសម្រាំងទីខាងក្នុងគឺជាកត្តាសំខាន់, សម្រាប់កុមារអាយុក្រោម៦ឆ្នាំ, បើកបញ្ញាញាណគឺពិសេសងាយស្រួល, ខ្ញុំមិនចាំបាច់ប្រើដៃ, ខ្ញុំនិយាយមួយភ្លាមគាត់នឹងវាយបើករួចស្រេច។ ដោយសារតែកុមារទទួលរង

ឥទ្ធិពលមិនល្អរបស់ពិភពសារធាតុពីកំណើតតិចតួចណាស់, ខ្លួនឯងក៏គ្មានធ្វើរឿងអ្វីអាក្រក់ផងដែរ, ប្រភេទឈើសម្រាំងពីកំណើតនោះបានថែទាំទុកល្អខ្លាំងណាស់។ កុមារដែលអាយុ៦ឆ្នាំឡើង, បញ្ញាញាណជាបណ្ដើរៗពិបាកនឹងបើក, គឺដោយសារតែស្របតាមការកើនឡើងនៃអាយុ, ទទួលនូវឥទ្ធិពលរបស់ពិភពខាងក្រៅក៏កើនឡើងថែម។ ពិសេសគឺជាការអប់រំនាថ្ងៃក្រោយមិនត្រឹមត្រូវ, ត្រូវគេបង្ខូចប្រែក្លាយទៅជាអាក្រក់សុទ្ធតែអាចបណ្ដាលឱ្យឈើសម្រាំងរបស់គាត់រលាយ, ដល់កម្រិតណាមួយជាក់ស្ដែងអាចរលាយបាត់សូន្យ។ សម្រាប់មនុស្សដែលឈើសម្រាំងរលាយបាត់សូន្យ, គឺអាចតាមរយៈការហាត់គង់នាថ្ងៃក្រោយសន្សឹមៗបំពេញមកវិញ, ប៉ុន្តែត្រូវចំណាយពេលវេលាយូរអង្វែងណាស់, ត្រូវតែចំណាយនិងរងទុក្ខជាច្រើន។ ដូច្នេះនិយាយថា, ឈើសម្រាំងគឺដ៏មានតម្លៃបំផុត។

ខ្ញុំមិនគាំទ្រផ្ដល់នូវមតិបើកបញ្ញាញាណឱ្យមនុស្សនៅជាន់ថ្នាក់ទិព្វចក្ខុវិស័យ, ដោយសារតែមនុស្សហាត់គង់ពេលដែលអំណាចគង់មិនធំ, ក្នុងពេលហាត់គង់ថាមពលដែលប្រមូលផ្ដុំមិនច្រើនស្មើនឹងថាមពលដែលចំណាយនៅពេលមើលធ្លុះ។ ឫទ្ធានុភាពសាយភាយបាត់ច្រើនរួចហើយ, បញ្ញាញាណអាចនឹងត្រូវបានបិទមកវិញ, នៅពេលបិទរួចហើយវាមិនងាយស្រួលទេក្នុងការបើកម្ដងទៀត។ ដូច្នេះ, ជាធម្មតាពេលបើកបញ្ញាញាណឱ្យមនុស្សគឺបើកនៅជាន់ថ្នាក់បញ្ញាចក្ខុវិស័យ។ មិនថាមើលឃើញបានច្បាស់ឬក៏អត់, អាច

ធ្វើឱ្យអ្នកបួសហាត់មើលឃើញអ្វីៗនៃអវកាសផ្សេង។ ទទួលនូវឥទ្ធិពលដោយលក្ខខណ្ឌពីកំណើត, មនុស្សខ្លះមើលឃើញយ៉ាងច្បាស់; មនុស្សខ្លះមើលឃើញអ្វីមួយភ្លែតមានមួយភ្លែតបាត់; មនុស្សខ្លះមិនអាចមើលឃើញច្បាស់, ប៉ុន្តែទីបំផុតអាចធ្វើឱ្យលោកអ្នកមើលឃើញពន្លឺ។ បែបនេះ, សម្រាប់អ្នកហាត់គង់អភិវឌ្ឍសំដៅឡើងជាន់ថ្នាក់ខ្ពស់គឺមានកន្លែងល្អ, មើលឃើញមិនច្បាស់អាចតាមរយៈការហាត់គង់នាថ្ងៃក្រោយបំពេញឡើងវិញ។

មនុស្សមានឈីសម្រាំងមិនគ្រប់គ្រាន់, ទស្សនីយភាពដែលបញ្ញាញាណមើលឃើញគឺខ្មៅនិងស; មនុស្សមានឈីសម្រាំងនៅបានយ៉ាងច្រើន, ទស្សនីយភាពដែលបញ្ញាញាណមើលឃើញគឺមានពណ៌, ទស្សនីយភាពដែលមើលឃើញក៏កាន់តែច្បាស់។ ឈីសម្រាំងកាន់តែច្រើន, កម្រិតច្បាស់កាន់តែល្អ។ ប៉ុន្តែ, មនុស្សម្នាក់ៗសុទ្ធតែមិនដូចគ្នា, មនុស្សខ្លះចាប់កំណើតមកបញ្ញាញាណជាក់ស្តែងគឺបើករួចហើយ, មនុស្សខ្លះបិទស្ទះយ៉ាងធ្ងន់ធ្ងរ។ ទស្សនីយភាពពេលដែលបញ្ញាញាណបើក, មានចំណុចដូចបែបផ្ការីក, រីកតាមមួយជាន់ៗ។ ពេលអង្គុយសមាធិ, មុនដំបូងរកឃើញថាបញ្ញាញាណមានមួយក្រុមពន្លឺ, មុនដំបូងពន្លឺមិនសូវភ្លឺខ្លាំង, ក្រោយមកក៏នឹងប្រែក្លាយទៅជាក្រហម។ មនុស្សខ្លះបញ្ញាញាណបានបិទតឹង, នៅពេលបើកចេញអាចប្រតិកម្មខ្លាំងក្លាណាស់។ អាចមានអារម្មណ៍ថាផ្លូវរន្ធចម្បងនិងទីតាំងសានកិនសាច់ដុំតឹងឡើង, ហាក់ដូចជាសាច់នៅទីនោះប្រមូលផ្តុំគ្នាក្តួចចូលទៅក្នុង, ចំណុចចាក់

ម្ទុលវិទ្យាសាស្ត្រថាយយ៉ាងនិងខាងមុខថ្វាស់ហើម, ឈើ, នេះសុទ្ធតែជាប្រតិកម្មនៃការបើកបញ្ញាញាណ។ មនុស្សដែលបញ្ញាញាណងាយស្រួលបើក, ពេលចៃដន្យអាចមើលឃើញអ្វីមួយចំនួន។ នៅក្នុងថ្នាក់បង្រៀនមានមនុស្សបានមើលឃើញបរមីរបស់ខ្ញុំដោយចៃដន្យ, នៅពេលដែលគាត់មើលដោយចេតនាក៏បាត់ទៅវិញ, តាមពិតគឺបានប្រើភ្នែកមើលរួចហើយ។ ពេលដែលបិទភ្នែកមើលឃើញអ្វីមួយ, ហើយស្មោះស្ម័គ្រថៃទាំស្ថានភាពនោះ, បន្តិចម្តងៗជាក់ស្តែងអាចមើលឃើញកាន់តែច្បាស់។ ប្រសិនបើចង់មើលដោយប្រុងប្រយ័ត្ន, តាមពិតគឺប៉ះដល់ភ្នែកវិញហើយ, រត់ឆ្លងសរសៃប្រសាទនៃភ្នែករួចហើយ, ជាក់ស្តែងមើលមិនឃើញទៀត។

ជាន់ថ្នាក់បញ្ញាញាណមិនដូចគ្នាអវកាសដែលមើលឃើញក៏មិនដូចគ្នា, មានផ្នែកស្រាវជ្រាវខ្លះមិនយល់ពីគោលសីលធម៌នេះ, នាំឱ្យវិសោធកម្មឈើគង់មួយចំនួនសម្រេចមិនបានលទ្ធផលដែលរំពឹងទុក, សូម្បីតែនឹងលេចឡើងលទ្ធផលផ្ទុយមកវិញ។ ឧបមា, មានវិទ្យាស្ថានមួយបានរចនាមួយប្រភេទវិធីសាស្ត្រនៃការសាកល្បងសីលគង់ពិសេស, ទុកឱ្យគ្រូឈីគង់មើលក្នុងប្រអប់បិទជិតមួយមានរបស់អ្វី។ ដោយសារតែជាន់ថ្នាក់បញ្ញាញាណរបស់គ្រូឈីគង់មិនដូចគ្នា, ដូច្នេះលទ្ធផលនៃចម្លើយក៏នីមួយៗមិនដូចគ្នា, ដល់ទីបញ្ចប់, បុគ្គលិកសាកល្បងសន្មតថាបញ្ញាញាណគឺជាក្លែងក្លាយ, គឺបញ្ឆោតមនុស្ស។ ការសាកល្បងបែបនេះជាធម្មតាមនុស្សដែលជាន់ថ្នាក់បញ្ញាញាណទាប 'មើលធ្លុះ' គឺលទ្ធផលល្អ, ដោយសារតែ

បញ្ញាញាណរបស់គាត់គ្រាន់តែបើកនៅជាន់ថ្នាក់ទិព្វចក្ខុវិស័យ, គ្រាន់តែសមស្របសង្កេតមើលរឿងរ៉ាវនៃអវកាសសារធាតុ, ដូច្នេះមនុស្សដែលមិនយល់បញ្ញាញាណគិតថាសីលគង់របស់គាត់ខ្ពស់បំផុត។ វត្ថុណាមួយ, មិនថាវាគឺជាសារធាតុសរីរាង្គឬក៏សារធាតុអសរីរាង្គ, នៅអវកាសមិនដូចគ្នានឹងបង្ហាញរូបរាងមិនដូចគ្នា។ ឧបមាកែវមួយគ្រឿង, នៅពេលវាបានផលិតចេញមក, ជាក់ស្តែងក្នុងពេលដំណាលគ្នាមានរាងកាយវិញ្ញាណមួយស្ថិតនៅក្នុងអវកាសមួយផ្សេងទៀត, លើសពីនេះទៀតនៅមុនពេលរាងកាយវិញ្ញាណនេះស្ថិតនៅក៏អាចជាអ្វីផ្សេងរួចហើយ។ ជាន់ថ្នាក់បញ្ញាញាណទាបបំផុតមើលឃើញគឺជាគ្រឿងកែវ; ខ្ពស់ជាងមួយជាន់មើលឃើញគឺជារាងកាយវិញ្ញាណនោះនៅអវកាសផ្សេង; ខ្ពស់បន្តិចទៀតមើលឃើញគឺជាទម្រង់សារធាតុពីមុនរបស់រាងកាយវិញ្ញាណនោះ។

## ៣. ទូរនេត្រ

បន្ទាប់ពីបញ្ញាញាណបើករួចហើយ, មនុស្សខ្លះនឹងលេចឡើង ‘ទូរនេត្រ’, អាចមើលឃើញអ្វីនៃខាងក្រៅឃ្លាតឆ្ងាយរាប់ពាន់ម៉ាយល៍។ មនុស្សគ្រប់គ្នាសុទ្ធតែមានអវកាសដែលខ្លួនឯងកាន់កាប់, នៅក្នុងអវកាសនេះគាត់ដូចជាទំហំនៃចក្រវាល, នៅអវកាសជាក់លាក់របស់គាត់, ខាងមុខថ្ងាសរបស់គាត់មានមុខកញ្ចក់មួយ, នៅអវកាសរបស់ពួកយើងនេះមើលមិនឃើញ។ មុខកញ្ចក់នេះមនុស្សគ្រប់គ្នាសុទ្ធតែមាន, គ្រាន់តែមនុស្សដែលមិនហាត់គង់មុខ

កញ្ចក់នេះគឺផ្កាប់ចូល; មនុស្សដែលហាត់គង់មុខកញ្ចក់នេះបន្តិចម្តងៗក្រឡាប់មកវិញ។ បន្ទាប់ពីក្រឡាប់មកហើយជាក់ស្តែងអាចបញ្ចាំងដល់អ្វីដែលគាត់ចង់មើល។ នៅអវកាសជាក់លាក់របស់គាត់, គាត់គឺធំណាស់, រាងកាយរបស់គាត់ធំណាស់, មុខកញ្ចក់នេះក៏ជាក់ស្តែងធំណាស់ផងដែរ, ចង់មើលអ្វីមុខកញ្ចក់នឹងអាចបញ្ចាំងដល់។ ប៉ុន្តែបញ្ចាំងដល់រួចហើយគាត់នៅតែមិនអាចមើលឃើញ, រូបភាពនៅតែឈប់នៅលើកញ្ចក់ភ្លាមៗ។ កញ្ចក់នឹងវិលក្រឡាប់, យកវត្ថុដែលបញ្ចាំងដល់ឱ្យលោកអ្នកមើលបន្តិចក៏ក្រឡាប់ទៅវិញម្តងទៀត, ឆាប់រហ័សណាស់ក៏ក្រឡាប់ទៅម្តងទៀត, បន្តក្រឡាប់។ ខ្សែភាពយន្តគឺ២៤រូបភាពក្នុងមួយវិនាទីជាក់ស្តែងអាចមើលឃើញចលនាបន្ត។ ល្បឿនវិលក្រឡាប់របស់កញ្ចក់នៅលឿនជាងនេះទៅទៀត, ដូច្នេះមើលឃើញគឺជាបន្តបន្ទាប់, មើលបានច្បាស់ណាស់, នេះជាក់ស្តែងគឺជាទូរនេត្រ។ គោលសីលធម៌របស់ទូរនេត្រគឺសាមញ្ញយ៉ាងនេះឯង។ នេះសុទ្ធតែជាអាថ៌កំបាំងក្នុងអាថ៌កំបាំង, តែប៉ុន្មានពាក្យខ្ញុំបាននិយាយវាចេញមកហើយ។

## ៤. អវកាស

អវកាស, ពួកយើងឃើញវាគឺស្មុគស្មាញណាស់។ មនុស្សជាតិពួកយើងគ្រាន់តែដឹងអំពីអវកាសដែលមនុស្សជាតិស្ថិតនៅបច្ចុប្បន្ន, អវកាសដទៃទៀតនៅតែគ្មានវិធីសាស្ត្ររុករកចេញបាន។ សម្រាប់អវកាសផ្សេងៗ, គ្រូឈីគង់ពួកយើងបានមើលឃើញដល់រាប់សិបជាន់ថ្នាក់អវកាសរួចហើយ, តាមទ្រឹស្តីក៏អាចពន្យល់ចេញ

បាន, ប៉ុន្តែនៅក្នុងវិទ្យាសាស្ត្រនៅតែគ្មានវិធីសាស្ត្របញ្ជាក់បាន។ មានរឿងមួយចំនួនទោះបីលោកអ្នកមិនទទួលស្គាល់វាស្ថិតនៅក៏ដោយ, ប៉ុន្តែវាពិតជាបានឆ្លុះបញ្ចាំងមកដល់អវកាសរបស់ពួកយើងរួចហើយ។ ឧបមាថា, លើពិភពលោកមានតំបន់មួយហៅថាប្រជុំកោះប៊ើមូដា, គេហៅថាត្រីកោណបិសាច, កប៉ាល់ខ្លះមកដល់ទីនេះក៏បាត់ខ្លួន; យន្តហោះខ្លះមកដល់ទីនេះក៏បាត់ខ្លួនផងដែរ, បន្ទាប់ពីប៉ុន្មានឆ្នាំកន្លងទៅក៏លេចឡើងម្តងទៀត។ គ្មាននរណាម្នាក់អាចពន្យល់ពីហេតុផលនេះបាន, គ្មាននរណាម្នាក់រត់ផុតពីទ្រឹស្តីនៃផ្នត់គំនិតដែលមនុស្សជាតិកំពុងមាន។ តាមពិតទៅវាជាក់ស្តែងគឺជាផ្លូវរន្ធដែលឆ្លងដល់អវកាសមួយផ្សេង។ វាមិនស្រដៀងទ្វាររបស់ពួកយើងដែលមានស្លាបទ្វារតាមបែបធម្មតានេះទេ, ស្ថានភាពរបស់វាគឺមិនអាចទាយទុកជាមុនបាន, ប្រសិនបើកប៉ាល់មួយឆ្លងកាត់នៅពេលទ្វារនៅទីនោះត្រូវបានបើកចេញ, វានឹងងាយស្រួលចូលទៅក្នុង។ មនុស្សមិនមានអារម្មណ៍ថាអវកាសនេះខុសគ្នាទេ, ភ្លាមៗបានចូលទៅក្នុងរួចហើយ, វាខុសគ្នានឹងវេលា-អវកាសរបស់ពួកយើង, មិនអាចប្រើម៉ាយល៍មកបង្ហាញបានទេ, សែនឆ្ងាយដប់ម៉ឺនប្រាំបីពាន់ម៉ាយល៍, នៅទីនេះតែមួយចំណុចប៉ុណ្ណោះ, ជាក់ស្តែងគឺស្ថិតនៅក្នុងវេលាតែមួយនៅកន្លែងតែមួយ។ កប៉ាល់ចូលទៅវិលវល់មួយរយៈ, ហើយក៏ត្រឡប់មកវិញដោយភ្លាមៗ, ប៉ុន្តែនៅលើពិភពលោកបានកន្លងផុតទៅជាច្រើនទសវត្សរ៍រួចហើយ, ដោយសារតែវេលានៃអវកាសទាំងពីរមិនដូចគ្នា។ ក្នុងអវកាសនីមួយៗ

នៅមានពិភពឯកតា, ជាក់ស្តែងដូចជាពួកយើងគួររូបភាពរចនាសម្ព័ន្ធនុយក្លេអ៊ែរ, ចន្លោះរវាងមួយគ្រាប់បាល់មានមួយខ្សែតភ្ជាប់, ប្រសព្វ៧ប្រសព្វ៨សុទ្ធតែជាគ្រាប់បាល់, សុទ្ធតែមានខ្សែតភ្ជាប់, គឺស្មុគស្មាញណាស់។

៤ឆ្នាំមុនសង្គ្រាមលោកលើកទី២, កងទ័ពអាកាសអង់គ្លេសមានអ្នកបើកយន្តហោះម្នាក់ទៅបំពេញបេសកកម្ម, ពាក់កណ្តាលផ្លូវបានជួបនឹងព្យុះផ្គររន្ទះខ្លាំង, ផ្អែកលើបទពិសោធន៍របស់គាត់បានរកឃើញអាកាសយានដ្ឋានមួយដែលគេបោះបង់ចោល។ ខណៈពេលដែលអាកាសយានដ្ឋានបានបង្ហាញខ្លួននៅចំពោះមុខ, ភ្លាមៗគឺជាទស្សនីយភាពមួយផ្សេង, ភ្លាមៗនោះពេញផ្ទៃមេឃរាប់ម៉ឺនម៉ាយល៍គ្មានពពក, ជាក់ស្តែងដូចជាពីពិភពមួយផ្សេងទៀតឆ្លងកាត់មក។ យន្តហោះដែលនៅលើអាកាសយានដ្ឋានត្រូវបានលាបពណ៌លឿង, នៅលើដីមានមនុស្សមមាញឹកធ្វើអ្វីៗ, គាត់មានអារម្មណ៍ចម្លែកណាស់! បន្ទាប់ពីបានចុះចតគ្មាននរណាម្នាក់ចាប់អារម្មណ៍នឹងគាត់, ប៉មបញ្ជាការក៏មិនទាក់ទងជាមួយនឹងគាត់ផងដែរ។ គាត់មើលឃើញមេឃក៏ឈប់ភ្លៀងរួចហើយ, យ៉ាងរហ័សបានចាកចេញទៅ, គាត់បានហោះឡើងវិញ។ ពេលហោះឃ្លាតពីអាកាសយានដ្ឋានស្មើនឹងចម្ងាយមួយនេះដែលគាត់ទើបតែមើលឃើញអាកាសយានដ្ឋាន, សាជាថ្មីបានធ្លាក់ចូលទៅក្នុងព្យុះម្តងទៀត។ ទីបំផុតបានហោះត្រឡប់មកវិញ។ គាត់បានរាយការណ៍ពីស្ថានភាព, កំណត់ត្រាហោះហើរទាំងអស់ត្រូវបានសរសេរចេញ,

ថ្នាក់លើមិនជឿ។ ៤ឆ្នាំក្រោយមក, សង្គ្រាមលោកលើកទី២បានផ្ទុះឡើងខ្លាំង។ គាត់ត្រូវបានផ្ទេរទៅអាកាសយានដ្ឋានដែលគេបោះបង់ចោលនោះ។ ភ្លាមៗគាត់បានចងចាំទស្សនីយភាពនេះកាលពី៤ឆ្នាំមុនពិតជាដូចគ្នា។ គ្រូឈីគង់ពួកយើងសុទ្ធតែដឹងថាគឺជារឿងដូចម្ដេច, គាត់ជាក់ស្ដែងគឺរត់មុនដល់៤ឆ្នាំបន្ទាប់អនុវត្តរឿងមុនមួយលើករួចហើយ, គាត់ជាក់ស្ដែងគឺរត់ទៅមុនដល់ខាងនោះសម្ដែងមុនមួយឈុតរួចហើយ, ឈុតទីមួយនៅមិនទាន់ចាប់ផ្ដើមផងគាត់បានសម្ដែងមុនមួយឈុតរួចហើយ, ត្រឡប់ក្រោយសម្ដែងម្ដងទៀតតាមលំដាប់លំដោយ។

## V. ព្យាបាលជំងឺដោយឈីគង់និងព្យាបាលជំងឺនៅមន្ទីរពេទ្យ

សម្ដែងពីលើទ្រឹស្ដី, ព្យាបាលជំងឺដោយឈីគង់និងព្យាបាលជំងឺនៅមន្ទីរពេទ្យគឺមិនដូចគ្នាទាំងស្រុង។ វេជ្ជសាស្ត្រលោកខាងលិចពិនិត្យជំងឺគឺប្រើវិធីសាស្ត្រនៃសង្គមមនុស្សសាមញ្ញ, ទោះបីមានការធ្វើតេស្ដមន្ទីរពិសោធន៍, ត្រួតពិនិត្យកាំរស្មីឬក៏វិធីសាស្ត្រផ្សេងៗជាដើម, គ្រាន់តែអាចសង្កេតឃើញរោគសញ្ញានៃអវកាសនេះប៉ុណ្ណោះ, មើលមិនឃើញព័ត៌មាននៃអវកាសដទៃទៀត, មើលមិនឃើញមូលហេតុស្ថិតនៅដែលនាំឱ្យមានជំងឺ។ ប្រសិនបើជំងឺរបស់គាត់ស្រាលបង្គួរ, ថ្នាំជាក់ស្ដែងអាចធ្វើឱ្យធាតុបង្កជំងឺ (វេជ្ជសាស្ត្រលោកខាងលិចសម្ដែងថា ‵រោគពុល′, ឈីគង់សម្ដែងថា ‵កម្ម′) លុបបំបាត់ឬក៏រត់ចេញឆ្ងាយ។ នៅក្នុងកាលៈទេសៈដែលជំងឺយ៉ាងធ្ងន់ធ្ងរ, គុណភាពថ្នាំជាក់ស្ដែងដោះស្រាយមិនបាន, ប្រសិនបើ

បង្កើនបរិមាណថ្នាំមនុស្សក៏ទ្រាំមិនបានផងដែរ។ ដោយសារតែមានជំងឺខ្លះមិនមែនសុទ្ធតែកំណត់នៅខាងក្នុងលោកីយ៍ធម៌ប៉ុណ្ណោះទេ, ជំងឺខ្លះធំណាស់, លើសផុតពីវិសាលភាពនៃលោកីយ៍ធម៌, ហេតុនោះមន្ទីរពេទ្យព្យាបាលមិនបាន។

វេជ្ជសាស្ត្រចិនគឺជាវេជ្ជសាស្ត្របុរាណរបស់ប្រទេសយើង, ជាមួយនឹងសីលគង់ពិសេសនៃការបួសហាត់រាងកាយមនុស្សគឺមិនអាចបំបែកបានទេ។ សម័យបុរាណចាប់អារម្មណ៍យ៉ាងខ្លាំងការបួសហាត់រាងកាយមនុស្ស, លទ្ធិខុងជឺ, តាវវង្ស, ពុទ្ធវង្ស, រួមបញ្ចូលនិសិស្សដែលសិក្សាលទ្ធិខុងជឺសុទ្ធតែសម្តែងអង្គុយសមាធិ។ អង្គុយសមាធិគឺបានចាត់ទុកជាមួយប្រភេទជំនាញការ, យូរៗទៅ, ទោះបីមិនមានហាត់គង់ក៏ដោយ, ប៉ុន្តែអាចបញ្ចេញគង់និងសីលគង់។ តើការចាក់ម្ជុលវិទ្យាសាស្ត្រនៃវេជ្ជសាស្ត្រចិនសម្រាប់ខ្សែវណ្ណៃនៃរាងកាយមនុស្សហេតុអ្វីបានរកឃើញច្បាស់លាស់យ៉ាងនោះ? ចំណុចចាក់ម្ជុលវិទ្យាសាស្ត្រនិងចំណុចចាក់ម្ជុលវិទ្យាសាស្ត្រហេតុអ្វីមិនតភ្ជាប់គ្នាតាមជួរទទឹង? មិនតភ្ជាប់ប្រសព្វគ្នា? ហេតុអ្វីបានជាតភ្ជាប់គ្នាតាមជួរបណ្តោយ? ធ្វើដូចម្តេចការពិពណ៌នាត្រឹមត្រូវយ៉ាងនោះ? អ្នកដែលមានសីលគង់ពិសេសសម័យទំនើប, ដែលប្រើភ្នែកមើលឃើញដូចគ្នានឹងការពិពណ៌នានៃវេជ្ជសាស្ត្រចិន, មូលហេតុជាក់ស្តែងគឺវេជ្ជបណ្ឌិតល្បីឈ្មោះនៃសម័យបុរាណជាធម្មតាសុទ្ធតែមានសីលគង់ពិសេស។ ក្នុងប្រវត្តិសាស្ត្រប្រទេសយើង, លីស៊ីហ្សេន, ស៊ុនសឺមៀវ, ប៉ៀនធ្វៀ, ហ្វាធួរតាមពិត

ទៅសុទ្ធតែជាគ្រូធំឈីគង់ដែលមានសីលគង់ពិសេស។ វេជ្ជសាស្ត្រចិនបង្រៀនមកដល់សព្វថ្ងៃ, បានធ្វើវង្វេងបាត់ផ្នែកសីលគង់រួចហើយ, គ្រាន់តែថែរក្សាបានវិធីសាស្ត្រប៉ុណ្ណោះ។ អតីតកាលវេជ្ជសាស្ត្រចិនគឺប្រើភ្នែក (រួមបញ្ចូលសីលគង់ពិសេស) ដើម្បីពិនិត្យជំងឺ, ក្រោយមកក៏សង្វេបបានវិធីសាស្ត្រដែលចាប់ជិពចរ។ ប្រសិនបើប្រើវិធីសាស្ត្រពិនិត្យជំងឺនៃវេជ្ជសាស្ត្រចិនបន្ថែមវិធីសាស្ត្រសីលគង់ពិសេសទៀត, អាចនិយាយបានថាកន្លងដ៏ច្រើនឆ្នាំទៅមុខទៀតវេជ្ជសាស្ត្រលោកខាងលិចរបស់បរទេសក៏ដេញមិនទាន់វេជ្ជសាស្ត្រចិននៃប្រទេសចិនផងដែរ។

ព្យាបាលជំងឺដោយឈីគង់គឺលើមូលដ្ឋានកម្ចាត់ចោលមូលហេតុដែលនាំឱ្យមានជំងឺ។ ខ្ញុំសន្មតថាជំងឺជាក់ស្តែងគឺជាមួយប្រភេទ "កម្ម", ព្យាបាលជំងឺជាក់ស្តែងគឺជួយរំលាយកម្ម។ គ្រូឈីគង់ខ្លះព្យាបាលជំងឺសម្តែងបញ្ចេញឈីខ្មៅ, បញ្ចេញឈីបំពេញឈី, នៅជាន់ថ្នាក់យ៉ាងរាក់បំផុតគាត់យកឈីខ្មៅបញ្ចេញកម្ចាត់ចោលរួចហើយ, ប៉ុន្តែមូលហេតុមូលដ្ឋានដែលផលិតឈីខ្មៅគាត់មិនបានដឹង, ឈីខ្មៅទាំងនេះសាជាថ្មីបានមកម្តងទៀត, ជំងឺម្តងទៀតបានកើតឡើងវិញ។ តាមពិតទៅមិនមែនឈីខ្មៅបណ្តាលឱ្យគាត់មានជំងឺទេ, វត្តមាននៃឈីខ្មៅគ្រាន់តែធ្វើឱ្យគាត់ពិបាកទ្រាំប៉ុណ្ណោះ។ ប៉ុន្តែមូលហេតុមូលដ្ឋានដែលបណ្តាលឱ្យគាត់មានជំងឺគឺនៅក្នុងអវកាសដទៃទៀតកំពុងមានរាងកាយវិញ្ញាណមួយ។ ជាច្រើនគ្រូឈីគង់មិនយល់ច្បាស់រឿងប្រភេទនេះ។ ដោយសារតែរាងកាយ

វិញ្ញាណនោះមានឥទ្ធិពលខ្លាំងណាស់, ជាធម្មតាប៉ះមិនបានទេ, ក៏មិនហ៊ានប៉ះវាផងដែរ។ ហ្វាលូនគង់ពិនិត្យជំងឺជាក់ស្ដែងគឺផ្ដោតលើរាងកាយវិញ្ញាណនោះផ្ទាល់ដើម្បីធ្វើឃាត, យកចេញអ្វីជាមូលដ្ឋានដែលបង្កើតជំងឺ, លើសពីនេះទៀតដាក់កម្រមបមួយនៅទីតាំងមានជំងឺ, មិនអនុញ្ញាតឱ្យជំងឺម្ដងទៀតច្រោះចូលបាន។

ឈីគង់អាចពិនិត្យជំងឺ, ប៉ុន្តែមិនអាចជ្រៀតជ្រែកស្ថានភាពសង្គមមនុស្សសាមញ្ញ។ ប្រសិនបើអនុវត្តលើទ្រង់ទ្រាយធំជាក់ស្ដែងនឹងជ្រៀតជ្រែកស្ថានភាពមនុស្សសាមញ្ញ, នេះគឺមិនអនុញ្ញាត , ប្រសិទ្ធភាពក៏មិនល្អផងដែរ។ អ្នករាល់គ្នាដឹងថា, ជាធម្មតាបើកវេជ្ជគ្រឹះឈីគង់, មន្ទីរពេទ្យឈីគង់, មជ្ឈមណ្ឌលស្ដារនីតិសម្បទាឈីគង់, មុនពេលដែលគាត់មិនទាន់បើកប្រសិទ្ធភាពព្យាបាលអាចយ៉ាងល្អ, ដរាបណាបើករបរពិនិត្យជំងឺ, ប្រសិទ្ធភាពរបស់វាជាក់ស្ដែងធ្លាក់ចុះដុនដាបមួយរំពេច, ជាក់ស្ដែងគឺមិនអនុញ្ញាតប្រើធម៌ដែលលើសផុតពីមនុស្សសាមញ្ញមកជំនួសមុខងាររបស់សង្គមមនុស្សសាមញ្ញ។ ធ្វើយ៉ាងនេះហើយជាក់ស្ដែងជៀសមិនរួចទាបដូចគ្នាជាមួយធម៌នៃសង្គមមនុស្សសាមញ្ញ។

សីលគង់ពិសេស 'មើលធ្លុះរាងកាយមនុស្ស', អាចមើលឃើញដូចជាចំណិត, មើលតាមមួយជាន់ៗ, អាចមើលឃើញជាលិកាទន់ក៏ដូចជាទីតាំងណាមួយនៃរាងកាយ។ ការស្កេនCTបច្ចុប្បន្នទោះបីអាចមើលឃើញយ៉ាងច្បាស់លាស់, ប៉ុន្តែ, វាយ៉ាងណាមិញគឺប្រើម៉ាស៊ីន, ចំណាយពេលណាស់, ប្រើខ្សែភាពយន្តច្រើនណាស់,

ឃើតណាស់, ថ្លៃណាស់។ មិនមានភាពងាយស្រួល, ត្រឹមត្រូវល្អដូចសីលគង់ពិសេសរបស់មនុស្សទេ។ គ្រូឈីគង់បិទភ្នែកបោសភ្លាម, ជាក់ស្តែងអាចមើលឃើញច្បាស់លាស់ដោយផ្ទាល់ទីតាំងណាមួយរបស់អ្នកជំងឺ។ តើនេះមិនមែនបច្ចេកវិទ្យាខ្ពស់ឬ? នេះគឺជាបច្ចេកវិទ្យាខ្ពស់ដែលសូម្បីតែខ្ពស់ជាងប្រៀបនឹងបច្ចេកវិទ្យាខ្ពស់ទំនើប។ ទោះយ៉ាងណាក៏ដោយ, កម្រិតប្រភេទនេះនៅប្រទេសចិនសម័យបុរាណជាក់ស្តែងមានរួចមកហើយ, គឺជាបច្ចេកវិទ្យាខ្ពស់ដែលមាននៅសម័យបុរាណ។ ហ្វាធួរមើលចេញបានក្នុងខួរក្បាលឆាវឆាវមានកើតដំបៅ, ចង់ធ្វើការវះកាត់ឱ្យគាត់។ ឆាវឆាវមិនអាចទទួលយកបាន, គិតថាគឺជាការធ្វើបាបគាត់, គាត់ចាប់ហ្វាធួរ, លទ្ធផលឆាវឆាវនៅតែស្លាប់ដោយដំបៅខួរក្បាល។ ក្នុងប្រវត្តិសាស្រ្តមានយ៉ាងច្រើនវេជ្ជបណ្ឌិតធំនៃវេជ្ជសាស្រ្តចិនសុទ្ធតែមានសីលគង់ពិសេស, គ្រាន់តែ, នៅក្នុងសង្គមទំនើបដោយសារតែមនុស្សគ្រប់គ្នាស្វែងរកអ្វីដែលប្រាកដនិយមខ្លាំងពេក, ហើយភ្លេចនូវប្រពៃណីបុរាណ។

បួសហាត់ឈីគង់ជាន់ថ្នាក់ខ្ពស់របស់ពួកយើង, ជាក់ស្តែងគឺត្រូវតែយល់ដឹងសាជាថ្មីអ្វីនៃប្រពៃណី, នៅក្នុងការអនុវត្តជាក់ស្តែងយកវាបន្តស្នងមរតកនិងចម្រើនលូតលាស់ទៅមុខ, សាជាថ្មីប្រើការដើម្បីផ្តល់ផលប្រយោជន៍ដល់សង្គមមនុស្សជាតិ។

# VI. ឈីគង់ពុទ្ធវង្សនិងពុទ្ធសាសនា

ពួកយើងនៅពេលដែលនិយាយដល់ឈីគង់ពុទ្ធវង្ស, ជាច្រើនមនុស្សជាក់ស្ដែងស្រមៃដល់បញ្ហាមួយ៖ ពុទ្ធវង្សគឺជាបួសព្រះពុទ្ធ, ជាក់ស្ដែងគិតដល់រឿងរ៉ាវក្នុងព្រះពុទ្ធសាសនា។ ខ្ញុំនៅទីនេះសូមបញ្ជាក់យ៉ាងច្បាស់ថា, ហ្វាលូនគង់គឺជាឈីគង់ពុទ្ធវង្ស, គឺជាមហាធម៌បង្រៀនសុចរិត, គ្មានទំនាក់ទំនងជាមួយនឹងពុទ្ធសាសនា។ ឈីគង់ពុទ្ធវង្សគឺជាឈីគង់ពុទ្ធវង្ស, ពុទ្ធសាសនាគឺជាពុទ្ធសាសនា, ទោះបីគោលបំណងនៃការបួសហាត់គឺដូចគ្នា, ប៉ុន្តែដើរផ្លូវខុសពីគ្នា, មិនមែនធម្មក្ខន្ធតែមួយ, តម្រូវក៏មិនដូចគ្នាផងដែរ។ ខ្ញុំនៅទីនេះលើកឡើងពាក្យមួយថា "ពុទ្ធ", ពេលសម្ដែងគង់លើជាន់ថ្នាក់ខ្ពស់នៅពេលក្រោយខ្ញុំនឹងលើកឡើងទៀត, ខ្លួនវាផ្ទាល់គ្មានឱជារសអបិយជំនឿអ្វី។ មនុស្សខ្លះនៅពេលណាស្ដាប់ឮដល់ "ពុទ្ធ" ពិតជាមិនគួរឱ្យជឿ, និយាយថាលោកអ្នកកំពុងផ្សព្វផ្សាយអបិយជំនឿ; មិនមែនបែបនេះទេ។ "ពុទ្ធ" នេះគឺជាភាសាសំស្ក្រឹត, ពីប្រទេសឥណ្ឌាចម្លងមក, សរសេរតាមសូរសព្ទជាពីរអក្សរហៅថា "ពុទ្ធោ" (Buddha), គេបានលុបអក្សរ "ធោ" ចោល, រួចហើយហៅថា "ពុទ្ធ", បកប្រែជាភាសាចិនជាក់ស្ដែងគឺជា "អង្គត្រាស់ដឹង", មនុស្សដែលបានត្រាស់ដឹងរួចហើយ (មើលវចនានុក្រម]«ឆីហាយ»)។

## ១. ឈីគង់ពុទ្ធវង្ស

ឈីគង់ពុទ្ធវង្សដែលបង្រៀនចេញនាពេលបច្ចុប្បន្នមានពីរប្រភេទ។ មួយប្រភេទគឺបំបែកចេញពីព្រះពុទ្ធសាសនា, វានៅក្នុង

ការអភិវឌ្ឍន៍រាប់ពាន់ឆ្នាំបានលេចឡើងជាច្រើនអធិសង្ឃ, ពួកគាត់នៅក្នុងដំណើរការបួសហាត់, នៅពេលបួសដល់ជាន់ថ្នាក់ដ៏ខ្ពស់, នឹងមានគ្រូខាងលើបង្រៀនឱ្យពួកគាត់អ្វីមួយចំនួន, ទទួលបាននូវការបង្រៀនពិតប្រាកដនៃជាន់ថ្នាក់ខ្ពស់ជាង។ រឿងទាំងនេះកន្លងមកនៅក្នុងពុទ្ធសាសនាសុទ្ធតែជាការបង្រៀនដោយឯកតោ, នៅពេលដែលអធិសង្ឃជិតដល់១០០ឆ្នាំទើបបង្រៀនឱ្យសិស្សម្នាក់ទៀត, យោងតាមទ្រឹស្តីព្រះពុទ្ធសាសនាដើម្បីបួស, លើកកម្ពស់ជារូម។ ឈីគង់ប្រភេទនេះ, មើលទៅគឺមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងពុទ្ធសាសនា។ ក្រោយមកព្រះសង្ឃត្រូវបានបណ្តេញចេញពីវត្តអារាម, ដូចនៅក្នុងសម័យកាល 'មហាបដិវត្តន៍វប្បធម៌', គង់ហ្វាទាំងនេះបានហូរធ្លាក់ទៅក្នុងសាធារណៈជន, ក៏មានការអភិវឌ្ឍន៍ចំនួនធំនៅក្នុងសាធារណៈជនផងដែរ។

មួយប្រភេទផ្សេងទៀតក៏ជាឈីគង់ពុទ្ធវង្សផងដែរ, ឈីគង់ពុទ្ធវង្សប្រភេទនេះគ្រប់ជំនាន់សុទ្ធតែមិនមានបញ្ចូលក្នុងពុទ្ធសាសនា, តែងតែបួសដោយភាពសម្ងាត់ក្នុងសាធារណៈជនឬក៏នៅក្នុងភ្នំជ្រៅ។ គង់ហ្វាប្រភេទនេះសុទ្ធតែមានកន្លែងពិសេសតែមួយគត់, វាសុទ្ធតែតម្រូវជ្រើសរើសកូនសិស្សមួយដែលល្អ, វត្តិមហាគុណធម៌ដែលពិតជាមានគ្រប់គ្រាន់សមត្ថភាពបួសហាត់ឡើងជាន់ថ្នាក់ខ្ពស់។ មនុស្សបែបនេះអស់រយៈពេលជាច្រើនឆ្នាំទើបអាចលេចឡើងក្នុងលោកម្នាក់។ គង់ហ្វាទាំងនេះមិនអាចផ្សព្វផ្សាយជាសាធារណៈបានទេ, តម្រូវចិត្តគំនិតខ្ពស់ណាស់, បង្កើនគង់ក៏ឆាប់

រហ័សខ្លាំងណាស់ផងដែរ, គង់ហ្វាប្រភេទនេះមិនមែនភាគតិច។ តាវវង្សក៏ដូចគ្នាផងដែរ, ដូចគ្នាគឺជាគង់តាវវង្ស, មានបែងចែកជានិកាយគុនលុន, និកាយអឿម៉យ, និកាយវូតាងជាដើម។ ក្នុងនិកាយនីមួយៗនៅមានធម្មក្ខន្ធខុសៗគ្នា, មុខវិជ្ជាគង់ហ្វានីមួយៗសុទ្ធតែខុសពីគ្នាឆ្ងាយខ្លាំងណាស់, សុទ្ធតែមិនអាចលាយបញ្ចូលដើម្បីហាត់បានទេ។

## ២. ពុទ្ធសាសនា

ពុទ្ធសាសនាគឺជាមួយសំណុំនៃការបួសហាត់ដែលសក្យមុនីជាង២ពាន់ឆ្នាំមុននៅឥណ្ឌាខ្លួនឯងបានត្រាស់ដឹងដោយផ្អែកលើមូលដ្ឋានបួសហាត់ដែលលោកធ្លាប់មាន។ សម្ដែងសង្ខេបជាក់ស្ដែងគឺជា៣អក្សរ 〝សីល-សមាធិ-បញ្ញា〞។ សីលគឺដើម្បីសមាធិ។ ពុទ្ធសាសនាមិនសម្ដែងអំពីហាត់គង់, តាមពិតទៅគឺកំពុងហាត់គង់, ពេលគាត់រម្ងាប់ចុះអង្គុយនៅទីនោះជាក់ស្ដែងគឺជាការហាត់គង់។ ដោយសារតែនៅពេលមនុស្សស្ងប់ចុះពេលផ្ដោតចិត្ត, ថាមពលនៃចក្រវាលនឹងប្រមូលផ្ដុំនៅលើរាងកាយរបស់គាត់, ដើរតួនាទីនៃការហាត់គង់។ ៶សីល៸ នៃពុទ្ធសាសនា, ជាក់ស្ដែងគឺត្រូវលះបង់រាល់តណ្ហារបស់មនុស្សសាមញ្ញ, បោះបង់ចោលទាំងអស់នូវអ្វីដែលមនុស្សសាមញ្ញប្រកាន់, ដោយហេតុនេះសម្រេចបានស្ថានភាពនៃ៶សភាពគ្មានបំណងស្ងប់ស្ងាត់៸, ជាក់ស្ដែងអាចរម្ងាប់ចុះបាន, នៅក្នុងសមាធិបន្តលើកកម្ពស់ជាន់ថ្នាក់, បន្ទាប់មកត្រាស់ដឹងបើកបញ្ញា, យល់ដឹងពីចក្រវាល, មើលឃើញសេចក្ដីពិតនៃចក្រវាល។

នៅពេលសក្យមុនីចាប់ផ្តើមបង្រៀនធម៌មួយថ្ងៃគ្រាន់តែធ្វើរឿង ៣យ៉ាង៖ សម្តែងធម៌ (ដែលបង្រៀនជាចម្បងគឺអរហន្តធម៌), កូនសិស្សស្តាប់ធម៌; បន្ទាប់មកគឺឱបបាត្រ (ចាន) ដើរទ្រង់បាត្រ (សុំបាយ); បន្ទាប់មកទៀតជាក់ស្តែងគឺអង្គុយសមាធិបួសពិត។ បន្ទាប់ពីសក្យមុនីមិននៅលើលោកនិងបន្ទាប់ពីបានឆ្លងកាត់ការតស៊ូរវាងព្រាហ្មសាសនានិងពុទ្ធសាសនា, ពីរប្រភេទសាសនានេះបានរួមបញ្ចូលគ្នាក្លាយជាមួយប្រភេទសាសនាហិនឌូ, ដូច្នេះបច្ចុប្បន្ននៅឥណ្ឌាគ្មានពុទ្ធសាសនាទេ។ នៅក្នុងដំណើរការនៃការអភិវឌ្ឍន៍និងវិវត្តន៍ក្រោយមក, បានលេចឡើងពុទ្ធសាសនាមហាយាន, រាលដាលដល់ប្រទេសចិនដីគោកជាក់ស្តែងគឺជាពុទ្ធសាសនាបច្ចុប្បន្ន។ ពុទ្ធសាសនាមហាយានមិនមែនជំនឿតែសក្យមុនីមួយធ្វើជាអង្គគោរពបូជា, ប៉ុន្តែគឺជំនឿជាច្រើនព្រះពុទ្ធ, ជំនឿជាច្រើនព្រះយូឡាយ, ព្រះពុទ្ធអាមីធួនិងព្រះពុទ្ធគ្រូឱសថជាដើម។ វិន័យក៏ច្រើនជាង, គោលដៅបួសហាត់ក៏ខ្ពស់ជាងផងដែរ។ នាពេលនោះសក្យមុនីនៅក្នុងចំណោមសិស្សពិសេសធ្លាប់បានបង្រៀនព្រះពោធិសត្វធម៌, ក្រោយមកបានយកអ្វីទាំងនេះតម្រៀបចេញហើយអភិវឌ្ឍក្លាយជាពុទ្ធសាសនាមហាយានបច្ចុប្បន្ន, បួសព្រះពោធិសត្វវិស័យ។ ឥឡូវនេះក្នុងតំបន់អាស៊ីភាគអាគ្នេយ៍នៅតែរក្សាប្រពៃណីពុទ្ធសាសនាហិនយាន, ប្រើទេពអំណាចប្រារព្ធពិធីធម៌។ ក្នុងដំណើរការនៃការវិវត្តន៍របស់ពុទ្ធសាសនា, មួយសាខាបានបង្រៀនចូលទៅក្នុងទីបេប្រទេសយើងហៅថា ‵ចាងមី៊′; មួយសាខាផ្សេង

តាមរយៈស៊ីនជាំងបានបង្រៀនចូលទឹកដីជនជាតិហាន់ហៅថា ‵ថាងមី៊′ (បន្ទាប់ពីយុគសម័យពន្លត់ព្រះពុទ្ធក្នុងអំឡុងឆ្នាំហ៊ូឆាង បានបាត់ខ្លួនរួចហើយ); មួយសាខាទៀតជាក់ស្តែងគឺនៅតណ្ហា បង្កើតជាយោគៈគង់។

នៅក្នុងពុទ្ធសាសនាមិនសម្តែងអំពីហាត់គង់, ក៏មិនហាត់ឈី គង់ផងដែរ, នេះគឺដើម្បីរក្សានិងការពារវិធីសាស្រ្តបួសហាត់នៃ ប្រពៃណីពុទ្ធសាសនា, ក៏ជាហេតុផលដ៏សំខាន់ដែលពុទ្ធសាសនា អាចរីករាលដាលជាង២០០០ឆ្នាំដោយគ្មានការធ្លាក់ចុះ។ ជាក់ស្តែងដោយសារតែគាត់មិនទទួលយកនូវអ្វីដែលមកពីខាងក្រៅ, ទើបងាយស្រួលក្នុងការរក្សាប្រពៃណីផ្ទាល់ខ្លួន។ ធម៌បួសនៃពុទ្ធសាសនាក៏មិនដូចគ្នាទាំងស្រុង។ ពុទ្ធសាសនាហិនយានសង្កត់ធ្ងន់ ទៅលើប្រោសខ្លួនឯង, បួសខ្លួនឯង; ពុទ្ធសាសនាមហាយានបាន អភិវឌ្ឍរហូតដល់ ‵ប្រោសខ្លួនឯងប្រោសមនុស្ស′, ‵ប្រោសសត្វ លោកទាំងឡាយ′។

## VII. សុចរិតធម៌និងទុចរិតធម៌

### ១. ទ្វារចំហៀងផ្លូវឆ្វេង

ទ្វារចំហៀងផ្លូវឆ្វេងក៏ត្រូវបានគេហៅថាធម៌បួសទ្វារវិសេស។ នៅមុនពេលមានសាសនា, បណ្តានិកាយឈីគង់បានស្ថិតនៅរួច មកហើយ។ គង់ហ្វាដែលក្រៅពីសាសនាមានជាច្រើនកំពុងស្ទួង បង្រៀននៅក្នុងសាធារណៈជន, ភាគច្រើនគ្មានក្លាយជាមួយសំណុំ ប្រព័ន្ធបួសហាត់ពេញលេញ, គ្មានមួយសំណុំទ្រឹស្តីពេញលេញ។

ប៉ុន្តែធម៌បួសទ្វារវិសេសមានវិធីសាស្ត្របួសហាត់ពង្រឹងពិសេសតាមលក្ខណៈជាប្រព័ន្ធនិងពេញលេញ, ក៏កំពុងស្មងបង្រៀននៅក្នុងសាធារណៈជនផងដែរ។ គង់ហ្វាប្រភេទនេះជាធម្មតាបានគេហៅថា ‵ទ្វារចំហៀងផ្លូវឆ្វេង′។ ហេតុអ្វីបានគេហៅថា ‵ទ្វារចំហៀងផ្លូវឆ្វេង′? មើលពីផ្ទៃនៃអក្សរ, ‵ទ្វារចំហៀង′ ជាក់ស្តែងគឺជាទ្វារនៅម្ខាង, ‵ផ្លូវឆ្វេង′ ជាក់ស្តែងគឺដែលល្វីល្វើ។ មនុស្សរាល់គ្នាសន្មតថាវិធីសាស្ត្របួសហាត់របស់ពីរវង្សពុទ្ធនិងតាវសុទ្ធតែជាសុចរិតធម៌, គង់ហ្វាដទៃទៀតសុទ្ធតែជាទ្វារចំហៀងផ្លូវឆ្វេង, ឬក៏ជាទុចរិតធម៌។ ជាការពិតមិនមែនបែបនេះទេ។ ទ្វារចំហៀងផ្លូវឆ្វេងគ្រប់ជំនាន់សុទ្ធតែជាការបួសសម្ងាត់ឬក៏បង្រៀនដោយឯកតា, មិនអាចយកចេញមកបង្ហាញមនុស្សបានទេ។ នៅពេលបង្រៀនចេញ, មនុស្សរាល់គ្នាសុទ្ធតែមិនងាយស្រួលពន្យល់។ ពួកគាត់ក៏បានហៅគង់ហ្វាខ្លួនឯងថាមិនមែនពុទ្ធមិនមែនតាវ។ វិធីសាស្ត្របួសហាត់របស់វាមានតម្រូវចិត្តគំនិតតឹងរឹង, វាគឺយោងតាមលក្ខណៈពិសេសនៃចក្រវាលដើម្បីបួសហាត់, សម្តែងអនុវត្តករុណា, រក្សាចិត្តគំនិត។ ក្នុងចំណោមអធិជនសុទ្ធតែមានជំនាញការពិសេស, មានជំនាញការពិសេសខ្លះក៏អស្ចារ្យណាស់ផងដែរ។ ខ្ញុំធ្លាប់បានជួបអធិជនទ្វារវិសេស៣រូប, បានបង្រៀនឱ្យខ្ញុំអ្វីមួយចំនួន, នៅក្នុងពីរវង្សពុទ្ធនិងតាវសុទ្ធតែរកមិនឃើញ។ អ្វីទាំងនេះនៅក្នុងដំណើរការបួសហាត់សុទ្ធតែពិបាកណាស់, គង់ដែលបានហាត់ចេញក៏ពិសេសតែមួយគត់ផងដែរ។ ផ្ទុយមកវិញ, ក្នុងគង់ហ្វាមួយចំនួននៃពីរវង្សពុទ្ធ

និងតាវដែលបានបង្រៀនបច្ចុប្បន្ន, មានខ្លះកង្វះនូវតម្រូវចិត្តគំនិត តឹងរឹង, ដូច្នេះបួសមិនខ្ពស់, ដូច្នេះ, សម្រាប់គង់ហ្វានៃវង្សនីមួយៗ គួរតែសង្កេតមើលដោយមិនលំអៀង។

## ២. ឈីគង់សិល្បៈក្បាច់គុន

ឈីគង់សិល្បៈក្បាច់គុនគឺបានបង្កើតឡើងដោយឆ្លងកាត់ សម័យកាលប្រវត្តិសាស្ត្រយូរលង់, មានមួយសំណុំប្រព័ន្ធទ្រឹស្តី, វិធី បួសហាត់ពេញលេញ, បានបង្កើតជាប្រព័ន្ធឯករាជ្យ។ ប៉ុន្តែ និយាយដោយតឹងរឹង, វាគ្រាន់តែជាការបង្ហាញរបស់សីលគង់ដែល លេចឡើងនៅជាន់ថ្នាក់ទាបបំផុតក្នុងគង់ហ្វាបួសផ្ទៃក្នុងប៉ុណ្ណោះ។ សីលគង់ដែលលេចឡើងក្នុងបួសហាត់សិល្បៈក្បាច់គុន, សុទ្ធតែ លេចឡើងក្នុងគង់បួសផ្ទៃក្នុង។ បួសហាត់ឈីគង់សិល្បៈក្បាច់គុន ក៏ចាប់ផ្តើមពីការហាត់ឈីផងដែរ, ឧបមានៅពេលកាប់ដុំថ្ម, ចាប់ ផ្តើមជាក់ស្តែងត្រូវតែបង្វិលដៃដើម្បីផ្លាស់ទីឈី, ពេលវេលាយូរឈី នឹងកើតឡើងការផ្លាស់ប្តូររឹងមាំនិងប្រាកដ, បង្កើតទៅជាចង្កោម ថាមពល, មើលទៅដូចជាស្ថិតនៅពន្លឺមួយប្រភេទ, នៅពេល សម្រេចបានកម្រិតប្រភេទនេះ, គង់ជាក់ស្តែងនឹងចាប់ផ្តើមដំណើរ ការ។ ដោយសារតែគង់គឺជាសារធាតុកម្រិតខ្ពស់, មាននាំភាពវៃ ឆ្លាតជាមួយ, វាត្រូវបានឃុំគ្រងដោយផ្ទត់គំនិតនៃខួរក្បាល, ស្ថិត នៅក្នុងអវកាសផ្សេងទៀត។ នៅពេលវាយបុកមិនចាំបាច់ផ្លាស់ទី ឈី, ពេលគិតដល់គង់បានមករួចហើយ។ ជាមួយនឹងការបួស ហាត់, គង់នឹងបន្តពង្រឹង, ភាគល្អិតក្លាយជាស្ទើងជាង, ថាមពល

ក្លាយជាធំជាង, បានលេចឡើងជំនាញ "បាតដៃដែក", "បាតដៃបារ៉ែត"។ ដោយមើលឃើញពីលើភាពយន្តនិងទស្សនាវដ្ដី, ប៉ុន្មានឆ្នាំថ្មីៗនេះបានលេចឡើងជំនាញ "កម្របជួងមាស", "អាវក្រោះ", នេះគឺបានបង្កើតឡើងដោយការប្ហូសសិល្បៈក្បាច់គុននិងប្ហូសផ្ទៃក្នុងដំណាលគ្នា, គឺ 'ប្ហូសទាំងខាងក្នុងនិងខាងក្រៅ' លេចឡើងមក។ ចង់ប្ហូសផ្ទៃក្នុងជាក់ស្ដែងត្រូវគោរពគុណធម៌, ត្រូវប្ហូសចិត្តគំនិត។ សម្ដែងទៅតាមទ្រឹស្ដី, ជំនាញរបស់គាត់ឈានដល់កម្រិតជាក់លាក់, វាបណ្ដាលឱ្យគង់ត្រូវបានបញ្ចេញពីខាងក្នុងរាងកាយ, បញ្ចេញនៅខាងក្រៅរាងកាយ, ដោយសារតែដង់ស៊ីតេខ្ពស់, នឹងបង្កើតជាខែលការពារ។ ឈីគង់សិល្បៈក្បាច់គុនសម្ដែងទៅតាមទ្រឹស្ដីភាពខុសគ្នាធំបំផុតជាមួយនឹងការប្ហូសផ្ទៃក្នុងរបស់ពួកយើងនៅកន្លែងសិល្បៈក្បាច់គុនគឺហាត់ក្នុងចលនាខ្លាំងក្លា, គ្មានចូលទៅក្នុងភាពស្ងប់ស្ងាត់។ មិនចូលទៅក្នុងភាពស្ងប់ស្ងាត់ឈីរត់ក្រោមស្បែក, ឈីលេចចេញតាមសាច់ដុំ, មិនចូលទៅក្នុងតានធៀន, ដូច្នេះមិនប្ហូសជីវិត, ក៏មិនអាចប្ហូសជីវិត។

## ៣. ប្ហូសបញ្ញាសនិងកម្មីគង់

មនុស្សខ្លះគ្មានធ្លាប់បានហាត់ឈីគង់, ស្រាប់តែក្នុងមួយយប់ទទួលបានគង់, ថាមពលក៏មិនតូច, នៅអាចពិនិត្យជំងឺឱ្យមនុស្សទៀត, មនុស្សរាល់គ្នាក៏ហៅគាត់ថា 'គ្រូឈីគង់', គាត់ក៏កំពុងបង្រៀនមនុស្សដទៃផងដែរ; មនុស្សខ្លះត្បិតអីមិនធ្លាប់បានរៀនគង់ហ្វា, ឬក៏ធ្លាប់បានរៀនប៉ុន្មានចលនា, ខ្លួនឯងបានកែច្នៃបន្តិចរួច

ហើយបង្រៀនមនុស្សដទៃ។ មនុស្សប្រភេទនេះមិនស័ក្តិសមធ្វើជាគ្រូឈីគង់ទេ, គាត់គ្មានអ្វីអាចស្នងបង្រៀនឱ្យមនុស្សដទៃ។ អ្វីដែលគាត់បង្រៀនជាការពិតមិនអាចបួសហាត់ឡើងជាន់ថ្នាក់ខ្ពស់, ភាគច្រើនគឺដើម្បីព្យាបាលជំងឺកាយសម្បទា។ តើគង់ប្រភេទនេះបានមកដូចម្ដេច? មុនដំបូងសម្ដែងបន្តិចអំពីបួសបញ្ច្រាស។ ដែលគេហៅថាបួសបញ្ច្រាសគឺសំដៅទៅលើមនុស្សមួយចំនួនដែលមានចិត្តគំនិតយ៉ាងខ្ពស់បំផុត, ល្អខ្លាំងណាស់, ច្រើនតែជាមនុស្សចាស់, អាយុជាង៥០ឆ្នាំ, វាឃើតពេលសម្រាប់គាត់ក្នុងការបួសហាត់តាំងពីដំបូង, ចង់ជួបបានគ្រូ(ជាន់)ខ្ពស់ដែលចិត្តជីវិតបួសទាំងទ្វេមិនងាយស្រួលទេ។ នៅពេលដែលគាត់គិតចង់ហាត់គង់, គ្រូខាងលើនឹងបន្ថែមថាមពលដ៏ធំដល់គាត់ដោយផ្អែកលើមូលដ្ឋាននៃចិត្តគំនិតរបស់គាត់, ពីលើចុះក្រោមបួសផ្ទុយមកវិញ, នេះជាក់ស្ដែងឆាប់រហ័សជាង។ គ្រូខាងលើនៅលើអាកាសវិវត្ត, បន្តពីខាងក្រៅរាងកាយបន្ថែមថាមពលដល់គាត់, ជាពិសេសនៅពេលដែលគាត់ពិនិត្យជំងឺ, បង្កើតវាល, ថាមពលដែលគ្រូខាងលើផ្ដល់ឱ្យប្រៀបដូចពីក្នុងបំពង់ដឹកជញ្ជូនឱ្យគាត់, មនុស្សខ្លះគាត់ខ្លួនឯងនៅតែមិនដឹងថាពីណាមក។ នេះជាក់ស្ដែងគឺជាបួសបញ្ច្រាស។

នៅមានមួយប្រភេទទៀតគឺជា ៉កម្មគង់៉។ កម្មគង់មិនកំហិតតាមអាយុទេ។ មនុស្សក្រៅពីសតិម្ចាស់នៅមានសតិរង, ជាធម្មតាសតិរងមានជាន់ថ្នាក់ខ្ពស់ជាងសតិម្ចាស់។ មនុស្សខ្លះជាន់ថ្នាក់សតិរងខ្ពស់ណាស់, អាចទាក់ទងជាមួយនឹងអង្គត្រាស់ដឹងបាន,

មនុស្សប្រភេទនេះនៅពេលចង់ហាត់គង់, សតិរងក៏ចង់លើកកម្ពស់ជាន់ថ្នាក់ផងដែរ, ជាបន្ទាន់បានទាក់ទងជាមួយនឹងអង្គមហាត្រាស់ដឹងដើម្បីខ្ចីគង់។ បន្ទាប់ពីខ្ចីគង់ឱ្យគាត់រួចហើយ, ក៏ជាក្នុងមួយយប់ទទួលបានគង់, បន្ទាប់ពីទទួលបានគង់ក៏អាចពិនិត្យជំងឺឱ្យមនុស្ស, បន្ធូរបន្ថយការឈឺចាប់របស់អ្នកជំងឺ។ គាត់ជាធម្មតាជ្រើសប្រើវិធីសាស្ត្របង្កើតវាល, នៅអាចផ្តល់ថាមពលដល់មនុស្សតែម្នាក់, បង្រៀនឱ្យមនុស្សបច្ចេកទេសមួយចំនួន។

ជាធម្មតាមានមនុស្សបែបនេះ, ចាប់ផ្តើមគឺល្អណាស់, មានគង់រួចហើយ, កេរ្តិ៍ឈ្មោះដ៏អស្ចារ្យ, កិត្តិនាមនិងផលប្រយោជន៍បានទាំងព្រម។ អត្រានៃកិត្តិនាមនិងផលប្រយោជន៍នៅក្នុងខួរក្បាលបានកាន់កាប់មួយផ្នែកដ៏ធំ, បានលើសពី(ផ្នែក)ហាត់គង់, ចាប់ពីពេលនេះទៅគង់ក៏ធ្លាក់ចុះ, គង់ជាក់ស្តែងកាន់តែតូច, ទីបំផុតអ្វីក៏គ្មានទៀត។

## ៤. ភាសាចក្រវាល

មនុស្សខ្លះភ្លាមៗអាចនិយាយចេញមួយប្រភេទភាសា, ប្រភេទភាសានេះបាននិយាយយ៉ាងស្ទាត់ជំនាញ, ប៉ុន្តែវាមិនមែនជាភាសានៃសង្គមមនុស្សជាតិ។ តើហៅថាអ្វី? ហៅថា ‛ភាសាចក្រវាល៎។ ដែលគេហៅថា ‛ភាសាចក្រវាល៎, វាគ្រាន់តែជាភាសានៃរាងកាយជីវិតមួយនោះដែលមិនខ្ពស់ពេកប៉ុណ្ណោះ។ បច្ចុប្បន្នមនុស្សហាត់ឈីគង់នៅក្នុងប្រទេសមានមិនតិចបានលេចឡើងប្រភេទកាលៈទេសៈនេះ, សូម្បីតែមនុស្សខ្លះចេះនិយាយជាច្រើនប្រភេទភាសា

ខុសគ្នាទៀតផង។ ជាការពិតណាស់, ភាសានៃសង្គមមនុស្សជាតិពួកយើងក៏ស្មុគស្មាញណាស់ផងដែរ, មានជាងមួយពាន់ប្រភេទ។ តើភាសាចក្រវាលត្រូវបានរាប់ចូលជាសីលគង់ដែរឬទេ? ខ្ញុំនិយាយថាវាមិនអាចរាប់ចូលបាន, វាមិនមែនជាមួយប្រភេទសីលគង់របស់រាងកាយផ្ទាល់, ក៏មិនមែនជាមួយប្រភេទសីលគង់ដែលមកពីខាងក្រៅផ្តល់ឱ្យលោកអ្នកផងដែរ, ប៉ុន្តែគឺដោយសារបានមួយប្រភេទរាងកាយជីវិតដែលមកពីខាងក្រៅបញ្ចូល។ រាងកាយជីវិតនេះប្រភពមកពីជាន់ថ្នាក់ខ្ពស់បន្តិច, យ៉ាងហោចណាស់ក៏ខ្ពស់ជាងមនុស្សជាតិពួកយើងបន្តិច, គឺវាកំពុងនិយាយ។ មនុស្សដែលនិយាយភាសាចក្រវាលគ្រាន់តែដើរតួនាទីជាមីក្រូហ្វូនប៉ុណ្ណោះ។ ពាក្យដែលមនុស្សភាគច្រើននិយាយគាត់ខ្លួនឯងក៏មិនដឹងថាអត្ថន័យទូទៅគឺជាអ្វី, មានតែមនុស្សដែលមានសីលគង់ "អានគំនិត" រួចហើយ, គាត់អាចដឹងពីអត្ថន័យទូទៅ។ ដោយសារវាមិនមែនជាសីលគង់, បន្ទាប់ពីមនុស្សជាច្រើនបាននិយាយរួចហើយ, មានអារម្មណ៍ពេញចិត្តខ្លាំងណាស់, នៅតែគិតថាអស្ចារ្យណាស់, គិតថាគឺជាសីលគង់។ តាមពិតទៅមនុស្សដែលជាន់ថ្នាក់បញ្ញាញាណខ្ពស់អាចសង្កេតមើលបាន, នៅទិសបញ្ឆៀងខាងលើគាត់ធានាមានរាងកាយជីវិតមួយនៅទីនោះនិយាយ, ប្រើមាត់អ្នកនិយាយដើម្បីនិយាយ។

វាបង្រៀនឱ្យគាត់ភាសាចក្រវាល, ក្នុងពេលដំណាលគ្នាគង់ក៏បានបញ្ជូនឱ្យគាត់មួយផ្នែក, ប៉ុន្តែ, មនុស្សម្នាក់នេះពីពេលនេះត

ទៅនឹងត្រូវគ្រប់គ្រងនៅក្នុងដៃរបស់វា, នេះជាក់ស្តែងមិនមែនសុចរិតធម៌។ លោកអ្នកកុំឃើញថាវានៅអវកាសជាន់ខ្ពស់បន្តិច, វាមិនមែនបួសហាត់សុចរិតធម៌ទេ, ដូច្នេះវាក៏មិនដឹងធ្វើដូចម្តេចបណ្តាលឱ្យអ្នកបួសហាត់ព្យាបាលជំងឺកាយសម្បទា, ដោយហេតុនោះទើបជ្រើសប្រើប្រភេទវិធីសាស្ត្រនេះ, តាមរយៈការនិយាយដើម្បីបញ្ចេញថាមពល។ ដោយសារថាមពលនេះគឺរប៉ាត់រប៉ាយ, អំណាចតូចណាស់, វាដើរតួនាទីជាក់លាក់សម្រាប់ជំងឺតូចតាចមួយចំនួន, ធំជាងនេះនឹងមិនដំណើរការទេ។ ក្នុងពុទ្ធសាសនាសម្តែងថាមនុស្សលើឋានសួគ៌គ្មានទុក្ខដើម្បីរង, គ្មានទំនាស់, មិនអាចបួសហាត់, មិនអាចហ្វឹកហាត់, មិនអាចលើកកម្ពស់ជាន់ថ្នាក់, ដូច្នេះទើបគិតដល់វិធីសាស្ត្រជួយមនុស្សព្យាបាលជំងឺកាយសម្បទា, ដោយហេតុនេះខ្លួនឯងទទួលបានការលើកកម្ពស់បន្តិច។ នេះជាក់ស្តែងគឺជាភាសាចក្រវាល។ ភាសាចក្រវាលមិនមែនជាសីលគង់, ក៏មិនមែនជាឈីគង់។

## ៥. ព័ត៌មានរាងកាយភ្ជាប់

គ្រោះថ្នាក់យ៉ាងធំក្នុងព័ត៌មានរាងកាយភ្ជាប់គឺត្រូវរាងកាយភ្ជាប់ដោយ(រាងកាយ)វិញ្ញាណ(ជាន់)ទាប, ទាំងអស់នេះត្រូវបាននាំមកដោយសារការបួសហាត់ទុចរិតធម៌។ វាមានគ្រោះថ្នាក់ខ្លាំងណាស់សម្រាប់មនុស្ស, ផលវិបាករបស់មនុស្សដែលត្រូវរាងកាយភ្ជាប់គឺគួរឱ្យខ្លាចណាស់។ មនុស្សខ្លះហាត់គង់ហាត់មិនទាន់បានប៉ុន្មានផង, ចិត្តគឺចង់ពិនិត្យជំងឺឱ្យមនុស្ស, ចង់ក្លាយជាអ្នកមាន,

តែងតែគិតអំពីរឿងទាំងនេះ។ ដំបូងឡើយមនុស្សម្នាក់នេះល្អណាស់, ឬក៏មានគ្រូកំពុងគ្រប់គ្រងគាត់។ ប៉ុន្តែនៅពេលដែលគាត់គិតអំពីរឿងពិនិត្យជំងឺ, ក្លាយជាអ្នកមានជាក់ស្តែងខូចហើយ, គាត់ជាក់ស្តែងបាននាំមករបស់ទាំងនេះ, វាមិននៅក្នុងអវកាសសារធាតុរបស់ពួកយើងទេ, ប៉ុន្តែវាគឺស្ថិតនៅយ៉ាងពិតប្រាកដ។

មនុស្សហាត់គង់រូបនេះភ្លាមៗមានអារម្មណ៍ថាបញ្ញាញាណបានបើករួចហើយ, មានគង់រួចហើយ, តាមពិតគឺរាងកាយភ្ជាប់បានធ្វើម្ចាស់ខួរក្បាលរបស់គាត់, រូបភាពដែលវាមើលឃើញបានបញ្ជាំងចូលខួរក្បាលរបស់គាត់, មានអារម្មណ៍ថាបញ្ញាញាណខ្លួនឯងបានបើករួចហើយ, តាមពិតវាមិនត្រូវបានបើកទាល់តែសោះ។ រាងកាយភ្ជាប់ហេតុអ្វីចង់ឱ្យគង់ទៅគាត់? ហេតុអ្វីចង់ជួយគាត់? ដោយសារចក្រវាលពួកយើងនេះមិនអនុញ្ញាតឱ្យសត្វបួសសម្រេច, សត្វមិនសម្តែងចិត្តគំនិត, មិនលើកកម្ពស់ឡើងបាន, មិនអនុញ្ញាតឱ្យវាទទួលបានសុចរិតធម៌។ ដូច្នេះវាជាក់ស្តែងចង់ភ្ជាប់នៅលើរាងកាយមនុស្ស, ចង់បានខ្លឹមសារនៃរាងកាយមនុស្ស។ ចក្រវាលនៅមានគោលសីលធម៌មួយទៀត, ហៅថា ‵មិនបាត់មិនបាន′។ វាជាក់ស្តែងបំពេញនូវតម្រូវកិត្តិនាមនិងផលប្រយោជន៍របស់លោកអ្នក, ឱ្យលោកអ្នកក្លាយជាអ្នកមាន, ឱ្យលោកអ្នកល្បីល្បាញ។ ប៉ុន្តែវានឹងមិនជួយលោកអ្នកដោយទទេ, វាក៏ចង់បាន, ចង់ទទួលបានខ្លឹមសាររបស់លោកអ្នក។ នៅពេលវាចាកចេញពីលោកអ្នក, លោកអ្នកនឹងគ្មាននៅអ្វីទាំងអស់, ក្លាយជាចុះខ្សោយ

ណាស់, ឬក៏ក្លាយជាមនុស្សរុក្ខជាតិ! នេះគឺជាចិត្តគំនិតមិនសុចរិតនាំមក។ `សុចរិតមួយបង្អាប់រាប់រយទុចរិត´, ចិត្តរបស់លោកអ្នកដ៏ត្រឹមត្រូវនឹងមិននាំមកភាពអាក្រក់, នោះគឺនិយាយថា, ត្រូវធ្វើជាមនុស្សហាត់គង់ស្មោះត្រង់និងថ្លៃថ្នូរ, មិនចង់បានអ្វីរញ៉េរញ៉ៃទាំងអស់, ជាក់ស្តែងចង់បួសហាត់សុចរិតធម៌។

## ៦. គង់ហ្វាសុចរិតក៏អាចហាត់ចេញទុចរិតធម៌

មានមនុស្សមួយចំនួនទោះបីគង់ដែលគាត់ចង់រៀនគឺជាសុចរិតធម៌, ប៉ុន្តែដោយសារមិនអាចតឹងរឹងតម្រូវខ្លួនឯង, មិនសម្តែងចិត្តគំនិត, ពេលហាត់គង់គិតដល់អ្វីមិនល្អមួយចំនួន, នេះជាក់ស្តែងបានកំពុងហាត់ទុចរិតធម៌ដោយមិនដឹងខ្លួន។ ឧបមាហាត់លំហាត់ឈរគំនរក៏ដោយ, ហាត់អង្គុយសមាធិក៏ដោយ, មនុស្សនៅទីនោះហាត់គង់, តាមពិតទៅមនោគតិកំពុងគិតដល់លុយផង, គិតដល់កិត្តិនាមនិងផលប្រយោជន៍ផង, គិតដល់ `មនុស្សមិនល្អសម្រាប់ខ្ញុំបន្ទាប់ពីខ្ញុំបញ្ចេញបានសីលគង់រួចហើយកែៗគាត់´ ផង; ឬក៏គិតដល់សីលគង់នេះសីលគង់នោះផងជាដើម, នាំយកនូវអ្វីមិនល្អមួយចំនួនបន្ថែមទៅក្នុងគង់, តាមពិតទៅគឺកំពុងហាត់ទុចរិតធម៌។ រឿងនេះគឺគ្រោះថ្នាក់ណាស់, ជាក់ស្តែងអាចទាក់ទាញអ្វីដែលមិនល្អមួយចំនួន, ដូចជា(រាងកាយ)វិញ្ញាណ(ជាន់)ទាបទាំងនេះ, ប្រហែលជាគាត់បានទាក់ទាញមកហើយគាត់នៅតែមិនទាន់ដឹងផង។ ដោយសារចិត្តប្រកាន់របស់គាត់ខ្លាំងក្លាពេក, ឱបយកចិត្តចំណង់មករៀនតាវគឺមិនបានទេ, ចិត្តរបស់គាត់មិន

សុចរិត, គ្រូក៏គ្មានវិធីការពារគាត់បានដែរ។ ដូច្នេះ, មនុស្សហាត់គង់ត្រូវតែរក្សាតឹងរឹងចិត្តគំនិត, ចិត្តសុចរិតគ្មានចំណង់, បើមិនដូច្នោះទេជាក់ស្តែងអាចលេចឡើងបញ្ហា។

# ជំពូកទី២ • ហ្វាលូនគង់

ហ្វាលូនគង់មានប្រភពចេញមកពី 'មហាធម៌បួសហាត់ហ្វាលូន' នៃពុទ្ធវង្ស, គាត់គឺជាមួយប្រភេទវិធីសាស្ត្រពិសេសនៃការបួសហាត់ឈីគង់ពុទ្ធវង្ស, ប៉ុន្តែមានកន្លែងពិសេសតែមួយគត់ដែលខុសពីវិធីសាស្ត្របួសហាត់ធម្មតារបស់ពុទ្ធវង្ស។ គង់ហ្វាមួយនេះក្នុងអតីតកាលតម្រូវអ្នកបួសហាត់ត្រូវបួសហាត់ពង្រឹងពិសេសដែលជាការសិក្សារបស់មនុស្សមហានិស្ស័យមានចិត្តគំនិតយ៉ាងខ្ពស់បំផុត។ ដើម្បីធ្វើឱ្យមនុស្សហាត់គង់ច្រើនថែមទៀតទទួលបានការលើកកម្ពស់, ក្នុងពេលដំណាលគ្នាបំពេញនូវតម្រូវការភាគច្រើនអ្នកដែលមានឆន្ទៈបួសហាត់, ជាពិសេស(ខ្ញុំ)បានយកគង់ហ្វានេះរៀបចំចេញជាមួយសំណុំវិធីសាស្ត្របួសហាត់សមស្របជាសកលដើម្បីបង្រៀនចេញ, ទោះបីបែបនេះក្តី, គាត់ក៏បានលើសសែនឆ្ងាយរួចហើយពីអ្វីដែលបានរៀននិងជាន់ថ្នាក់ប្រៀបនឹងបណ្តាគង់ហ្វាទូទៅ។

## I. តួនាទីរបស់ហ្វាលូន

ហ្វាលូននៃហ្វាលូនគង់មានគ្រប់យ៉ាងដូចគ្នានឹងលក្ខណៈពិសេសរបស់ចក្រវាល។ វាគឺជារូបភាពបង្រួមតូចរបស់ចក្រវាល។ អ្នកបួស

ហាត់ហ្វាលូនគង់មិនត្រឹមតែអាចបង្កើនបានឆាប់រហ័សសីលគង់ និងអំណាចគង់ប៉ុណ្ណោះទេ, ថែមទាំងក្នុងរយៈពេលដ៏ខ្លីនឹងហាត់ចេញបានហ្វាលូនដែលមានអំណាចមិនអាចប្រៀបផ្ទឹម។ ហ្វាលូនបន្ទាប់ពីបានបង្កើត, គឺស្ថិតនៅដូចជាមួយប្រភេទរាងកាយជីវិតដែលមានភាពវៃឆ្លាត, ជាធម្មតានៅទីតាំងពោះទាបរបស់អ្នកហាត់គង់បង្វិលមិនឈប់ដោយស្វ័យប្រវត្តិ, បន្តប្រមូលវិវត្តថាមពលពីក្នុងចក្រវាល, ទីបំផុតនៅក្នុងរាងកាយអ្នកហាត់គង់ផ្លាស់ប្តូរទៅជាគង់, ដោយហេតុនេះសម្រេចបានប្រសិទ្ធភាព `ធម៌ហាត់មនុស្ស´, នោះគឺនិយាយថា, ទោះបីជាមនុស្សមិនកំពុងហាត់គង់គ្រប់ពេលក៏ដោយ, ប៉ុន្តែហ្វាលូនកំពុងហាត់មនុស្សជានិច្ច។ ហ្វាលូនប្រើខាងក្នុងប្រោសខ្លួនឯង, មានគ្រប់គ្រាន់តួនាទីធ្វើឱ្យកាយសម្បទារឹងមាំ, បើកប្រាជ្ញាបើកបញ្ញានិងការពារអ្នកហាត់គង់មិនឱ្យលេចឡើងគម្លាត, លើសពីនេះទៀតអាចការពារអ្នកបួសហាត់ជៀសវាងពីមនុស្សដែលមានចិត្តគំនិតទាបលុកលុយនិងរំខាន; ហ្វាលូនប្រើខាងក្រៅប្រោសមនុស្ស, អាចព្យាបាលជំងឺនិងបំបាត់អំពើអាក្រក់ឱ្យមនុស្ស, ផ្លាស់ប្តូរទាំងអស់ស្ថានភាពមិនសុចរិត។ ហ្វាលូននៅទីតាំងពោះទាបបង្វិលមិនឈប់, បង្វិលទៅមុខ(តាមទ្រនិចនាឡិកា) ៩ជុំ, បង្វិលបញ្ច្រាស(ទ្រនិចនាឡិកា)៩ជុំ។ នៅពេលបង្វិលទៅមុខស្រូបយកថាមពលខ្លាំងក្លាពីចក្រវាល, ថាមពលធំខ្លាំងណាស់។ ជាមួយនឹងការកើនឡើងនៃអំណាចគង់ថាមពលបង្វិលកាន់តែធំជាងមុន, ទោះបីដោយចេតនាឱបឈើស្រោចកំពូលក៏សម្រេចមិន

បានផងដែរ; នៅពេលវិលបញ្ច្រាសបញ្ចេញថាមពល, ប្រោសសត្វលោកទាំងឡាយ, កែតម្រូវស្ថានភាពមិនត្រឹមត្រូវ, មនុស្សគ្រប់គ្នាដែលនៅក្បែរអ្នកហាត់គង់នឹងទទួលបានអត្ថប្រយោជន៍។ នៅប្រទេសយើងក្នុងចំណោមឈីគង់ទាំងអស់ដែលបានបង្រៀនចេញ, ហ្វាលូនគង់គឺជាគង់ហ្វាតែមួយគត់ដែលអាចសម្រេចបាន ‵ធម៌ហាត់មនុស្ស′។

ហ្វាលូនគឺដ៏មានតម្លៃបំផុត, គឺជារបស់ដែលមាសរាប់ពាន់ប្ដូរមិនបាន។ គ្រូរបស់ខ្ញុំនៅពេលបង្រៀនហ្វាលូនឱ្យខ្ញុំបាននិយាយចំពោះខ្ញុំថា៖ ‵ហ្វាលូននេះមិនអាចបង្រៀនទៅឱ្យនរណាបានទេ, មនុស្សដែលបួសតាវរាប់ពាន់ឆ្នាំសុទ្ធតែចង់ទទួលបានគាត់ប៉ុន្តែគាត់ទទួលមិនបាន។′ ធម្មក្ខន្ធរបស់ពួកយើងឆ្លងកាត់យុគសម័យមួយពិតជាយូរអង្វែងណាស់ទើបអាចបង្រៀនទៅឱ្យមនុស្សម្នាក់, ខុសនឹង(ធម្មក្ខន្ធ)នោះដែលរាប់សិបឆ្នាំបង្រៀនទៅឱ្យមនុស្សម្នាក់, ដូច្នេះហ្វាលូនគឺដ៏មានតម្លៃខ្លាំងណាស់។ បច្ចុប្បន្ន, ទោះបីជាពួកយើងបានយកគាត់ចេញមកវិវត្តនិងគ្មានអានុភាពធំដូចដើមទៀតក៏ដោយ, ប៉ុន្តែគាត់ក៏ដ៏មានតម្លៃខ្លាំងណាស់ផងដែរ។ អ្នកបួសហាត់ទទួលបានគាត់គឺស្មើនឹងបួសសម្រេចបានពាក់កណ្ដាលរួចហើយ, អ្វីដែលនៅសល់គឺគ្រាន់តែត្រូវការលោកអ្នកលើកកម្ពស់ចិត្តគំនិត, អនាគតនឹងមានមួយជាន់ថ្នាក់យ៉ាងខ្ពស់កំពុងរង់ចាំលោកអ្នក។ ជាការពិត, មនុស្សដែលគ្មានវាសនា, អនាគតគាត់ខ្លួនឯងហាត់ៗក៏មិនបានផងដែរ, ហ្វាលូនក៏ជាក់ស្ដែងមិនស្ថិតនៅទៀត។

ហ្វាលូនគង់គឺជាគង់(ហ្វា)ពុទ្ធវង្ស, ប៉ុន្តែគាត់បានហួសផុតទាំងស្រុងពីវិសាលភាពរបស់ពុទ្ធវង្ស, ដែលបានហាត់គឺជាចក្រវាលទាំងមូល។ អតីតកាលបួសហាត់ពុទ្ធវង្សគឺសម្តែងអំពីគោលសីលធម៌នៃពុទ្ធវង្ស, បួសហាត់តាវវង្សគឺសម្តែងអំពីគោលសីលធម៌នៃតាវវង្ស, គ្មាននរណាម្នាក់ពីមូលដ្ឋាននិយាយឱ្យបានហ្មត់ចត់អំពីចក្រវាល។ ចក្រវាលដូចគ្នានឹងមនុស្ស, ក្រៅពីសមាសភាគសារធាតុ, នៅមានលក្ខណៈពិសេសរបស់វាស្ថិតនៅ, សរុបមកជាក់ស្តែងគឺជា៣អក្សរ, ហៅថា "សច្ចៈ-ករុណា-ខន្តី"។ បួសហាត់តាវវង្សជាចម្បងភ្ញាក់ដឹងនៅលើ "សច្ចៈ", និយាយពាក្យសច្ចៈ, ប្រព្រឹត្តរឿងសច្ចៈ, ត្រឡប់មកសច្ចៈ, ទីបំផុតសម្រេចបានធ្វើជាអង្គសច្ចំ។ បួសហាត់ពុទ្ធវង្សដាក់ចំណុចសំខាន់នៅលើ "ករុណា", កើតចេញចិត្តមហាមេត្តា, ប្រោសសត្វលោកទាំងឡាយ។ ធម្មក្ខន្ធរបស់ពួកយើងនេះគឺបួសដំណាលគ្នា "សច្ចៈ-ករុណា-ខន្តី", ទីបំផុតសម្រេចបានការជ្រួតជ្រាបជាមួយនឹងចក្រវាល។

ហ្វាលូនគង់គឺជាគង់ហ្វាចិត្តជីវិតបួសទាំងទ្វេ, បន្ទាប់ពីអំណាចគង់និងចិត្តគំនិតសម្រេចបានជាន់ថ្នាក់ជាក់លាក់, តម្រូវនៅលោកីយ៍ជាក់ស្តែងសម្រេចបានស្ថានភាពត្រាស់ដឹង (បើកគង់), បួសសម្រេចបាន 'រាងកាយមិនអាចបំផ្លាញ'។ ហ្វាលូនគង់ជាទូទៅចែកចេញជា 'លោកីយ៍ធម៌' និង 'ផុតពីលោកីយ៍ធម៌' ដែលនីមួយៗមានជាច្រើនជាន់ថ្នាក់, សង្ឃឹមថាអ្នកដែលមានឆន្ទៈភាគច្រើនឧស្សាហ៍ព្យាយាមបួសហាត់, បន្តលើកកម្ពស់ចិត្តគំនិត, សម្រេច

បានត្រាស់ដឹងពេញលេញ។

## II. រូបសណ្ឋានរបស់ហ្វាលូន

ហ្វាលូនរបស់ហ្វាលូនគង់គឺជារាងកាយសារធាតុថាមពលខ្ពស់បង្វិលដែលមានភាពវៃឆ្លាត។ ហ្វាលូនគឺយោងទៅតាមច្បាប់ប្រតិបត្តិការនៃរាងកាយលោកធាតុចក្រវាលទាំងមូលដើម្បីបង្វិល, និយាយនៅក្នុងន័យណាមួយ, ហ្វាលូនគឺជារូបភាពបង្រួមតូចរបស់ចក្រវាល។

ចំកណ្ដាលហ្វាលូនគឺជានិមិត្តសញ្ញាអក្សរ "卍" របស់ពុទ្ធវង្ស (អានថា "វ៉ាន", ក្នុងអក្សរសំស្ក្រឹតអានថា Srivasta, មានន័យថា "ប្រមូលសំណាងរាសី" (មើល [វចនានុក្រម] «ឆឺហាយ»)), គឺជាស្នូលរបស់ហ្វាលូន, ពណ៌របស់វាស្ទើរតែពណ៌មាសលឿង, ពណ៌ផ្ទៃខាងក្រោយគឺជាពណ៌ក្រហមភ្លឺស្រស់ខ្លាំងណាស់។ ពណ៌ផ្ទៃខាងក្រោយនៃវង់មូលខាងក្រៅគឺជាពណ៌ទឹកក្រូច។ ថៃជីបួនទិសនិងហ្វាលូនពុទ្ធវង្សបួនទិស, ពួកគាត់បានរៀបចន្លោះគ្នា, ចែកចាយជា៨ទិស។ ថៃជីបានផ្សំដោយពណ៌ក្រហមនិងខ្មៅជារបស់តាវវង្ស; ថៃជីបានផ្សំដោយពណ៌ក្រហមនិងផ្ទៃមេឃជារបស់មហាតាវដើមកំណើតដំបូង។ ហ្វាលូនតូចនៅបួនទិសក៏ជាពណ៌មាសលឿងផងដែរ, ពណ៌ផ្ទៃខាងក្រោយរបស់ហ្វាលូនអាចផ្លាស់ប្ដូរ, វដ្ដផ្លាស់ប្ដូរក្រហមទឹកក្រូចលឿងបៃតងផ្ទៃមេឃស្វាយ, ពណ៌គឺស្រស់ស្អាតខ្លាំងណាស់ (ចូលមើលរូបនៅខាងដើមសៀវភៅ)។ ពណ៌របស់និមិត្តសញ្ញាអក្សរ "卍" នៅចំកណ្ដាលនិងថៃជីមិនផ្លាស់ប្ដូរ។

ហ្វាលូនធំនិងតូចជាមួយនឹងនិមិត្តសញ្ញាអក្សរ "卍" ទាំងនេះសុទ្ធតែកំពុងបង្វិលដោយស្វ័យប្រវត្តិ។ ឫសគល់របស់ហ្វាលូនបានកើតនៅក្នុងចក្រវាល, ចក្រវាលកំពុងបង្វិល, កញ្ចុំផ្កាយទាំងអស់កំពុងបង្វិល, ដូច្នេះហ្វាលូនក៏កំពុងបង្វិលផងដែរ។ សម្រាប់មនុស្សដែលមានជាន់ថ្នាក់បញ្ញាញាណទាប, អាចមើលឃើញហ្វាលូនដូចជាកង្ហារកំពុងវិល, សម្រាប់មនុស្សដែលមានជាន់ថ្នាក់បញ្ញាញាណខ្ពស់, អាចមើលឃើញទស្សនីយភាពរបស់ហ្វាលូន, នោះគឺស្អាតខ្លាំងណាស់, ស្រស់ខ្លាំងណាស់, នឹងបណ្ដាលឱ្យការប្ដូសហាត់របស់មនុស្សហាត់គង់ខ្លាំងក្លាឧស្សាហ៍ព្យាយាមថែមទៀត។

## III. លក្ខណៈប្ដូសហាត់របស់ហ្វាលូនគង់

### ១. ធម៌ហាត់មនុស្ស

អ្នកសិក្សាហ្វាលូនគង់មិនត្រឹមតែអាចបង្កើនអំណាចគង់និងសីលគង់បានយ៉ាងឆាប់រហ័សប៉ុណ្ណោះទេ, ថែមទាំងអាចហាត់ចេញបានហ្វាលូន។ ហ្វាលូននឹងបង្កើតនៅក្នុងរយៈពេលដ៏ខ្លី, ពេលបង្កើតបានភ្លាម, អានុភាពរបស់គាត់ធំណាស់, គាត់អាចការពារអ្នកហាត់គង់មិនលេចឡើងគម្លាត, ថែមទាំងអាចការពារមនុស្សរូបនេះមិនទទួលរងនូវការជ្រៀតជ្រែករបស់មនុស្សដែលមានចិត្តគំនិតទាប។ តាមទ្រឹស្ដីក៏ខុសគ្នាទាំងស្រុងនឹងធម៌ប្ដូសនៃប្រពៃណីផងដែរ។ ដោយសារតែបន្ទាប់ពីហ្វាលូនបានបង្កើត, នឹងបង្វិលមិនឈប់ដោយស្វ័យប្រវត្តិ, គឺស្ថិតនៅដូចជាមួយប្រភេទរាងកាយជីវិតដែលមានភាពវៃឆ្លាត, ជាធម្មតានៅទីតាំងពោះទាបរបស់

មនុស្សហាត់គង់បន្តប្រមូលថាមពល។ ហ្វាលូនគឺតាមរយៈការបង្វិលដោយស្វ័យប្រវត្តិដើម្បីប្រមូលថាមពលពីក្នុងចក្រវាល។ ច្បាស់ណាស់ពីព្រោះការបង្វិលមិនឈប់ដោយស្វ័យប្រវត្តិរបស់គាត់, ដោយហេតុនោះសម្រេចបានគោលបំណង `ធម៌ហាត់មនុស្ស´, នោះគឺមនុស្សមិនបានកំពុងហាត់គង់គ្រប់ពេលទេ, ប៉ុន្តែហ្វាលូនកំពុង `ហាត់មនុស្ស´ មិនឈប់។ មនុស្សរាល់គ្នាដឹងថា, មនុស្សសាមញ្ញពេលថ្ងៃត្រូវធ្វើការ, ពេលល្ងាចត្រូវសម្រាក, ពេលវេលាហាត់គង់មានកំណត់ណាស់។ ប្រសិនបើចង់សម្រេចបានហាត់គង់មិនឈប់២៤ម៉ោង, មានតែអ្វីដែលគេហៅថាគ្រប់ពេលគិតពីរឿងហាត់គង់គឺមិនបានទេ, ឬក៏ជ្រើសយកវិធីសាស្ត្រណាមួយជាដើម, សុទ្ធតែពិបាកសម្រេចបានគោលបំណងកំពុងហាត់គង់២៤ម៉ោងពិតប្រាកដ។ ទោះយ៉ាងណាក៏ដោយហ្វាលូនបន្តបង្វិល, ពីក្នុងចក្រវាលបង្វិលស្រូបឈីចំនួនធំចូលទៅខាងក្នុង (ទម្រង់ដំបូងដែលថាមពលស្ថិតនៅ), មិនឈប់ទាំងថ្ងៃយប់, គ្រប់ពេលវេលាមិនឈប់ស្រូបឈីចូលនិងនៅគ្រប់ទិសក្នុងហ្វាលូនដើម្បីស្តុកទុកនិងបំលែង, ធ្វើអោយឈីក្លាយទៅជាសារធាតុកម្រិតខ្ពស់ជាង, ទីបំផុតនៅលើរាងកាយអ្នកបួសហាត់ផ្លាស់ប្តូរទៅជា "គង់", នេះជាក់ស្តែងគឺជាធម៌ហាត់មនុស្ស។ ការបួសហាត់របស់ហ្វាលូនគង់ខុសគ្នាទាំងស្រុងនឹងទ្រឹស្តីហាត់គង់បែបឈីគង់ `តានតាវ´ នៃបណ្តាវង្ស, បណ្តានិកាយ។

លក្ខណៈពិសេសធំបំផុតរបស់បួសហាត់ហ្វាលូនគង់គឺបួស

ហាត់ហ្វាលូន, មិនដើរ `តានតាវ´, ដែលបង្រៀនចេញមកបច្ចុប្បន្ន មិនថាគឺជាគង់ហ្វានៃវង្សណាមួយឬក៏និកាយណាមួយ, រាល់និកាយនៃពុទ្ធសាសនាឬក៏តាវសាសនា, របស់ពុទ្ធវង្សឬរបស់តាវវង្ស, របស់ប្រជាប្រិយ, ជាច្រើនធម៌បួសក្នុងទ្វារចំហៀង, សុទ្ធតែដើរតានតាវ, ហៅថាឈើគង់តានតាវ។ ការបួសហាត់របស់ព្រះសង្ឃ, សមណី, តាវវត្តីសុទ្ធតែបានដើរផ្លូវតានតាវមួយនេះ។ បន្ទាប់ពីអាយុ១០០នៅពេលដែលបានបូជា, នឹងហាត់ចេញសារីរិកធាតុ។ ឧបករណ៍វិទ្យាសាស្រ្តបច្ចុប្បន្នមិនអាចរកឃើញវាគឺបានប្រើសារធាតុអ្វីមកផ្សំ, រឹងខ្លាំងណាស់, ល្អមើល។ តាមពិតទៅវាគឺជាសារធាតុថាមពលខ្ពស់ដែលជ្រើសប្រមូលមកពីអវកាស
ផ្សេង, មិនមែនជាអ្វីនៃអវកាសនេះរបស់ពួកយើងទេ, ជាក់ស្តែងគឺជា `តាន´ នោះ។ ឈើគង់តានតាវចង់នៅក្នុងកំឡុងឆ្នាំដែលមានជីវិតសម្រេចបានស្ថានភាពត្រាស់ដឹងគឺពិបាកខ្លាំណាស់, អតីតកាលមនុស្សដែលហាត់តានតាវច្រើនណាស់បានលើកតាន, នៅពេលដល់ `វិមាននីវ៉ាន´ តានក៏លើកចេញមកមិនបាន, មនុស្សត្រូវជាប់ស្ទះហើយស្លាប់នៅទីនេះ។ មនុស្សខ្លះមានចេតនាចង់បំផ្ទុះវាចោល, ប៉ុន្តែគ្មានវិធីសាស្រ្តដើម្បីយកវាទៅបំផ្ទុះបាន។ ករណីខ្លះជាក់ស្តែងមានបែបនេះ, ជីតារបស់គាត់ហាត់មិនទាន់បានសម្រេច, បន្ទាប់ពីអាយុ១០០បានខាកចេញអោយឪពុករបស់គាត់, ឪពុកគាត់ហាត់មិនទាន់បានសម្រេច, បន្ទាប់ពីអាយុ១០០បានខាកចេញអោយគាត់។ រហូតដល់បច្ចុប្បន្នគាត់នៅតែគ្មានអ្វីសោះ,

ពិបាកណាស់! ពិតប្រាកដណាស់, មានគង់ហ្វាដ៏ច្រើនក៏ល្អណាស់ផងដែរ, ប្រសិនបើទទួលបានការបង្រៀនពិតប្រាកដរួចហើយក៏ល្អណាស់ផងដែរ, ជាក់ស្តែងខ្លាចតែគាត់មិនបង្រៀនឱ្យលោកអ្នកអ្វីនៃកម្រិតខ្ពស់ដូច្នោះ។

## ២. បួសហាត់សតិម្ចាស់

មនុស្សគ្រប់គ្នាសុទ្ធតែមានមួយសតិម្ចាស់, ជាធម្មតាធ្វើរឿងរ៉ាវ, គិតពីបញ្ហាជាក់ស្តែងគឺពឹងផ្អែកលើសតិម្ចាស់។ មនុស្សម្នាក់ក្រៅពីសតិម្ចាស់នៅមានមួយទៅច្រើនសតិរងស្ថិតនៅ, ក្នុងពេលដំណាលគ្នានៅមានព័ត៌មាននៃបុព្វបុរសក្នុងត្រកូល។ សតិរងនិងសតិម្ចាស់ហៅឈ្មោះមួយដូចគ្នា។ ជាធម្មតាសតិរងប្រៀបនឹងសតិម្ចាស់មានសមត្ថភាពខ្លាំងជាងជាន់ថ្នាក់ខ្ពស់ជាង, គាត់មិនត្រូវបានសង្គមមនុស្សសាមញ្ញពួកយើងបោកបញ្ឆោតទេ, គាត់អាចមើលឃើញអវកាសជាក់លាក់របស់គាត់។ ជាច្រើនគង់ហ្វាសុទ្ធតែដើរផ្លូវបួសហាត់សតិរង, រូបកាយសតិម្ចាស់របស់គាត់គ្រាន់តែមានមុខងារជាយានដឹកជញ្ជូនប៉ុណ្ណោះ, រឿងរ៉ាវប្រភេទនេះមនុស្សហាត់គង់ជាទូទៅនៅតែមិនបានដឹង, សូម្បីតែមានមោទនភាពខ្លាំងទៀតផង។ មនុស្សរស់នៅក្នុងសង្គម, អ្វីដែលប្រាកដនិយមធ្វើឱ្យគាត់ពិបាកបោះបង់ណាស់, ពិសេសគឺអ្វីដែលគាត់ប្រកាន់។ ហេតុនេះមានជាច្រើនធម្មក្ខន្ធសង្កត់ធ្ងន់ការឆ្លងកាត់ក្នុងសមាធិ, តាំងសមាធិដាច់ខាត, ពេលដែលវិវត្តនៅក្នុងសមាធិ, គឺសតិរងរបស់គាត់កំពុងវិវត្តនៅក្នុងសង្គមនោះ, នៅក្នុងការវិវត្តន៍សម្រេចបានការលើក

កម្ពស់។ មានថ្ងៃមួយសតិរងរបស់គាត់បួសឡើងរួចហើយ, គាត់បានយកគង់របស់លោកអ្នកចេញទៅ, សតិម្ចាស់និងរូបកាយរបស់លោកអ្នកគ្មានបានអ្វីទាំងអស់, លោកអ្នកពេញមួយជីវិតបួសហាត់ខិតខំបោះបង់ចោលដោយឥតប្រយោជន៍, នោះហើយគឺគួរឱ្យអាណិតណាស់។ មានគ្រូឈើគង់ល្បីល្បាញមួយចំនួន, បណ្តាប្រភេទសីលគង់ធំធេងណាស់, កិត្តិនាមខ្ពង់ខ្ពស់ណាស់, ប៉ុន្តែគង់របស់គាត់ជាមូលដ្ឋានមិនបានកើនឡើងលើខ្លួនគាត់ទាល់តែសោះ, គាត់នៅតែមិនដឹងផង។

ហ្វាលូនគង់ពួកយើងគឺបួសហាត់តម្រង់ផ្ទាល់សតិម្ចាស់, តម្រូវគង់ពិតជាកើនឡើងនៅលើរាងកាយលោកអ្នកដោយពិតប្រាកដ, ជាការពិតសតិរងក៏ទទួលបានមួយចំណែក, គាត់ស្ថិតនៅក្នុងទីតាំងរងលើកកម្ពស់ឡើងតាម។ គង់ហ្វាពួកយើងមួយនេះជាក់ស្តែងគឺតម្រូវចិត្តគំនិតតឹងរឹង, ទុកឱ្យលោកអ្នកនៅក្នុងសង្គមមនុស្សសាមញ្ញ, នៅក្នុងលក្ខខណ្ឌស្មុគស្មាញបំផុតហ្វឹកហាត់ចិត្តគំនិត, ពីក្នុងនោះសម្រេចបានលើកកម្ពស់, (ដូច)ផ្កាឈូកមួយទងផុសចេញពីភក់, ដូច្នេះគឺអនុញ្ញាតឱ្យលោកអ្នកបួសបានសម្រេច។ ហ្វាលូនគង់ដ៏មានតម្លៃគឺដ៏មានតម្លៃនៅទីនេះ, ដ៏មានតម្លៃគឺដ៏មានតម្លៃនៅលោកអ្នកខ្លួនឯងទទួលបានគង់ ប៉ុន្តែក៏ពិបាកខ្លាំងណាស់ផងដែរ, ពិបាកគឺពិបាកត្រង់ថាលោកអ្នកដើរលើផ្លូវមួយនៅក្នុងបរិយាកាសស្មុគស្មាញបំផុតដើម្បីហ្វឹកហាត់។

គោលបំណងហាត់គង់ជាការពិតណាស់ត្រូវបួសហាត់សតិ

ម្ចាស់, គឺត្រូវតែគ្រប់ពេលវេលាប្រើសតិម្ចាស់បញ្ជាការហាត់គង់របស់ខ្លួនឯង, សតិម្ចាស់មានតួនាទីសម្រេច, ប៉ុន្តែមិនអាចផ្តល់ឱ្យសតិរងបាន។ បើមិនដូច្នោះទេមានថ្ងៃមួយ, សតិរងបួសឡើងទៅរួចហើយ, គង់ក៏បានយកទៅជាមួយ, ប៉ុន្តែរូបកាយនេះនិងសតិម្ចាស់គឺគ្មានបានអ្វីទាំងអស់។ នៅពេលលោកអ្នកចង់បួសហាត់ឡើងជាន់ថ្នាក់ខ្ពស់, សតិម្ចាស់របស់លោកអ្នកដូចជាគេងលក់មិនដឹង, លោកអ្នកហាត់គង់អ្វីក៏មិនដឹង, បែបនេះមិនបានទេ។ លោកអ្នកពិតប្រាកដត្រូវតែច្បាស់លាស់ថាលោកអ្នកកំពុងហាត់គង់, កំពុងបួសឡើងទៅលើ, កំពុងលើកកម្ពស់ចិត្តគំនិត, នៅពេលនោះលោកអ្នកទើបមានសិទ្ធិសកម្ម, លោកអ្នកទើបអាចទទួលបានគង់។ ពេលខ្លះនៅពេលលោកអ្នកស្ថិតក្នុងស្ថានភាពវង្វេងស្មារតី, រឿងនោះបានធ្វើសម្រេចរួចហើយ, លោកអ្នកក៏មិនដឹងថាបានធ្វើសម្រេចដូចម្តេច, រឹងមាំនិងប្រាកដគឺសតិរងកំពុងផ្តើមផលប៉ះពាល់, គឺសតិរងកំពុងបញ្ជា។ ឧបមាលោកអ្នកអង្គុយសមាធិនៅទីនោះ, បើកភ្នែកមើលសំដៅចំពោះមុខ, មាន `ខ្លួនឯង´ ម្នាក់ទៀតនៅចំពោះមុខ, នោះជាក់ស្តែងគឺជាសតិរងរបស់លោកអ្នក។ ឧបមាលោកអ្នកអង្គុយសមាធិនៅទីនោះ, លោកអ្នកប្រឈមមុខនឹងទិសខាងជើង, ប៉ុន្តែភ្លាមៗលោកអ្នករកឃើញថាលោកអ្នកនៅខាងជើងពិតមែន, លោកអ្នកគិតថាតើខ្ញុំចេញមកដោយរបៀបណា, នេះគឺជាខ្លួនឯងពិតរបស់លោកអ្នកបានចេញមក, ដែលអង្គុយនោះគឺជារាងកាយនិងសតិរងរបស់លោកអ្នក។ រឿងនេះអាចសម្គាល់ចេញ

បាន។

បួសហាត់ហ្វាលូនគង់មិនអាច 'ភ្លេចខ្លួន' ទាំងស្រុង, 'ភ្លេចខ្លួន' មិនត្រូវគ្នានឹងការបួសហាត់មហាធម៌របស់ហ្វាលូនគង់, ហាត់គង់ត្រូវតែពិតប្រាកដរក្សាខួរក្បាលឱ្យប្រុងប្រយ័ត្ន។ នៅពេលហាត់គង់ សតិម្ចាស់រឹងមាំបន្តិច, នឹងមិនលេចឡើងគម្លាត, អ្វីៗធម្មតាមិនអាចជ្រៀតជ្រែកនិងធ្វើបាបលោកអ្នកបានទេ។ សតិម្ចាស់ខ្សោយពេក, មានរបស់ខ្លះនឹងឡើងមក។

## ៣. ហាត់គង់មិនសម្តែងទិសដៅ, ពេលវេលា

ជាច្រើនគង់ហ្វាសុទ្ធតែយកចិត្តទុកដាក់ថាហាត់គង់ប្រឈមនឹងទិសដៅអ្វីដែលល្អ, ម៉ោងប៉ុន្មានហាត់គង់ដែលល្អ។ នៅទីនេះ ពួកយើងមិនសម្តែងអំពីវាទាំងស្រុង។ បួសហាត់ហ្វាលូនគង់គឺយោងទៅតាមលក្ខណៈពិសេសនៃចក្រវាលដើម្បីហាត់, យោងទៅតាមគោលការណ៍របស់ចក្រវាលដើម្បីហាត់, ដូច្នេះមិនសម្តែងទិសដៅ, ពេលវេលា។ ពួកយើងហាត់គង់ស្មើនឹងអង្គុយនៅលើហ្វាលូនដើម្បីហាត់, គឺគ្រប់ទិសទាំងអស់, បង្វិលជានិច្ច, ហ្វាលូនរបស់ពួកយើងនិងចក្រវាលគឺសមកាលកម្ម។ ចក្រវាលកំពុងដំណើរការ, ប្រព័ន្ធកញ្ចុំផ្កាយកំពុងដំណើរការ, ភពផ្កាយទាំង៩កំពុងវិលជុំវិញព្រះអាទិត្យ, ផែនដីខ្លួនឯងក៏កំពុងបង្វិល, តើខាងកើតត្បូងលិចជើងនៅឯណា? ខាងកើតត្បូងលិចជើងដែលពួកយើងនិយាយគឺមនុស្សនៃផែនដីឈរនៅលើទស្សនៈនៃផែនដីបែងចែកចេញ, ដូច្នេះលោកអ្នកឈរនៅទិសដៅណាមួយដើម្បីហាត់ក៏ដូចជាកំពុង

ឈរនៅគ្រប់ទិសដៅដើម្បីហាត់។

មនុស្សខ្លះសម្តែងថាពាក់កណ្តាលយប់ហាត់គង់ដែលល្អ, ថ្ងៃត្រង់ហាត់គង់ដែលល្អ, ឬក៏ពេលវេលាណាដែលល្អ។ ពួកយើងក៏មិនសម្តែងរឿងនេះផងដែរ។ ដោយសារតែលោកអ្នកមិនហាត់គង់ហ្វាលូនកំពុងហាត់លោកអ្នក, ហ្វាលូនគ្រប់ពេលគ្រប់វេលាជំនួយលោកអ្នកហាត់គង់, `ធម៌ហាត់មនុស្ស´។ ឈីគង់តានតាវគឺមនុស្សទៅហាត់តាន, ហ្វាលូនគង់គឺធម៌ហាត់មនុស្ស។ ពេលវេលាលោកអ្នកច្រើនគឺហាត់ច្រើនបន្តិច, ពេលវេលាលោកអ្នកតិចគឺហាត់តិចបន្តិច, វាអាចបត់បែនបាន។

## IV. ចិត្តជីវិតបួសទាំងទ្វេ

បួសហាត់ហ្វាលូនគង់គឺបួសទាំង `ចិត្ត´ ទាំង `ជីវិត´, គឺតាមរយៈការហាត់គង់មុនដំបូងផ្លាស់ប្តូររាងកាយ, រាងកាយមិនបាត់បង់, សតិម្ចាស់និងរាងកាយសាច់រួបរួមជាមួយ, សម្រេចបានបួសសម្រេចជារួម។

### ១. ផ្លាស់ប្រែរាងកាយ

រាងកាយរបស់មនុស្សគឺបានផ្សំឡើងដោយសាច់, ឈាមនិងគ្រោងឆ្អឹង, មានរចនាសម្ព័ននិងសមាសភាគម៉ូលេគុលមិនដូចគ្នា។ តាមរយៈការហាត់គង់ធ្វើឱ្យសមាសភាគម៉ូលេគុលនៃរាងកាយបំលែងទៅជាសារធាតុថាមពលខ្ពស់, បែបនេះ, ការផ្សំឡើងរាងកាយមនុស្សលែងនៅជាសមាសភាគនៃសារធាតុដើមទៀតហើយ,

ប៉ុន្តែបានកើតឡើងការផ្លាស់ប្តូរជាមូលដ្ឋាន, ប៉ុន្តែ, អ្នកប្ចូសហាត់គឺប្ចូសហាត់នៅក្នុងសង្គមមនុស្សសាមញ្ញ, រស់នៅក្នុងចំណោមហ្វូងមនុស្ស, មិនអាចរំខានដល់ស្ថានភាពសង្គមមនុស្សជាតិបានទេ, ដូច្នេះការប្រួលប្រែប្រភេទនេះមិនប្រែផ្លាស់រចនាសម្ព័ន្ធម៉ូលេគុលដើមរបស់គាត់, លំដាប់លំដោយនៃម៉ូលេគុលមិនបានប្រែផ្លាស់, គ្រាន់តែប្រែផ្លាស់សមាសភាគដើមនៃម៉ូលេគុលប៉ុណ្ណោះ។ សាច់របស់រាងកាយមនុស្សនៅតែទន់, ឆ្អឹងនៅតែរឹង, ឈាមរាវនៅតែហូរ, កាត់មួយកាំបិតនឹងនៅតែហូរឈាម។ យោងតាមទ្រឹស្តី `ធាតុទាំង៥´ នៃប្រទេសចិនបុរាណ, ដោយ `លោហៈ´ `ឈើ´ `ទឹក´ `ភ្លើង´ `ដី´ បង្កើតជាអ្វីៗទាំងអស់, រាងកាយមនុស្សក៏ដូចគ្នាផងដែរ។ នៅពេលដែលមនុស្សប្ចូសហាត់កើតឡើងការផ្លាស់ប្តូរនៃរាងកាយ, ដោយសារតែយកសារធាតុថាមពលខ្ពស់ជំនួសឱ្យសមាសភាគដើមរបស់ម៉ូលេគុល, ដល់ពេលនេះរាងកាយមនុស្សលែងត្រូវបានផ្សំឡើងពីសារធាតុដើមទៀតហើយ។ ដែលគេហៅថា "មិននៅក្នុងធាតុទាំង៥", ជាក់ស្តែងគឺជាគោលសីលធម៌នេះ។

លក្ខណៈពិសេសធំបំផុតនៃគង់ហ្វាចិត្តជីវិតប្ចូសទាំងទ្វេគឺពន្យាពេលជីវិតមនុស្ស, រារាំងភាពចាស់ខ្សោយ។ ហ្វាលូនគង់របស់យើងក៏មានលក្ខណៈពិសេសគួរឱ្យកត់សម្គាល់នេះផងដែរ។ ហ្វាលូនគង់គឺដើរតាមផ្លូវបែបនេះ៖ ពីមូលដ្ឋានប្រែក្លាយសមាសភាគម៉ូលេគុលនៃរាងកាយមនុស្ស, ប្រើសារធាតុថាមពលខ្ពស់ដែលប្រមូលបានស្តុកទុកនៅក្នុងកោសិកានីមួយៗ, ទីបំផុតជំនួស

សមាសភាគម៉ូលេគុលដោយសារធាតុថាមពលខ្ពស់, នឹងមិនកើតឡើងការស្លាប់កោសិកាតាមកាលកំណត់, គាត់បានដើរចេញពី 'ធាតុទាំង៥' រួចហើយ, ក្លាយជារាងកាយដែលផ្សំឡើងដោយសារធាតុនៃអវកាសផ្សេង, មិនត្រូវបានរឹតត្បិតដោយអវកាសនិងពេលវេលារបស់ពួកយើងទៀត, មនុស្សម្នាក់នេះនឹងនៅក្មេងយូរអង្វែង។

អធិសង្ឃបុរាណអាយុកាលវែងណាស់, ឥឡូវនេះមានមនុស្សអាយុរាប់រយឆ្នាំកំពុងដើរនៅតាមផ្លូវលោកអ្នកមើលគាត់មិនចេញ, គាត់នៅក្មេងណាស់, ស្លៀកពាក់ដូចគ្នានឹងមនុស្សសាមញ្ញ, លោកអ្នកនឹងមិនដឹង។ អាយុកាលរបស់មនុស្សមិនគួរខ្លីដូចបច្ចុប្បន្ន។ សម្តែងតាមទស្សនៈនៃវិទ្យាសាស្ត្របច្ចុប្បន្ន, មនុស្សអាចរស់ដល់អាយុជាង២០០ឆ្នាំ។ នេះបើយោងតាមកំណត់ត្រា, ចក្រភពអង់គ្លេសមានមនុស្សម្នាក់ឈ្មោះ Femcath រស់បានអាយុ២០៧ឆ្នាំ។ ជប៉ុនមានមនុស្សម្នាក់ឈ្មោះ Mitsu Taira រស់បានអាយុ២៤២ឆ្នាំ។ រាជវង្សថាងប្រទេសយើងមានព្រះសង្ឃមួយអង្គហួយចាវរស់បានអាយុ២៩០ឆ្នាំ។ កត់ត្រាសៀនជីនៃស្រុកយុងថៃហ្វូជាន, ឆិនជូនកើតនៅឆ្នាំដំបូងនៃជុងហឿរជួកាលស្តេចស៊ីហ្សុងក្នុងរាជវង្សថាង(គ.ស៨៨១), បានស្លាប់នៅកំឡុងឆ្នាំថៃឌីញនៃរាជវង្សយាន គ.ស ឆ្នាំ១៣២៤, រស់បានអាយុ៤៤៣ឆ្នាំ។ ទាំងអស់នេះគឺសុទ្ធតែមានភស្តុតាងអាចពិនិត្យបាន, មិនមែនជាការស្រមើស្រមៃ។ សិក្ខាកាមហ្វាលូនគង់ពួកយើងឆ្លងកាត់ការបួសហាត់, ស្នាម

ជ្រួញនៅលើមុខត្រូវបានកាត់បន្ថយគួរឱ្យកត់សម្គាល់, មុខពេញដោយរស្មី, រាងកាយស្រោលខ្លាំងណាស់, ដើរតាមផ្លូវ, ធ្វើការងារដោយមិនមានអារម្មណ៍នឿយហត់, នេះគឺជារឿងធម្មតា។ ខ្លួនខ្ញុំបានប្ដូសហាត់រាប់សិបឆ្នាំ, មនុស្សដទៃសុទ្ធតែនិយាយថាមុខរបស់ខ្ញុំគឺដូចកាលពី២០ឆ្នាំមុនមិនមានការផ្លាស់ប្ដូរធំ, ជាក់ស្ដែងគឺជាមូលហេតុនេះ។ ហ្វាលូនគង់ពួកយើងមាននាំជាមួយរបស់ខ្លាំងក្លាសម្រាប់ប្ដូសជីវិត, អ្នកប្ដូសហាត់ហ្វាលូនគង់មើលពីលើអាយុជាមួយនឹងមនុស្សសាមញ្ញខុសគ្នាធំណាស់, មើលទៅជាមួយនឹងអាយុពិតប្រាកដមិនត្រូវគ្នា, ដូច្នេះ, លក្ខណៈពិសេសធំបំផុតនៃគង់ហ្វាចិត្តជីវិតប្ដូសទាំងទ្វេគឺអាចពន្យាពេលជីវិតមនុស្ស, រារាំងភាពចាស់ខ្សោយរបស់មនុស្ស, អូសបន្លាយអាយុកាលមនុស្ស។

## ២. វង់សកលហ្វាលូន

រាងកាយមនុស្សពួកយើងគឺជាចក្រវាលតូចមួយ, ថាមពលនៃរាងកាយមនុស្សវិលជុំវិញរាងកាយមួយជុំ, ត្រូវបានគេហៅថា ‹វដ្ដចក្រវាលតូច›, ក៏បានគេហៅថា ‹វដ្ដវង់សកល› ផងដែរ។ តភ្ជាប់២ខ្សែវណ្ណរ៉ឺន-ទូ, សម្ដែងយោងតាមជាន់ថ្នាក់, នេះនៅតែជាវង់សកលសម្បកក្រៅ, មិនអាចដើរតួនាទីប្ដូសជីវិតបាន។ វង់សកលតូចពិតប្រាកដគឺពី ‹វិមាននីវ៉ាន› ដល់ ‹តានធៀន›, រង្វិលជុំនៅខាងក្នុង។ តាមរយៈការបង្វិលជុំនៅខាងក្នុងនឹងជំរុញ(រាល់ខ្សែវណ្ណ)រាងកាយពង្រីកពីក្នុងចេញក្រៅ, ខ្សែវណ្ណទាំងអស់ត្រូវបានបើកស្រឡះ។ ហ្វាលូនគង់ពួកយើងតាំងពីដំបូងគឺតម្រូវខ្សែវណ្ណទាំងអស់

ត្រូវបានបើកស្រឡះ។

វង់សកលធំជាក់ស្ដែងគឺជាការបង្វិលនៃ៨ខ្សែវណ្ណផ្សេងគ្នា, រត់ជុំវិញរាងកាយទាំងមូលជារង្វង់មួយ។ ប្រសិនបើវង់សកលធំបានបើកស្រឡះរួចហើយ, នឹងនាំមកនូវស្ថានភាពមួយ៖ មនុស្សហាត់គង់រូបនេះអាចអណ្ដែតឡើងបាន, ក្នុង(សៀវភៅ) «គម្ពីរតាន» បានសរសេរថា "កណ្ដាលថ្ងៃចេសហោះឡើង", ជាក់ស្ដែងគឺជាអត្ថន័យមួយនេះ។ ប៉ុន្តែ, ជាធម្មតានឹងចាក់សោរផ្នែកណាមួយនៃរាងកាយរបស់លោកអ្នក, ធ្វើឱ្យលោកអ្នកអណ្ដែតហោះឡើងមិនបាន, ប៉ុន្តែវានឹងនាំមកឱ្យលោកអ្នកស្ថានភាពមួយ៖ ដើរតាមផ្លូវស្រាលហើយលឿនខ្លាំងណាស់, ឡើងភ្នំហាក់ដូចជាមានមនុស្សរុញលោកអ្នក។ បន្ទាប់ពីវង់សកលធំបានបើកស្រឡះរួចហើយនឹងនាំមកមួយប្រភេទសីលគង់៖ អាចធ្វើឱ្យឈីនៅផ្នែកផ្សេងៗរបស់សរីរាង្គខាងក្នុងនៃរាងកាយមនុស្សផ្លាស់ទីជាមួយគ្នា៖ ឈីនៅលើបេះដូងរត់ទៅលើក្រពះ, ឈីនៅលើក្រពះរត់ទៅលើពោះវៀន, ជាមួយនឹងការពង្រឹងនៃអំណាចគង់, វាយចេញមកខាងក្រៅរាងកាយជាក់ស្ដែងគឺជា(សីល)គង់ 'ផ្ទេរជញ្ជូន'។ វង់សកលប្រភេទនេះក៏បានគេហៅថាវង់សកល 'ខ្សែបណ្ដោយ' ឬក៏វង់សកល 'មេឃនិងដី'។ ការបង្វិលរបស់វានៅតែមិនអាចសម្រេចបានគោលបំណងនៃការវិវត្តន៍រាងកាយ, នៅត្រូវមានវង់សកលមួយប្រភេទទៀតដែលឆ្លុះបញ្ចាំងជាមួយវាស្ថិតនៅ, វាបានគេហៅថាវង់សកល 'ខ្សែបន្ទាត់ព្រំដែន'។ ការបង្វិលនៃវង់សកលខ្សែបន្ទាត់ព្រំដែនគឺបែបនេះ៖ ពីចំណុចចាក់

ម្ទុលវិទ្យាសាស្រ្ត "ហ្វួយយិន" ឬក៏ពីចំណុចចាក់ម្ទុលវិទ្យាសាស្រ្ត "ប៉ាយហ្វួយ" វាយចេញមក, ចាប់ផ្តើមដើរនៅចំណុចប្រសព្វនៃពីរមុខអវិជ្ជមាននិងវិជ្ជមាននៃរាងកាយ, ពោលគឺដើរនៅសងខាងនៃរាងកាយ។

ការបង្វិលវង់សកលនៃហ្វាលូនគង់ធំជាងឆ្ងាយណាស់ប្រៀបនឹងការបង្វិលរបស់៨ខ្សែវណ្ណដែលបានសម្តែងនៅក្នុងគង់ហ្វាទូទៅ, វាគឺជាបណ្តាខ្សែវណ្ណឈីបញ្ឈរនិងផ្តេកឆ្លងកាត់គ្នានៃរាងកាយទាំងមូលសុទ្ធតែកំពុងប្រតិបត្តិការ, តម្រូវជារួមភ្លាមៗបានបើកស្រឡះទាំងអស់, បង្វិលទាំងអស់។ ក្នុងហ្វាលូនគង់ពួកយើងសុទ្ធតែភ្ជាប់មកជាមួយអ្វីទាំងនេះ, មិនចាំបាច់លោកអ្នកទៅហាត់ដោយចេតនា, ក៏មិនចាំបាច់ប្រើគំនិតដើម្បីណែនាំ, ប្រសិនបើលោកអ្នកចង់ធ្វើបែបនេះលោកអ្នកនឹងដើរគម្លាត។ នៅក្នុងថ្នាក់បង្រៀនខ្ញុំបានដំឡើងឱ្យលោកអ្នកយន្តការឈីនៅខាងក្រៅរាងកាយ, វារង្វិលជុំដោយស្វ័យប្រវត្តិ។ យន្តការឈីគឺជារបស់ពិសេសមួយប្រភេទដែលមាននៅក្នុងការហាត់គង់លើជាន់ថ្នាក់ខ្ពស់, គឺជាផ្នែកមួយនៃការហាត់គង់ដោយស្វ័យប្រវត្តិរបស់ពួកយើង, វាក៏បង្វិលជាប្រចាំមិនឈប់ដូចគ្នានឹងហ្វាលូន, ដឹកនាំខ្សែវណ្ណឈីខាងក្នុងរាងកាយបង្វិល។ លោកអ្នកមិនធ្លាប់បានហាត់វង់សកល, តាមពិតទៅខ្សែវណ្ណឈីនោះត្រូវបាននាំយកមកបង្វិលជាមួយគ្នារួចហើយ, ពីជ្រៅខាងក្នុងក៏ដូចជាខាងក្រៅបង្វិលជាមួយគ្នា, ពួកយើងតាមរយៈលំហាត់គឺដើម្បីពង្រឹងយន្តការឈីនៅខាងក្រៅរាង

កាយ។

## ៣. បើកស្រឡះខ្សែវណ្ណ

គោលបំណងនៃការបើកស្រឡះខ្សែវណ្ណគឺដើម្បីធ្វើឱ្យថាមពលដំណើរការ, ផ្លាស់ប្តូរសមាសភាគម៉ូលេគុលរបស់កោសិកា, បំលែងឆ្តោះទៅជាសារធាតុថាមពលខ្ពស់។ មនុស្សដែលមិនហាត់គង់ខ្សែវណ្ណគឺត្រូវរាំងស្ទះឬក៏សូម្បីតែតូចណាស់ផង, ខ្សែវណ្ណរបស់មនុស្សហាត់គង់នឹងភ្លឺឡើងបន្តិចម្តងៗ, កន្លែងដែលមិនបើកស្រឡះនឹងត្រូវបានបើកស្រឡះ។ ខ្សែវណ្ណរបស់មនុស្សដែលហាត់គង់បានល្អនឹងពង្រីក, បួសហាត់ដល់ជាន់ថ្នាក់ខ្ពស់ខ្សែវណ្ណនឹងកាន់តែទូលាយ, មនុស្សខ្លះខ្សែវណ្ណធំទូលាយដូចចុងម្រាមដៃ។ ប៉ុន្តែបើកស្រឡះខ្សែវណ្ណខ្លួនវាមិនតំណាងឱ្យការបួសដល់កម្រិតណា, មានគង់ខ្ពស់ប៉ុណ្ណា។ តាមរយៈការហាត់គង់ធ្វើឱ្យខ្សែវណ្ណកាន់តែភ្លឺនិងពង្រីក, ទីបំផុតរាប់រយខ្សែវណ្ណភ្ជាប់ទៅជាបំណែកមួយ, នៅពេលនោះមនុស្សម្នាក់នេះមិនមានខ្សែវណ្ណក៏មិនមានចំណុចចាក់ម្ជុលវិទ្យាសាស្ត្រ, ផ្ទុយមកវិញសម្តែង, រាងកាយទាំងមូលសុទ្ធតែជាខ្សែវណ្ណក៏សុទ្ធតែជាចំណុចចាក់ម្ជុលវិទ្យាសាស្ត្រ។ នៅពេលនេះវានៅតែមិនអាចពន្យល់ថាមនុស្សម្នាក់នេះបានសម្រេចធម៌រួចហើយនោះទេ, វាគ្រាន់តែជាមួយប្រភេទនៃការបង្ហាញក្នុងដំណើរការបួសហាត់ហ្វាលូនគង់, ដែលជាការបង្ហាញនៃមួយជាន់ថ្នាក់។ នៅពេលមកដល់ជំហានមួយនេះរួចហើយ, បួសហាត់នៅក្នុងលោកីយ៍ធម៌បានដើរដល់ចុងបញ្ចប់ហើយ, នៅ

ពេលដំណាលគ្នាពីខាងក្រៅសង្កេតមើលនាំមកនូវស្ថានភាពយ៉ាងជាក់ស្តែងមួយ៖ ‵ផ្កា៣ប្រមូលផ្តុំនៅកំពូល′។ គង់នោះបានបញ្ចេញដ៏អស្ចារ្យរួចហើយ, សុទ្ធតែមានរូបរាង, សសរគង់ក៏ខ្ពស់ណាស់ផងដែរ, លើសពីនេះទៀតនៅលើក្បាលលេចឡើងផ្កា៣ទង, ១ទងដូចជាផ្កាឈូក, ១ទងដូចជាផ្កាបញ្ចុះមាស។ ផ្កា៣ទងនឹងបង្វិលដោយខ្លួនឯង, បង្វិលដោយខ្លួនឯងក្នុងពេលដំណាលគ្នាក៏បង្វិលឆ្លាស់គ្នាផងដែរ។ នៅលើផ្កានីមួយៗមានសសរមួយ, សសរឈានដល់មេឃ, ខ្ពស់ខ្លាំងណាស់។ សសរទាំង៣នេះក៏ជាមួយនឹងផ្កានោះឆ្លាស់គ្នាបង្វិល, ក៏បង្វិលដោយខ្លួនឯងផងដែរ, ខ្លួនគាត់ផ្ទាល់មានអារម្មណ៍ថាក្បាលធ្ងន់ណាស់។ នៅពេលនេះ, គាត់គ្រាន់តែបានដើរបញ្ចប់ជំហានចុងក្រោយនៅក្នុងការបួសហាត់លោកីយ៍ធម៌ប៉ុណ្ណោះ។

## V. គំនិត

បួសហាត់ហ្វាលូនគង់មិននាំយកគំនិតជាមួយ។ គំនិតខ្លួនវាមិនអាចធ្វើបានអ្វីទាំងអស់, ប៉ុន្តែគាត់អាចធ្វើពាក្យបញ្ជាចេញ។ ដែលពិតជាដំណើរការគឺជាសីលគង់, វាមានសមត្ថភាពផ្ទត់គំនិតរបស់រាងកាយវិញ្ញាណ, ទទួលយកពាក្យបញ្ជាពីព័ត៌មាននៃខួរក្បាល។ ប៉ុន្តែមនុស្សជាច្រើនពិសេសគឺនៅក្នុងពិភពឈីគង់មានទស្សនៈច្រើនណាស់, សន្មតថាគំនិតអាចធ្វើបានរឿងរ៉ាវដ៏ច្រើន។ មនុស្សខ្លះសម្តែងថាគំនិតបើកសីលគង់, គំនិតបើកបញ្ញាញាណ, គំនិតព្យាបាលជំងឺ, គំនិតផ្ទេរជញ្ជូនជាដើម, នេះគឺជាមួយប្រភេទយល់

ដឹងខុស។ នៅជាន់ថ្នាក់ទាប, នៅក្នុងមនុស្សសាមញ្ញគំនិតបញ្ជា អង្គញាណនិងអវៈយវៈ។ នៅជាន់ថ្នាក់ខ្ពស់, នៅក្នុងមនុស្សហាត់គង់គំនិតអាចធ្វើឱ្យថ្កើងឡើង, បញ្ជាសីលគង់ធ្វើរឿងរ៉ាវ, នោះគឺសីលគង់ត្រូវបានគំនិតឃុំគ្រង។ នេះគឺជាទស្សនៈរបស់ពួកយើងចំពោះគំនិត។ ពេលខ្លះឃើញគ្រូឈីគង់ព្យាបាលជំងឺឱ្យមនុស្ស, មិនទាន់កម្រើកដៃផងអ្នកជំងឺនិយាយថាជាសះស្បើយរួចហើយ, គិតថាគឺជាគំនិតព្យាបាលជាសះស្បើយ, តាមពិតទៅគឺគាត់វាយចេញមួយប្រភេទសីលគង់, បញ្ជាសីលគង់ដើម្បីព្យាបាលជំងឺឬក៏ធ្វើរឿងរ៉ាវអ្វីមួយ, ដោយសារតែសីលគង់ដើរនៅក្នុងអវកាសផ្សេង, ភ្នែករបស់មនុស្សសាមញ្ញមើលមិនឃើញ, មិនដឹងគិតថាគឺជាគំនិតបានធ្វើរួចហើយ។ មនុស្សមួយចំនួនគិតថាអាចប្រើគំនិតព្យាបាលជំងឺ, សុទ្ធតែនាំមនុស្សគម្លាតរួចហើយ, ទស្សនៈនេះត្រូវតែបញ្ជាក់ច្បាស់។

ផ្ចិតគំនិតរបស់មនុស្សគឺជាមួយប្រភេទព័ត៌មាន, គឺជាមួយប្រភេទថាមពល, គឺជាមួយប្រភេទទម្រង់អត្ថិភាពរបស់សារធាតុ។ នៅពេលផ្ចិតគំនិតមនុស្សកំពុងគិតពីបញ្ហា, ក្នុងខួរក្បាលបង្កើតចេញមួយប្រភេទប្រេកង់ស៍, ពេលខ្លះសូត្រមន្តគាថាដ៏មានប្រសិទ្ធភាព, ហេតុអ្វីទៅ? ដោយសារតែចក្រវាលក៏មានប្រេកង់ស៍ញ័ររបស់វា, ពេលដែលមន្តគាថាដែលលោកអ្នកសូត្រកើតឡើងអនុវរភាពជាមួយនឹងប្រេកង់ស៍របស់ចក្រវាលជាក់ស្តែងអាចបង្កើតផលប៉ះពាល់។ ជាការពិតណាស់ត្រូវតែជាព័ត៌មានដែលស្លូតទើបអាច

ដំណើរការ, ដោយសារតែអ្វីដែលអាក្រក់គឺមិនត្រូវបានអនុញ្ញាតស្ថិតនៅក្នុងចក្រវាល។ គំនិតក៏ជាមួយប្រភេទវិធីផ្ទត់គំនិតដែលពិសេសផងដែរ, បរមីរបស់គ្រូធំឈើគង់ជាន់ថ្នាក់ខ្ពស់ជាក់ស្ដែងបានឃុំគ្រងនិងបញ្ជាដោយផ្ទត់គំនិតរបស់ម្ចាស់កាយ។ បរមីក៏មានផ្ទត់គំនិតផ្ទាល់ខ្លួនរបស់គាត់, មានសមត្ថភាពដោះស្រាយបញ្ហានិងធ្វើរឿងដោយឯករាជ្យរបស់ខ្លួន, គាត់គឺជាខ្លួនឯងមួយដែលឯករាជ្យទាំងស្រុង។ ក្នុងពេលដំណាលគ្នា, បរមីអាចដឹងពីផ្ទត់គំនិតម្ចាស់កាយរបស់គ្រូឈើគង់, យោងតាមផ្ទត់គំនិតម្ចាស់កាយដើម្បីធ្វើរឿងរ៉ាវ។ ឧបមាគ្រូឈើគង់ចង់ព្យាបាលជំងឺឱ្យមនុស្សម្នាក់, គាត់នឹងទៅ(ធ្វើ); នៅពេលគ្មានគំនិតមួយនេះផ្ញើចេញ, គាត់គឺមិនទៅ(ធ្វើ)។ ពេលដែលគាត់បានមើលឃើញរឿងរ៉ាវដ៏ល្អៗគាត់នឹងសកម្មទៅធ្វើ។ គ្រូធំខ្លះនៅមិនទាន់សម្រេចបានកម្រិតត្រាស់ដឹង, មានរឿងរ៉ាវមួយចំនួនគាត់នៅមិនទាន់ដឹង, ប៉ុន្តែបរមីរបស់គាត់បានដឹងរួចហើយ។

គំនិតនៅមានអត្ថន័យមួយទៀតហៅថាការបំផុសគំនិត។ ការបំផុសគំនិតមិនមែនផ្ញើចេញមកពីសតិម្ចាស់របស់មនុស្សទេ។ ផ្នែកចំណេះដឹងរបស់សតិម្ចាស់គឺមានកម្រិតណាស់, ប្រសិនបើចង់បង្កើតអ្វីដែលមិនមានក្នុងសង្គម, គ្រាន់តែពឹងផ្អែកសតិម្ចាស់មិនបានទេ។ ការបំផុសគំនិតមកពីសតិរង។ មនុស្សមួយចំនួនធ្វើនិពន្ធ, ធ្វើស្រាវជ្រាវវិទ្យាសាស្ត្រ, នៅពេលច្របាច់ខួរក្បាលក៏ធ្វើមិនចេញ, បន្ធូរសម្រាកសិន, ចេញខាងក្រៅកំសាន្តមួយជុំ។ ភ្លាមៗនោះ,

ការបំផុសគំនិតបានមកដោយអចេតនា, ជាបន្ទាន់កាន់បិចសរសេរ ជាសៀវភៅ, បង្កើតចេញអ្វីមួយ។ នេះគឺដោយសារតែនៅពេល សតិម្ចាស់ដ៏រឹងមាំ, ឃុំគ្រងខួរក្បាល, ទប់មិនឱ្យចេញបាន។ នៅ ពេលសតិម្ចាស់បន្ធូរអារម្មណ៍ភ្លាម, សតិរងចាប់ផ្តើមដំណើរការ, វា ធ្វើម្ចាស់ការខួរក្បាល។ សតិរងគឺស្ថិតនៅក្នុងអវកាសមួយផ្សេង, មិនត្រូវបានចងភ្ជាប់ដោយអវកាសមួយនេះ, អាចបង្កើតចេញអ្វី ដែលថ្មី។ ប៉ុន្តែសតិរងក៏មិនអាចលើសលប់, ជ្រៀតជ្រែកដល់ស្ថាន ភាពនៃសង្គមមនុស្សសាមញ្ញ, ប៉ះពាល់ដល់ដំណើរការនៃការ អភិវឌ្ឍន៍សង្គម។

ការបំផុសគំនិតមកពីទិដ្ឋភាពពីរ, មួយគឺបានផ្តល់ដោយសតិរង , សតិរងមិនត្រូវបានបោកបញ្ឆោតដោយលោកីយ៍, គាត់អាចបង្កើត ការបំផុសគំនិត។ មួយទៀតគឺមកពីពាក្យបញ្ជា, ការណែនាំរបស់ រាងកាយវិញ្ញាណខ្ពស់នៅជាន់ថ្នាក់ខ្ពស់។ នៅពេលមានរាងកាយវិ ញ្ញាណខ្ពស់ណែនាំ, ផ្នត់គំនិតបានបើកចំហ, អាចធ្វើចេញរឿងរ៉ាវ ដែលមិនទាន់បានបង្កើត។ ការអភិវឌ្ឍន៍ទាំងមូលនៃសង្គមនិង ចក្រវាលសុទ្ធតែមានច្បាប់ជាក់លាក់របស់វា, អ្វីៗគ្រប់យ៉ាងសុទ្ធតែ មិនមែនចៃដន្យ។

## VI. ជាន់ថ្នាក់បួសហាត់របស់ហ្វាលូនគង់

### ១. បួសហាត់ជាន់ថ្នាក់ខ្ពស់

ហ្វាលូនគង់គឺឈរនៅលើជាន់ថ្នាក់ដ៏ខ្ពស់ដើម្បីបួសហាត់,

ដូច្នេះបញ្ចេញគង់ពិសេសឆាប់រហ័ស។ មហាតាវគឺសាមញ្ញនិងងាយស្រួលបំផុត។ ពីទស្សនៈម៉ាក្រូឃើញថាចលនារបស់ហ្វាលូនគង់មានតិចតួចណាស់, ប៉ុន្តែវាឃ្លុំគ្រងគ្រប់ផ្នែកទាំងអស់នៃរាងកាយ, ឃ្លុំគ្រងរបស់ជាច្រើនដែលត្រូវបានបង្កើត។ ដរាបណាចិត្តគំនិតឡើងតាមទាន់, គង់នឹងកើនឡើងយ៉ាងឆាប់រហ័ស, មិនចាំបាច់ខំប្រឹងដោយចេតនា, ជ្រើសប្រើវិធីសាស្ត្រណាមួយ, ឬក៏ 'រៀបស្លកបង្កើតឡ, រើសឱសថស្លតាន, កែសំរួលភ្លើងប៉ុន្មាន, កែសំរួលឱសថប៉ុន្មាន'។ ពឹងផ្អែកលើការណែនាំដោយគំនិតគឺស្មុគស្មាញណាស់, ងាយស្រួលលេចឡើងគម្លាតណាស់។ ពួកយើងនៅទីនេះផ្តល់ជូនអ្នករាល់គ្នានូវធម្មក្ខន្ធងាយស្រួលបំផុត, ធម្មក្ខន្ធមួយល្អបំផុត, ក៏ជាធម្មក្ខន្ធមួយពិបាកបំផុតផងដែរ។ រាងកាយមនុស្សហាត់គង់ឈានដល់ស្ថានភាព 'សដូចទឹកដោះ', ដែលនៅក្នុងគង់ហ្វាដទៃទៀតត្រូវហាត់ក្នុងពេលវេលាជាងដប់ឆ្នាំ, ច្រើនទសវត្សរ៍ឬក៏យូរជាងនេះ, ប៉ុន្តែពួកយើងភ្លាមៗនឹងនាំលោកអ្នកដល់ជំហានមួយនេះ។ ពេលដែលលោកអ្នកមិនទាន់យល់ដឹងបានផង, ជាន់ថ្នាក់មួយនេះបានកន្លងផុតទៅរួចហើយ, ប្រហែលជាមានតែពីរឬបីម៉ោងប៉ុណ្ណោះ។ មានថ្ងៃមួយ, លោកអ្នកមានអារម្មណ៍ថាយ៉ាងរសើប, បន្ទាប់ពីមួយរយៈក៏មិនរសើបទៀត, តាមពិតទៅជាក់ស្តែងគឺមួយជាន់ថ្នាក់ធំបានកន្លងផុតទៅរួចហើយ។

## ២. ទម្រង់បង្ហាញរបស់គង់

រាងកាយរបស់សិក្ខាកាមហ្វាលូនគង់បានឆ្លងកាត់ការកែសំរួល

ជាក់ស្ដែងបានឈានដល់មួយប្រភេទស្ថានភាពសមស្របសម្រាប់បួសហាត់មហាធម៌, នេះជាក់ស្ដែងគឺជាស្ថានភាព "រាងកាយសដូចទឹកដោះ"។ មានតែកែសំរួលដល់ស្ថានភាពនេះទើបអាចបញ្ចេញគង់បាន។ មនុស្សដែលមានជាន់ថ្នាក់បញ្ញាញាណខ្ពស់នឹងមើលឃើញបាន, គង់ជាក់ស្ដែងបញ្ចេញនៅខាងលើស្បែករបស់មនុស្សហាត់គង់, បន្ទាប់មកបញ្ចូលទៅខាងក្នុងរាងកាយរបស់មនុស្សហាត់គង់; បន្ទាប់មកចេញម្ដងទៀត, ចូលម្ដងទៀត, ធ្វើបែបនេះម្ដងហើយម្ដងទៀត, ដើរមួយជាន់ថ្នាក់ៗ, ពេលខ្លះដើរយ៉ាងលឿន។ នេះគឺជាគង់លើកទីមួយ។ បន្ទាប់ពីគង់លើកទីមួយបញ្ចេញរួចហើយ, រាងកាយរបស់មនុស្សហាត់គង់លែងនៅជារាងកាយធម្មតាទៀតហើយ, បន្ទាប់ពីឈានដល់រាងកាយសដូចទឹកដោះ, ចាប់តាំងពីពេលនេះនឹងមិនកើតជំងឺទៀត។ នៅពេលក្រោយលេចឡើងឈឺកន្លែងនេះ, ឈឺកន្លែងនោះ, ឬក៏ពិបាកទ្រាំទីតាំងណាមួយ, បែបដូចជាមានជំងឺ, ប៉ុន្តែនេះមិនមែនជំងឺទេ, គឺអំណាចកម្មកំពុងផ្ដើមផលប៉ះពាល់។ ចាំពេលបញ្ចេញគង់លើកទីពីរ, រាងកាយវិញ្ញាណនោះជាក់ស្ដែងធំណាស់ហើយ, គាត់នឹងផ្លាស់ទី, នឹងនិយាយគ្នា។ ពេលខ្លះចេញមករ៉ុយៗ, ពេលខ្លះចេញមកដង់ស៊ីតេក្រាស់ណាស់, រវាងពួកគាត់នឹងនិយាយជាមួយគ្នាទៀត។ ខាងក្នុងរាងកាយវិញ្ញាណនេះជាក់ស្ដែងស្តុកទុកថាមពលចំនួនធំ, វាគឺប្រើដើម្បីផ្លាស់ប្ដូររាងកាយ។

បួសហាត់ហ្វាលូនគង់ដល់កម្រិតដ៏ខ្ពស់, ពេលខ្លះលេចឡើង

`ទារក´, ពាសពេញតួខ្លួន, ពួកគាត់រពិសណាស់, ល្មោភលេង, ចិត្តល្អណាស់។ អាចហាត់ចេញមួយប្រភេទរាងកាយផ្សេងទៀត, នោះជាក់ស្ដែងគឺជា `ទារកអមតៈ´។ គាត់អង្គុយនៅលើបល្ល័ងផ្កាឈូក, ស្រស់ស្អាតខ្លាំងណាស់។ ទារកអមតៈដែលបញ្ចេញពីការហាត់គង់ជាក់ស្ដែងគឺដោយអវិជ្ជមាននិងវិជ្ជមាននៃរាងកាយមនុស្សសុខដុមជាមួយគ្នាហើយបង្កើត, អ្នកបួសហាត់ប្រុសឬស្រីសុទ្ធតែអាចហាត់ចេញទារកអមតៈ។ ទារកអមតៈនៅពេលដំបូងតូចណាស់, ធំឡើងបន្តិចម្ដងៗ, ទីបំផុតធំស្មើនឹងរាងកាយមនុស្សហាត់គង់, មើលទៅដូចគ្នា, គឺនៅក្នុងរាងកាយរបស់គាត់។ មនុស្សមានសីលគង់ពិសេសមើលមកគាត់, និយាយថាគាត់មានពីររាងកាយ, តាមពិតទៅជាក់ស្ដែងគឺរាងកាយពិតប្រាកដរបស់គាត់បួសសម្រេចរួចហើយ។ លើសពីនេះទៀត, បរមីជាច្រើននឹងត្រូវបានបួសចេញផងដែរ។ និយាយរួម, សីលគង់ដែលអាចបញ្ចេញក្នុងចក្រវាលសុទ្ធតែមាននៅក្នុងហ្វាលូនគង់; សីលគង់ដែលអាចបញ្ចេញនៅក្នុងគង់ហ្វាដទៃក៏សុទ្ធតែមាននៅក្នុងហ្វាលូនគង់ផងដែរ។

## ៣. បួសហាត់ផុតពីលោកីយ៍ធម៌

មនុស្សហាត់គង់តាមរយៈការហាត់គង់ធ្វើឱ្យខ្សែវណ្ណពង្រីក, បន្តពង្រីក, ធ្វើឱ្យខ្សែវណ្ណភ្ជាប់ជាបំណែកមួយ, នោះគឺហាត់រហូតដល់គ្មានខ្សែវណ្ណ, គ្មានចំណុចចាក់ម្ជុលវិទ្យាសាស្ត្រ; ផ្ទុយមកវិញសម្ដែង, រាងកាយទាំងមូលសុទ្ធតែជាខ្សែវណ្ណ, សុទ្ធតែជាចំណុច

ចាក់ម្ទុលវិទ្យាសាស្ត្រ។ នេះនៅមិនអាចពន្យល់ថាលោកអ្នកបានត្រាស់ដឹងរួចហើយនោះទេ, វាគ្រាន់តែជាមួយប្រភេទនៃការបង្ហាញក្នុងដំណើរការបួសហាត់ហ្វាលូនគង់, ការបង្ហាញនៃមួយជាន់ថ្នាក់។ នៅពេលមកដល់ជំហានមួយនេះរួចហើយ, បួសហាត់នៅក្នុងលោកីយ៍ធម៌បានដើរដល់ទីបញ្ចប់រួចហើយ, គង់មួយនោះបានបញ្ចេញដ៏អស្ចារ្យរួចហើយ, សុទ្ធតែមានរូបរាង, សសរគង់ក៏ខ្ពស់ណាស់ផងដែរ, លើសពីនេះទៀតខាងលើក្បាលលេចឡើងផ្កាពទង។ នៅពេលនេះ, គាត់គ្រាន់តែដើរបញ្ចប់រួចហើយជំហានចុងក្រោយនៅក្នុងលោកីយ៍ធម៌។

នៅពេលបោះមួយជំហានទៀតទៅមុខ, ជាក់ស្តែងគ្មានអ្វីនៅសល់, ដាក់គង់ទាំងអស់ផ្ទុកចូលក្នុងអវកាសជ្រៅបំផុតក្នុងរាងកាយ, គាត់ជាក់ស្តែងក្លាយជាស្ថានភាព ‵រាងកាយសសុទ្ធ′, រាងកាយរបស់មនុស្សម្នាក់នេះគឺថ្លាយង់។ បោះមួយជំហានទៀត, ចូលទៅក្នុងបួសហាត់ផុតពីលោកីយ៍ធម៌, ត្រូវបានគេស្គាល់ផងដែរថាជាបួសហាត់ ‵ពុទ្ធកាយ′។ គង់ដែលបញ្ចេញម្តងទៀតស្ថិតក្នុងប្រភេទនៃទេពអំណាច។ នៅពេលនោះ, អានុភាពរបស់គាត់គ្មានដែនកំណត់, ធំខ្លាំងណាស់, នៅពេលឈានដល់កម្រិតខ្ពស់ជាងនឹងបួសទៅជាអង្គមហាត្រាស់ដឹង។ នេះជាក់ស្តែងសង្កេតមើលលោកអ្នកបួសហាត់ចិត្តគំនិតដូចម្តេច, បួសហាត់ដល់ជាន់មួយណា, ផលញាណជាក់ស្តែងដល់ជាន់មួយនោះ។ អ្នកមានឆន្ទៈធំទទួលបានសុចរិតធម៌, សម្រេចមគ្គផលខ្ពស់បំផុត, នោះគឺបួស

សម្រេចធម៌ពេញលេញ។

## ជំពូកទី៣ • បួសហាត់ចិត្តគំនិត

អ្នកបួសហាត់ហ្វាលូនគង់ទាំងអស់ត្រូវដាក់ការបួសហាត់ចិត្តគំនិតជាមុន, ទទួលស្គាល់ចិត្តគំនិតគឺជាកូនសោរនៃការបង្កើនគង់, នេះគឺជាគោលសីលធម៌នៃការហាត់គង់ដល់ជាន់ថ្នាក់ខ្ពស់។ និយាយយ៉ាងហ្មត់ចត់, អំណាចគង់ដែលកំណត់ជាន់ថ្នាក់មិនមែនហាត់បានមកទេ, ប៉ុន្តែគឺពឹងផ្អែកលើចិត្តគំនិតបួសចេញមក។ លើកកម្ពស់ចិត្តគំនិតនិយាយគឺងាយស្រួល, ប៉ុន្តែធ្វើគឺពិបាកណាស់ៗ។ អ្នកបួសហាត់ត្រូវមានការចំណាយអតិបរមា, ត្រូវលើកកម្ពស់ការភ្ញាក់ដឹង, ត្រូវអាចរងទុក្ខក្នុងទុក្ខ, ត្រូវអាចខន្តីរឿងដែលពិបាកខន្តី។ល។ ហេតុអ្វីមានមនុស្សមួយចំនួនហាត់គង់ច្រើនឆ្នាំប៉ុន្តែមិនបង្កើនគង់? មូលហេតុចម្បង៖១គឺមិនសម្តែងអំពីចិត្តគំនិត; ២គឺមិនទទួលបានសុចរិតធម៌ជាន់ថ្នាក់ខ្ពស់។ បញ្ហានេះត្រូវតែដោះស្រាយ។ ច្រើនណាស់គ្រូបង្រៀនគង់សុទ្ធតែសម្តែងអំពីចិត្តគំនិត, នេះគឺពិតជាបង្រៀនគង់; មួយចំនួននោះគ្រាន់តែបង្រៀនចលនា, បច្ចេកទេសប៉ុន្តែមិនសម្តែងអំពីចិត្តគំនិត, តាមពិតទៅស្មើនឹងបង្រៀនទុចរិតធម៌។ ដូច្នេះ, មនុស្សហាត់គង់ត្រូវតែខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការលើកកម្ពស់ចិត្តគំនិត, ទើបអាចបួសហាត់ឈានចូលជាន់ថ្នាក់ខ្ពស់ជាង។

## I. អត្ថន័យរបស់ចិត្តគំនិត

ចិត្តគំនិតដែលហ្វាលូនគង់សម្ដែង, មិនមែនគ្រាន់តែ "គុណធម៌" ដែលអាចហ៊ុំព័ទ្ធបានទេ, វិសាលភាពគ្របដណ្ដប់របស់វាធំទូលាយជាង "គុណធម៌" ច្រើនណាស់, វារួមបញ្ចូលខ្លឹមសារគ្រប់ទិដ្ឋភាពទាំងអស់របស់ "គុណធម៌" នៅខាងក្នុង។ "គុណធម៌" គ្រាន់តែជាមួយប្រភេទបង្ហាញនៃចិត្តគំនិតរបស់មនុស្សម្នាក់, ការប្រើ "គុណធម៌" សុទ្ធសាធដើម្បីអត្ថាធិប្បាយអត្ថន័យរបស់ចិត្តគំនិតគឺមិនគ្រប់គ្រាន់ទេ។ ចិត្តគំនិតរួមបញ្ចូលទាំងបញ្ហាដោះស្រាយដូចម្ដេចជាមួយនឹងទិដ្ឋភាពពីរនៃការ "បាន" និង "លះបង់"។ "បាន" ជាក់ស្ដែងគឺទទួលបាននូវភាពសមកាលកម្មជាមួយនឹងលក្ខណៈពិសេសនៃចក្រវាល។ លក្ខណៈសម្បត្តិពិសេសដែលបង្កើតចក្រវាលគឺ "សច្ចៈ-ករុណា-ខន្តី", ភាពសមកាលកម្មរបស់មនុស្សហាត់គង់ម្នាក់ជាមួយនឹងលក្ខណៈពិសេសនៃចក្រវាលត្រូវបានបង្ហាញនៅលើ "គុណធម៌" ផ្ទាល់ខ្លួនរបស់គាត់។ "លះបង់" ជាក់ស្ដែងគឺត្រូវលះបង់ចោលនូវបណ្ដាមនោគតិនិងចរិយាមិនល្អដូចជាលោភលន់, ផលប្រយោជន៍, សម្រស់, តណ្ហា, សម្លាប់, វាយតប់, លួច, ភ្លន់, បោកប្រាស់, ច្រណែន។ល។ ប្រសិនបើប្ដូសហាត់ឡើងជាន់ថ្នាក់ខ្ពស់, គឺត្រូវលះបង់ចោលរាល់ការស្វែងរកដែលមានស្រាប់របស់មនុស្សចំពោះតណ្ហា, នោះគឺត្រូវលះបង់ចោលរាល់ចិត្តប្រកាន់, ជាក់ស្ដែងគឺត្រូវមើលយ៉ាងស្រាលរាល់កិត្តិនាម, ផលប្រយោជន៍របស់មនុស្ស។

មនុស្សគឺដោយសាររាងកាយសាច់និងចរិតផ្សំឡើងជាមនុស្សម្នាក់ពេញលេញ។ ចក្រវាលក៏ដូចគ្នាផងដែរ, ក្រៅពីលក្ខណៈសារធាតុ, ក្នុងពេលដំណាលគ្នាក៏ស្ថិតនៅលក្ខណៈពិសេស "សច្ចៈ-ករុណា-ខន្តី"។ នៅគ្រប់ភាគល្អិតនៃខ្យល់អាកាសសុទ្ធតែមានស្ថិតនៅលក្ខណៈពិសេសប្រភេទនេះ។ បង្ហាញនៅក្នុងសង្គមមនុស្សសាមញ្ញ, ធ្វើអំពើល្អទទួលបានប្រជាប្រិយភាព, ធ្វើអំពើអាក្រក់ត្រូវទទួលទណ្ឌកម្ម។ នៅជាន់ថ្នាក់ខ្ពស់គឺបង្ហាញពីស្ថានភាពសីលគង់។ សម្របខ្លួននឹងលក្ខណៈពិសេសនេះជាក់ស្ដែងគឺជាមនុស្សល្អ, ងាកចេញពីគាត់ជាក់ស្ដែងគឺជាមនុស្សអាក្រក់, អនុលោមជាមួយនឹងគាត់, សមកាលកម្មជាមួយនឹងគាត់ជាក់ស្ដែងគឺជាអង្គសម្រេចធម៌។ បែបនេះជាក់ស្ដែងតម្រូវមនុស្សហាត់គង់ត្រូវតែមានចិត្តគំនិតយ៉ាងខ្ពស់បំផុតដើម្បីសមកាលកម្មជាមួយនឹងលក្ខណៈពិសេសមួយនេះ, នេះទើបអាចបួសហាត់ឡើងជាន់ថ្នាក់ខ្ពស់។

ធ្វើជាមនុស្សល្អងាយស្រួលជាង, ប៉ុន្តែចង់បួសហាត់ចិត្តគំនិតគឺមិនងាយស្រួលដូច្នោះទេ។ អ្នកបួសហាត់ត្រូវមានការបំរុងស្មារតី, ចំណង់ចិត្តសុចរិត, គំនិតស្មោះត្រង់ជាមុន។ ប្រជាជនរស់នៅលើពិភពលោក, សង្គមគឺស្មុគស្មាញ, លោកអ្នកចង់ប្រព្រឹត្តល្អ, ប៉ុន្តែក៏មានមនុស្សមិនឱ្យលោកអ្នកប្រព្រឹត្តល្អ; លោកអ្នកមិនរំលោភធ្វើបាបអ្នកដទៃ, ប៉ុន្តែអ្នកដទៃដោយសារគ្រប់ហេតុផលមកធ្វើបាបលោកអ្នក។ នៅទីនេះគឺមានមួយចំនួនចេញមកពីហេតុផលខុសពីធម្មជាតិ, លោកអ្នកអាចភ្ញាក់ដឹងបានថាហេតុអ្វីឬទេ? លោកអ្នកគួរ

ធ្វើដូចម្តេច? អ្វីៗទាំងអស់នៅលើពិភពលោកត្រូវៗខុសៗ, គ្រប់ពេលកំពុងពិនិត្យចិត្តគំនិតរបស់លោកអ្នក។ ក្នុងពេលប្រឈមមុខនឹងភាពអាម៉ាស់គ្មានឈ្មោះ, នៅពេលផលប្រយោជន៍សំខាន់របស់លោកអ្នកត្រូវបានធ្វើឱ្យខូចខាត, នៅចំពោះមុខមាសប្រាក់, នៅចំពោះមុខសម្រស់នារី, នៅក្នុងការតស៊ូដើម្បីអំណាច, នៅពេលដែលការច្រណែននិងកំហឹងលេចចេញជាជម្លោះ, នៅក្នុងវិះគន់សង្គមគ្រប់ប្រភេទ, ទំនាស់ក្នុងគ្រួសារនិងលំបាកវេទនាមើលឃើញនិងមើលមិនឃើញ, តើលោកអ្នករមែងអាចប្រើតម្រូវចិត្តគំនិតតឹងរឹងដើម្បីគ្រប់គ្រងខ្លួនឯងបានឬទេ? ពិតប្រាកដណាស់, ប្រសិនបើលោកអ្នកធ្វើបានអ្វីៗគ្រប់យ៉ាង, លោកអ្នកជាក់ស្តែងគឺជាអង្គត្រាស់ដឹងរួចហើយ។ យ៉ាងណាមិញមនុស្សហាត់គង់ភាគច្រើនគឺចាប់ផ្តើមពីមនុស្សសាមញ្ញ, បួសហាត់ចិត្តគំនិតក៏មានការលើកកម្ពស់បន្តិចម្តងៗ។ អ្នកមានឆន្ទៈបួសហាត់ត្រូវមានការប្តេជ្ញាចិត្តដើម្បីស៊ូទ្រាំនឹងការលំបាកធំធេងនិងដោះស្រាយការពិបាកធំៗ, ទីបំផុតនឹងសម្រេចមគ្គផលខ្ពស់បំផុត។ សង្ឃឹមថាអ្នកបួសហាត់ដ៏ច្រើនសន្ធឹកសន្ធាប់, រក្សាតឹងរឹងចិត្តគំនិត, លើកកម្ពស់អំណាចគង់ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

## II. បាត់និងបាន

នៅក្នុងពិភពឈើគង់, ពិភពសាសនាសុទ្ធតែសម្តែងអំពីបាត់និងបាន។ មានមនុស្សមួយចំនួនសន្មតថា ‘បាត់’ ជាក់ស្តែងគឺជាសេចក្តីសប្បុរស, ធ្វើរឿងល្អខ្លះ, នរណាពិបាកជួយបន្តិច; ‘បាន’ ជាក់

ស្តែងគឺទទួលបានគង់។ ព្រះសង្ឃក្នុងវត្តអារាមក៏និយាយដូច្នេះ, គួរឱ្យទាន។ នេះគឺមើល ‵បាត់′ ចង្អៀតណាស់ហើយ។ ប៉ុន្តែបាត់ដែលពួកយើងនិយាយគឺអត្ថន័យធំទូលាយ, ជារឿងធំណាស់។ ពួកយើងតម្រូវបាត់ទៅគឺជាចិត្តរបស់មនុស្សសាមញ្ញ, គឺជាបណ្តាចិត្តប្រកាន់ដែលមិនលះបង់, ប្រសិនបើអាចបាត់ទៅអ្វីដែលលោកអ្នកគិតថាសំខាន់, អាចបាត់ទៅអ្វីដែលលោកអ្នកគិតថាមិនអាចបោះបង់ចោល, នេះគឺ ‵បាត់′ ពិតប្រាកដ។ ជួយមនុស្សធ្វើរឿងល្អមួយចំនួន, បង្ហាញចិត្តមេត្តាខ្លះ, នេះគ្រាន់តែជាមួយផ្នែកនៃការ ‵បាត់′ ប៉ុណ្ណោះ។

ធ្វើជាមនុស្សសាមញ្ញចង់បានកិត្តិនាមកាន់តែច្រើន, ផលប្រយោជន៍កាន់តែច្រើន, ចង់រស់ក្នុងជីវិតកាន់តែធូរធារ, កាន់តែសុខស្រួល, ប្រាក់កាសកាន់តែច្រើន, នេះគឺជាគោលដៅរបស់មនុស្សសាមញ្ញ។ ប៉ុន្តែមនុស្សហាត់គង់ពួកយើងជាក់ស្តែងមិនដូច្នោះទេ, ដែលពួកយើងទទួលបានគឺជាគង់, ជាក់ស្តែងមិនមែនអ្វីទាំងនេះ។ ពួកយើងត្រូវបាត់បង់ផលប្រយោជន៍ផ្ទាល់ខ្លួន, មើលឱ្យស្រាលជាងមុនបន្តិច, ប៉ុន្តែក៏មិនមែនទុកឱ្យលោកអ្នកពិតជាបាត់បង់ទៅអ្វី។ ពួកយើងគឺបួសហាត់នៅក្នុងសង្គមមនុស្សសាមញ្ញ, នៅត្រូវតែរក្សាដូចនឹងមនុស្សសាមញ្ញ, សំខាន់គឺលោកអ្នកត្រូវបោះបង់ចោលចិត្តមួយនោះ, មិនមែនចង់ឱ្យលោកអ្នកពិតជាបាត់បង់ទៅអ្វី។ អ្វីដែលជារបស់លោកអ្នកនឹងមិនបាត់បង់, អ្វីដែលមិនមែនរបស់លោកអ្នកក៏មិនអាចទទួលបានដែរ, ទទួលបានហើយក៏ត្រូវប្រគល់

ឱ្យអ្នកដទៃ, មានទទួលបានត្រូវតែមានបាត់បង់។ ជាការពិត, ភ្លាមៗធ្វើបានដ៏ខ្ពស់ទាំងអស់ក៏មិនអាចទៅរួច, ក្នុងវេលាមួយយប់នឹងក្លាយជាអង្គត្រាស់ដឹងក៏ធ្វើទៅមិនរួចផងដែរ។ ប៉ុន្តែ, បួសបន្តិចម្តងៗ, លើកកម្ពស់មួយជំហានៗគឺអាចធ្វើបាន, លោកអ្នកអាចបាត់ទៅបានប៉ុន្មានជាក់ស្តែងនឹងទទួលបានប៉ុណ្ណោះ។ ក្នុងការពាក់ព័ន្ធនឹងផលប្រយោជន៍លោកអ្នករមែងមើលវាយ៉ាងស្រាល, ស៊ូទទួលបានតិចតែបន្ធូរអារម្មណ៍ជាជាង។ ខាងសម្ភារៈលោកអ្នកអាចនឹងរងគ្រោះ, ប៉ុន្តែនៅលើគុណធម៌លោកអ្នកនឹងទទួលបានកាន់តែច្រើន, នៅលើគង់លោកអ្នកនឹងទទួលបានកាន់តែច្រើន, នេះគឺជាគោលសីលធម៌នៅទីនោះ, ប៉ុន្តែមិនមែនចង់ឱ្យលោកអ្នកដោយចេតនាទៅយកកេរ្តិ៍ឈ្មោះផលប្រយោជន៍ប្រាក់កាសធ្វើការផ្តោះប្តូរ, រឿងនេះត្រូវប្រើការភ្ញាក់ដឹងឈានមួយជំហានទៀតដើម្បីយល់ដឹងបាន។

មានមនុស្សដែលបួសមហាតាវមួយរូបធ្លាប់បាននិយាយថា ‛អ្វីដែលមនុស្សដទៃចង់បានខ្ញុំមិនចង់បាន, អ្វីដែលមនុស្សដទៃមានខ្ញុំគ្មាន; ប៉ុន្តែអ្វីដែលខ្ញុំមានមនុស្សដទៃគ្មាន, អ្វីដែលមនុស្សដទៃមិនចង់បានខ្ញុំចង់បាន՛។ ធ្វើជាមនុស្សសាមញ្ញម្នាក់ពិបាកមានពេលពេញចិត្តណាស់, ចង់បានអ្វីៗគ្រប់យ៉ាង។ មានតែដុំថ្មនៅក្រោមដីប៉ុណ្ណោះដែលគាត់មិនរើស។ ប៉ុន្តែមនុស្សបួសតាវរូបនេះនិយាយថា ‛អញ្ចឹងខ្ញុំនឹងរើសដុំថ្មនោះ՛។ សុភាសិតនិយាយថារបស់ដែលកម្រទើបមានតម្លៃ, របស់ដែលតិចទើបចម្លែក, ដុំថ្មនៅទីនេះគ្មាន

តម្លៃ, មកដល់ទីនោះហើយជាក់ស្ដែងមានតម្លៃបំផុត។ នៅទីនេះបាននិយាយចេញទស្សនវិជ្ជាមួយដែលមនុស្សសាមញ្ញម្នាក់និយាយចេញមិនបាន។ មិនតិចអធិជនមហាគុណធម៌ដែលបួសសម្រេច, ពួកគាត់សុទ្ធតែគ្មានអ្វីទាំងអស់, សម្រាប់ពួកគាត់, គ្មានអ្វីដែលឯកជនមិនអាចលះបង់ចោលបាន។

ផ្លូវហាត់គង់នេះគឺត្រឹមត្រូវបំផុត, មនុស្សហាត់គង់ទើបជាឆ្លាតបំផុត។ មនុស្សសាមញ្ញចង់ដណ្ដើមអ្វីនោះ, ចង់បានកន្លែងល្អបន្តិចនោះគឺជាបណ្ដោះអាសន្ន, សូម្បីតែដណ្ដើមបានហើយ, រើសបានហើយ, ឬក៏ទទួលបានកន្លែងល្អបន្តិចហើយតើអាចធ្វើអ្វីបាន? មនុស្សសាមញ្ញមានប្រយោគថា៖ កើតមិននាំមកជាមួយ, ស្លាប់មិននាំទៅជាមួយ; ពេលមកខ្លួនមួយទទេ, ពេលទៅខ្លួនមួយទទេ, សូម្បីតែឆ្អឹងក៏ត្រូវដុតក្លាយជាផេះទាំងអស់។ មិនថាលោកអ្នកមានទ្រព្យស្ដុកស្ដម្ភ, មន្ត្រីខ្ពង់ខ្ពស់លេចធ្លោ, អ្វីក៏លោកអ្នកយកទៅជាមួយមិនបានដែរ, ប៉ុន្តែ ‵គង់′ អាចនាំទៅជាមួយបាន, ដោយសារតែវាគឺបង្កើននៅលើរាងកាយសតិម្ចាស់របស់លោកអ្នក។ ខ្ញុំប្រាប់លោកអ្នកពាក្យនេះ, ‵គង់′ គឺមិនងាយស្រួលបានមកទេ, វាដ៏មានតម្លៃខ្លាំងណាស់ពិបាកទទួលបានខ្លាំងណាស់, គឺមាសរាប់ពាន់ប្ដូរមិនបាន។ ពេលដែលគង់របស់លោកអ្នកខ្ពស់ណាស់រួចហើយ, ប្រសិនបើមានថ្ងៃមួយលោកអ្នកនិយាយថាមិនស្ម័គ្រចិត្តហាត់គង់បន្តទៀត, ដរាបណាលោកអ្នកមិនធ្វើអំពើអាក្រក់, ពេលនោះគង់របស់លោកអ្នកនឹងផ្លាស់ប្ដូរជាសម្ភារៈទាំងអស់ដែលលោកអ្នកត្រូវ

ការ, អាចទទួលបានទាំងអស់។ ប៉ុន្តែក្រៅពីអ្វីដែលលោកអ្នកទទួលបានក្នុងលោកីយ៍, អ្វីដែលមនុស្សប្ញូសហាត់ទទួលបានលោកអ្នកនឹងមិនទទួលបានទៀតឡើយ។

មនុស្សមួយចំនួនដើម្បីផលប្រយោជន៍ឯកជនណាមួយ, យករបស់ដែលជាគោលមិនមែនជារបស់ខ្លួន, ទទួលបានតាមរយៈមធ្យោបាយដែលមិនត្រឹមត្រូវ, គាត់សន្មតថាកាន់កាប់បានភាពងាយស្រួលរួចហើយ, តាមពិតផលប្រយោជន៍ដែលគាត់ទទួលបានគឺប្រើគុណធម៌ផ្ដោះប្ដូរជាមួយគេ, គ្រាន់តែគាត់មិនដឹងប៉ុណ្ណោះ។ សម្រាប់មនុស្សហាត់គង់នឹងត្រូវកាត់បន្ថយលើគង់; សម្រាប់មនុស្សមិនហាត់គង់នឹងត្រូវកាត់បន្ថយលើអាយុកាល, ឬក៏កាត់បន្ថយលើទិដ្ឋភាពផ្សេងទៀត។ និយាយឱ្យខ្លី, គណនីនេះគឺត្រូវតែគណនា, នេះគឺជាគោលសីលធម៌នៅក្នុងចក្រវាល។ មនុស្សខ្លះតែងតែសម្លុតគេ, ធ្វើបាបមនុស្សដោយពាក្យអាក្រក់, ជាដើម, ជាមួយនឹងការកើតឡើងនៃចរិយាទាំងនេះ, គាត់ជាក់ស្ដែងបានយកមួយចំណែកគុណធម៌ដែលតាមនោះបោះឱ្យភាគីម្ខាងទៀតរួចហើយ, យកគុណធម៌ផ្ដោះប្ដូរទៅនឹងការជេរប្រមាថអ្នកដទៃ។

មនុស្សមួយចំនួនអះអាងថា, ធ្វើមនុស្សល្អនឹងរងទុក្ខ។ នៅក្នុងមនុស្សសាមញ្ញសង្កេតឃើញថាគាត់គឺរងទុក្ខ, ប៉ុន្តែគាត់ទទួលបានរបស់ដែលមនុស្សសាមញ្ញមិនអាចទទួលបាន, នោះជាក់ស្ដែងគឺជា "គុណធម៌"—សារធាតុពណ៌ស—វាគឺជារបស់ដ៏មានតម្លៃខ្លាំងណាស់។ គ្មានគុណធម៌ជាក់ស្ដែងគ្មានគង់, នោះគឺជាសច្ចៈធម៌ដាច់

ខាត។ ជាច្រើនមនុស្សហេតុអ្វីហាត់គង់មិនបង្កើនគង់? ជាក់ស្ដែងគឺមិនយកគុណធម៌បួសឡើងទៅលើ។ មនុស្សជាច្រើនសុទ្ធតែកំពុងសម្ដែងអំពីគុណធម៌, សុទ្ធតែកំពុងតម្រូវគុណធម៌, ហើយមិនបានសម្ដែងចេញគោលសីលធម៌ដែលពិតជាបំលែងគុណធម៌ទៅជាគង់, ពឹងផ្អែកលើឯកជនដើម្បីភ្ញាក់ដឹង។ គម្ពីរតាចាងបានសរសេរជាងមួយម៉ឺនក្បាល, ពេលដែលសក្យមុនីនៅមានជីវិតសម្ដែងធម៌ជាង៤០ឆ្នាំ, សុទ្ធតែសម្ដែងអំពីគុណធម៌មួយនេះ; សៀវភៅបួសតាវនៃប្រទេសចិនបុរាណសុទ្ធតែនិយាយអំពីគុណធម៌មួយនេះ; ឡៅជឺបានសរសេរ «គម្ពីរសីលធម៌» ៥០០០អក្សរក៏សម្ដែងគឺជាគុណធម៌មួយនេះ, ប៉ុន្តែមនុស្សខ្លះជាក់ស្ដែងមិនភ្ញាក់ដឹង។

ពួកយើងសម្ដែងអំពី `បាត់´, មានបានជាក់ស្ដែងមានបាត់, លោកអ្នកពិតជាចង់បួសហាត់, ជាក់ស្ដែងនឹងជួបប្រទះទុក្ខវេទនាមួយចំនួន។ បង្ហាញនៅក្នុងជីវិត, មួយគឺទទួលទោសមួយចំនួនលើរាងកាយ, កន្លែងនេះមិនស្រួលកន្លែងនោះមិនស្រួល, ប៉ុន្តែមិនមែនជំងឺ។ លើសពីនេះទៀតជាក់ស្ដែងគឺបង្ហាញនៅក្នុងសង្គម, គ្រួសារ, កន្លែងធ្វើការសុទ្ធតែអាចលេចឡើង, ភ្លាមៗកើតឡើងទំនាស់ដោយសារផលប្រយោជន៍, លេចឡើងកកិតមនោសញ្ចេតនា, គោលបំណងគឺទុកឱ្យលោកអ្នកលើកកម្ពស់ចិត្តគំនិត។ រឿងរ៉ាវទាំងនេះជាធម្មតាមកដល់យ៉ាងចៃដន្យ, មើលទៅខ្លាំងក្លាខ្លាំងណាស់។ ប្រសិនបើលោកអ្នកជួបប្រទះរឿងមួយរំខានខ្លាំង, ធ្វើឱ្យលោកអ្នកចូលផ្លូវទល់, បាត់មុខខ្លាំង, អាម៉ាស់មុខខ្លាំង, ពេលនោះ

លោកអ្នកទប់ទល់ដូចម្តេច? លោកអ្នកសែនស្ងប់ស្ងាត់, អាចធ្វើបានចំណុចមួយនេះ, ចិត្តគំនិតនោះរបស់លោកអ្នកនៅក្នុងគ្រោះមួយនេះនឹងលើកកម្ពស់, គង់នោះរបស់លោកអ្នកក៏បានកើនឡើងខ្ពស់តាមនោះ។ លោកអ្នកអាចធ្វើបានបន្តិចម្តងៗ, លោកអ្នកនឹងទទួលបានបន្តិចម្តងៗ; លោកអ្នកចំណាយប៉ុណ្ណា, លោកអ្នកជាក់ស្តែងអាចទទួលបានប៉ុណ្ណោះ។ មនុស្សនៅក្នុងគ្រោះជាធម្មតាមិនប្រាកដភ្ញាក់ដឹងចេញបាន, ប៉ុន្តែពួកយើងត្រូវតែភ្ញាក់ដឹងបាន, មិនអាចច្រឡំជាមួយនឹងមនុស្សសាមញ្ញ, នៅពេលកើតមានទំនាស់ត្រូវតែអាកប្បកិរិយាខ្ពស់។ ពួកយើងបួសហាត់នៅក្នុងមនុស្សសាមញ្ញ, ហ្វឹកហាត់ចិត្តគំនិតក៏ត្រូវតែហ្វឹកហាត់នៅក្នុងមនុស្សសាមញ្ញ, ត្រូវតែដួលរលំប៉ុន្មានដង, ពីក្នុងនោះទទួលបានមេរៀន។ ប្រសិនបើចង់រំខានអ្វីក៏មិនជួបប្រទះ, ហើយអាចបង្កើនគង់ដោយងាយស្រួល, នោះគឺមិនអាចទេ។

## III. "សច្ចៈ-ករុណា-ខន្តី" បួសដំណាលគ្នា

ធម្មក្ខន្ធនេះរបស់ពួកយើងគឺបួស "សច្ចៈ-ករុណា-ខន្តី" ដំណាលគ្នា។ "សច្ចៈ", ជាក់ស្តែងគឺនិយាយពាក្យសច្ចៈ, ធ្វើរឿងសច្ចៈ, ត្រឡប់មកសច្ចៈ, ទីបំផុតធ្វើជាអង្គសច្ចំ។ "ករុណា", ជាក់ស្តែងគឺកើតចេញចិត្តមេត្តា, ធ្វើអ្វីដែលល្អប្រោសមនុស្ស។ ជាពិសេសសង្កត់ធ្ងន់ទៅលើសមត្ថភាពខន្តី, មានតែខន្តី, ទើបអាចបួសចេញបានអង្គមហាគុណធម៌។ "ខន្តី", វាគឺជាអ្វីខ្លាំងណាស់, គឺបានហួសពីសច្ចៈ

និងករុណា។ ដំណើរការបួសហាត់ទាំងមូលសុទ្ធតែតម្រូវធ្វើឱ្យលោកអ្នកដើម្បីខន្តី, រក្សាជាប់ចិត្តគំនិត, មិនអាចមិនប្រុងប្រយ័ត្ន។

ជួបរឿងអាចខន្តីបានមិនងាយស្រួលទេ។ មនុស្សខ្លះនិយាយថា៖ "វាយមិនសងដៃ, ជេរមិនតមាត់", សូម្បីតែកាលៈទេសៈដ៏អាម៉ាស់នៅក្នុងចំណោមសាច់ញាតិនិងមិត្តភក្តិសុទ្ធតែខន្តីបាន, តើនេះមិនក្លាយទៅជា "អា-Q" ហើយឬ?! ខ្ញុំនិយាយថាការបង្ហាញរបស់លោកអ្នកគ្រប់ទិដ្ឋភាពសុទ្ធតែដ៏ធម្មតា, បញ្ញាមិនទាបជាងអ្នកដទៃ, គ្រាន់តែថានៅទិដ្ឋភាពផលប្រយោជន៍ឯកជនមើលយ៉ាងស្រាលតែប៉ុណ្ណោះ, គ្មាននរណានឹងនិយាយថាលោកអ្នកឆោតល្ងង់ទេ។ អាចខន្តីគឺមិនមែនទន់ខ្សោយ, មិនមែនជា "អា-Q", គឺជាការបង្ហាញនៃឆន្ទៈដ៏រឹងមាំ, គឺជាការបង្ហាញនៃការអត់ធ្មត់ដោយខ្លួនឯង។ 'ហានស៊ីន' ក្នុងប្រវត្តិសាស្ត្រចិន, ធ្លាប់ត្រូវបានធ្វើឱ្យអាម៉ាស់លូនក្រោមក្រលៀន, ជាក់ស្តែងគឺជាមហាខន្តី។ សម័យបុរាណមានពាក្យនិយាយថា៖ "មនុស្សធម្មតារងប្រមាថ, ទាញដាវចេញមកច្បាំង"។ មនុស្សសាមញ្ញមួយរូបពេលដែលគាត់ត្រូវធ្វើឱ្យអាម៉ាស់, គាត់នឹងទាញដាវចេញដើម្បីច្បាំង, គាត់នឹងបើកមាត់ជេរមនុស្ស, បញ្ចេញកណ្តាប់ដៃវាយមនុស្ស។ មនុស្សមកទីលោកីយ៍គឺមិនងាយស្រួល, មនុស្សខ្លះជាក់ស្តែងព្រោះតែចាញ់ឈ្នះដើម្បីរស់, រឹតតែមិនស័ក្តិសម, ក៏នឿយហត់ណាស់ផងដែរ។ ប្រទេសចិនមានប្រយោគមួយថា៖ "ថយក្រោយមួយជំហាន, សមុទ្រនិងមេឃបើកទូលាយ"។ ពេលដែលលោកអ្នកជួបប្រទះរឿងរំខានហើយថយ

ក្រោយមួយជំហាន, លោកអ្នកនឹងរកឃើញថាគឺជាទស្សនីយភាពមួយផ្សេង។

ធ្វើជាមនុស្សហាត់គង់, សម្រាប់មនុស្សដែលកើតឡើងទំនាស់ជាមួយលោកអ្នក, សម្រាប់មនុស្សដែលធ្វើឱ្យលោកអ្នកអាម៉ាស់, លោកអ្នកមិនត្រឹមតែត្រូវខន្តី, ត្រូវអាកប្បកិរិយាខ្ពស់ប៉ុណ្ណោះទេ, ថែមទាំងត្រូវអរគុណគាត់ទៀតផង។ ប្រសិនបើគ្មានគាត់កើតជម្លោះជាមួយលោកអ្នក, តើលោកអ្នកធ្វើម្តេចអាចលើកកម្ពស់ចិត្តគំនិតបាន, តើធ្វើម្តេចនឹងនៅពេលរងទុក្ខលំបាកយកសារធាតុពណ៌ខ្មៅផ្លាស់ប្តូរទៅជាសារធាតុពណ៌សបាន, តើធ្វើម្តេចបង្កើនគង់? មនុស្សនៅក្នុងគ្រោះមហន្តរាយគឺពិបាកទ្រាំណាស់, ប៉ុន្តែពេលនេះត្រូវតែឃាត់ជាប់, ដោយសារតែជាមួយនឹងពេលដែលអំណាចគង់បង្កើន, គ្រោះមហន្តរាយនោះគឺបន្តកើនឡើង, ជាក់ស្តែងគឺសង្កេតមើលចិត្តគំនិតលោកអ្នកអាចឬក៏មិនអាចលើកកម្ពស់ឡើងទៅលើ។ ពេលចាប់ផ្តើមប្រហែលជាធ្វើឱ្យលោកអ្នកខឹង, ខឹងដល់ថ្នាក់ពិបាកទ្រាំ, សម្លុតលោកអ្នកពិបាកទ្រាំណាស់, លោកអ្នកខឹងដល់ថ្នាក់ឈឺថ្លើម, ឈឺក្រពះ, ប៉ុន្តែលោកអ្នកគ្មានការវាយប្រហារ, លោកអ្នកខន្តី, នេះជាក់ស្តែងល្អ, លោកអ្នកចាប់ផ្តើមខន្តីរួចហើយ, មួយប្រភេទនៃការខន្តីដោយចេតនា។ លោកអ្នកនឹងសន្សឹមៗបន្តលើកកម្ពស់ចិត្តគំនិត, លោកអ្នកនឹងពិតជាមើលស្រាលរឿងរ៉ាវនោះ, នៅពេលនោះជាក់ស្តែងគឺការលើកកម្ពស់កាន់តែធំ។ មនុស្សសាមញ្ញជាក់ការកកិតមួយចំនួន, រឿងរ៉ាវបន្តិច

បន្តួចមើលឃើញធំណាស់, រស់ជាក់ស្តែងដោយសារតែចាញ់ឈ្នះ, មិនអាចខន្តី, ហួសចិត្តរួចហើយរឿងអ្វីក៏ហ៊ានធ្វើទាំងអស់។ ប៉ុន្តែធ្វើជាមនុស្សហាត់គង់, អ្វីដែលអ្នកដទៃមើលឃើញដ៏ធំ, លោកអ្នកមើលឃើញជាក់ស្តែងដ៏តូច, ដ៏តូច, តូចខ្លាំងណាស់។ ដោយសារតែគោលដៅនោះរបស់លោកអ្នកវែងឆ្ងាយខ្លាំងណាស់, ឆ្ងាយនិងធំខ្លាំងណាស់, លោកអ្នកនឹងមានអាយុស្មើនឹងចក្រវាល។ លោកអ្នកសាកគិតរឿងនោះម្តងទៀត, អាចមានក៏អាចគ្មាន, លោកអ្នកឆ្ពោះទៅធំជាងរួចហើយសាកគិត, រឿងទាំងនោះសុទ្ធតែអាចឆ្លងផុតបាន។

## IV. កម្ចាត់ចិត្តច្រណែន

ចិត្តច្រណែនគឺជាឧបសគ្គធំបំផុតក្នុងការហាត់គង់, មានឥទ្ធិពលចំពោះមនុស្សហាត់គង់ធំខ្លាំងណាស់, នឹងជះឥទ្ធិពលផ្ទាល់ដល់អំណាចគង់របស់មនុស្សហាត់គង់, នឹងធ្វើបាបអ្នកបួសហាត់ដូចគ្នា, ជ្រៀតជ្រែកធ្ងន់ធ្ងរដល់ការបួសហាត់ឆ្ពោះឡើងលើរបស់ពួកយើង។ ធ្វើជាមនុស្សហាត់គង់គឺត្រូវតែកម្ចាត់មួយរយភាគរយ។ មនុស្សខ្លះហាត់គង់ដល់ជាន់ថ្នាក់ជាក់លាក់រួចហើយ, ប៉ុន្តែចិត្តច្រណែនជាក់ស្តែងគឺកម្ចាត់មិនបាន, ហើយកាន់តែមិនកម្ចាត់ជាក់ស្តែងកាន់តែងាយស្រួលពង្រឹង។ ប្រភេទផលប៉ះពាល់ផ្ទុយនេះធ្វើឱ្យចិត្តគំនិតដទៃដែលគាត់បានលើកកម្ពស់រួចហើយក៏ក្លាយទៅជាផុយស្រួយខ្លាំងណាស់។ ចិត្តច្រណែនហេតុអ្វីបានជាយកវាចេញតែមួយដើម្បីសម្តែង? ដោយសារតែចិត្តច្រណែននៅក្នុងចំណោម

ជនជាតិចិនបង្ហាញចេញខ្លាំងក្លាបំផុត, លេចធ្លោបំផុត, សមាមាត្រធំបំផុតនៅក្នុងចិត្តរបស់គេ, ប៉ុន្តែមនុស្សជាច្រើនមិនបានដឹង។ ចិត្តច្រណែនគឺមានតែមួយគត់នៅបូព៌ា, ហៅថា 'ច្រណែនបូព៌ា' ឬក៏ 'ច្រណែនអាស៊ី'។ ជនជាតិចិនតម្រង់ចិត្តទៅក្នុងណាស់, ស្រគត់ស្រគំណាស់, មិនងាយស្រួលក្នុងការបង្ហាញចេញ, នេះជាក់ស្តែងងាយស្រួលកកើតចិត្តច្រណែន។ អ្វីៗគ្រប់យ៉ាងសុទ្ធតែត្រូវបែងចែកជាពីរ, ចរិតតម្រង់ទៅក្នុងមានផ្នែកល្អ, ក៏មានផ្នែកមិនល្អផងដែរ។ ជនជាតិលោកខាងលិចតម្រង់ចិត្តចេញក្រៅណាស់, លោកអ្នកឧបមានិយាយថា, កូនក្មេងប្រសិនបើនៅសាលាបាន១០០ពិន្ទុ, វានឹងសប្បាយចិត្តខ្លាំងរត់មកផ្ទះផងស្រែកឡើងផង៖ "កូនបាន១០០ពិន្ទុហើយ,..." អ្នកជិតខាងសុទ្ធតែនឹងបើកទ្វារ, បើកបង្អួចសំដៅទៅគាត់ជូនពរ៖ "Tomជូនពរកូន!" សប្បាយចិត្តជំនួសគាត់។ ប្រសិនបើនៅប្រទេសចិនលោកអ្នកគិតសាកមើល, ឮភ្លាមនឹងខ្មើមរអើម៖ 'បាន១០០ពិន្ទុមានអ្វីអស្ចារ្យណាស់ទៅ, មានអ្វីគួរឱ្យអួតអាងណាស់ទៅ!' ប្រតិកម្មជាក់ស្តែងខុសគ្នាទាំងស្រុង, មានមួយប្រភេទចិត្តសាស្ត្រនៃការច្រណែន។

មនុស្សដែលមានចិត្តច្រណែនមើលងាយមនុស្សដទៃ, មិនអនុញ្ញាតឱ្យមនុស្សដទៃលើសពីខ្លួនឯង, ឃើញមនុស្សដទៃខ្លាំងជាងគាត់ក្នុងចិត្តគាត់នឹងបាត់បង់តុល្យភាព, ទ្រាំមិនបាន, មិនគោរព។ ដំឡើងប្រាក់ខែដំឡើងជាមួយគ្នា, យកប្រាក់រង្វាន់ត្រូវបានច្រើនដូចគ្នា, មេឃធ្លាក់ចុះទាំងអស់គ្នាទល់។ ឃើញមនុស្សដទៃរកប្រាក់

បានច្រើនជាងគាត់ជាក់ស្តែងកើតជំងឺក្រហមភ្នែក, ទោះយ៉ាងណាក៏ដោយលើសពីគាត់ជាធម្មតាគឺមិនបាន។ មនុស្សមួយចំនួនធ្វើចេញលទ្ធផលនៃការស្រាវជ្រាវវិទ្យាសាស្ត្រហើយមិនហ៊ានទទួលប្រាក់រង្វាន់, ខ្លាចមនុស្សដទៃច្រណែន; មនុស្សមួយចំនួនត្រូវបានគេបោះឆ្នោតឱ្យមានមុខងារកិត្តិយសណាមួយក៏មិនហ៊ាននិយាយស្តី, ខ្លាចច្រណែនសើចចម្អក។ ឃើញគ្រូឈើគង់ផ្សេងសម្តែងមេរៀនគឺមិនគោរព, ទៅកកូរ, នេះជាក់ស្តែងគឺជាបញ្ហាចិត្តគំនិត។ អ្នករាល់គ្នាហាត់គង់រួមជាមួយគ្នា, មនុស្សខ្លះពេលវេលាហាត់គង់ខ្លី, ប៉ុន្តែបញ្ចេញសីលគង់រួចហើយ។ បន្ទាប់មក, មានមនុស្សជាក់ស្តែងនិយាយថាៈ គាត់មានអ្វីអស្ចារ្យ, ខ្ញុំហាត់អស់ច្រើនឆ្នាំមកហើយ, លិខិតបញ្ជាក់គឺមួយគំនរធំ, ខ្ញុំនៅមិនទាន់បញ្ចេញសីលគង់ផងតើគាត់ធ្វើម្តេចអាចបញ្ចេញបាន? ចិត្តច្រណែនជាក់ស្តែងឡើងមករួចហើយ។ ហាត់គង់គឺតម្រង់ចិត្តទៅក្នុងរក, ខ្លួនឯងប្ញសហាត់ខ្លួនឯងច្រើនជាង, រកមូលហេតុចេញពីខ្លួនឯង។ ខ្លួនឯងធ្វើមិនទាន់គ្រប់នៅទិដ្ឋភាពណាមួយ, ខ្លួនឯងត្រូវតែខិតខំដើម្បីលើកកម្ពស់, ប្រើការប្រឹងប្រែងតម្រង់ទៅក្នុង។ មនុស្សដែលសុទ្ធតែប្រើការប្រឹងប្រែងតម្រង់ចេញក្រៅ, មនុស្សដទៃសុទ្ធតែប្ញសល្អរួចហើយ, សុទ្ធតែឡើងទៅរួចហើយ, ជាក់ស្តែងលោកអ្នកមិនទាន់ឡើងទៅ, តើលោកអ្នកមិនមែនខ្ជះខ្ជាយពេលវេលាទេឬ? ប្ញសហាត់ត្រូវតែប្ញសខ្លួនឯង។

ចិត្តច្រណែននៅតែនឹងធ្វើបាបដល់អ្នកប្ញសដូចគ្នា, ឧបមា

និយាយពាក្យមិនល្អស្ដាប់មួយចំនួនធ្វើឱ្យចិត្តរបស់មនុស្សមិនអាចចូលទៅក្នុងស្ងប់; ពេលដែលគាត់មានសីលគង់ជាក់លាក់រួចហើយ , ផុសពីការច្រណែនអាចប្រើសីលគង់ធ្វើបាបមនុស្សបួសដូចគ្នា។ ឧទាហរណ៍មានមនុស្សបួសហាត់យ៉ាងល្អម្នាក់កំពុងអង្គុយសមាធិហាត់គង់, ដោយសារតែលើរាងកាយគាត់មានគង់, អង្គុយនៅទីនោះដូចភ្នំមួយផ្ទាំង។ ពេលនេះអណ្ដែតមកពីរជីវិត, មានម្នាក់អតីតកាលគឺជាព្រះសង្ឃ, ដោយសារតែមានចិត្តច្រណែនមិនទាន់បួសឡើងទៅលើបាន, ទោះបីមានអំណាចគង់ជាក់លាក់, ប៉ុន្តែនៅពុំទាន់បួសសម្រេច។ ពេលដែលពួកគាត់មកដល់កន្លែងមនុស្សអង្គុយសមាធិនៅទីនេះ, ម្នាក់និយាយថា៖ ‵នេះគឺជានរណាគេកំពុងបួសហាត់នៅទីនេះ, ពួកយើងរាំងផ្លូវទៅបានហើយ!′ ប៉ុន្តែម្នាក់ទៀតនិយាយថា៖ ‵នឹកដល់ឆ្នាំនោះខ្ញុំមួយដៃពុះបាត់មួយម៉ឺភ្នំថៃសាន។′ បន្តមកក៏សំដៅមនុស្សហាត់គង់ពុះមួយដៃ។ ប៉ុន្តែ, លើកដៃឡើងរួចហើយដាក់ចុះមិនបាន។ ដោយសារតែមនុស្សហាត់គង់គឺបួសហាត់សុចរិតធម៌, មានគម្របការពារ, គាត់ពុះមិនរួច។ គាត់ចង់ធ្វើបាបមនុស្សដែលបួសហាត់សុចរិតធម៌, បញ្ហាជាក់ស្ដែងធ្ងន់ធ្ងរហើយ, ត្រូវបានដាក់ទណ្ឌកម្ម។ មនុស្សដែលមានចិត្តច្រណែនធ្វើបាបខ្លួនឯងផងព្រមទាំងធ្វើបាបមនុស្ស។

## V. កម្ចាត់ចិត្តប្រកាន់

‵ចិត្តប្រកាន់′ គឺសំដៅទៅលើមនុស្សហាត់គង់សម្រាប់រឿងអ្វីមួយ, គោលដៅអ្វីមួយទទូចមិនបោះចោល, មានការស្វែងរកហួសប្រ

មាណ, មិនអាចផ្តាច់ចេញបាន, សូម្បីតែរឹងរូសខ្លាំងណាស់ផង, មិនស្តាប់ដំបូន្មាន។ មនុស្សខ្លះស្វែងរកនៅលោកីយ៍ទទួលបានសីលគង់មួយចំនួន, រឿងនេះជៀសមិនរួចនឹងជះឥទ្ធិពលដល់ការបួសហាត់ឡើងជាន់ថ្នាក់ខ្ពស់, ចិត្តសាស្រ្តមួយនេះកាន់តែខ្លាំងក្លា, កាន់តែមិនងាយស្រួលបោះបង់, ចិត្តសាស្រ្តជាក់ស្តែងកាន់តែគ្មានតុល្យភាពនិងមិនស្ថិតស្ថេរ, ក្រោយមកជាក់ស្តែងនឹងសន្មតថាខ្លួនឯងគ្មានទទួលបានអ្វីទាំងអស់, សូម្បីតែកាន់ជាប់អាកប្បកិរិយាសង្ស័យសម្រាប់អ្វីដែលធ្លាប់បានរៀន។ ចិត្តប្រកាន់កើតឡើងពីតណ្ហារបស់មនុស្ស, លក្ខណៈពិសេសរបស់វាគឺគោលដៅឬក៏គោលបំណងមានកម្រិតច្បាស់លាស់, ច្បាស់ណាស់, ជាក់លាក់, ខ្លួនគាត់ផ្ទាល់ជាធម្មតានៅតែមិនដឹង។ ចិត្តប្រកាន់របស់មនុស្សសាមញ្ញគឺច្រើនណាស់, គាត់ដើម្បីស្វែងរកអ្វីមួយប៉ុន្តែមិនសម្រេចបានគោលបំណង, គាត់អាចប្រើគ្រប់កលល្បិចដើម្បីទទួលបាននៅក្នុងដៃ។ ធ្វើជាមនុស្សហាត់គង់ចិត្តប្រកាន់គឺជាការបង្ហាញមួយផ្សេងទៀត។ ឧបមាស្វែងរកប្រភេទសីលគង់ណាមួយ, ញៀននឹងប្រភេទទស្សនីយភាពណាមួយ, យកចិត្តទុកដាក់នឹងប្រភេទការបង្ហាញណាមួយជាដើម។ ធ្វើជាមនុស្សហាត់គង់, មិនថាលោកអ្នកចង់បានអ្វីសុទ្ធតែខុសទាំងអស់, រឿងនេះចាំបាច់កម្ចាត់ចោល។ តាវវង្សសម្តែង `គ្មាន´, ពុទ្ធវង្សសម្តែង `ទទេ´, ចូល `ទ្វារទទេ´, ទីបំផុតពួកយើងចាំបាច់ឈានដល់ `ទទេ´ `គ្មាន´, ត្រូវតែកម្ចាត់ចិត្តប្រកាន់ទាំងអស់, យកអ្វីដែលលោកអ្នកលះបង់មិនបានត្រូវតែ

លះបង់ទាំងអស់។ ដូចជា, សម្រាប់ការស្វែងរកសីលគង់, លោកអ្នកចំណង់ជាក់ស្តែងគឺចង់ប្រើ, តាមពិតទៅវាផ្ទុយនឹងលក្ខណៈពិសេសនៃចក្រវាលរបស់ពួកយើង, តាមពិតទៅនៅតែជាបញ្ហាចិត្តគំនិត។ ចង់ទទួលបាន, ជាក់ស្តែងចង់បង្ហាញនៅចំពោះមុខមនុស្ស, ឬក៏បង្ហាញៗ។ របស់នោះមិនមែនបង្ហាញឱ្យមនុស្សដទៃមើលបានទេ។ ប្រសិនបើគោលបំណងដែលលោកអ្នកប្រើដ៏បរិសុទ្ធ, ជាក់ស្តែងគឺចង់ធ្វើរឿងល្អ, រឿងល្អនោះដែលលោកអ្នកបានធ្វើមិនប្រាកដថាជារឿងល្អនោះទេ, រឿងនៃមនុស្សសាមញ្ញលោកអ្នកប្រើវិធីសាស្ត្រវិសាមញ្ញដើម្បីគ្រប់គ្រងនឹងមិនប្រាកដថាជារឿងល្អ។ មនុស្សខ្លះស្តាប់ឮខ្ញុំសម្តែងនៅលើថ្នាក់បង្រៀនមានមនុស្ស៧០ភាគរយសុទ្ធតែបើកបញ្ញាញាណរួចហើយ, បន្ទាប់មកក៏ពិចារណា៖ 'ហេតុអ្វីខ្ញុំមិនមានអារម្មណ៍ទំ?' ពេលមកផ្ទះហាត់គង់យកចិត្តទុកដាក់ក៏ផ្តោតអារម្មណ៍ទៅលើបញ្ញាញាណ, គិតដល់ថ្នាក់ឈឺក្បាល, លទ្ធផលនៅតែអ្វីក៏មើលមិនឃើញ, នេះជាក់ស្តែងគឺជាចិត្តប្រកាន់។ មនុស្សម្នាក់ៗគុណសម្បត្តិរាងកាយមិនដូចគ្នា, និស្ស័យក៏មិនដូចគ្នា, បញ្ញាញាណមិនអាចមើលឃើញដំណាលគ្នា, ក៏មិនអាចសុទ្ធតែមានជាន់ថ្នាក់ដូចគ្នា។ មនុស្សខ្លះអាចមើលឃើញ, មនុស្សខ្លះមិនអាចមើលឃើញ, សុទ្ធតែជារឿងធម្មតា។

ចិត្តប្រកាន់អាចធ្វើឱ្យអំណាចគង់របស់មនុស្សហាត់គង់លេចឡើងស្ថានភាពជាប់គាំង, វង្វេង, ធ្ងន់ធ្ងរនៅអាចនាំមនុស្សហាត់គង់ដើរចូលផ្លូវទុចរិត។ ពិសេសគឺមានសីលគង់មួយចំនួន, ចិត្តគំនិត

មិនល្អគឺអាចប្រើដើម្បីធ្វើរឿងអាក្រក់។ ក៏មានឧទាហរណ៍នៃការប្រើប្រាស់សីលគង់ដើម្បីធ្វើរឿងអាក្រក់ដោយសារតែចិត្តគំនិតមិនរឹងមាំ។ នៅតំបន់នោះមាននិស្សិតមហាវិទ្យាល័យភេទប្រុសម្នាក់បានបញ្ចេញមួយប្រភេទសីលគង់ឃុំគ្រងផ្នត់គំនិត, សីលគង់មួយនេះអាចប្រើផ្នត់គំនិតរបស់គាត់ដើម្បីឃុំគ្រងមនោគតិនិងអាកប្បកិរិយារបស់មនុស្សដទៃ, គាត់នឹងប្រើវាដើម្បីធ្វើរឿងអាក្រក់។ មនុស្សខ្លះពេលកំពុងហាត់គង់បានលេចឡើងទស្សនីយភាពមួយចំនួន, តែងតែចង់ឃើញនិងយល់ច្បាស់, ស្វែងយល់, នេះក៏ជាចិត្តប្រកាន់ផងដែរ។ មនុស្សខ្លះមានប្រភេទចំណង់ចំណូលចិត្តណាមួយហើយក្លាយជាញៀន, ពិបាកលះបង់ណាស់, ក៏ជាចិត្តប្រកាន់ផងដែរ។ ដោយសារតែនិស្ស័យមិនដូចគ្នាគោលបំណងមិនដូចគ្នា, មនុស្សខ្លះហាត់គង់គឺដើម្បីឈានដល់កម្រិតខ្ពស់បំផុត; មនុស្សខ្លះជាក់ស្តែងគឺដើម្បីទទួលបានអ្វីមួយចំនួន។ ប្រភេទមនោគតិទីពីរជៀសមិនរួចនឹងធ្វើឱ្យគោលបំណងនៃការហាត់គង់លេចឡើងដែនកំណត់។ ចិត្តប្រកាន់បែបនេះមិនលុបបំបាត់, ជាក់ស្តែងគឺហាត់គង់ក៏មិនអាចបង្កើនគង់បាន។ ដូច្នេះ,មនុស្សហាត់គង់ត្រូវមើលយ៉ាងស្រាលផលប្រយោជន៍សម្ភារៈទាំងអស់, ដោយគ្មានការស្វែងរក, ទាំងអស់បណ្តោយតាមធម្មជាតិ, បែបនេះជាក់ស្តែងនឹងទប់ស្កាត់ចិត្តប្រកាន់លេចឡើង, រឿងនេះជាក់ស្តែងចង់សង្កេតមើលចិត្តគំនិតរបស់មនុស្សហាត់គង់ដូចម្តេច។ ចិត្តគំនិតមិនលើកកម្ពស់ពីមូលដ្ឋាន, នាំតាមចិត្តប្រកាន់ណាមួយទៅជាមួយគឺសុទ្ធតែបួសមិន

បានសម្រេច។

## VI. អំណាចកម្ម

### ១. ការបង្កើតនៃអំណាចកម្ម

អំណាចកម្មគឺជាមួយប្រភេទសារធាតុពណ៌ខ្មៅដែលផ្ទុយនឹង `គុណធម៌´។ ក្នុងពុទ្ធសាសនាហៅវាថា `បាបកម្ម´; ពួកយើងនៅទីនេះហៅថា `អំណាចកម្ម´។ ដូច្នេះធ្វើរឿងអាក្រក់ក៏ហៅថា `សាងកម្ម´។ កម្មឬក៏អំណាចកម្មគឺដោយសារតែកំហុសរបស់មនុស្សរូបនោះនៅក្នុងជីវិតនេះឬក៏ជីវិតអតីតកាលបង្កើតចេញ, ដូចជាធ្លាប់សម្លាប់ជីវិត, ធ្លាប់ម៉ាក់ងាយនរណា, ធ្លាប់ដណ្ដើមយកផលប្រយោជន៍របស់នរណា, ធ្លាប់និយាយដើមក្រោយខ្នងនរណា, មិនរាក់ទាក់ចំពោះនរណាជាដើម, សុទ្ធតែនឹងបង្កើតចេញអំណាចកម្ម។ នៅមានអំណាចកម្មគឺដោយសារបុព្វបុរសឬក៏សាច់ញាតិនិងមិត្តភក្តិផ្ទេរមក។ នៅពេលមនុស្សម្នាក់បញ្ចេញកណ្ដាប់ដៃវាយមនុស្ស, ក្នុងពេលដំណាលគ្នាបានយកសារធាតុពណ៌សបោះឱ្យភាគីម្ខាងទៀត, បំណែកកន្លែងនោះលើរាងកាយខ្លួនឯងនឹងត្រូវបានសារធាតុពណ៌ខ្មៅជំនួស។ សម្លាប់ជីវិតគឺជាការធ្វើអំពើអាក្រក់, ធ្វើរឿងអាក្រក់ធំបំផុត, នឹងបង្កើនអំណាចកម្មដ៏ធ្ងន់ធ្ងរ។ អំណាចកម្មគឺជាមូលហេតុចម្បងដែលនាំឱ្យមនុស្សមានជំងឺ, ជាការពិតវាមិនប្រាកដផ្លុះបញ្ចាំងចេញមកគឺជាមួយប្រភេទជំងឺ, ក៏អាចជួបប្រទះបញ្ហាខ្លះជាដើម, គឺសុទ្ធតែអំណាចកម្មកំពុងផ្ដើមផលប៉ះពាល់។ ដូច្នេះមនុស្សហាត់គង់ដាច់ខាតមិនអាចធ្វើរឿងរ៉ាវមិនល្អ, ចរិយា

មិនល្អទាំងអស់នឹងបង្កើតចេញព័ត៌មានមិនល្អ, នឹងមានឥទ្ធិពលធ្ងន់ធ្ងរដល់បញ្ហាហាត់គង់របស់លោកអ្នក។

មនុស្សមួយចំនួនគាំទ្រប្រមូលឈីនៃរុក្ខជាតិ, នៅពេលបង្រៀនគង់ក៏បង្រៀនធ្វើដូចម្ដេចដើម្បីប្រមូលឈីនៃរុក្ខជាតិផងដែរ។ ឈីនៃដើមឈើអ្វីដែលល្អ, ឈីនៃដើមឈើអ្វីជាពណ៌អ្វី, ពិភាក្សាដោយចំណាប់អារម្មណ៍ខ្លាំង។ នៅក្នុងឧទ្យានមួយនៅភាគឦសានរបស់ពួកយើង, មានមនុស្សមួយចំនួនមិនដឹងជាហាត់គង់អ្វី, រមៀលពាសពេញដី, ក្រោកឡើងដើរជុំវិញដើមស្រល់, ប្រមូលឈីនៃដើមស្រល់, ក្នុងរយៈពេលកន្លះឆ្នាំបានប្រមូលធ្វើឱ្យដើមស្រល់មួយដុំឡើងស្ងួតលឿងអស់, នេះគឺជាចរិយាសាងកម្ម, នេះក៏ជាការសម្លាប់ជីវិត! មិនថាពីទិដ្ឋភាពធ្វើឱ្យមាតុភូមិពណ៌បៃតងដើម្បីរក្សាតុល្យភាពអេកូឡូស៊ីឬក៏ពីលើជាន់ថ្នាក់ខ្ពស់ដើម្បីសម្ដែង, ប្រមូលឈីនៃរុក្ខជាតិគឺសុទ្ធតែមិនល្អ។ ចក្រវាលដ៏ធំធេងគ្មានដែនគ្មានកំណត់, គ្រប់ទីកន្លែងមានឈីអនុញ្ញាតឱ្យលោកអ្នកទៅប្រមូល, លោកអ្នកទោះបីទៅប្រមូលបានរួចហើយ, ហេតុអ្វីផ្ទុយមកវិញសម្លុតធ្វើបាបរុក្ខជាតិ? ធ្វើជាមនុស្សហាត់គង់ចិត្តមេត្តារបស់លោកអ្នកទៅទីណាបាត់រួចហើយ?

សព្វសត្វសុទ្ធតែមានវិញ្ញាណ។ វិទ្យាសាស្ត្របច្ចុប្បន្នធ្លាប់បានយល់ដឹងពីរុក្ខជាតិមិនត្រឹមតែមានជីវិត, លើសពីនេះទៀតនៅមានភាពវៃឆ្លាត, មានផ្នត់គំនិតនិងអារម្មណ៍, សូម្បីតែមានទាំងសីលគង់អតិអារម្មណ៍ទៀតផង។ នៅពេលដែលបញ្ញាញាណរបស់លោក

អ្នកឈានដល់ធម៌ចក្ខុវិស័យ, លោកអ្នកនឹងរកឃើញថាចក្រវាលគឺជាទស្សនីយភាពមួយផ្សេង, នៅពេលលោកអ្នកចេញផុតពីទ្វារ, ដុំថ្មនោះ, ជញ្ជាំង, ដើមឈើជាដើមសុទ្ធតែនឹងនិយាយជាមួយលោកអ្នក។ វត្ថុណាមួយសុទ្ធតែមានរាងកាយជីវិតស្ថិតនៅ, នៅពេលដែលវាកំពុងបង្កើតឡើង, បានមានមួយរាងកាយជីវិតបញ្ចូលរួចហើយ។ សារធាតុសរីរាង្គនិងសារធាតុអសរីរាង្គគឺជាមនុស្សជាតិលើផែនដីពួកយើងបែងចែកចេញ។ មនុស្សនៅក្នុងវត្តគាត់ធ្វើបែកចានរួចហើយក្នុងចិត្តគាត់សុទ្ធតែពិបាកទ្រាំ, ដោយសារតែនៅពេលវាត្រូវធ្វើឱ្យខូចពេលណា, រាងកាយជីវិតនោះនឹងដោះលែងចេញមក, វាមិនទាន់បញ្ចប់សព្វគ្រប់ដំណើរជីវិតរបស់វា, ជាក់ស្តែងគ្មានកន្លែងអាចទៅ។ ដូច្នេះជាក់ស្តែងស្អប់មនុស្សដែលសម្លាប់វាខ្លាំងណាស់, កាន់តែស្អប់មនុស្សម្នាក់នោះអំណាចកម្មនឹងកាន់តែធំ។ "គ្រូឈីគង់" ខ្លះនៅតែបរបាញ់សត្វ, ចិត្តមេត្តារបស់គាត់ទៅទីណារួចហើយ? ពុទ្ធនិងតាវទាំងពីរវង្សធ្វើសកម្មភាពសុទ្ធតែមិនរំលោភបំពានលើច្បាប់នៃធម្មជាតិ។ គាត់ធ្វើបែបនេះជាក់ស្តែងគឺជាចរិយាសម្លាប់ជីវិត។

មានមនុស្សសម្តែងថាគាត់អតីតកាលសាងកម្មច្រើនណាស់, សម្លាប់មាន់, សម្លាប់ត្រី, ស្ទូចត្រីជាដើម, តើមិនអាចហាត់គង់បានទៀតមែនទេ? មិនត្រូវទេ។ លោកអ្នកពេលនោះគឺធ្វើដោយមិនដឹង, វានឹងមិនបង្កជាអំណាចកម្មធំជាង, ចាប់ពីពេលនេះតទៅកុំធ្វើរឿងនេះម្តងទៀតគឺបានហើយ។ ធ្វើម្តងទៀតជាក់ស្តែងគឺដឹង

ច្បាស់ហើយរំលោភដោយចេតនា, ជាក់ស្តែងមិនបានទេ។ សិក្ខាកាមខ្លះជាក់ស្តែងមានអំណាចកម្មប្រភេទនេះ។ លោកអ្នកមកចូលរួមក្នុងថ្នាក់បង្រៀនជាក់ស្តែងមានវាសនា, លោកអ្នកជាក់ស្តែងអាចបួសហាត់ឡើងលើ។ តើរុយ, មូសចូលទៅក្នុងផ្ទះវាយឬក៏មិនវាយ? អ្នករាល់គ្នាបច្ចុប្បន្នលើជាន់ថ្នាក់នេះធ្វើរឿងនេះ, វាយងាប់រួចហើយក៏មិនគិតថាខុស។ ដេញមិនចេញវាយងាប់គឺវាយងាប់យ៉ាងនេះឯង។ នៅពេលអ្វីមួយគួរតែស្លាប់, តាមធម្មជាតិវាជាក់ស្តែងគួរតែស្លាប់។ សក្យមុនីពេលនៅលើលោក, មានម្តងគាត់ចង់ងូតទឹក, បានហៅកូនសិស្សទៅបោសសំអាតអាងងូតទឹក។ កូនសិស្សរកឃើញថានៅក្នុងអាងងូតទឹកមានសត្វល្អិត, ត្រឡប់ទៅសួរគាត់ធ្វើដូចម្តេច? លោកបាននិយាយម្តងទៀតថា៖ ៉យើងចង់កូនបោសសំអាតគឺជាអាងងូតទឹក៉។ កូនសិស្សយល់ដឹងហើយ, បោសសំអាតអាងងូតទឹកបានស្អាត។ មានបញ្ហាមួយចំនួនលោកអ្នកមិនចំបាច់មើលវាសំខាន់ខ្លាំងពេក, យើងមិនមែនសុំឱ្យលោកអ្នកធ្វើជាមនុស្សម្នាក់ដែលប្រយ័ត្នប្រយែងរឿងការតូចតាច។ នៅក្នុងបរិយាកាសស្មុគស្មាញ, រឹតបន្តឹងស្មារតីគ្រប់ពេលដល់ថ្នាក់យ៉ាងបន្ទាន់, រស់ខ្លាចតែធ្វើខុសរឿងបន្តិចបន្តួច, ខ្ញុំនិយាយថានេះមិនបានទេ, នេះជាក់ស្តែងគឺជាមួយប្រភេទប្រកាន់ហើយ, ភាពខ្លាចខ្លួនវាផ្ទាល់ជាក់ស្តែងគឺជាការប្រកាន់។

ពួកយើងត្រូវមានបេះដូងមួយដោយចិត្តមេត្តា, ដោះស្រាយរឿងរ៉ាវណាមួយក៏ឱបយកបេះដូងមួយដែលមានចិត្តអាណិត

អាសូរ, ជាក់ស្ដែងមិនងាយស្រួលលេចឡើងបញ្ហា។ ចំពោះផលប្រយោជន៍ឯកជនមើលស្រាលបន្តិច, ក្នុងចិត្តសប្បុរសបន្តិច, លោកអ្នកធ្វើរឿងអ្វីក៏ទទួលរងការដាក់កម្រិតរបស់វា, ដូច្នេះលោកអ្នកជាក់ស្ដែងមិនអាចធ្វើចេញរឿងរ៉ាវអាក្រក់បាន។ មិនជឿលោកអ្នកសង្កេតមើល, លោកអ្នកតែងតែឱបយកអាកប្បកិរិយាខឹង, តែងតែចង់ប្រយុទ្ធ, តស៊ូ, រឿងល្អនោះនៅចំពោះមុខលោកអ្នកក៏នឹងធ្វើទៅជារឿងអាក្រក់។ ខ្ញុំច្រើនតែឃើញមនុស្សមួយចំនួននៅពេលណាដែលសមហេតុផលនឹងមិនអនុញ្ញាតឱ្យនរណា, នៅពេលដែលគាត់ចាប់បានហេតុផល, គាត់អាចចាប់បានរបស់ដើម្បីគ្រប់គ្រងមនុស្ស។ ក្នុងពេលដំណាលគ្នាពួកយើងក៏មិនអាចដោយសារតែមើលឃើញរឿងមួយមិនសមភ្នែក, ហើយរំយោលភាពត្រូវនិងខុស, ពេលខ្លះរឿងរ៉ាវដែលលោកអ្នកមើលឃើញមិនសមភ្នែកមិនប្រាកដគឺខុសនោះទេ។ ធ្វើជាមនុស្សហាត់គង់នៅពេលបន្តលើកកម្ពស់ជាន់ថ្នាក់, លោកអ្នកនិយាយចេញមួយប្រយោគគឺមាននាំថាមពលជាមួយ, លោកអ្នកនឹងដាក់កម្រិតមនុស្សសាមញ្ញ, ប៉ុន្តែមិនអាចនិយាយផ្ដេសផ្ដាស់។ ពិសេសនៅពេលដែលលោកអ្នកមើលមិនឃើញសេចក្ដីពិតនៃបញ្ហា, នៅពេលដែលមើលមិនឃើញទំនាក់ទំនងបានកំណត់ទុកជាមុន, នឹងងាយស្រួលធ្វើរឿងអាក្រក់, នឹងងាយស្រួលសាងកម្ម។

## ២. រំលាយកម្ម

ច្បាប់នៃលោកីយ៍ដូចគ្នានឹងច្បាប់នៃឋានសួគ៌, អ្វីដែលជំពាក់

អ្នកដទៃគឺត្រូវតែសង, សូម្បីតែអ្វីដែលមនុស្សសាមញ្ញជំពាក់អ្នកដទៃក៏ត្រូវតែសងផងដែរ។ មនុស្សរស់មួយឆាកជីវិត, ការលំបាក និងវិនាសដែលលោកអ្នកបានជួប, សុទ្ធតែជាផលវិបាកដែលអំណាចកម្មបង្កើតចេញ, លោកអ្នកត្រូវតែសងអ្វីទាំងនោះ។ មនុស្សដែលបួសហាត់ពិតប្រាកដពួកយើង, ផ្លូវនៃខ្សែជីវិតរបស់លោកអ្នកនឹងផ្លាស់ប្ដូរ, ត្រូវតែរៀបចំសាជាថ្មីប្រភេទផ្លូវមួយដែលសមស្របសម្រាប់ការបួសហាត់របស់លោកអ្នក, អំណាចកម្មនោះរបស់លោកអ្នកបានកាត់បន្ថយចុះមួយផ្នែកដោយលោកគ្រូ, ផ្នែកដែលនៅសល់ជាក់ស្ដែងគឺបានប្រើដើម្បីលើកកម្ពស់ចិត្តគំនិតឱ្យលោកអ្នក, លោកអ្នកខ្លួនឯងតាមរយៈការហាត់គង់និងបួសហាត់ចិត្តគំនិតបានដោះដូរវាបាត់ទៅ, សងបាត់ទៅ។ ចាប់ពីពេលនេះទៅបញ្ហាដែលអ្នករាល់គ្នាជួបប្រទះសុទ្ធតែមិនមែនការចៃដន្យ, សូមអ្នករាល់គ្នាត្រូវមានការត្រៀមមនោគតិមួយនេះ។ អនុញ្ញាតឱ្យលោកអ្នកឆ្លងផុតការលំបាកទាំងនេះ, អ្វីដែលមនុស្សសាមញ្ញបោះបង់ចោលមិនបានទាំងស្រុងអនុញ្ញាតឱ្យលោកអ្នកបោះបង់ចោល។ លោកអ្នកនឹងជួបប្រទះរឿងរំខានជាច្រើន, បញ្ហាអាចមកអំពីគ្រួសារ, សង្គមគ្រប់ទិដ្ឋភាពបង្កើតចេញមក; ឬក៏ភ្លាមៗជួបប្រទះគ្រោះថ្នាក់អ្វីមួយ; សូម្បីតែដើមឡើយគឺភាគីម្ខាងទៀតមិនល្អ, ប៉ុន្តែផ្ទុយមកវិញការស្ដីបន្ទោស, ភាពអយុត្តិធម៌បានដាក់លើខ្លួនលោកអ្នក, ជាដើម។ មនុស្សហាត់គង់គឺមិនគួរកើតមានជំងឺ, ប៉ុន្តែជាធម្មតាក៏ស្រាប់តែកើតជំងឺធ្ងន់, ការមកនៃជំងឺធ្ងន់ធ្ងរណាស់, ធ្វើ

ទារុណកម្មពិបាកទ្រាំណាស់, ដល់មន្ទីរពេទ្យពិនិត្យក៏ពិនិត្យមិនចេញជំងឺ, ប៉ុន្តែមិនដឹងហេតុអ្វីជំងឺមិនទាន់ព្យាបាលផងក៏ជាសះស្បើយរួចហើយ, តាមពិតទៅជាក់ស្ដែងគឺប្រភេទបំណុលអ្វីមួយដែលលោកអ្នកជំពាក់តាមរយៈទម្រង់ប្រភេទនេះបានសងរួចហើយ។ ប្រហែលជាមានថ្ងៃមួយ, គូស្នេហ៍របស់លោកអ្នកដោយគ្មានហេតុផលបានបង្កបញ្ហា, ឆាប់ខឹងជាមួយលោកអ្នក, រឿងរ៉ាវតូចតាចក៏អាចបង្កឱ្យមានជម្លោះធំផងដែរ, ក្រោយមកក៏មានអារម្មណ៍ថាចម្លែកមិនអាចពន្យល់។ ធ្វើជាមនុស្សហាត់គង់លោកអ្នកគួរតែច្បាស់លាស់ហេតុអ្វីបានជាកើតចេញរឿងរ៉ាវនោះ, ជាក់ស្ដែងគឺរបស់នោះមក, តម្រូវឱ្យលោកអ្នកសងកម្មនោះ។ នៅពេលនេះលោកអ្នកត្រូវតែទប់ជាប់ខ្លួនឯង, ឃាត់ជាប់ចិត្តគំនិតដោះស្រាយរឿងរ៉ាវនោះ, ឱ្យតម្លៃនិងអរគុណដល់គាត់ដែលបានជួយលោកអ្នករំលាយកម្ម។

អង្គុយសមាធិរយៈពេលយូរជាក់ស្ដែងនឹងឈឺជើង, មនុស្សខ្លះឈឺដូចស្លាប់ទៅរស់ឡើងវិញ។ មនុស្សដែលមានជាន់ថ្នាក់បញ្ញាញាណខ្ពស់មើលឃើញថា, នៅពេលកំពុងឈឺដ៏ខ្លាំង, ពីខាងក្នុងនិងខាងក្រៅរាងកាយមនុស្សហាត់គង់មានរបស់ពណ៌ខ្មៅមួយដុំដ៏ធំកំពុងធ្លាក់ចុះរំលាយបាត់ទៅ។ ភាពឈឺចាប់នៃការអង្គុយសមាធិគឺឈឺមួយលើកៗថែមទាំងពិបាកទ្រាំក្នុងចិត្តណាស់, មនុស្សខ្លះមានការភ្ញាក់ដឹង, នោះគឺមិនយកជើងចេញ, (សារធាតុ)ពណ៌ខ្មៅដែលរំលាយទៅជាក់ស្ដែងផ្លាស់ប្ដូរទៅជាពណ៌ស, បំលែងទៅជា

គង់។ អំណាចកម្មរបស់មនុស្សហាត់គង់មិនអាចតាមរយៈការអង្គុយសមាធិនិងហាត់គង់រំលាយបាត់ទៅទាំងស្រុងបានទេ, នៅត្រូវតែលើកកម្ពស់ចិត្តគំនិតនិងការភ្ញាក់ដឹង, ឆ្លងកាត់និងរងទុក្ខវេទនាមួយចំនួន។ ដែលសំខាន់គឺពួកយើងធ្វើមនុស្សត្រូវមានសប្បុរសធម៌, ចិត្តករុណាក្នុងហ្វាលូនគង់ពួកយើងផុសចេញមកឆាប់ណាស់, មនុស្សជាច្រើនមកទីនោះហាត់គង់អង្គុយភ្លាម, ស្រក់ទឹកភ្នែកគ្មានឈ្មោះ, គិតដល់អ្វីចិត្តក៏សោកសៅ, ឃើញនរណាក៏រងទុក្ខ, ជាក់ស្តែងបានកើតចេញចិត្តមេត្តាមកហើយ, ធម្មជាតិរបស់លោកអ្នក, `ខ្លួនឯង´ ពិតប្រាកដរបស់លោកអ្នកចាប់ផ្តើមទំនាក់ទំនងជាមួយលក្ខណៈពិសេស "សច្ចៈ-ករុណា-ខន្តី" នៃចក្រវាល។ នៅពេលដែលចិត្តករុណារបស់លោកអ្នកផុសចេញមក, លោកអ្នកធ្វើរឿងជាក់ស្តែងករុណាណាស់។ ពីក្នុងចិត្តរបស់លោកអ្នកដល់ខាងក្រៅកំពុងបង្ហាញ, មើលឃើញភ្លាមគឺសប្បុរសធម៌ណាស់, នៅពេលនោះនរណាក៏មិនហ៊ានមើលងាយលោកអ្នកផងដែរ។ នៅពេលនោះមានមនុស្សពិតជាមើលងាយលោកអ្នក, ចិត្តមហាមេត្តានោះរបស់លោកអ្នកចាប់ផ្តើមដំណើការ, លោកអ្នកនឹងមិនសងដៃ, វាគឺជាមួយប្រភេទអំណាច, វាក៏ជំរុញលោកអ្នកដើម្បីនឹងមិនដូចជាមនុស្សសាមញ្ញ។

នៅពេលដែលលោកអ្នកជួបប្រទះគ្រោះមហន្តរាយ, ចិត្តមេត្តានោះនឹងជួយលោកអ្នកឆ្លងផុតទ្វារពិបាក, ក្នុងពេលដំណាលគ្នាបរមីរបស់ខ្ញុំមើលថៃនិងការពារលោកអ្នក, ការពារជីវិតរបស់លោក

អ្នក, ប៉ុន្តែការលំបាកត្រូវតែអនុញ្ញាតឱ្យលោកអ្នកឆ្លងបាន។ ឧបមាពេលខ្ញុំនៅថៃយានបើកថ្នាក់បង្រៀនមានមួយគូប្តីប្រពន្ធចាស់មកចូលរួមថ្នាក់បង្រៀនរបស់ខ្ញុំប្រញាប់ឆ្លងផ្លូវ, ពេលដើរនៅពាក់កណ្តាលផ្លូវ, ឡានតូចមួយគ្រឿងបានរត់មកដល់, បើកបរយ៉ាងលឿន, ភ្លាមៗនោះបានសម្រុកដួលនិងព្យួរស្ត្រីចំណាស់ទៅតាម, ព្យួរចេញទៅឆ្ងាយជាង១០ម៉ែត្រ, ធ្លាក់ចុះនៅលើផ្លូវ។ រថយន្តតូចបើករត់ជាង២០ម៉ែត្រទៀតទើបឈប់។ អ្នកបើកបរបានលោតចេញពីឡានហើយនិយាយពាក្យសម្តីមិនល្អស្តាប់មួយចំនួន; មនុស្សដែលអង្គុយក្នុងឡានក៏និយាយពាក្យសម្តីមិនល្អស្តាប់មួយចំនួនផងដែរ។ ស្ត្រីចំណាស់អ្វីក៏មិននិយាយ, នៅពេលនោះនឹកដល់ពាក្យដែលខ្ញុំបានសម្តែង, បន្ទាប់ពីក្រោកឈរឡើង, ស្ត្រីចំណាស់និយាយថា៖ ‵គ្មានអ្វីទេ, គ្មានអ្វីទេ, កន្លែងណាក៏គ្មានអ្វីទាំងអស់′, គាត់បានទាញលោកប្តីជាមួយគ្នាចូលក្នុងសាវនដ្ឋាន។ ប្រសិនបើពេលនោះគាត់និយាយមួយប្រយោគ៖ ‵អូយ៉ា! ខ្ញុំកន្លែងនេះខូចហើយ, កន្លែងនោះខូចហើយ, លោកនាំខ្ញុំចូលមន្ទីរពេទ្យទៅ′។ នោះគឺពិតជាខូចហើយ, ប៉ុន្តែគាត់មិនធ្វើដូច្នោះ។ ស្ត្រីចំណាស់និយាយជាមួយខ្ញុំថា៖ ‵លោកគ្រូ, កូនដឹងគឺជារឿងដូចម្តេច, រឿងនេះគឺជួយកូនរំលាយកម្មទេតើ! លុបបំបាត់គ្រោះមួយធំ, រំលាយកម្មមួយដុំធំ′។ ប៉ុន្តែគិតអំពីចិត្តគំនិត, ការភ្ញាក់ដឹងរបស់គាត់ល្អណាស់, អាយុធំដូច្នោះ, ល្បឿនឡានលឿនដូច្នោះ, ព្យួរទៅឆ្ងាយដូច្នោះ, ដួលទៅនឹងដីយ៉ាងខ្លាំង, ក្រោកឡើងហើយ, ចិត្ត

សុចរិតណាស់។

ពេលខ្លះនៅពេលគ្រោះមហន្តរាយមកដល់, មើលទៅធំខ្លាំងណាស់, ជាធម្មតាគឺគិតដូចម្តេចក៏គ្មានផ្លូវ។ ប្រហែលជាកន្លងទៅរយៈពេលប៉ុន្មានថ្ងៃ, ភ្លាមៗនោះមានផ្លូវចេញ, ភ្លាមៗនោះរឿងរ៉ាវបានកើតឡើងការផ្លាស់ប្តូរធំ, តាមពិតទៅគឺចិត្តគំនិតរបស់ពួកយើងលើកកម្ពស់រួចហើយ, របស់នោះក៏រំលាយទៅដោយធម្មជាតិ។

ចង់លើកកម្ពស់វិស័យនៃមនោគតិជាក់ស្តែងចាំបាច់ត្រូវឆ្លងកាត់សាកល្បងគ្រប់ប្រភេទនៃទុក្ខវេទនាក្នុងលោកីយ៍, នៅក្នុងដំណើរការនេះចិត្តគំនិតលោកអ្នកពិតជាឡើងទៅរួចហើយ, មានស្មោះភាពរួចហើយ, កម្មក៏រំលាយរួចហើយ, ទុក្ខវេទនារបស់លោកអ្នកក៏បានកន្លងទៅរួចហើយ, គង់ក៏បង្កើនរួចហើយ។ ប្រសិនបើនៅក្នុងឱកាសសាកល្បងចិត្តគំនិត, គ្មានរក្សាជាប់ចិត្តគំនិត, ធ្វើរឿងខុសឆ្គង, នៅពេលនេះលោកអ្នកកុំធ្លាក់ទឹកចិត្ត, ត្រូវតែសង្ខេបយ៉ាងសកម្មអំពីមេរៀននោះ, ស្វែងរកគម្លាត, ខិតខំបន្ថែមនៅលើ "សច្ចៈ-ករុណា-ខន្តី"។ បញ្ហាពិបាកបន្ទាប់នៃការត្រួតពិនិត្យចិត្តគំនិតអាចម្តងទៀតនឹងមកដល់ជាបន្តបន្ទាប់។ ជាមួយនឹងការលើកកម្ពស់នៃអំណាចគង់, ទុក្ខវេទនាដើម្បីសាកល្បងចិត្តគំនិតអាចមកដល់កាន់តែសាហាវ, កាន់តែភ្លាមៗ។ រាល់ពេលដែលលោកអ្នកឆ្លងមួយទ្វារអំណាចគង់នឹងកើនឡើងបន្តិច; ទ្វារឆ្លងកាត់មិនបានគង់នឹងជាប់គាំង។ សាកល្បងតូចបង្កើនតិច; សាកល្បងធំបង្កើន

ច្រើន។ សង្ឃឹមថាមនុស្សហាត់គង់គ្រប់រូបនឹងត្រៀមខ្លួនដើម្បីរង ទុក្ខធំ, ត្រូវមានការប្ដេជ្ញាចិត្តនិងការតស៊ូដើម្បីប្រឈមនឹងការលំបាកធំ។ គ្មានចំណាយនឹងមិនទទួលបានគង់ពិតប្រាកដ។ ចង់មានផាសុខភាពដោយមិនចំណាយ, មិនរងទុក្ខហើយទទួលបានគង់, គឺគ្មានគោលសីលធម៌នេះទេ។ ចិត្តគំនិតមិនប្រែទៅជាល្អជាមូលដ្ឋាន, នាំយកចិត្តប្រកាន់ឯកជនណាមួយគឺបួសមិនបានសម្រេចជាអង្គត្រាស់ដឹងធំឡើយ។

## VII. អន្ទងខ្មោច

អន្ទងខ្មោចគឺសំដៅទៅលើមនុស្សហាត់គង់នៅក្នុងដំណើរការហាត់គង់លេចឡើងបាតុភូតឬក៏ទស្សនីយភាពដែលមានឥទ្ធិពលដល់ការហាត់គង់, គោលបំណងគឺរារាំងមនុស្សហាត់គង់បួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់, ក៏អាចនិយាយថាគឺខ្មោចមកប្រមូលបំណុល។

គង់ហ្វាពេលបួសហាត់ដល់ជាន់ថ្នាក់ខ្ពស់, ជៀសមិនផុតនឹងជួបប្រទះបញ្ហា ‵អន្ទងខ្មោច′។ មួយឆាកជីវិតរបស់មនុស្សម្នាក់និងបុព្វបុរសរបស់គាត់ជៀសមិនផុតនឹងធ្លាប់បានធ្វើរឿងមិនល្អមួយចំនួន, រឿងមិនល្អទាំងនេះបានហៅថាអំណាចកម្ម។ ‵និស្ស័យ′ របស់មនុស្សម្នាក់ល្អឬក៏មិនល្អ, នឹងកំណត់អំណាចកម្មដែលគាត់នាំតាមច្រើនឬតិច, សូម្បីតែមនុស្សដ៏ល្អម្នាក់, ក៏មិនអាចគ្មានអំណាចកម្មផងដែរ។ ដោយសារលោកអ្នកមិនបួសហាត់, ដូច្នេះលោកអ្នកមិនអាចយល់ដឹងបាន។ ប្រសិនបើលោកអ្នកគ្រាន់តែ

ដើម្បីព្យាបាលជំងឺកាយសម្បទា, នឹងមិនមានខ្មោចមកគ្រប់គ្រងលោកអ្នក, ពេលដែលលោកអ្នកបួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់, វានឹងចង់គ្រប់គ្រងលោកអ្នក។ វាអាចប្រើគ្រប់ប្រភេទវិធីសាស្រ្តដើម្បីជ្រៀតជ្រែកលោកអ្នក, គោលបំណងគឺមិនអនុញ្ញាតឱ្យលោកអ្នកបួសហាត់ឡើងលើជាន់ថ្នាក់ខ្ពស់, បណ្ដាលឱ្យលោកអ្នកបួសហាត់មិនបានសម្រេច។ វិធីសាស្រ្តដែលខ្មោចលេចឡើងមានច្រើនប្រភេទ, មានខ្លះគឺលេចឡើងជាបាតុភូតនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកយើង; មានខ្លះគឺជាទម្រង់ព័ត៌មានដែលមកពីអវកាសផ្សេងដើម្បីធ្វើការជ្រៀតជ្រែត, បណ្ដាលឱ្យលោកអ្នកដរាបណាអង្គុយចុះសមាធិនឹងមានប្រភេទរឿងអ្វីមួយមកជ្រៀតជ្រែក, ធ្វើឱ្យលោកអ្នកមិនអាចចូលទៅក្នុងស្ងប់, គ្មានផ្លូវបួសឡើងលើជាន់ថ្នាក់ខ្ពស់បាន; ពេលខ្លះដរាបណាលោកអ្នកអង្គុយសមាធិនឹងចង់គេងលក់ឬក៏ស្រមើស្រមៃ, មិនអាចចូលទៅក្នុងស្ថានភាពហាត់គង់បាន, ពេលខ្លះដរាបណាលោកអ្នកហាត់គង់, ដើមឡើយជាបរិយាកាសស្ងប់ស្ងាត់ណាស់, ស្រាប់តែសូរសម្លេងបោះជំហានមកដល់, សម្លេងរុញទ្វារ, សម្លេងស៊ីផ្លេរថយន្ត, ទូរស័ព្ទជ្រៀតជ្រែក, សម្លេងរំខានគ្រប់ប្រភេទ, ធ្វើឱ្យលោកអ្នកស្ងប់ចុះមិនបាន។

នៅមានមួយប្រភេទទៀតគឺខ្មោច ‘សម្រស់’, មនុស្សហាត់គង់នៅពេលអង្គុយសមាធិឬក៏ក្នុងសុបិន្ត, នៅចំពោះមុខគាត់នឹងលេចឡើងបុរសស្អាតឬក៏នារីស្អាត, ទាក់ទាញលោកអ្នកលួងលោមលោកអ្នក, ធ្វើចលនាមួយចំនួនសម្រើបផ្លូវភេទរបស់លោក

អ្នក, លួងលោមចិត្តលោភលន់ស្រឡាញ់សម្រស់របស់លោកអ្នក។ ដរាបណាលោកអ្នកមិនអាចឆ្លងកាត់បានម្តង, វានឹងកើនឡើងជាលំដាប់, លួងលោមលោកអ្នក, រហូតដល់លោកអ្នកបោះបង់គំនិតនៃការបួសឡើងលើជាន់ថ្នាក់ខ្ពស់ទើបឈប់។ ទ្វារមួយនេះគឺពិបាកឆ្លងកាត់ណាស់, មនុស្សហាត់គង់ជាច្រើនដោយសារតែរឿងនេះដែលបានបញ្ចប់ភ្លាមៗ។ សង្ឃឹមថាអ្នកទាំងអស់គ្នានឹងមានការរៀបចំស្មារតី, ប្រសិនបើមនុស្សខ្លះរក្សាចិត្តគំនិតមិនគ្រប់, ម្តងឆ្លងកាត់មិនបានត្រូវតែសង្ខេបឱ្យបានហ្មត់ចត់មេរៀននេះ, វានឹងមកយាយីលោកអ្នកច្រើនដង, រហូតដល់លោកអ្នកពិតជារក្សាជាប់ចិត្តគំនិត, កម្ចាត់ទាំងស្រុងចិត្តប្រកាន់ប្រភេទនោះទើបឈប់។ នេះគឺជាទ្វារមួយធំ, ចាំបាច់ត្រូវតែឆ្លងកាត់, បើមិនដូច្នេះទេជាក់ស្តែងមិនអាចសម្រេចធម៌, មិនអាចបួសសម្រេច។

មួយប្រភេទទម្រង់ផ្សេងទៀតរបស់ខ្មោចគឺនៅពេលហាត់គង់ឬក៏ក្នុងសុបិន្ត, ភ្លាមៗនោះបានមើលឃើញមុខគួរឱ្យខ្លាចមួយចំនួន, សាហាវណាស់, ពិតប្រាកដណាស់, ឬក៏កាន់ដាវចង់សម្លាប់មនុស្ស, ប៉ុន្តែវាគ្រាន់តែបំភ័យមនុស្ស, វាពិតជាកាត់ក៏កាត់មិនបាន, ដោយសារតែលោកគ្រូបានដាក់ខែលការពារនៅក្រៅរាងកាយរបស់មនុស្សហាត់គង់ឱ្យគាត់រួចហើយ, កាត់មិនដល់។ គោលបំណងដែលវាបំភ័យមនុស្សគឺមិនអនុញ្ញាតឱ្យលោកអ្នកហាត់គង់បាន។ អ្វីទាំងនេះសុទ្ធតែជាការបង្ហាញនៃមួយជាន់ថ្នាក់, មួយដំណាក់កាល, យ៉ាងឆាប់រហ័សនឹងលោតរំលង, ពីរបីថ្ងៃ, មួយ

សប្តាហ៍ឬក៏ពីរបីសប្តាហ៍។ ដើម្បីមើលថាតើចិត្តគំនិតខ្ពស់ប៉ុណ្ណា, មើលថាតើចំពោះរឿងរ៉ាវមួយនេះលោកអ្នកយល់ឃើញនិងទប់ទល់ដូចម្តេច។

## VIII. និស្ស័យនិងភ្ញាក់ដឹង

‵និស្ស័យ′ គឺសំដៅទៅលើសារធាតុពណ៌សដែលមនុស្សម្នាក់នាំមកពីកំណើត, ជាក់ស្តែងគឺជាគុណធម៌, ប្រភេទសារធាតុមានសរីរាង្គនេះ, នាំមកច្រើនរួចហើយនិស្ស័យជាការពិតជាក់ស្តែងល្អ។ មនុស្សដែលមាននិស្ស័យល្អងាយស្រួលត្រឡប់មកសច្ចៈ, ងាយស្រួលយល់ដឹងតាវ, ដោយសារតែមនោគតិរបស់គាត់គ្មានឧបសគ្គ, ដរាបណាបានស្តាប់អំពីរៀនឈីគង់, ដរាបណាបានស្តាប់អំពីអ្វីនៃការបួសហាត់, គាត់នឹងបង្កើតចេញចំណាប់អារម្មណ៍, គាត់នឹងស្ម័គ្រចិត្តដើម្បីរៀន, អាចទំនាក់ទំនងជាមួយនឹងចក្រវាល។ ដូចដែលឡៅជឺបាននិយាយថា៖ ‶វត្តីលំដាប់លើស្តាប់តាវ, ឧស្សាហ៍ព្យាយាមធ្វើឱ្យបាន; វត្តីលំដាប់កណ្តាលស្តាប់តាវ, ភ្លេចនៅភ្លេចបាត់; វត្តីលំដាប់ក្រោមស្តាប់តាវ, មហាសំណើច, មិនសើចមិនគ្រប់ហៅថាតាវ″។ មនុស្សដែលងាយស្រួលត្រឡប់មកសច្ចៈនិងភ្ញាក់ដឹងតាវគឺជា ‶វត្តីលំដាប់លើ″។ ផ្ទុយមកវិញ, មនុស្សដែលមានសារធាតុពណ៌ខ្មៅច្រើន, មនុស្សដែលនិស្ស័យទាបនៅខាងក្រៅរាងកាយរបស់គាត់បង្កើតឡើងមួយប្រភេទរបាំង, ធ្វើឱ្យគាត់មិនអាចទទួលយកអ្វីដែលល្អ។ ប្រសិនបើនៅពេលដែលមានទំនាក់ទំនងជាមួយអ្វីដែលល្អ, វានឹងជំរុញធ្វើឱ្យគាត់មិនជឿ, តាម

ពិតទៅនេះគឺជាផលប៉ះពាល់របស់អំណាចកម្ម។

និយាយអំពី `និស្ស័យ´ ជៀសមិនផុតការពាក់ព័ន្ធដល់បញ្ហា `ភ្ជាក់ដឹង´។ ដរាបណានិយាយដល់ `ភ្ជាក់ដឹង´, មនុស្សខ្លះនឹងសន្មត ថាភ្ជាក់ដឹងជាក់ស្ដែងគឺជាឆ្លាតវៃ។ មនុស្សដែលឆ្លាតវៃ, កលល្បិច ដែលមនុស្សសាមញ្ញនិយាយភាពពិតចាកខុសគ្នាឆ្ងាយណាស់ពី ការបួសហាត់ដែលពួកយើងបានសម្ដែង, មនុស្សឆ្លាតវៃប្រភេទនេះ ជាធម្មតាមិនងាយស្រួលត្រាស់ដឹង, គាត់គ្រាន់តែឱ្យតម្លៃពិភព លោកនៃសម្ភារៈប្រាកដនិយម, អ្វីក៏មិនរងទុក្ខ, អ្វីមានគុណសម្បត្តិ សុទ្ធតែមិនដោះលែង។ ជាពិសេសគឺមានមនុស្សដោយឡែក, សន្មតខ្លួនឯងថាមានការអប់រំខ្ពស់, មានចំណេះដឹង, ឆ្លាតវៃ ណាស់, មើលការបួសហាត់គឺជារឿងព្រេងនិទាន។ ហាត់គង់បួស ចិត្តគំនិត, សម្រាប់គាត់មិនគួរឱ្យជឿ, សន្មតថាមនុស្សហាត់គង់ សុទ្ធតែជាអ្នកល្ងង់ខ្លៅ, ជាអបិយជំនឿ។ `ភ្ជាក់ដឹង´ ដែលពួកយើង សម្ដែង, មិនមែនសំដៅទៅលើឆ្លាតវៃ, ប៉ុន្តែគឺសំដៅទៅលើភាពត្រ ឡប់មកសច្ចៈរបស់ចរិតមនុស្ស, ធ្វើជាមនុស្សល្អមួយរូប, ស្រប តាមលក្ខណៈពិសេសនៃចក្រវាល។ និស្ស័យសម្រេចភ្ជាក់ដឹង របស់មនុស្សម្នាក់, និស្ស័យល្អ, ភ្ជាក់ដឹងក៏នឹងល្អផងដែរ។ និស្ស័យ សម្រេចភ្ជាក់ដឹង, ភ្ជាក់ដឹងក៏មិនទទួលរងការដាក់កម្រិតទាំងស្រុង របស់និស្ស័យ។ និស្ស័យទោះបីល្អប៉ុណ្ណា, ប៉ុន្តែការយល់ដឹងខ្សោយ , ភ្ជាក់ដឹងមិនដល់ក៏មិនបាន។ មនុស្សខ្លះនិស្ស័យមិនល្អណាស់ទេ, ប៉ុន្តែគាត់ភ្ជាក់ដឹងបានល្អ, ជាក់ស្ដែងអាចបួសឡើងលើ។ ពួកយើង

គឺ ‵ប្រោសសត្វលោកទាំងឡាយ′, មើលភ្ជាក់ដឹងមិនមើលនិស្ស័យ។ ទោះបីលោកអ្នកនាំតាមអ្វីមិនល្អយ៉ាងច្រើន, ឱ្យតែលោកអ្នកមានការប្ដេជ្ញាចិត្តបួសឡើងលើ, គំនិតមួយនេះរបស់លោកអ្នកផុសចេញជាក់ស្ដែងគឺជាគំនិតសុចរិត។ មានគំនិតនេះ, លោកអ្នកក៏គ្រាន់តែចំណាយច្រើនជាងមនុស្សដទៃបន្តិច, ទីបំផុតនៅតែអាចបួសសម្រេចបាន។

រាងកាយរបស់មនុស្សហាត់គង់គឺបរិសុទ្ធរួចទៅហើយ, បន្ទាប់ពីបញ្ចេញគង់ហើយរាងកាយគឺមិនអាចមានជំងឺទៀត, ដោយសារតែសារធាតុថាមពលខ្ពស់នៅខាងក្នុងរាងកាយលែងអនុញ្ញាតឱ្យសារធាតុពណ៌ខ្មៅស្ថិតនៅទៀតហើយ។ ប៉ុន្តែមនុស្សខ្លះជាក់ស្ដែងគឺមិនជឿ, តែងតែគិតថាខ្លួនឯងមានជំងឺ, និយាយថា ‵ហេតុអ្វីខ្ញុំពិបាកទ្រាំយ៉ាងនេះ!′ ពួកយើងនិយាយថាអ្វីដែលលោកអ្នកទទួលបានគឺជាគង់, លោកអ្នកទទួលបានប្រការល្អដូច្នោះ, តើនៅតែមិនស្រួលមែនទេ? បួសហាត់តើ, ជាក់ស្ដែងគឺត្រូវចំណាយសមតាមនោះ។ តាមពិតទៅនោះគឺសុទ្ធតែជាអ្វីនៅសម្បកក្រៅ, គ្មានឥទ្ធិពលបន្តិចលើរាងកាយរបស់លោកអ្នក, មើលទៅហាក់ដូចជាជំងឺ, ជាមូលដ្ឋានជាក់ស្ដែងមិនមែនជំងឺ, ជាក់ស្ដែងពឹងផ្អែកលើលោកអ្នកខ្លួនឯងដើម្បីភ្ញាក់ដឹង។ មនុស្សហាត់គង់មិនត្រឹមតែត្រូវរងទុក្ខក្នុងទុក្ខប៉ុណ្ណោះទេ, នៅត្រូវមានការភ្ញាក់ដឹងល្អ។ មនុស្សខ្លះជួបប្រទះរឿងរំខាននៅតែមិនភ្ញាក់ដឹង, ខ្ញុំនៅទីនេះសម្ដែងជាន់ថ្នាក់ខ្ពស់, ធ្វើដូចម្ដេចបរមាណើយខ្ពស់តម្រូវខ្លួនឯង, ប៉ុន្តែគាត់នៅតែ

ច្រទង្វាំជាមួយនឹងមនុស្សសាមញ្ញ, គាត់សូម្បីតែមិនអាចដាក់ខ្លួនឯងនៅស្ថានភាពនៃមនុស្សហាត់គង់ពិតប្រាកដដើម្បីហាត់គង់, ក៏មិនជឿថាខ្លួនឯងនឹងនៅជាន់ថ្នាក់ខ្ពស់។

ជាន់ថ្នាក់ខ្ពស់សម្ដែងភ្ញាក់ដឹងគឺសំដៅទៅលើត្រាស់ដឹង។ ភ្ញាក់ដឹង, មានបែងចែកជាភ្ញាក់ដឹងភ្លាមនិងភ្ញាក់ដឹងបន្តិចម្ដងៗ។ ភ្ញាក់ដឹងភ្លាមគឺសំដៅទៅលើដំណើរការបួសហាត់ទាំងមូលសុទ្ធតែហាត់ដោយត្រូវបានចាក់សោរ។ បន្ទាប់ពីលោកអ្នកបញ្ចប់ដំណើរការបួសហាត់រួចហើយ, បន្ទាប់ពីចិត្តគំនិតទទួលបានការលើកកម្ពស់រួចហើយ, ដល់ទីបញ្ចប់ភ្លាមៗ, សីលគង់ទាំងអស់បំផ្ទុះចេញមក, បញ្ញាញាណភ្លាមៗបើកដល់ជាន់ថ្នាក់ខ្ពស់បំផុត, ផ្ទត់គំនិតអាចទំនាក់ទំនងជាមួយនឹងជីវិតជាន់ខ្ពស់នៅអវកាសផ្សេងទៀត, ភ្លាមៗនោះមើលឃើញសេចក្ដីពិតនៃបណ្ដាអវកាសនិងបណ្ដាពិភពឯកតាក្នុងចក្រវាលទាំងមូល, និងមានទំនាក់ទំនងជាមួយនឹងពួកគេ, អាចបង្ហាញបានមហាទេពអំណាច។ ភ្ញាក់ដឹងភ្លាមផ្លូវមួយនេះពិបាកដើរបំផុត, គ្រប់ជំនាន់គឺសុទ្ធតែជ្រើសរើសមនុស្សដែលមាននិស្ស័យយ៉ាងខ្ពស់ធ្វើជាសិស្ស, គ្រប់ជំនាន់គឺសុទ្ធតែគង់ហ្វាបង្រៀនឯកតា។ មនុស្សសាមញ្ញម្នាក់មិនអាចទ្រាំបានទេ! ខ្ញុំគឺបានដើរផ្លូវភ្ញាក់ដឹងភ្លាមមួយនេះ។

ឥឡូវនេះអ្វីដែលខ្ញុំបង្រៀនឱ្យអ្នករាល់គ្នាគឺជារបស់ភ្ញាក់ដឹងបន្តិចម្ដងៗ។ វានៅក្នុងដំណើរការបួសហាត់, គួរបញ្ចេញសីលគង់អ្វីនឹងបញ្ចេញសីលគង់នោះ, ប៉ុន្តែក៏មិនមែនដាច់ខាតថាបញ្ចេញ

សីលគង់រួចហើយជាក់ស្ដែងផ្ដល់ឱ្យលោកអ្នកប្រើ។ នៅពេលចិត្តគំនិតរបស់លោកអ្នកនៅមិនទាន់ឈានដល់ជាន់ថ្នាក់ជាក់លាក់, មិនទប់ជាប់ខ្លួនឯងបាន, ងាយស្រួលធ្វើរឿងអាក្រក់, សីលគង់បណ្ដោះអាសន្នមិនផ្ដល់ឱ្យលោកអ្នកប្រើ, ប៉ុន្តែទីបញ្ចប់នឹងផ្ដល់ឱ្យលោកអ្នក។ តាមរយៈការប្ញសហាត់, ជាន់ថ្នាក់នឹងលើកកម្ពស់បន្តិចម្ដងៗ, បន្តិចម្ដងៗយល់ដឹងសេចក្ដីពិតនៃចក្រវាល, ក៏ដូចគ្នានឹងការភ្ញាក់ដឹងភ្លាម, ចុងក្រោយសម្រេចបានត្រាស់ដឹងពេញលេញ។ ផ្លូវភ្ញាក់ដឹងបន្តិចម្ដងៗមួយនេះងាយស្រួលដើរជាង, មិនមានគ្រោះថ្នាក់ទេ។ ដែលពិបាកគឺដំណើរការប្ញសហាត់លោកអ្នកសុទ្ធតែមើលឃើញទាំងអស់, លោកអ្នកគួរតែតឹងរឹងតម្រូវខ្លួនឯងជាងនេះ។

## IX. ចិត្តស្ងប់ស្ងាត់

មនុស្សមួយចំនួនហាត់គង់ស្ងប់ចុះមិនបាន, កំពុងមើលរកវិធីសាស្ត្រចូលទៅក្នុងស្ងប់។ មនុស្សខ្លះសួរខ្ញុំថា៖ 'លោកគ្រូ, កូនហាត់គង់ហេតុអ្វីស្ងប់ចុះមិនបាន។ លោកគ្រូបង្រៀនឱ្យកូនវិធីសាស្ត្រអ្វីមួយ, ជ្រើសប្រើបច្ចេកទេសអ្វីមួយ, ធ្វើឱ្យកូនអង្គុយសមាធិអាចស្ងប់ចុះបាន'។ ខ្ញុំនិយាយថាលោកអ្នកធ្វើដូចម្ដេចស្ងប់ចុះបានទៅ! ព្រះអាទិទេពមកបង្រៀនលោកអ្នកវិធីសាស្ត្រលោកអ្នកក៏ស្ងប់ចុះមិនបានផងដែរ។ ហេតុអ្វីទៅ? ដោយសារតែខ្លួនលោកអ្នកផ្ទាល់ចិត្តមិនស្ងប់ស្ងាត់។ មនុស្សរស់នៅក្នុងសង្គមមួយនេះ, ស្នេហា៧តណ្ហា៦, ផលប្រយោជន៍ឯកជនគ្រប់ទិដ្ឋភាព,

ដែលជារបស់ខ្លួនឯងផ្ទាល់សូម្បីតែជារបស់សាច់ញាតិនិងមិត្តភក្តិលោកអ្នកសុទ្ធតែព្យួរនៅក្នុងចិត្ត, កាន់កាប់សមាមាត្រធំខ្លាំងណាស់ក្នុងខួរក្បាល, ដាក់នៅទីតាំងយ៉ាងខ្ពស់, តើនៅពេលអង្គុយហាត់គង់អាចស្ងប់ចុះបានទេ? ដោយចេតនាទៅបង្រ្កាបវា, ហើយវាបានបត់ចេញក្រៅដោយខ្លួនឯង។

ក្នុងធម៌បួសនៃពុទ្ធសាសនាសម្តែង "សីល-សមាធិ-បញ្ញា"។ សីល, ជាក់ស្តែងគឺត្រូវបោះបង់ចោលអ្វីនៃការប្រកាន់ទាំងនោះ។ មនុស្សខ្លះជ្រើសប្រើសូត្រធម៌, ត្រូវតែចិត្តមួយមិនរឹករវរដើម្បីសូត្រ, ធ្វើឱ្យមនោគតិរបស់ខ្លួនឯងឈានដល់ស្ថានភាពដែលគំនិតមួយតំណាងរាប់ម៉ឺនគំនិត។ ប៉ុន្តែវាគឺជាមួយប្រភេទនៃជំនាញការ, តែមិនមែនមួយប្រភេទនៃវិធីសាស្ត្រ។ មិនជឿលោកអ្នកសូត្រសាកមើលទៅ, ធានាថាក្នុងមាត់សូត្រធម៌, ក្នុងខួរក្បាលវិញមានអ្វីផ្សេងទៀតកំពុងកក្រើកឡើង។ តាំងពីដំបូងឡាម៉ាទីបេបង្រៀនសូត្រព្រះធម៌មួយថ្ងៃត្រូវតែសូត្ររាប់សិបម៉ឺនដង, សូត្រមួយសប្តាហ៍។ សូត្រដល់ងប់ងុលវិលមុខ, ចុងក្រោយក្នុងខួរក្បាលអ្វីក៏គ្មាន, គំនិតមួយតំណាងឱ្យរាប់ម៉ឺនគំនិតរួចហើយ។ នោះគឺជាមួយប្រភេទជំនាញការ, លោកអ្នកមិនប្រាកដធ្វើបានឡើយ។ ក៏មានគង់ហ្វាមួយចំនួនបង្រៀនលោកអ្នកវិធីសាស្ត្រគំនិតរក្សានៅតានធៀន, រាប់លេខ, ឬក៏ភ្នែកមើលវត្ថុជាដើម, តាមពិតទៅវិធីសាស្ត្រទាំងនេះសុទ្ធតែមិនអាចធ្វើឱ្យលោកអ្នកស្ងប់ចុះបានដាច់ខាត។ មនុស្ស

ហាត់គង់ត្រូវតែមានបេះដូងមួយដែលស្ងប់ស្ងាត់, ត្រូវតែលះបង់ជាបណ្ដើរផលប្រយោជន៍ឯកជន, ត្រូវតែលះបង់ចោលចិត្តលោភលន់ចង់បានតណ្ហា។

តាមពិតទៅអាចស្ងប់ចុះបានឬទេ, សមាធិបានឬទេ, ឆ្លុះបញ្ចាំងថាភាពជំនាញការមនុស្សម្នាក់ខ្ពស់ឬទាប, ជាន់ថ្នាក់ខ្ពស់ឬទាប។ អង្គុយចុះភ្លាមនឹងអាចស្ងប់ចុះបាន, នេះគឺជាការបង្ហាញរបស់ជាន់ថ្នាក់។ បណ្ដោះអាសន្នស្ងប់ចុះមិនបាន, ធ្វើមិនទាន់បានកុំប្រញាប់, លោកអ្នកអាចនៅក្នុងដំណើរការបួសហាត់ធ្វើបានបន្តិចម្ដងៗ។ ចិត្តគំនិតគឺលើកកម្ពស់បន្តិចម្ដងៗ, គង់គឺបង្កើនបន្តិចម្ដងៗ។ ប្រសិនបើមិនមើលស្រាលទាំងស្រុងផលប្រយោជន៍និងតណ្ហាឯកជន, គង់គឺមិនអាចបង្កើនឡើងលើបាន។

មនុស្សហាត់គង់គ្រប់ពេលគ្រប់វេលាទាំងអស់ត្រូវតែយកបរមាណីយខ្ពស់ដើម្បីតម្រូវខ្លួនឯង។ គ្រប់ប្រភេទបាតុភូតស្មុគស្មាញក្នុងសង្គម, ជាច្រើនរបស់ដែលថោកទាប, មិនល្អ, អ្វីៗនៃស្នេហា៧តណ្ហា៦, គ្មានពេលវេលាណាដែលមិនជ្រៀតជ្រែកមនុស្សហាត់គង់ឡើយ។ អ្វីៗដែលឃោសនាក្នុងទូរទស្សន៍, ភាពយន្ត, អត្ថបទនិពន្ធសិល្បៈ, វាគឺដឹកនាំលោកអ្នកដើម្បីធ្វើជាអ្នកខ្លាំងក្នុងមនុស្សសាមញ្ញ, ធ្វើជាមនុស្សសាមញ្ញកាន់តែព្រោះអ្វីប្រាកដនិយម។ លោកអ្នកពុះពារមិនផុតអ្វីទាំងនេះ, លោកអ្នកនឹងឃ្លាតឆ្ងាយកាន់តែធំជាមួយនឹងចិត្តគំនិត, អារម្មណ៍របស់មនុស្សហាត់គង់, គង់ដែលលោកអ្នកទទួលបាននឹងកាន់តែតិច។ មនុស្សហាត់គង់ត្រូវតែ

មានតិចឬក៏គ្មានទាក់ទងជាមួយនឹងអ្វីមិនល្អកម្រិតទាបទាំងនោះ, គួរតែធ្វើបាន 'មើលតែមិនឃើញ', 'ស្តាប់តែមិនឮ', មិនរំភើបចិត្តដោយសារតែមនុស្សដទៃ, មិនរំជួលចិត្ត។ ខ្ញុំតែងតែនិយាយ, ចិត្តមនុស្សសាមញ្ញគឺជះឥទ្ធិពលលើខ្ញុំមិនបានទេ, នរណានិយាយថាខ្ញុំល្អ, ខ្ញុំនឹងមិនដោយសារតែហេតុនោះហើយសប្បាយ; នរណាជេរខ្ញុំថាមិនល្អខ្ញុំក៏នឹងមិនដោយសារតែហេតុនោះហើយខឹងសម្បារ។ ការជ្រៀតជ្រែកចិត្តគំនិតរវាងមនុស្សជាមួយគ្នាឬក៏រវាងបណ្តាមនុស្សសាមញ្ញទោះបីធ្ងន់ធ្ងរដល់ណាក៏មិនដំណើការសម្រាប់ខ្ញុំ។ មនុស្សហាត់គង់ត្រូវមើលយ៉ាងស្រាលទាំងអស់ផលប្រយោជន៍ដែលទទួលបាន, អ្វីក៏មិនដាក់នៅក្នុងចិត្ត, នៅពេលនោះចិត្តភ្ញាក់ដឹងតាវរបស់លោកអ្នកទើបបានរាប់ថាគឺប៉ុនប្រសប់។ គ្មានចិត្តបង្ខំចង់បានកេរ្តិ៍ឈ្មោះផលប្រយោជន៍, មើលកត្តិនាម, ផលប្រយោជន៍និងឋានៈដូចជាអ្វីដែលប្រងើយកណ្តើយ, លោកអ្នកនឹងមិនបារម្ភ, មិនខឹង, តែងតែស្ថិតក្នុងស្ថានភាពនៃតុល្យភាពផ្លូវចិត្ត។ ដាក់អ្វីគ្រប់យ៉ាងចុះ, តាមធម្មជាតិជាក់ស្តែងនឹងស្ងប់ស្ងាត់។

ខ្ញុំបានយកមហាធម៌សម្តែងឱ្យលោកអ្នករួចហើយ, ៥សំណុំលំហាត់ក៏បង្រៀនឱ្យលោកអ្នករួចហើយ, កែសំរួលល្អរាងកាយឱ្យលោកអ្នករួចហើយ, ដំឡើង "ហ្វាលូន", "យន្តការឈី" ឱ្យលោកអ្នករួចហើយ, នៅមានបរមីរបស់ខ្ញុំការពារលោកអ្នកទៀត។ ដែលគួរផ្តល់ឱ្យលោកអ្នកទាំងស្រុងបានផ្តល់ឱ្យលោកអ្នករួចហើយ។ ក្នុងអំឡុងពេលនៅលើថ្នាក់បង្រៀនគឺមើលមកខ្ញុំ, ចាប់ពីពេលនេះត

ទៅជាក់ស្ដែងមើលលើលោកអ្នក(ខ្លួនឯង)ហើយ, `គ្រូដឹកចូលខ្លោងទ្វារ, ប្ដូសហាត់នៅឯកជន´។ ដរាបណាលោកអ្នករៀនជ្រួតជ្រាបមហាធម៌, ស្មារតីនិងចិត្តភ្ញាក់ដឹងបាន, គ្រប់ពេលវេលារក្សាជាប់ចិត្តគំនិត, ឧស្សាហ៍ព្យាយាមប្ដូសពិតប្រាកដ, អាចរងទុក្ខក្នុងទុក្ខ, អាចខន្តីរឿងដែលពិបាកខន្តី, ខ្ញុំគិតថាលោកអ្នកប្រាកដនឹងប្ដូសហាត់បានជោគជ័យ។

*ចិត្តគឺជាមាគ៌ានៃការប្ដូសគង់*

*ភាពលំបាកគឺជាទូកឆ្លងកាត់មហាធម៌គ្មានព្រំដែន*

# ជំពូកទី៤ • លំហាត់ហ្វាលូនគង់

ហ្វាលូនគង់គឺជាវិធីសាស្ត្រពិសេសមួយប្រភេទរបស់ប្ដូសហាត់ពុទ្ធវង្ស, មានកន្លែងពិសេសតែមួយគត់របស់វាខុសជាមួយនឹងវិធីសាស្ត្រប្ដូសហាត់ពុទ្ធវង្សធម្មតា។ ដោយសារតែគង់ហ្វានេះជាមហាធម៌ប្ដូសហាត់ឧត្ដម, អតីតកាល(ជា)ធម៌ប្ដូសហាត់ពង្រឹងពិសេសដែលតម្រូវការសិក្សានៃអង្គដែលមានចិត្តគំនិតយ៉ាងខ្ពស់បំផុតឬក៏មនុស្សមហានិស្ស័យ, ដូច្នេះពិបាកក្នុងការជាសកល។ ប៉ុន្តែដើម្បីធ្វើឱ្យមនុស្សហាត់គង់កាន់តែច្រើនទទួលបានការលើកកម្ពស់, យល់ច្បាស់អំពីធម្មក្ខន្ធនេះ, ក្នុងពេលដំណាលគ្នាក៏បំពេញនូវតម្រូវការនៃមនុស្សភាគច្រើនដែលមានឆន្ទៈប្ដូសហាត់, ដូច្នេះ(ខ្ញុំ)បានយកគង់ហ្វានេះចងក្រងទៅជាមួយសំណុំនៃវិធីសាស្ត្រប្ដូសហាត់ដែលសមស្របក្នុងការជាសកលដើម្បីបង្រៀនចេញ។

សូម្បីតែបែបនេះក្តី, គាត់ក៏បានលើសផុតពីអ្វីដែលបានរៀននិងជាន់ថ្នាក់ប្រៀបនឹងគង់ហ្វាធម្មតា។

អ្នកបួសហាត់ហ្វាលូនគង់មិនត្រឹមតែអាចបង្កើនអំណាចគង់និងសីលគង់បានយ៉ាងឆាប់រហ័សប៉ុណ្ណោះទេ, លើសពីនេះទៀតក្នុងអំឡុងពេលដ៏ខ្លីនឹងហាត់ចេញបានហ្វាលូនដែលមានអានុភាពឥតប្រៀបផ្ទឹម។ បន្ទាប់ពីហ្វាលូនបានបង្កើត, ជាធម្មតានៅទីតាំងពោះទាបបង្វិលមិនឈប់ដោយស្វ័យប្រវត្តិ, បន្តប្រមូលនិងវិវត្តថាមពលពីក្នុងចក្រវាល, ចុងក្រោយនៅក្នុងរាងកាយមនុស្សហាត់គង់បំលែងទៅជា `គង់´, ដោយហេតុនេះសម្រេចបានគោលបំណង `ធម៌ហាត់មនុស្ស´។

គង់ហ្វានេះបានបង្កើតឡើងដោយ៥សំណុំចលនា, នោះគឺ៖ លំហាត់ព្រះពុទ្ធបង្ហាញដៃមួយពាន់, លំហាត់ឈរឱបហ្វាលូន, លំហាត់ស្រោចស្រឡះពីរប៉ូល, លំហាត់វង់សកលហ្វាលូននិងលំហាត់ពង្រឹងទេពអំណាច។

## I. លំហាត់ព្រះពុទ្ធបង្ហាញដៃមួយពាន់

***គោលសីលធម៌៖*** ស្នូលនៃ "លំហាត់ព្រះពុទ្ធបង្ហាញដៃមួយពាន់" ជាក់ស្តែងគឺលាតសន្ធឹង, បណ្តាលឱ្យរាប់រយខ្សែវណ្ណទាំងអស់បើកស្រឡះ។ សម្រាប់អ្នកចាប់ផ្តើមដំបូងរៀនឈីគង់, បន្ទាប់ពីតាមរយៈការហាត់គង់អាចយ៉ាងឆាប់រហ័សទទួលបានឈី; សម្រាប់មនុស្សមានបទពិសោធន៍ហាត់គង់អាចយ៉ាងឆាប់រហ័សទទួលបានការលើកកម្ពស់។ សំណុំគង់ហ្វានេះតាំងពីដំបូងតម្រូវ

រាប់រយខ្សែវណ្ណទាំងអស់បើកស្រឡះ, ធ្វើឱ្យអ្នកហាត់គង់ឈរនៅលើមួយជាន់ថ្នាក់ដ៏ខ្ពស់ដើម្បីហាត់។ ចលនានៃគង់ហ្វានេះសាមញ្ញណាស់, ដោយសារតែមហាតាវគឺសាមញ្ញនិងងាយស្រួលបំផុត, ចលនាទោះបីសាមញ្ញក្តី, ប៉ុន្តែនៅកម្រិតម៉ាក្រូបានឃុំគ្រងទាំងមូលអ្វីដែលគង់ហ្វាត្រូវការហាត់ចេញ។ នៅពេលរៀននិងហាត់គង់នេះ, នឹងមានអារម្មណ៍រាងកាយឡើងកំដៅ, អារម្មណ៍ពិសេសនៃវាលថាមពលដ៏ខ្លាំង, មូលហេតុគឺបណ្តាលមកពីពង្រីកនិងបើកស្រឡះទាំងអស់ផ្លូវឈីនៃរាងកាយទាំងមូល។ គោលបំណងរបស់វាគឺវាយស្រឡះទីកន្លែងដែលឈីស្ទះ, រលូនអត់រាំងស្ទះ, ប្រមូលផ្តុំឈីនៅក្នុងរាងកាយនិងនៅក្រោមស្បែកដើម្បីធ្វើចលនាខ្លាំងក្លា, ស្រូបយកចំនួនធំថាមពលនៅក្នុងចក្រវាល, ក្នុងពេលដំណាលគ្នាអាចបណ្តាលឱ្យអ្នកហាត់គង់យ៉ាងឆាប់រហ័សឈានចូលស្ថានភាពនៅក្នុងវាលថាមពលឈីគង់។ សំណុំគង់ហ្វានេះត្រូវបានប្រើជាលំហាត់មូលដ្ឋាននៃហ្វាលូនគង់ដើម្បីហាត់, រាល់ពេលហាត់គង់ជាធម្មតាបួសហាត់គង់ហ្វានេះដំបូង, គឺជាមួយប្រភេទវិធីសាស្រ្តក្នុងការពង្រឹងបួសហាត់។

***វគ្គ៖***

Shēnshén héyī, dòngjìng suíjī;
Dǐngtiān dúzūn, qiānshǒu Fó lì.

***ឥរិយាបថបម្រុង៖*** រាងកាយទាំងមូលសម្រាក, សម្រាកតែមិនរលុង, ជើងទាំងពីរបើកទូលាយស្មើស្មា, ឈរត្រង់តាមធម្មតា, ជើងទាំងពីរពត់កោងបន្តិច, ពីរកន្លែងជង្គង់និងចង្កេះក្នុងសភាពសម្រាកតាមធម្មតា; ថ្គាមក្រោមចូលក្នុងបន្តិច, អណ្តាតប៉ះក្រាសធ្មេញលើ, ធ្មេញបំបែកគ្នាបន្តិច, មាត់បបេមាត់បិទជិត, ភ្នែកទាំងគូបិទបន្តិច, មុខនាំចិត្តសន្តិភាពជាមួយ។ ក្នុងពេលហាត់គង់នឹងមានអារម្មណ៍ខ្លួនឯងធំខ្ពស់ខ្លាំងណាស់។

***ដៃពីរភ្ជាប់ត្រា៖*** ដៃទាំងពីរលើកឡើង, ប្រអប់បាតដៃផ្ងារឡើងលើ។ ចុងម្រាមមេដៃសងខាងប៉ះគ្នាថ្នមៗ, ម្រាមដៃបួនដែលនៅសល់បិទហើយត្រួតគ្នា, ប្រុសដៃឆ្វេងនៅខាងលើ, ស្រីដៃស្តាំនៅខាងលើ, បង្កើតជាទម្រង់រាងពងក្រពើ, ដាក់នៅលើពោះទាប។ ដើមដៃទាំងពីរឆ្ពោះទៅមុខបន្តិច, កែងដៃទាំងពីរព្យួរឡើង, បណ្តាលឱ្យចន្លោះក្លៀកបើក (ដូចរូប១.១)។

***មីទ្បើកសន្ទឹងខ្នង៖*** ចាប់ផ្តើមជាមួយដៃពីរភ្ជាប់ត្រា, ពេលលើកពីឥរិយាបថត្រាដៃ, ជាមួយនឹងការលើកដៃឡើង, ភ្លៅជើងទាំងពីរលាតត្រង់បន្តិចម្តង, នៅពេលដៃលើកដល់ខាងមុខក្បាល, ដោះដៃពីរភ្ជាប់ត្រាចេញ, ហើយវិលបាតដៃឆ្ពោះទៅលើបន្តិចម្តង, ពេលមកដល់កន្លែងកំពូលក្បាល, ប្រអប់បាតដៃឆ្ពោះទៅលើ, ម្រាមដៃ

ទាំងដប់ទល់មុខគ្នា, ចុងម្រាមដៃឃ្លាតពីគ្នា២០ទៅ២៥សង់ទីម៉ែត្រ (ដូចរូប១.២)។ ក្នុងពេលដំណាលគ្នា, ក្បាលឆ្ពោះឡើងកំពូល, ជើងទាំងពីរជាន់ចុះក្រោម, រាងកាយសន្ធឹងត្រង់, ប្រើកម្លាំងនៅគល់បាតដៃទាំងពីររុញឡើងលើ, រាងកាយទាំងមូលបន្តិចម្តងសន្ធឹងត្រង់, សន្ធឹងប្រមាណ២ទៅ៣វិនាទី, រាងកាយទាំងមូលសម្រាកភ្លាមៗ។ ពិសេសពីរកន្លែងជង្គង់និងចង្កេះត្រូវតែត្រឡប់ទៅសភាពសម្រាកតាមធម្មតា។

***យូឡាយស្រោចកំពូល៖*** ធ្វើបន្តពីឥរិយាបថខាងលើ, ដៃទាំងពីរក្នុងពេលដំណាលគ្នាបាតដៃបង្វែរចេញក្រៅ១៤០ដឺក្រេធ្វើដៃជា "រាងជីវឡាវ", សន្ធឹងកដៃនិងទម្លាក់បាតដៃចុះ(ដូចរូប១.៣)។ ដៃទាំងពីរទម្លាក់ចុះទល់មុខជាមួយទ្រូង, ចម្ងាយរវាងដៃនិងទ្រូងប្រហែល១០សង់ទីម៉ែត្រ, បន្តផ្លាស់ទីឆ្ពោះទៅរកពោះទាប (ដូចរូប ១.៤)។

***ដៃទាំងពីររួមដប់៖*** បន្ទាប់ពីដៃបានមកដល់ពោះទាប, បន្ទាប់មកភ្លាមៗលើកដៃទាំងពីរឡើងមកខាងមុខទ្រូង "រួមដប់" (ដូចរូប ១.៥)។ នៅពេល "រួមដប់", ម្រាមដៃនិងម្រាមដៃ, គល់បាតដៃនិងគល់បាតដៃបិទជិត, រក្សាចន្លោះរវាងប្រអប់បាតដៃ, កែងដៃទាំងពីរព្យួរឡើង, កំភួនដៃទាំងពីរបង្កើតជាបន្ទាត់ត្រង់។ (ដៃទាំងពីរលើកលែងតែពេល "រួមដប់", "ភ្ជាប់ត្រា", ទាំងអស់គឺជា "បាតដៃផ្កាឈូក", ដូចគ្នានៅខាងក្រោម)។



រូប១.១



រូប១.២



រូប១.៣



រូប១.៤



រូប១.៥



រូប១.៦

***បាតដៃចង្កុលមេឃនិងដី៖*** ចាប់ផ្ដើមពីឥរិយាបថ "រួមដប់"។ ដោះលែងបាតដៃទាំងពីរ, ចន្លោះគម្លាតរបស់វាប្រហែល២ទៅ៣សង់ទីម៉ែត្រ, ក្នុងពេលដំណាលគ្នាចាប់ផ្ដើមបង្វិលបាតដៃ, ប្រុសដៃឆ្វេង(ស្រីដៃស្ដាំ) បង្វិលឆ្ពោះទៅរកទ្រូង, ដៃស្ដាំបង្វិលឆ្ពោះចេញពីទ្រូង, បង្កើតជាដៃឆ្វេងនៅខាងលើ, ដៃស្ដាំនៅខាងក្រោម, ជាមួយនឹងកំភួនដៃបង្កើតជារូបរាងអក្សរ "មួយ", (ដូចរូប១.៦)។ បន្ទាប់មក, កំភួនដៃឆ្វេងពង្រីកឆ្ពោះទៅទិសខាងឆ្វេងបញ្ឆៀងឡើងលើ, ប្រអប់បាតដៃឆ្ពោះចុះក្រោម, កម្ពស់ដៃជាមួយនឹងក្បាលខ្ពស់ស្មើគ្នាទើបឈប់; ដៃស្ដាំនៅខាងមុខទ្រូង, ប្រអប់បាតដៃឆ្ពោះឡើងលើ។ ជាមួយនឹងដៃឆ្វេងបន្តិចម្ដងឈានដល់ទីតាំង, រាងកាយទាំងមូលបន្តិចម្ដងសន្ធឹងត្រង់, ក្បាលឆ្ពោះឡើងកំពូល, ជើងជាន់ចុះក្រោម។ ដៃឆ្វេងសន្ធឹងត្រង់ឆ្ពោះទៅទិសខាងឆ្វេងបញ្ឆៀងឡើងលើ, ដៃស្ដាំនៅខាងមុខទ្រូង, ជាមួយនឹងដើមដៃសន្ធឹងឆ្ពោះចេញក្រៅ, (ដូចរូប១.៧)។ សន្ធឹងប្រមាណ២ទៅ៣វិនាទី, រាងកាយទាំងមូលសម្រាកភ្លាមៗ។ ដៃឆ្វេងម្ដងទៀតត្រឡប់មកដល់ខាងមុខទ្រូងជាមួយនឹងដៃស្ដាំបង្កើតជាស្ថានភាព "រួមដប់"។ បន្ទាប់មកបង្វិលបាតដៃម្ដងទៀត, ដៃស្ដាំ(ស្រីឆ្វេង)នៅខាងលើ, ដៃឆ្វេងពង្រីកនៅខាងក្រោម(ដូចរូប១.៨)។ ដៃស្ដាំធ្វើឡើងវិញចលនារបស់ដៃឆ្វេង, នោះគឺកំភួនដៃស្ដាំពង្រីកឆ្ពោះទៅទិសខាងស្ដាំបញ្ឆៀងឡើងលើ, ប្រអប់បាតដៃឆ្ពោះចុះក្រោម, កម្ពស់ដៃជាមួយនឹងក្បាលខ្ពស់ស្មើគ្នាទើបឈប់; ដៃឆ្វេងនៅខាងមុខទ្រូង, ប្រអប់

បាតដៃឆ្ពោះឡើងលើ។ បន្ទាប់ពីសន្ទឹង(ដូចរូប១.៩)រាងកាយទាំងមូលសម្រាកភ្លាមៗ។ បន្ទាប់ពីដកដៃមក, នៅខាងមុខទ្រូង "រួមដប់"(ដូចរូប១.៥)។

***ស្វាមាសបំបែកកាយ៖*** ចាប់ផ្ដើមពីឥរិយាបថ "រួមដប់"។ ដៃទាំងពីរនៅខាងមុខទ្រូងទាញចេញនិងលាតសន្ទឹងទៅសងខាង, ជាមួយនឹងស្នាបង្កើតជារូបរាងអក្សរ "មួយ", រាងកាយទាំងមូលបន្តិចម្ដងសន្ទឹងត្រង់, ក្បាលសំដៅឡើងកំពូល, ជើងជាន់ចុះក្រោម, ដៃទាំងពីរប្រើកម្លាំងសំដៅទៅសងខាង, កម្លាំងទាញចេញបួនជ្រុង(ដូចរូប១.១០), សន្ទឹងប្រមាណ២ទៅ៣វិនាទី, រាងកាយទាំងមូលសម្រាកភ្លាមៗ, ដៃទាំងពីរត្រឡប់មកដល់ខាងមុខទ្រូង "រួមដប់"។



រូប១.៧



រូប១.៨



រូប១.៩



រូប១.១០



រូប១.១១



រូប១.១២

***គូនាគចុះសមុទ្រ៖*** ចាប់ផ្ដើមពីឥរិយាបថ "រួមដប់", ដៃទាំងពីរបំបែកចេញ, លាតសន្ធឹងឆ្ពោះទៅទិសខាងមុខនិងចុះក្រោម។ នៅពេលដៃទាំងពីរបំបែកចេញស្របគ្នា, សន្ធឹងត្រង់, ជាមួយនឹងចន្លោះនៃភ្លៅជើងបង្កើតជាមុំស្រួចប្រហែល៣០ដឺក្រេ (ដូចរូប១.១១)។ រាងកាយទាំងមូលបន្តិចម្ដងសន្ធឹងត្រង់, ក្បាលឆ្ពោះឡើងកំពូល, ជើងជាន់ចុះក្រោម, សន្ធឹងប្រមាណ២ទៅ៣វិនាទី, រាងកាយទាំងមូលសម្រាកភ្លាមៗ, បន្ទាប់ពីដកដៃមក, នៅខាងមុខទ្រូង "រួមដប់"។

***ពោធិសត្វកាន់ផ្កាឈូក៖*** ចាប់ផ្ដើមពីឥរិយាបថ "រួមដប់"។ ដៃទាំងពីរបំបែកចេញហើយលាតសន្ធឹងទៅទិសបញ្ឆៀងចុះទាំងសងខាងរាងកាយ។ នៅពេលដៃឈានដល់សងខាងរាងកាយ, ដៃទាំងពីរសន្ធឹងត្រង់, ជាមួយនឹងចន្លោះភ្លៅជើងបង្កើតជាមុំស្រួចប្រហែល៣០ដឺក្រេ(ដូចរូប១.១២)។ នៅពេលនោះ, រាងកាយទាំងមូលបន្តិចម្ដងសន្ធឹងត្រង់, ចុងម្រាមដៃប្រើកម្លាំងឆ្ពោះចុះក្រោម, បន្ទាប់មក, រាងកាយទាំងមូលសម្រាកភ្លាមៗ, ដៃទាំងពីរត្រឡប់មកខាងមុខទ្រូង "រួមដប់"។

***អរហន្តលីភ្នំ៖*** ចាប់ផ្ដើមពីឥរិយាបថ "រួមដប់"។ ដៃទាំងពីរបំបែកចេញ, ហើយលាតសន្ធឹងឆ្ពោះទៅខាងក្រោយរាងកាយ, ក្នុងពេលដំណាលគ្នាបាតដៃទាំងពីរបង្វែរឆ្ពោះទៅទិសខាងក្រោយ។ នៅពេលដៃទាំងពីរឈានដល់ទាំងសងខាងរាងកាយ, កដៃទាំងពីរបន្តិចម្ដងថ្កក់ឡើង; បន្ទាប់ពីដៃនៅខាងក្រោយរាងកាយ, កដៃ

បង្កើតជាមុំ៤៥ដឺក្រេ(ដូចរូប១.១៣)។ រាងកាយទាំងមូលបន្តិចម្តង សន្ទឹងត្រង់, បន្ទាប់ពីដៃមកដល់ទីតាំង, ក្បាលឆ្ពោះឡើងកំពូល, ជើងជាន់ចុះក្រោម, រាងកាយត្រង់ឡើង, សន្ទឹងប្រមាណ២ទៅ៣វិនាទី, រាងកាយទាំងមូលសម្រាកភ្លាមៗ។ ដៃទាំងពីរដកមកវិញ, ត្រឡប់មកខាងមុខទ្រូង "រួមដប់"។

***ជីនកាងរុញភ្នំ៖*** ចាប់ផ្តើមពីឥរិយាបថ "រួមដប់"។ ដៃទាំងពីរបំបែកចេញ, ហើយរុញបាតដៃឈរឡើងឆ្ពោះទៅទិសខាងមុខ, ចុងម្រាមដៃឆ្ពោះឡើងលើ, ដៃនៅកម្ពស់ស្មា។ បន្ទាប់ពីដៃលាតត្រង់, ហើយប្រើកម្លាំងសន្ទឹង, ក្បាលឆ្ពោះឡើងកំពូល, ជើងជាន់ចុះក្រោម, រាងកាយសន្ទឹងត្រង់(ដូចរូប១.១៤)។ សន្ទឹងប្រមាណ២ទៅ៣វិនាទី, រាងកាយទាំងមូលសម្រាកភ្លាមៗ, ដៃទាំងពីរត្រឡប់មកខាងមុខទ្រូង "រួមដប់"។

***ត្រួតដៃលើគ្នានៅពោះទាប៖*** ចាប់ផ្តើមពីឥរិយាបថ "រួមដប់"។ ដៃទាំងពីរទម្លាក់ចុះយឺតៗ, ហើយប្រអប់បាតដៃបង្វែរឆ្ពោះទៅពោះ, នៅពេលដៃមកកន្លែងពោះទាប, ដៃទាំងពីរត្រួតគ្នា, ប្រុសដៃឆ្វេងនៅខាងក្នុង, ស្រីដៃស្តាំនៅខាងក្នុង, ប្រអប់បាតដៃទល់មុខខ្នងបាតដៃ។ ចន្លោះចម្ងាយរវាងដៃនិងដៃ, ដៃនិងពោះទាបប្រហែល៣សង់ទីម៉ែត្រ, ពេលវេលាត្រួតគ្នាជាធម្មតា៤០ទៅ១០០វិនាទី (ដូចរូប១.១៥)។

***ដកឥរិយាបថ៖*** ដៃពីរភ្ជាប់គ្រា(ដូចរូប១.១៦)។



រូប១.១៣



រូប១.១៤



រូប១.១៥



រូប១.១៦

## II. លំហាត់ឈរឱបហ្វាលូន

***គោលសីលធម៌៖*** គង់ហ្វានេះគឺជាសំណុំគង់ហ្វាទីពីរនៃហ្វាលូនគង់, ស្ថិតក្នុងលំហាត់ឈរសម្ធិ, បានបង្កើតឡើងដោយ៤ចលនាឱបកង់, ចលនាឯកតាណាស់, លើសពីនេះទៀតចលនានីមួយៗតម្រូវហាត់ក្នុងអំឡុងពេលដ៏យូរ។ មនុស្សដែលចាប់ផ្ដើមដំបូងរៀនឈរគំនរ, នៅពេលចាប់ផ្ដើមហាត់គង់ដៃទាំងពីរនឹងធ្ងន់ណាស់, ចុករោយណាស់, ប៉ុន្តែបន្ទាប់ពីហាត់ចប់នឹងមានអារម្មណ៍ភ្លាមថារាងកាយធូរស្រាល, មិនមានអារម្មណ៍អស់កម្លាំងបន្ទាប់ពីការងារ។ ជាមួយនឹងការកើនឡើងនៃពេលវេលា, បង្កើនចំនួនហាត់គង់, នៅចន្លោះដៃទាំងពីរនឹងលេចឡើង "ហ្វាលូន" កំពុងបង្វិល។ ហាត់លំហាត់ឈរឱបហ្វាលូនជាទៀងទាត់អាចធ្វើឱ្យរាងកាយទាំងមូលទាំងអស់ស្រោចស្រឡះ, បង្កើនអំណាចគង់។ "លំហាត់ឈរឱបហ្វាលូន" ស្ថិតក្នុងគង់ហ្វាបួសទាំងស្រុងនៃការបង្កើនបញ្ញា, លើកកម្ពស់ជាន់ថ្នាក់, ពង្រឹងទេពអំណាច, គង់ទោះបីសាមញ្ញក្ដី, ប៉ុន្តែអ្វីដែលហាត់បានគឺច្រើនណាស់, ទូលំទូលាយណាស់។ ចលនានៃគង់ហ្វានេះគួរតែជាធម្មជាតិ, ខ្លួនឯងដឹងថាកំពុងហាត់គង់, កុំអង្រួន, មានកម្រើកតូចក៏ជាធម្មតា។ នេះដូចគ្នានឹងគង់ហ្វាដទៃទៀតរបស់ហ្វាលូនគង់, បន្ទាប់ពីហាត់ចប់មិនដកគង់, ដោយសារតែហ្វាលូនគឺបង្វិលជានិច្ច, មិនអាចដកបញ្ឈប់បាន, ហាត់គង់តម្រូវពេលវេលានៃចលនានីមួយៗខុសគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់, កាន់តែយូរកាន់តែល្អ។

***វគ្គ៖***

Shēng huì zēng lì, róng xīn qīng tǐ,
Shì miào shì wù, Fălún chū qǐ.

***ឥរិយាបថបម្រុង៖*** រាងកាយទាំងមូលសម្រាក, សម្រាកតែមិនរលុង, ជើងពីរបើកទូលាយស្មើស្មា, ឈរត្រង់តាមធម្មតា, ជើងពីរពត់កោងបន្តិច, ពីរកន្លែងជង្គង់និងចង្កេះក្នុងសភាពសម្រាកតាមធម្មតា; ថ្គាមក្រោមចូលក្នុងបន្តិច, អណ្ដាតប៉ះក្រាសធ្មេញលើ, ធ្មេញបំបែកគ្នាបន្តិច, មាត់បបេមាត់បិទជិត, ភ្នែកទាំងគូបិទបន្តិច, មុខនាំចិត្តសន្តិភាពជាមួយ។

***ដៃពីរភ្ជាប់ត្រា*** (ដូចរូប២.១)

***ឱបកង់ខាងមុខក្បាល៖*** ចាប់ផ្ដើមពីឥរិយាបថដៃពីរភ្ជាប់ត្រា។ លើកដៃទាំងពីរយឺតៗពីខាងមុខពោះ, បន្ទាប់មកដោះភ្ជាប់ត្រាចេញ។ នៅពេលដៃទាំងពីរលើកដល់ខាងមុខក្បាល, ប្រអប់បាតដៃទល់មុខនឹងមុខ, ស្មើកម្ពស់នឹងចញ្ចើម, ចុងម្រាមដៃទាំងដប់ទល់មុខគ្នា, ចម្ងាយចន្លោះម្រាមដៃប្រហែល១៥សង់ទីម៉ែត្រ, ដៃទាំងពីរឱបមូល, រាងកាយទាំងស្រុងសម្រាក (ដូចរូប២.២)។

***ឱបកង់ខាងមុខពោះ៖*** ដៃទាំងពីរដាក់ចុះយឺតៗពីសភាព "ឱបកង់ខាងមុខក្បាល", ឥរិយាបថមិនផ្លាស់ប្ដូរ, ទម្លាក់ត្រង់រហូតដល់កន្លែងពោះទាប, ចម្ងាយដៃទៅពោះទាបប្រហែល១០សង់ទីម៉ែត្រ, កែងដៃទាំងពីរព្យួរឡើង, ក្លៀកបើកចន្លោះ, ប្រអប់បាតដៃឆ្ពោះឡើងលើ, ចុងម្រាមដៃទាំង១០ទល់មុខគ្នា, ចម្ងាយចន្លោះម្រាមដៃ

ប្រហែល១០សង់ទីម៉ែត្រ, ដៃទាំងពីរឱបមូល(ដូចរូប២.៣)។

***ឱបកង់លើកំពូលក្បាល៖*** ចាប់ផ្តើមពីឥរិយាបថ "ឱបកង់ខាងមុខពោះ", ឥរិយាបថមិនផ្លាស់ប្តូរ, ដៃទាំងពីរលើកឡើងយឺតៗដល់កំពូលក្បាល, ធ្វើជាឱបកង់លើកំពូលក្បាល។ ម្រាមដប់នៃដៃទាំងពីរទល់មុខគ្នា, ប្រអប់បាតដៃឆ្ពោះចុះក្រោម, ចម្ងាយចន្លោះម្រាមដៃប្រហែល២០ទៅ៣០សង់ទីម៉ែត្រ, ដៃទាំងពីរឱបជាទម្រង់មូល, ស្មាទាំងពីរ, ដៃ, កែងដៃ, កដៃទាំងអស់គឺសម្រាក(ដូចរូប២.៤)។



រូប២.១



រូប២.២



រូប២.៣



រូប២.៤

***ឱបកង់ទាំងសងខាង៖*** ដៃទាំងពីរដាក់ចុះពី "ឱបកង់លើកំពូលក្បាល", រហូតដល់សងខាងនៃក្បាល, ប្រអប់បាតដៃទល់មុខឆ្ពោះទៅត្រចៀកទាំងគូ, ស្មាទាំងពីរសម្រាក, កំភួនដៃបញ្ឈរត្រង់, ចម្ងាយរវាងដៃនិងត្រចៀកកុំជិតពេក (ដូចរូប២.៥)។

***ដៃត្រួតលើគ្នានៅពោះទាប៖*** ដៃទាំងពីរដាក់ចុះពី "ឱបកង់ទាំងសងខាង", រហូតដល់កន្លែងពោះទាបបង្កើតជាសភាពដៃត្រួតលើគ្នា (ដូចរូប២.៦)។ ដៃទាំងពីរ "ភ្ជាប់ត្រា" ដកឥរិយាបថ។



រូប២.៥



រូប២.៦

## III. លំហាត់ស្រោចស្រឡះពីរប៉ូល

***គោលសីលធម៌៖*** គង់ហ្វានេះគឺជាគង់ហ្វាយកឈីនៃចក្រវាល និងឈីនៃខាងក្នុងរាងកាយលាយនិងជ្រាបចូលគ្នា, បញ្ជូនចេញ និងស្រូបចូលចំនួនធំ, បណ្ដាលឱ្យអ្នកហាត់គង់ក្នុងរយៈពេលខ្លីបំផុត, យកឈីជំងឺឈីខ្មៅនៅខាងក្នុងរាងកាយរុញចេញខាងក្រៅរាងកាយ, ហើយបញ្ជូនចូលចំនួនធំឈីនៃចក្រវាល, បន្សុទ្ធរាងកាយ, ចូលទៅក្នុងស្ថានភាព "រាងកាយសសុទ្ធ" ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ក្នុងពេលដំណាលគ្នា, គង់នេះនៅអាច "បើកកំពូល" ក្នុងពេលកំពុងលើកដៃឡើងនិងចុះ, ក៏អាចវាយបើកផ្លូវខាងក្រោមជើងនៃរាងកាយមនុស្សក្នុងពេលកំពុងលើកដៃ

ឡើងនិងចុះ។

មុនពេលហាត់គង់ស្រមៃបន្តិចថាខ្លួនឯងគឺជាចុងទទេពីរខ្ពស់ធំ, ឈរកណ្ដាលមេឃនិងដី, ខ្ពស់ធំឥតប្រៀបផ្ទឹម។ ឈើនៅក្នុងរាងកាយផ្លាស់ទីតាមដៃឡើងនិងចុះ, ឡើងផុតពីកំពូលក្បាល, ដោយផ្ទាល់ដល់ចំណុចកំពូលនៃចក្រវាល; ឈើចុះក្រោមចេញទៅតាមបាតជើង, ចុះដល់ចំណុចកំពូលនៃចក្រវាល។ បន្ទាប់មកឈើផ្លាស់ទីតាមដៃ, ពីចំណុចកំពូលទាំងពីរត្រឡប់មកខាងក្នុងរាងកាយវិញ, ម្ដងទៀតចេញទៅពីទិសបញ្ច្រាស, ធ្វើដំណើរជុំសរុប៩ដង។ នៅពេលលើកដៃឡើងនិងចុះលើកទី៩, ដៃឆ្វេង (ស្រីស្ដាំ) កំពុងរង់ចាំនៅចំណុចកំពូលខាងលើដៃស្ដាំ (ស្រីឆ្វេង) លើកឡើងតាម។ បន្ទាប់មកត្រឡប់មកក្នុងពេលដំណាលគ្នាទម្លាក់ដៃ (ទាំងពីរ) ចុះឆ្ពោះទៅចំណុចកំពូលខាងក្រោម, ឆ្លងកាត់រាងកាយឆ្ពោះទៅលើលើកដៃឡើងនិងចុះ, បន្ទាប់ពីធ្វើដំណើរជុំ៩ដង, ដកឈើមកវិញ។ បន្ទាប់ពីដកមករួចហើយ, នៅទីតាំងពោះទាបរុញបង្វិលហ្វាលូនតាមទ្រនិចនាឡិកា, ធ្វើឱ្យឈើនៅខាងក្រៅរាងកាយបង្វិលចូលទៅក្នុងរាងកាយវិញ, បន្ទាប់មកដៃពីរភ្ជាប់ត្រា, បន្ទាប់ពីហាត់បញ្ចប់ដកឥរិយាបថមិនដកគង់។

***វគ្គ៖***

Jìnghuà běntǐ, Fǎ kāi dǐng dǐ;
Xīn cí yì měng, tōngtiān chè dì.

***ឥរិយាបថបម្រុង៖*** រាងកាយទាំងមូលសម្រាក, សម្រាកតែមិនរលុង, ជើងពីរបើកទូលាយស្មើស្មា, ឈរត្រង់តាមធម្មតា, ជើងទាំងពីរពត់កោងបន្តិច, ពីរកន្លែងជង្គង់និងចង្កេះក្នុងសភាពសម្រាកតាមធម្មតា; ថ្គាមក្រោមចូលក្នុងបន្តិច, អណ្តាតប៉ះក្រាសធ្មេញលើ, ធ្មេញបំបែកគ្នាបន្តិច, មាត់បបេមាត់បិទជិត, ភ្នែកទាំងគូបិទបន្តិច, មុខនាំចិត្តសន្តិភាពជាមួយ។ ដៃទាំងពីរភ្ជាប់ត្រា, រួមដប់។

***ដៃមួយលើកឡើងនិងចុះ៖*** ចាប់ផ្តើមពីឥរិយាបថ "រួមដប់"។ ធ្វើចលនាដៃមួយលើកឡើងលើនិងចុះក្រោម, ដៃធ្វើចលនាយឺតៗតាមយន្តការឈើនៅខាងក្រៅរាងកាយ, ឈើនៅខាងក្នុងរាងកាយគឺផ្លាស់ទីទៅតាមដៃឡើងនិងចុះ។ ប្រុសមុនដំបូងដៃឆ្វេងឆ្ពោះឡើងលើ, (ដូចរូប៣.១), ស្រីមុនដំបូងដៃស្តាំឆ្ពោះឡើងលើ។ ដៃពីទិសខាងមុខនៃសងខាងក្បាលយឺតៗលើកឡើងលើ, លើកផុតពីកំពូលក្បាល; ក្នុងពេលដំណាលគ្នា, ដៃស្តាំ (ស្រីឆ្វេង) យឺតៗដាក់ចុះក្រោម, បន្ទាប់មក, ជាមួយដៃមួយទៀតផ្លាស់វេនលើកដៃឡើងនិងចុះ (ដូចរូប៣.២)។ ប្រអប់បាតដៃទាំងពីរទល់មុខជាមួយរាងកាយ, រក្សាចម្ងាយ១០សង់ទីម៉ែត្រពីរាងកាយ។ នៅពេលធ្វើរាងកាយទាំងមូលត្រូវតែសម្រាក, ដៃលើកឡើងមួយដងនិងដាក់ចុះមួយដងបានរាប់ថាម្តង, លើកដៃឡើងនិងចុះសរុប៩ដង។



រូប៣.១



រូប៣.២

***ដៃទាំងពីរលើកឡើងនិងដាក់ចុះ៖*** នៅពេលដែលដៃនីមួយៗលើកឡើងនិងដាក់ចុះធ្វើដល់លើកទី៩, នោះគឺដៃឆ្វេង (ស្រីដៃស្តាំ) កំពុងនៅខាងលើ, ដៃមួយផ្សេងទៀតលើកឡើងតាម, បានន័យថា, ដៃទាំងពីរនៅទីតាំងលើកឡើងលើ (ដូចរូប៣.៣), បន្ទាប់មកដៃទាំងពីរក្នុងពេលដំណាលគ្នាលើកឡើងនិងដាក់ចុះ (ដូចរូប៣.៤)។ នៅពេលដៃទាំងពីរលើកឡើងនិងដាក់ចុះ, ប្រអប់បាតដៃទល់មុខជាមួយរាងកាយ, ឃ្លាតអំពីរាងកាយ១០សង់ទីម៉ែត្រ, មួយដងឡើងមួយដងចុះបានរាប់ថាម្តង, សរុបលើកដៃឡើងនិងដាក់ចុះ៩ដង។



រូប៣.៣



រូប៣.៤

***ដៃទាំងពីររុញបង្វិលហ្វាលូន៖*** នៅពេលបញ្ចប់លើកទី៩, ដៃទាំងពីរទម្លាក់ចុះពីខាងលើក្បាលឆ្លងកាត់ក្បាល, ទ្រូងឆ្ពោះទៅទីតាំងពោះទាប, រហូតទម្លាក់ដល់ទីតាំងពោះទាប, នៅទីតាំងពោះទាបរុញបង្វិលហ្វាលូន (ដូចរូប៣.៥, ៣.៦, និង ៣.៧)។ ប្រុសដៃឆ្វេងនៅខាងក្នុង, ស្រីដៃស្តាំនៅខាងក្នុង, ចម្ងាយរវាងដៃនិងដៃ, រវាងដៃនិងពោះទាបប្រហែលជា៤សង់ទីម៉ែត្រ, ឆ្ពោះទៅទិសតាមទ្រនិចនាឡិការុញបង្វិលហ្វាលូន៤ដង, យកថាមពលនៃខាងក្រៅរាងកាយបង្វិលត្រឡប់មកខាងក្នុងរាងកាយ។ នៅពេលរុញបង្វិលហ្វាលូនដៃទាំងពីរកុំចេញផុតពីតំបន់ពោះទាប។

***ដៃពីរភ្ជាប់គ្រា*** (ដូចរូប៣.៨)។



រូប៣.៥



រូប៣.៦



រូប៣.៧



រូប៣.៨

## IV. លំហាត់វង់សកលហ្វាលូន

***គោលសីលធម៌៖*** គង់ហ្វានេះគឺធ្វើឱ្យថាមពលនៃរាងកាយមនុស្សលំហូរតំបន់ធំ, មិនមែនមួយខ្សែវណ្ណឬក៏ពីរបីខ្សែវណ្ណកំពុងរត់, ប៉ុន្តែពីផ្នែកខាងអវិជ្ជមាននៃរាងកាយមនុស្សទាំងមូលរង្វិលជុំទៅផ្នែកខាងវិជ្ជមាន, ធ្វើដំណើរជុំមិនឈប់, លើសផុតឆ្ងាយខ្លាំងណាស់ពីធម៌បើកស្រឡះខ្សែវណ្ណធម្មតា, ឬក៏វង់សកលធំ, តូច។ គង់ហ្វានេះស្ថិតក្នុងលំហាត់ជាន់កណ្ដាលនៃហ្វាលូនគង់, ផ្អែកលើមូលដ្ឋាននៃលំហាត់៣មុន, តាមរយៈហាត់គង់ហ្វានេះអាចយ៉ាងឆាប់រហ័សវាយបើកខ្សែវណ្ណឈើនៃរាងកាយទាំងមូល (ក្នុងនោះរួមមានវង់សកលធំ), ពីលើចុះក្រោមជាបណ្ដើរបើកស្រឡះរាងកាយទាំងមូល។ លក្ខណៈធំបំផុតនៃគង់ហ្វានេះគឺប្រើការបង្វិលរបស់ "ហ្វាលូន" ដើម្បីកែតម្រូវស្ថានភាពមិនត្រឹមត្រូវនៃរាងកាយមនុស្ស, ធ្វើឱ្យចក្រវាលតូចនៃរាងកាយមនុស្សត្រឡប់មកស្ថានភាពចាប់ផ្ដើមដំបូង, សម្រេចបានខ្សែវណ្ណឈើនៃរាងកាយទាំងមូលបើកស្រឡះរលូន។ នៅពេលហាត់ដល់ស្ថានភាពនោះ, នៅក្នុងបួសហាត់លោកីយ៍ធម៌បានឈានដល់ជាន់ថ្នាក់ដ៏ខ្ពស់រួចហើយ, អ្នកមហានិស្ស័យអាចឈានចូលទៅក្នុងបួសហាត់មហាធម៌។ នៅពេលនោះ, អំណាចគង់និងទេពអំណាចនឹងកើនឡើងខ្លាំង។ នៅពេលហាត់, ដៃផ្លាស់ទីជាមួយនឹងយន្តការឈើ, ចលនាត្រូវតែ ՝ទន់ភ្លន់, យឺត, មូល՛។

***វគ្គ៖***

Xuánfǎ zhì xū, xīn qīng sì yù;
Fǎnběn guīzhēn, yōuyōu shì qǐ.

***ពរិយាបថបម្រុង៖*** រាងកាយទាំងមូលសម្រាក, សម្រាកតែមិនរលុង, ជើងពីរបើកទូលាយស្មើស្មា, ឈរត្រង់តាមធម្មតា, ជើងពីរពត់កោងបន្តិច, ពីរកន្លែងជង្គង់និងចង្កេះក្នុងសភាពសម្រាកតាមធម្មតា; ថ្គាមក្រោមចូលក្នុងបន្តិច, អណ្ដាតប៉ះក្រាសធ្មេញលើ, ធ្មេញបំបែកគ្នាបន្តិច, មាត់បបេមាត់បិទជិត, ភ្នែកទាំងគូបិទបន្តិច, មុខនាំចិត្តសន្តិភាពជាមួយ។

ដៃពីរភ្ជាប់ត្រា, រួមដប់។

ដៃទាំងពីរបំបែកសភាព "រួមដប់", រួចហើយទម្លាក់ឆ្ពោះចុះទីតាំងពោះទាប, ក្នុងពេលដំណាលគ្នាបង្វិលប្រអប់បាតដៃទាំងពីរទល់មុខឆ្ពោះទៅរាងកាយ។ ចម្ងាយរវាងដៃនិងរាងកាយប្រហែល១០សង់ទីម៉ែត្រ, ឆ្លងផុតពោះទាបសន្សឹងឆ្ពោះចុះចន្លោះជើងទាំងពីរ, បណ្ដោយតាមផ្នែកខាងក្នុងនៃជើងទាំងពីរចុះក្រោម, ក្នុងពេលដំណាលគ្នាបត់ខ្នងអង្គុយចុះ, (ដូចរូប៤.១)។ នៅពេលចុងម្រាមនៃដៃទាំងពីរជិតប៉ះដល់ដី, ដៃគូរពីចុងម្រាមជើងទៅក្រៅជើងរហូតដល់ខាងក្រៅកែងជើង (ដូចរូប៤.២)។

បន្ទាប់មក, កដៃទាំងពីរបត់ឡើងបន្តិច, ពីទីតាំងខាងក្រោយកែងជើងជាបណ្ដើរបណ្ដោយតាមខាងក្រោយជើងលើកឆ្ពោះឡើងលើ (ដូចរូប៤.៣), ដៃទាំងពីរលើកឆ្ពោះឡើងលើពីខាងក្រោយខ្នង

ហើយត្រង់ខ្នង, (ដូចរូប៤.៤)។ នៅក្នុងលំហាត់វង់សកលហ្វាលូនទាំងមូល, ដៃទាំងពីរមិនបានប៉ះទីតាំងណាមួយនៃរាងកាយ, បើមិនដូច្នេះទេ, ថាមពលលើដៃទាំងពីរនឹងដកត្រឡប់ចូលខាងក្នុងរាងកាយ។ នៅពេលដៃទាំងពីរមកដល់កន្លែងមិនអាចលើកឡើងបានទៀត, ក្ដាប់ដៃទទេ (ដូចរូប៤.៥), ហើយពីទីតាំងចន្លោះភ្លៅកអូសកាត់មក, ដៃទាំងពីរប្រសព្វគ្នាធំនៅខាងមុខទ្រូង (ដៃមួយណានៅខាងលើ, ដៃមួយណានៅខាងក្រោម, មិនមានតម្រូវពិសេស, ស្របតាមទម្លាប់ឯកជនកំណត់ខ្លួនឯង, ប្រុសឬស្រីមិនខុសគ្នា) (ដូចរូប៤.៦), លាបាតដៃទាំងពីរចេញ, បាតដៃទាំងពីរនៅលើស្មា (មានគម្លាត)។ បន្ទាប់មកភ្លាមៗបណ្ដោយតាមផ្នែកខាងលើនៃដើមដៃទាំងពីរទាញមកដល់ទីតាំងកដៃទាំងពីរ, បង្វែរប្រអប់បាតដៃនៃបាតដៃទាំងពីរទល់មុខគ្នា, នោះគឺវិលម្រាមដៃមេនៃដៃខាងក្រៅបង្វែរឆ្ពោះឡើងលើ, ម្រាមដៃមេនៃដៃខាងក្នុងបង្វែរឆ្ពោះចុះក្រោម, ចម្ងាយចន្លោះបាតដៃប្រហែល៣ទៅ៤សង់ទីម៉ែត្រ, នៅពេលនោះបាតដៃនិងកំភួនដៃបង្កើតជារូបរាងអក្សរ "មួយ" (ដូចរូប៤.៧)។ បន្ទាប់មកបាតដៃកាន់បង្វិលបាល់, នោះគឺដៃខាងក្រៅក្លាយជាដៃខាងក្នុង, ដៃខាងក្នុងក្លាយជាដៃខាងក្រៅ។ បន្ទាប់មក, ដៃទាំងពីររុញបណ្ដោយតាមផ្នែកខាងអវិជ្ជមាននៃកំភួនដៃនិងដើមដៃ, ហើយលើកឆ្ពោះឡើងលើនិងឆ្លងកាត់ក្បាល, (ដូចរូប៤.៨)។ បន្ទាប់ពីដៃទាំងពីរឆ្លងកាត់ក្បាល, ដៃទាំងពីរបង្កើតជាសភាពប្រសព្វគ្នា, និងបន្តធ្វើចលនាឆ្ពោះទៅទីតាំងឆ្អឹងខ្នង (ដូចរូប៤.៩)។ ដៃទាំងពីរ

បំបែកចេញពីឥរិយាបថប្រសព្វគ្នា, ចុងម្រាមដៃឆ្ពោះចុះក្រោម, តភ្ជាប់ជាមួយនឹងថាមពលរបស់ខ្នង, ម្ដងទៀតលើកដៃទាំងពីរស្របគ្នាពីខាងលើក្បាលធ្វើចលនាកាត់មកដល់ខាងមុខទ្រូង, (ដូចរូប ៤.១០)។ បែបនេះគឺជាវដ្តវង់សកលមួយដង, សរុបធ្វើ៩ដង។ បន្ទាប់ពីបញ្ចប់៩ដងហើយ, ដៃទាំងពីរឆ្លងកាត់ខាងមុខទ្រូងទម្លាក់ចុះឆ្ពោះទៅទីតាំងពោះទាប។

ត្រួតដៃលើគ្នានៅពោះទាប, ដៃពីរភ្ជាប់ត្រា។



រូប៤.១



រូប៤.២



រូប៤.៣



រូប៤.៤



រូប៤.៥



រូប៤.៦



រូប៤.៧



រូប៤.៨



រូប៤.៩



រូប៤.១០

## V. លំហាត់ពង្រឹងទេពអំណាច

***គោលសីលធម៌៖*** "លំហាត់ពង្រឹងទេពអំណាច" ស្ថិតក្នុងធម៌ប្ញសហាត់បិតិវន្តគង់នៃហ្វាលូនគង់, គឺជាគង់ហ្វាដែលប្រើក្បាច់ដៃរបស់ "ព្រះពុទ្ធ" បង្វិល "ហ្វាលូន" ពង្រឹងទេពអំណាច (រួមបញ្ចូលសីលគង់) និងប្ញសដំណាលគ្នាជាច្រើនផ្នែកនៃអំណាចគង់។ គង់ហ្វានេះស្ថិតក្នុងលំហាត់ខ្ពស់ជាងកម្រិតមធ្យម, ដើមឡើយស្ថិតក្នុងធម៌ដែល 'ហាត់សម្ងាត់'។ ដើម្បីបំពេញនូវតម្រូវការរបស់អ្នកដែលមានមូលដ្ឋានជាក់លាក់, ពិសេស(ខ្ញុំ)បានយកគង់ហ្វានេះបង្រៀនចេញ, បង្រៀនចេញដើម្បីប្រោសមនុស្សដែលមានវាសនា។ គង់ហ្វានេះតម្រូវហាត់ក្នុងពេលអង្គុយសមាធិ, ល្អបំផុតបត់ជើងពីរឡើង, ជ្រើសប្រើបត់ជើងមួយឡើងក៏បាន។ នៅពេលប្ញសហាត់ចរន្តឈីខ្លាំងក្លាណាស់, វាលថាមពលនៃខាងក្រៅរាងកាយធំណាស់។ ចលនាគឺធ្វើដំណើរតាមយន្តការឈីដែលលោកគ្រូដំឡើង, នៅពេលលើកដៃចិត្តធ្វើចលនាតាមគំនិត។ នៅពេលពង្រឹងទេពអំណាច, ទុកគំនិតឱ្យនៅទទេ, ផ្តោតអារម្មណ៍បន្តិចនៅលើបាតដៃទាំងពីរ។ បាតដៃនឹងមានអារម្មណ៍ក្តៅ, ធ្ងន់, ស្ពឹកអគ្គិសនី, ដូចជាមានវត្ថុ។ល។ ប៉ុន្តែមិនបានប្រើគំនិតស្វែងរកនិងចំណង់, បណ្តោយតាមធម្មជាតិ។ ពេលវេលាអង្គុយសមាធិតម្រូវកាន់តែយូរកាន់តែល្អ, អាចពឹងផ្អែកលើគង់ហើយកំណត់, ពេលវេលាកាន់តែយូរ, វិសមភាពកាន់តែធំ, បញ្ចេញគង់កាន់តែឆាប់រហ័ស។ នៅពេលហាត់គង់ (អ្វីក៏មិនចង់បាន, មិនមានគំនិតណាមួយ), បន្តិច

ម្តងៗចូលទៅក្នុងស្ងប់, ពីស្ថានភាពថាមវន្តគង់ដូចជាស្ងប់មិនមែន រម្ងាប់បន្តិចម្តងៗចូលទៅក្នុងសមាធិ។ ប៉ុន្តែសតិម្ចាស់ដឹងថាខ្លួនឯង កំពុងហាត់គង់។

***វគ្គ៖***

Yǒuyì wúyì, yìn suíjī qǐ;
Shì kōng fēi kōng, dòngjìng rúyì.

***ដៃពីរភ្ជាប់ត្រា៖*** អង្គុយជើងទាំងពីរបត់ឡើង, រាងកាយ ទាំងមូលសម្រាក, សម្រាកតែមិនរលុង, ខ្នងត្រង់កត្រង់កណ្តាល, ថ្គាមក្រោមចូលក្នុងបន្តិច, អណ្តាតប៉ះក្រាស់ធ្មេញលើ, ធ្មេញបំបែក គ្នាបន្តិច, មាត់បបេមាត់បិទជិត, ភ្នែកទាំងពីរបិទបន្តិច, ចិត្តបង្កើត មេត្តា, មុខនាំចិត្តសន្តិភាពជាមួយ។ ដៃទាំងពីរ "ភ្ជាប់ត្រា" ដាក់នៅ ទីតាំងពោះទាប, បន្តិចម្តងៗចូលទៅក្នុងស្ងប់ (ដូចរូប៥.១)។

***ក្បាច់ដៃទីមួយ៖*** (ពេលលើកដៃ, ចិត្តធ្វើចលនាតាមគំនិត, ធ្វើ ដំណើរតាមយន្តការឈីដែលលោកគ្រូដំឡើង, តម្រូវទន់ភ្លន់, យឺត, មូល) ដៃទាំងពីរលើកឡើងដោយទន់ភ្លន់ពីសភាព "ភ្ជាប់ត្រា", ពេលមកដល់ទិសខាងមុខក្បាលបន្តិចម្តងបង្វែរបាតដៃឆ្ពោះឡើង លើ, នៅពេលប្រអប់បាតដៃទាំងពីរឆ្ពោះឡើងលើ, ដៃក៏មកដល់ ចំណុចកំពូល(ដូចរូប៥.២), បន្ទាប់មកដៃទាំងពីរបំបែកគ្នាចេញ, នៅលើកំពូលក្បាលគូររង្វង់, ធ្វើចលនាឆ្ពោះទៅសងខាង, រហូត ផ្លាស់ទីដល់ទិសខាងមុខសងខាងក្បាល (ដូចរូប៥.៣)។ ភ្លាមៗ បន្ទាប់មក, ដៃទាំងពីរទន់ភ្លន់ដាក់ចុះក្រោម, ផ្អែកកែងដៃទាំងពីរ

ចូលក្នុងតាមដែលអាចធ្វើទៅបាន, ប្រអប់បាតដៃទាំងពីរឆ្ពោះទៅលើ, ចុងម្រាមដៃឆ្ពោះទៅមុខ, (ដូចរូប៥.៤)។ បន្ទាប់មក, កដៃទាំងពីរសន្ទឹងត្រង់, ហើយនៅខាងមុខទ្រូងប្រសព្វគ្នា។ ប្រុសដៃឆ្វេងធ្វើដំណើរនៅខាងក្រៅ, ស្រីដៃស្ដាំធ្វើដំណើរនៅខាងក្រៅ (ដូចរូប៥.៥), នៅពេលដៃទាំងពីរប្រសព្វគ្នាបង្កើតជារាងអក្សរ "មួយ", ដៃដែលនៅខាងក្រៅ, កដៃបង្វិលឆ្ពោះទៅខាងក្រៅ, ព្រមទាំងបង្វែរបាតដៃឆ្ពោះឡើងលើ, ហើយគូរកន្លះរង្វង់មូលធំ, ក្លាយជាបាតដៃឆ្ពោះទៅលើ, ចុងម្រាមដៃឆ្ពោះទៅខាងក្រោយ, ដៃគួរប្រើកម្លាំងខ្លះ; ដៃដែលនៅខាងក្នុងបន្ទាប់ពីប្រសព្វគ្នា, ប្រអប់បាតដៃបន្តិចម្ដងបង្វិលឆ្ពោះទៅទិសខាងក្រោម, រហូតដល់សន្ទឹងត្រង់, បាតដៃ, ដើមដៃបង្វិលប្រែទៅជាប្រអប់បាតដៃឆ្ពោះទៅទិសខាងក្រៅ, បាតដៃ, ដើមដៃនៅទិសបញ្ឆៀងចុះក្រោមនៃរាងកាយជាមួយរាងកាយបង្កើតជាមុំស្រួច៣០ដឺក្រេ (ដូចរូប៥.៦)។

***ក្បាច់ដៃទីពីរ៖*** បន្តពីឥរិយាបថមុន (រូប៥.៦), ដៃឆ្វេង (ដៃដែលនៅខាងលើ) ពីក្នុងចេញទៅ, ដៃស្ដាំវិលបាតដៃឆ្ពោះចូលក្នុង, ហើយធ្វើដំណើរឡើងលើ, ចលនាគ្រាន់តែដូចក្បាច់ដៃទីមួយផ្លាស់ប្ដូរគ្នា, ទីតាំងរបស់ដៃផ្ទុយគ្នាវិញ (ដូចរូប៥.៧)។

***ក្បាច់ដៃទីបី៖*** ប្រុសដៃស្ដាំ (ស្រីដៃឆ្វេង) កដៃសន្ទឹងត្រង់, បាតដៃទល់មុខឆ្ពោះទៅរាងកាយ, បន្ទាប់ពីឆ្លងកាត់ចំណុចប្រសព្វគ្នាខាងមុខទ្រូង, ប្រអប់បាតដៃបង្វិលឆ្ពោះចុះក្រោម, ដោយផ្ទាល់បញ្ឆៀងចុះដល់ទីតាំងខាងមុខកំភួនជើង, ដៃត្រូវតែសន្ទឹងត្រង់;

ប្រុសដៃឆ្វេង (ស្រីដៃស្តាំ) បង្វិលប្រអប់បាតដៃឆ្ពោះចូលក្នុង, ធ្វើដំណើរឡើងលើ, បន្ទាប់ពីឆ្លងកាត់ចំណុចប្រសព្វគ្នា, បង្វិលកដៃ ហើយធ្វើចលនាឆ្ពោះទៅទិសខាងមុខស្នាខាងឆ្វេង (ស្រីស្តាំ), បន្ទាប់ពីដៃដល់ទីតាំង, ប្រអប់បាតដៃឆ្ពោះឡើងលើ, ចុងម្រាមដៃឆ្ពោះទៅមុខ (ដូចរូប៥.៨)។

***ក្បាច់ដៃទីបួន៖*** ដូចឥរិយាបថក្បាច់ដៃទីបីដោយដៃផ្លាស់ប្តូរគ្នា, ប្រុសដៃឆ្វេង (ស្រីដៃស្តាំ) ធ្វើដំណើរនៅខាងក្នុង, ប្រុសដៃស្តាំ(ស្រីដៃឆ្វេង)ធ្វើដំណើរនៅខាងក្រៅ, ចលនាគ្រាន់តែដៃឆ្វេង និងស្តាំប្តូរគ្នា, ទីតាំងរបស់ដៃផ្ទុយមកវិញ (ដូចរូប៥.៩)។ ៤ក្បាច់ដៃដំបូង, ចលនាតឹតជាប់គ្នា, មិនមានឈប់បង្អាក់។



រូប៥.១



រូប៥.២



រូប៥.៣



រូប៥.៤



រូប៥.៥



រូប៥.៦



រូប៥.៧



រូប៥.៨



រូប៥.៩



រូប៥.១០

***ពង្រឹងទេពអំណាចរាងមូល៖*** ធ្វើបន្ត 〝ក្បាច់ដៃទីបួន〞។ ដៃខាងលើធ្វើដំណើរនៅខាងក្នុង, ដៃខាងក្រោមធ្វើដំណើរនៅខាងក្រៅ, ប្រុសដៃស្តាំបន្តិចម្តងបង្វិលបាតដៃ, ប្រអប់បាតដៃឆ្ពោះចូលទ្រូងចុះក្រោម។ ប្រុសដៃឆ្វេង (ស្រីដៃស្តាំ) លើកឡើងលើ, នៅពេលកំភួនដៃទាំងពីរមកដល់ខាងមុខទ្រូងបង្កើតជារាងអក្សរ 〝មួយ〞 (ដូចរូប៥.១០)។ ដៃទាំងពីរទាញចេញឆ្ពោះទៅសងខាង, (ដូចរូប៥.១១) ហើយបង្វិលប្រអប់បាតដៃចុះក្រោម, នៅពេលដៃទាំងពីរមកដល់ទិសខាងក្រៅនិងខាងលើជង្គង់, កម្ពស់របស់ដៃស្មើកម្រិតចង្កេះ, កំភួនដៃនិងកដៃគឺផ្តេក, ដៃទាំងពីរសម្រាក (ដូចរូប៥.១២)។ តរិយាបថនេះគឺយកទេពអំណាចខាងក្នុងរាងកាយវាយនៅលើដៃដើម្បីពង្រឹង, គឺបង្ហាញចេញទេពអំណាចរូបមូល។ នៅពេល

ពង្រឹងទេពអំណាច, ប្រអប់បាតដៃនឹងមានអារម្មណ៍ក្តៅ, ធ្ងន់, ស្ពឹក អគ្គិសនី, ដូចជាមានវត្ថុជាដើម, ប៉ុន្តែកុំប្រើគំនិតដើម្បីស្វែងរកនិង ចំណង់, បណ្តោយតាមធម្មជាតិ។ ធ្វើឥរិយាបថនេះពេលវេលា កាន់តែយូរកាន់តែល្អ, រហូតដល់មិនអាចព្យាយាមបានទៀតទើប ឈប់។



រូប៥.១១



រូប៥.១២

***ពង្រឹងទេពអំណាចរាងសសរះ*** បន្តឥរិយាបថខាងលើ។ ដៃស្តាំ (ស្រីឆ្វេង) ទាំងព្រមបង្វិលប្រអប់បាតដៃឆ្ពោះឡើងលើ, ទាំងព្រមធ្វើចលនាឆ្ពោះទៅទីតាំងពោះទាប, បន្ទាប់ពីដៃដល់ទីតាំង, ប្រអប់បាតដៃឆ្ពោះឡើងលើនៅទីតាំងពោះទាប; នៅពេលដំណាលគ្នាជាមួយចលនារបស់ដៃស្តាំ, ដៃឆ្វេង (ស្រីស្តាំ) ទាំងព្រមលើកឡើង, ទាំងព្រមធ្វើចលនាឆ្ពោះទៅទីតាំងក្រោមចង្កា, ប្រអប់បាតដៃនៅតែឆ្ពោះចុះក្រោម, កម្ពស់របស់ដៃស្មើកម្រិតនឹងក្រោមចង្កា, កំភួនដៃនិងបាតដៃគឺផ្តេក។ នៅពេលនោះ, ប្រអប់បាតដៃនៃដៃទាំងពីរទល់មុខគ្នា, ឥរិយាបថសមាធិ (ដូចរូប៥.១៣), នេះគឺជាពង្រឹងទេពអំណាចរាងសសរ, ដូចជាប្រភេទបាតដៃរន្ទះ។ ធ្វើដល់

ខ្លួនឯងមានអារម្មណ៍ថាមិនអាចព្យាយាមបានទៀតទើបឈប់។ បន្ទាប់មក, ដៃខាងលើពីទិសខាងមុខគូររូបពាក់កណ្តាលរង្វង់មូលមួយ, ទម្លាក់ចុះនៅទីតាំងពោះទាប; ក្នុងពេលដំណាលគ្នា, ដៃខាងក្រោមលើកឡើងលើ, ហើយក្រឡាប់ប្រអប់បាតដៃឆ្ពោះចុះក្រោម, លើកដល់ទីតាំងក្រោមចង្កា, (ដូចរូប៥.១៤)។ ដើមដៃស្មើកម្រិតនឹងស្មា, ប្រអប់បាតដៃនៃដៃទាំងពីរទល់មុខគ្នា។ នេះក៏ជាពង្រឹងទេពអំណាចរាងសសរ, គ្រាន់តែជាឥរិយាបថដៃផ្ទុយមកវិញប៉ុណ្ណោះ។ ធ្វើពេលវេលារហូតដល់ដៃរោយមិនអាចព្យាយាមបានទៀតគឺល្មម។



រូប៥.១៣



រូប៥.១៤

***បួសហាត់បិតិវន្តគង់៖*** បន្តឥរិយាបថខាងលើ, បន្ទាប់មក, ដៃខាងលើពីទិសខាងមុខគូររូបពាក់កណ្តាលរង្វង់មូលទម្លាក់ទៅទី

តាំងពោះទាប, ដៃទាំងពីរបង្កើតជាសភាពភ្ជាប់ត្រា (ដូចរូប៥.១៥), ឈានចូលក្នុងបួសហាត់បិតិវន្តគង់។ ចូលទៅក្នុងសមាធិ, ពេលវេលាកាន់តែយូរកាន់តែល្អ។

***ដកឥរិយាបថ៖*** ដៃទាំងពីរ "រួមដប់" (ដូចរូប៥.១៦), ចេញពីសមាធិ, ដោះសភាពបត់ប្រសព្វជើង។



រូប៥.១៥



រូប៥.១៦

# តម្រូវការនិងការប្រុងប្រយ័ត្នជាមូលដ្ឋានមួយចំនួននៃការប្ញូស ហាត់ហ្វាលូនគង់

១. ប្រាំសំណុំគង់ហ្វារបស់ហ្វាលូនគង់, អាចហាត់តាមលំដាប់លំដោយ, ក៏អាចជ្រើសរើសហាត់តាមចិត្តផងដែរ។ ប៉ុន្តែ, ជាធម្មតាតម្រូវហាត់សំណុំទីមួយមុនដំបូង, លើសពីនេះទៀតហាត់៣ដងបន្តបន្ទាប់ជាការប្រសើរ។ ជាការពិត, មិនហាត់សំណុំទីមួយ, ក៏អាចហាត់បណ្តាសំណុំឯទៀតមុនដំបូង, សំណុំលំហាត់នីមួយៗសុទ្ធតែអាចហាត់ដោយឡែកបាន។

២. ចលនាត្រូវជាក់លាក់, ចង្វាក់ត្រូវច្បាស់លាស់, បាតដៃនិងដើមដៃត្រូវតែទន់ភ្លន់, លើក្រោម, មុខក្រោយ, ឆ្វេងស្តាំ, ទាំងអស់ត្រូវ "ទន់ភ្លន់-យឺត-មូល" ធ្វើដំណើរតាមយន្តការឈើ។ មិនបានលឿនហួស, ក៏មិនបានយឺតហួស។

៣. នៅក្នុងហាត់គង់ត្រូវតែយកសតិម្ចាស់ឃុំគ្រងខ្លួនឯង។ ហ្វាលូនគង់គឺប្ញូសហាត់សតិម្ចាស់, មិនបានដោយចេតនាដើម្បីស្វែងរកការរំញ័រ, ប្រសិនបើមានរំញ័រជាក់ស្តែងត្រូវតែឃុំគ្រងឱ្យជាប់, ពេលចាំបាច់, អាចបើកភ្នែកចេញបាន។

៤. រាងកាយទាំងមូលសម្រាក។ ពិសេសគឺជង្គង់និងចង្កេះត្រូវតែសម្រាក, ឈរត្រង់ខ្លាំងពេក, ខ្សែរណ្តាឈើគឺមិនរលូនបាន។.

៥. ក្នុងអំឡុងពេលហាត់គង់, ចលនាត្រូវតែធូរស្រាលតាមធម្មជាតិ, លាតសន្ធឹងទូលាយ, ក្នុងទន់មានរឹង, យ៉ាងរលូនដូចបំណង, មានកម្លាំងជាក់លាក់, ក៏មិនតឹងរឹងផងដែរ។ ធ្វើចលនាដូច្នេះ,

ប្រសិទ្ធភាពនឹងបង្ហាញយ៉ាងច្បាស់។

៦. រាល់ពេលដែលហាត់គង់ចប់, "គ្រាន់តែដកឥរិយាបថ, មិនដកគង់", គ្រាន់តែធ្វើចលនា "ភ្ជាប់ត្រា" គឺបានហើយ, ភ្ជាប់ត្រាចប់, ដកឥរិយាបថបញ្ចប់។ មិនចាំបាច់ប្រើគំនិតដើម្បីដកគង់, ដោយសារតែហ្វាលូនគឺមិនអាចបញ្ឈប់បង្វិលបាន។

៧. អ្នកជំងឺរ៉ាំរ៉ៃរាងកាយខ្សោយ, អាចយោងតាមកាលៈទេសៈជាក់ស្តែងដើម្បីហាត់តិចជាង, ឬក៏ជ្រើសរើសសំណុំលំហាត់ណាមួយដើម្បីប្ញូសហាត់។ មិនអាចហាត់ថាមវន្តគង់អាចអង្គុយសមាធិ។ ហាត់គង់ជាទូទៅមិនគួរឈប់បន្ត។

៨. ទីកន្លែង, ពេលវេលា, និងទិសដៅហាត់គង់គ្មានតម្រូវពិសេស, ប៉ុន្តែទីកន្លែងគួរតែបរិសុទ្ធ, បរិយាកាសគួរតែស្ងប់ស្ងាត់។

៩. ហាត់គង់នេះមិននាំគំនិតជាមួយ, នឹងមិនកើតចេញគម្លាត។ ប៉ុន្តែមិនបានលាយបញ្ចូលជាមួយនឹងគង់ហ្វាដទៃ, ប្រសិនបើនៅពេលហាត់គង់បន្ថែមចូលគង់ហ្វាផ្សេង, ហ្វាលូនគឺនឹងខូចទ្រង់ទ្រាយ។

១០. នៅពេលហាត់គង់ពិតជាស្ងប់ចុះមិនបាន, អាចសូត្រឈ្មោះរបស់លោកគ្រូ, យូរៗទៅតាមធម្មជាតិនឹងស្ងប់ចុះបាន។

១១. នៅពេលហាត់គង់នឹងជួបប្រទះទុក្ខវេទនាមួយចំនួន, ទុក្ខវេទនាជាមួយប្រភេទវិធីសង "កម្ម"។ មនុស្សម្នាក់ៗសុទ្ធតែមាន "កម្ម", ពេលរាងកាយលេចឡើងមិនសុខស្រួល, មិនបានសន្មតថាគឺមានជំងឺ។ ដើម្បីរំលាយ "កម្ម", បោសជម្រះផ្លូវសម្រាប់ប្ញូស

ហាត់, ទុក្ខវេទនានឹងមកដល់ឆាប់រហ័សជាង, ជាមុនជាង។

១២. នៅពេលអង្គុយសមាធិបត់ប្រសព្វជើងឡើងមិនបាន, អាចមុនដំបូងអង្គុយនៅលើគែមកៅអីដើម្បីហាត់គង់, ក៏អាចទទួលបានប្រសិទ្ធភាពដូចគ្នា។ ប៉ុន្តែ, ធ្វើជាមនុស្សហាត់គង់, ត្រូវតែអាចអង្គុយបត់ប្រសព្វជើងបាន, ពេលវេលាយូរទៅជាបណ្តើរទីបំផុតនឹងបត់ប្រសព្វឡើងបាន។

១៣. ក្នុងពេលហាត់បិតិវន្តគង់, ប្រសិនបើមើលឃើញរូបភាព, ឬក៏ទស្សនីយភាពមួយចំនួន, មិនបានទៅចាប់អារម្មណ៍នឹងវា, នៅតែហាត់គង់របស់ខ្លួនឯង។ ប្រសិនបើមានបាតុភូតភ័យរន្ធត់ជ្រៀតជ្រែក, ឬក៏ទទួលរងនូវបំភ័យអ្វីមួយ, ត្រូវតែនឹកភ្លាមដល់៖ ៶ខ្ញុំមានលោកគ្រូហ្វាលូនគង់ការពារ, អ្វីក៏មិនខ្លាច៍; ឬក៏ស្រែកហៅឈ្មោះរបស់លោកគ្រូលី, បន្តហាត់គង់។

# ជំពូកទី៥ • ឆ្លើយសំណួរ

## I. ហ្វាលូននិងហ្វាលូនគង់

*សិស្ស៖ តើហ្វាលូនបានបង្កើតឡើងដោយអ្វី?*

គ្រូ៖ ហ្វាលូនគឺជាមួយប្រភេទរាងកាយវិញ្ញាណដែលបង្កើតឡើងដោយសារធាតុថាមពលខ្ពស់, បំលែងគង់ដោយខ្លួនឯង, មិនស្ថិតនៅក្នុងអវកាសរបស់ពួកយើងនេះ។

*សិស្ស៖ តើហ្វាលូន(ធម្មចក្រ)មានរាងដូចអ្វី?*

គ្រូ៖ ពណ៌របស់ហ្វាលូនគ្រាន់តែអាចនិយាយថាជាពណ៌មាសលឿង, អវកាសរបស់ពួកយើងនេះនៅមិនទាន់មានពណ៌ប្រភេទនេះ។ ផ្ទៃខាងក្រោយនៃរង្វង់គឺពណ៌ក្រហមស្រស់ស្អាតខ្លាំងណាស់; ផ្ទៃខាងក្រោយនៃរង្វង់ខាងក្រៅគឺពណ៌ទឹកក្រូច; មាន២ថៃជីក្រហមនិងខ្មៅគឺជាតាវវង្ស; មាន២ថៃជីក្រហមនិងផ្ទៃមេឃគឺជាមហាតាវពីកំណើត, នេះគឺជាពីរប្រភេទមិនដូចគ្នា, និមិត្តសញ្ញា "卍" គឺជាពណ៌មាសលឿង។ មនុស្សដែលមានជាន់ថ្នាក់បញ្ញាញាណទាបមើលឃើញគឺវិលៗនោះដូចកង្ហារអគ្គិសនី, ប្រសិនបើអាចមើលឃើញច្បាស់គឺស្អាតណាស់, នឹងធ្វើឱ្យការបួសហាត់របស់មនុស្សហាត់គង់កាន់តែក្លាហានឧស្សាហ៍ព្យាយាមថែមទៀត។

*សិស្ស៖ ហ្វាលូនកាលពីដំបូងនៅទីតាំងណា? បន្ទាប់មកនៅទីតាំងណា?*

គ្រូ៖ ហ្វាលូនដែលខ្ញុំពិតជាផ្តល់ឱ្យអ្នករាល់គ្នាមានតែមួយ

ប៉ុណ្ណោះ, នៅទីតាំងពោះទាប, ក៏ជាក់ស្តែងជាទីតាំងដែលពួកយើងនិយាយថាហាត់តានរក្សាតាន, ទីតាំងរបស់គាត់គឺមិនផ្លាស់ប្តូរ។ មនុស្សខ្លះអាចមើលឃើញហ្វាលូនជាច្រើនកំពុងបង្វិល, នោះគឺជាបរមីរបស់ខ្ញុំប្រើខាងក្រៅកំពុងកែសំរួលរាងកាយឱ្យលោកអ្នក។

*សិស្ស៖ តើហាត់គង់, អាចហាត់ចេញហ្វាលូនបានឬទេ? អាចហាត់ចេញបានប៉ុន្មាន? មួយនេះនិងដែលលោកគ្រូផ្តល់ឱ្យមានអ្វីខុសគ្នា?*

គ្រូ៖ ហាត់គង់អាចហាត់ចេញហ្វាលូន, ខណៈពេលអំណាចគង់របស់លោកអ្នកបន្តកើនឡើងជ្រៅថែម, ហ្វាលូនជាក់ស្តែងនឹងកាន់តែច្រើន, ហ្វាលូនគឺជាទម្រង់តែមួយ, គ្រាន់តែហ្វាលូនដែលនៅពោះទាបនឹងមិនផ្លាស់ទីទៅកន្លែងណា, នោះគឺជាឫស។

*សិស្ស៖ តើធ្វើដូចម្តេចពិនិត្យបានវត្តមាននិងការបង្វិលរបស់ហ្វាលូន?*

គ្រូ៖ មិនចាំបាច់ទៅពិសោធ, មនុស្សខ្លះឆាប់រសើបណាស់, គាត់នឹងមានអារម្មណ៍ថាហ្វាលូនកំពុងបង្វិល។ នៅពេលហ្វាលូនទើបបានដំឡើងកាលពីដំបូង, លោកអ្នកអាចនឹងមានអារម្មណ៍ថាក្នុងរាងកាយមានអ្វីមួយចំនួនមិនសម្របខ្លួន, ឈឺពោះ, មានអ្វីមួយកំពុងផ្លាស់ប្តូរ, មានអារម្មណ៍ក្តៅ។ល។ រង់ចាំបន្ទាប់ពីសម្របខ្លួនរួចហើយ, នឹងមិនមានអារម្មណ៍ទៀត។ ប៉ុន្តែមនុស្សដែលមានសីលគង់អាចមើលឃើញ, ជាក់ស្តែងដូចគ្នានឹងក្រពះដែរ, លោកអ្នកនឹងមិនមានអារម្មណ៍ក្រពះកំពុងផ្លាស់ប្តូរ។

*សិស្ស៖ ទិសដៅបង្ហិលនៃហ្វាលូនលើនិមិត្តរូបហ្វាលូនជាមួយនឹងហ្វាលូនលើកាតរបស់សិក្ខាកាមមិនដូចគ្នា (អំពី(វគ្គបង្រៀន) វដ្ដកាលទី១, ២នៅប៉េកាំង), ហ្វាលូននៅលើកាតរបស់សិក្ខាកាមសម្រាប់ការបង្រៀនគឺវិលបញ្ច្រាសទ្រនិចនាឡិកា, ហេតុអ្វី?*

គ្រូ៖ គោលបំណងជាក់ស្តែងគឺផ្តល់ឱ្យអ្នករាល់គ្នាអ្វីល្អមួយចំនួន, គាត់ឆ្ពោះចេញក្រៅបញ្ចេញថាមពលគឺកែសំរួលរាងកាយឱ្យអ្នករាល់គ្នា, ដូច្នេះគឺមិនបង្វិលតាមទ្រនិចនាឡិកា, លោកអ្នកអាចមើលឃើញគាត់គឺបង្វិល។

*សិស្ស៖ តើលោកគ្រូដំឡើងហ្វាលូនឱ្យសិក្ខាកាមម្នាក់ៗនៅពេលណា?*

គ្រូ៖ នៅទីនេះពួកយើងជាមួយនឹងអ្នករាល់គ្នានិយាយបន្តិច, ពួកយើងមានសិក្ខាកាមមួយចំនួនធ្លាប់បានហាត់ជាច្រើនគង់ហ្វា, ពិបាកគឺពិបាកនៅកន្លែងត្រូវយកភាពរញ៉េរញ៉ៃនៅលើរាងកាយរបស់គាត់កម្ចាត់ចោលទាំងអស់, អ្វីល្អរក្សាទុក, អ្វីអាក្រក់កម្ចាត់ចោល, បន្ថែមនីតិវិធីមួយទៀត។ បន្ទាប់ពីនោះ, ជាក់ស្តែងអាចដំឡើងហ្វាលូនបាន។ យោងទៅតាមគាត់ហាត់គង់ជាន់ថ្នាក់ខ្ពស់ឬទាប, ហ្វាលូនដែលបានដំឡើងធំឬតូចមិនដូចគ្នា។ មនុស្សមួយចំនួនមិនធ្លាប់បានហាត់គង់, ឆ្លងកាត់ការកែសំរួល, និស្ស័យក៏ល្អ, នៅលើថ្នាក់បង្រៀនរបស់ខ្ញុំនេះជំងឺបានកម្ចាត់រួចហើយ, ដើរចេញផុតពីជាន់ថ្នាក់ហាត់ឈី, ចូលទៅក្នុងស្ថានភាពរាងកាយសដូចទឹកដោះ, ក៏អាចដំឡើងហ្វាលូនបានផងដែរ។ មនុស្សជាច្រើនរាង

កាយអន់ខ្សោយណាស់, តែងតែកំពុងកែសំរួល, មិនបានកែសំរួលឱ្យល្អតើធ្វើម្ដេចដំឡើងហ្វាលូនបាន? នេះគ្រាន់តែជាមនុស្សមួយចំនួនតូចដំឡើងមិនបាន, មិនចាំបាច់ប្រញាប់, ខ្ញុំបានដំឡើងយន្តការឈើដែលបង្កើតហ្វាលូនរួចហើយ។

*សិស្ស៖ ហ្វាលូនគឺបាននាំយកជាមួយដោយរបៀបណា?*

គ្រូ៖ នេះគឺមិនមែននាំយកជាមួយ។ ខ្ញុំយកហ្វាលូនវាយចេញទៅដំឡើងនៅទីតាំងពោះទាបរបស់លោកអ្នក, ប៉ុន្ដែមិនមែននៅក្នុងអវកាសសារធាតុរបស់យើងនេះ, នៅក្នុងអវកាសដទៃទៀត, ប្រសិនបើនៅក្នុងអវកាសនេះ, ទីតាំងពោះទាបរបស់លោកអ្នកមានពោះវៀន, មានពោះវៀនទីនោះហើយបង្វិលគឺបង្វិលបានទេ? គាត់គឺនៅក្នុងអវកាសសារធាតុមួយផ្សេង, គ្មានប៉ះទង្គិចជាមួយនឹងលោកអ្នកនៅខាងនេះ។

*សិស្ស៖ តើថ្នាក់បង្រៀនបន្ទាប់នឹងបន្តផ្ដល់ឱ្យហ្វាលូនឬទេ?*

គ្រូ៖ លោកអ្នកគ្រាន់តែទទួលបានមួយប៉ុណ្ណោះ។ មនុស្សខ្លះមានអារម្មណ៍មានហ្វាលូនជាច្រើនកំពុងបង្វិល, នោះគឺប្រើខាងក្រៅ, ប្រើដើម្បីកែសំរួលរាងកាយរបស់លោកអ្នក។ លក្ខណៈធំបំផុតនៃគង់របស់ពួកយើងនេះគឺនៅពេលបញ្ចេញថាមពលវាយចេញទៅទាំងខ្សែៗហ្វាលូន, ដូច្នេះលោកអ្នកមិនហាត់គង់ក៏មានយ៉ាងច្រើនហ្វាលូននៅលើរាងកាយលោកអ្នកវិលមកវិលទៅ, កែសំរួលរាងកាយរបស់លោកអ្នក។ ហ្វាលូនដែលពិតជាផ្ដល់ឱ្យលោកអ្នកគឺមួយនោះនៅទីតាំងពោះទាប។

*សិស្ស៖ តើមិនហាត់គង់មានន័យថាហ្វាលូននឹងរលាយបាត់? តើហ្វាលូនអាចស្ថិតនៅរយៈពេលប៉ុន្មាន?*

គ្រូ៖ ដរាបណាលោកអ្នកមើលខ្លួនឯងជាមនុស្សហាត់គង់, យោងតាមតម្រូវចិត្តគំនិតដែលខ្ញុំបានសម្តែងដើម្បីធ្វើ, នៅពេលលោកអ្នកមិនហាត់គង់, គាត់មិនត្រឹមតែនឹងមិនរលាយបាត់ប៉ុណ្ណោះទេ, ផ្ទុយមកវិញនៅតែខ្លាំងថែមទៀត, អំណាចគង់របស់លោកអ្នកនៅតែនឹងកើនឡើង។ ប៉ុន្តែផ្ទុយមកវិញ, លោកអ្នកហាត់គង់ឧស្សាហ៍ព្យាយាមជាងនរណាទាំងអស់, ប៉ុន្តែមិនយោងតាមចិត្តគំនិតដែលខ្ញុំតម្រូវដើម្បីធ្វើ, ខ្លាចតែហាត់ក៏ដូចជាមិនហាត់, ទោះបីហាត់គង់, ក៏គ្មានប្រសិទ្ធភាព។ មិនថាលោកអ្នកហាត់ប្រភេទគង់ហ្វាណាមួយ, មិនយោងតាមតម្រូវដើម្បីធ្វើ, ទំនងណាស់អ្វីដែលហាត់បានគឺជាទុចរិតធម៌។ ប្រសិនបើក្នុងខួរក្បាលរបស់លោកអ្នកតែងតែគិតពីរឿងមិនល្អ, "នរណាហេតុម្តេចអាក្រក់យ៉ាងនោះ? រង់ចាំខ្ញុំបញ្ចេញសីសគង់បានរួចហើយនឹងមិនខកខានកែគាត់ម្តង"។ ជាក់ស្តែងគឺរៀនហ្វាលូនគង់, នៅក្នុងហាត់គង់បន្ថែមចូលអ្វីទាំងនេះ, មិនយោងតាមតម្រូវចិត្តគំនិតដែលខ្ញុំនិយាយ, តើមិនមែនកំពុងហាត់ទុចរិតធម៌ទេឬ?

*សិស្ស៖ លោកគ្រូតែងតែនិយាយ "ហ្វាលូនទោះបីចំណាយលុយ១០០លានយ័នក៏ទទួលមិនបានដែរ" គឺមានន័យអ្វី?*

គ្រូ៖ នោះគឺនិយាយថា, គាត់ដ៏មានតម្លៃណាស់។ អ្វីដែលខ្ញុំផ្តល់ឱ្យលោកអ្នកមិនត្រឹមតែគឺហ្វាលូនប៉ុណ្ណោះទេ, នៅមានប្រការ

មួយចំនួនដែលធានាឱ្យលោកអ្នកហាត់គង់គឺសុទ្ធតែដ៏មានតម្លៃទាំងអស់, គឺសុទ្ធតែមាសរាប់ពាន់ប្តូរមិនបាន។

*សិស្ស៖ តើមកឃើតពេលអាចឬក៏មិនអាចទទួលបានហ្វាលូន?*

គ្រូ៖ ដរាបណាលោកអ្នកគឺមកមុនបីថ្ងៃចុងក្រោយ, សុទ្ធតែអាចទទួលបានការកែសំរួល, ក្នុងពេលដំណាលគ្នាដំឡើងហ្វាលូននិងប្រការផ្សេងទៀត។ បីថ្ងៃចុងក្រោយទើបមកគឺពិបាកនិយាយណាស់, ប៉ុន្តែក៏នឹងទទួលបានការកែសំរួល, ដំឡើងអ្វីគឺពិបាកណាស់, ប្រហែលជាលក្ខខណ្ឌរបស់លោកអ្នកល្អក៏ដំឡើងបានផងដែរ។

*សិស្ស៖ តើប្រើហ្វាលូនដើម្បីកែតម្រូវស្ថានភាពមិនត្រឹមត្រូវនៃរាងកាយមនុស្សគឺជាមួយប្រភេទវិធីសាស្ត្រមែនទេ?*

គ្រូ៖ មិនមែនទាំងអស់ប្រើហ្វាលូនដើម្បីកែតម្រូវទេ, លោកគ្រូនឹងប្រើជាច្រើនវិធីសាស្ត្រដើម្បីកែតម្រូវ។

*សិស្ស៖ តើសាវតាបុរេប្រវត្តិនៃការបង្កើតហ្វាលូនគង់ដូចម្តេច?*

គ្រូ៖ ខ្ញុំគិតថាបញ្ហាមួយនេះធំខ្លាំងណាស់, ខ្ពស់ខ្លាំងណាស់, ហួសពីវិសាលភាពជាន់ថ្នាក់មួយនេះរបស់ពួកយើងគួរដឹង, នៅទីនេះមិនអាចសម្តែង។ តែមានមួយចំណុច, អ្នករាល់គ្នាត្រូវតែដឹង, នេះមិនមែនឈីគង់ពុទ្ធសាសនា, នេះគឺជាឈីគង់ពុទ្ធវង្ស, គាត់មិនមែនពុទ្ធសាសនា។ ប៉ុន្តែពួកយើងជាមួយនឹងពុទ្ធសាសនាមានគោលដៅរួមតែមួយ, គ្រាន់តែធម្មក្ខន្ធបួសមិនដូចគ្នា, ផ្លូវដើរមិនដូច

គ្នា, គោលដៅគឺដូចគ្នា។

*សិស្ស៖ ប្រវត្តិសាស្ត្រហ្វាលូនគង់មានរយៈពេលយូរប៉ុន្មាន?*

គ្រូ៖ គង់ហ្វាដែលខ្ញុំហាត់មិនដូចគ្នាទាំងស្រុងជាមួយនឹងសំណុំអ្វីបង្រៀនចេញមកនេះ។ ហ្វាលូនដែលខ្ញុំហាត់អានុភាពធំជាងប្រៀបធៀបនឹង(ហ្វាលូន)បង្រៀនចេញ, បង្កើនគង់ក៏ឆាប់រហ័សជាងប្រៀបជាមួយនឹងសំណុំគង់ហ្វាបច្ចុប្បន្ន។ ទោះបីដូច្នោះក្តី, សំណុំគង់ហ្វាមួយនេះដែលខ្ញុំបង្រៀនចេញបច្ចុប្បន្នក៏បង្កើនគង់ឆាប់រហ័សណាស់រួចហើយ, ដូច្នេះសម្រាប់តម្រូវចិត្តគំនិតរបស់អ្នកហាត់គង់ជាក់ស្តែងកាន់តែខ្ពស់កាន់តែតឹងរឹង។ អ្វីដែលខ្ញុំបង្រៀនចេញមកគឺបន្ទាប់ពីបានកែសំរួលរួចហើយនាំចេញមក, តម្រូវក៏មិនខ្ពស់ដូចនោះ, ប៉ុន្តែខ្ពស់ជាងប្រៀបនឹងគង់ធម្មតា, គាត់ខុសជាមួយនឹងរបស់ដើម, ដូច្នេះជាក់ស្តែងនិយាយថាខ្ញុំគឺជាស្ថាបនិក។ ដូចជាសួរថាតើប្រវត្តិហ្វាលូនគង់មានរយៈពេលនប៉ុន្មាន, មិនរាប់បញ្ចូលពេលមិនទាន់នាំចេញមកបង្រៀន, ខ្ញុំគឺខែឧសភាឆ្នាំមុន(១៩៩២)ចាប់ផ្តើមនៅភាគឦសានបង្រៀនគង់, លោកអ្នកអាចនិយាយថាគាត់គឺបានចាប់ផ្តើមពីខែឧសភាឆ្នាំមុន។

*សិស្ស៖ ពួកកូនស្តាប់សម្តែង, តើលោកគ្រូផ្តល់ឱ្យពួកកូនអ្វីខ្លះ?*

គ្រូ៖ ហ្វាលូនផ្តល់ឱ្យអ្នករាល់គ្នារួចហើយ។ មានហ្វាលូនដើម្បីឬសហាត់, នៅមានហ្វាលូនដើម្បីកែសំរួលរាងកាយទៀត, ក្នុងពេលដំណាលគ្នានៅមានបរមីរបស់ខ្ញុំកំពុងមើលថៃលោកអ្នក,

ម្នាក់ៗសុទ្ធតែមាន, ដរាបណាលោកអ្នកគឺហាត់ហ្វាលូនគង់។ លោកអ្នកមិនហាត់គង់បរមីតាមធម្មជាតិមិនគ្រប់គ្រងលោកអ្នក, ហៅគាត់ទៅគាត់ក៏មិនទៅដែរ។ លោកអ្នកកំពុងគិតអ្វី, បរមីរបស់ខ្ញុំដឹងច្បាស់ណាស់, ថ្លាខ្លាំងណាស់។

*សិស្ស៖ តើហ្វាលូនគង់អាចធ្វើឱ្យខ្លួនកូនបួសសម្រេចមគ្គផលខ្ពស់បំផុតបានទេ?*

គ្រូ៖ មហាធម៌គ្មានដែន។ ជាក់ស្តែងគឺបួសដល់ជាន់ថ្នាក់យូឡាយ, ក៏មិនត្រូវជាកំពូល។ ពួកយើងគឺជាសុចរិតធម៌, លោកអ្នកបួសទៅ! ដែលទទួលបានសុទ្ធតែបួសសម្រេចមគ្គផលខ្ពស់បំផុត។

## II. គោលសីលធម៌និងលំហាត់

*សិស្ស៖ មនុស្សខ្លះធ្វើចប់ "រង្វង់សកលធំ" ត្រឡប់ទៅផ្ទះ, សុបិន្តកំពុងអណ្តែតលើមេឃ, មើលឃើញច្បាស់លាស់ណាស់, នេះគឺជារឿងដូចម្តេច?*

គ្រូ៖ ខ្ញុំប្រាប់អ្នករាល់គ្នា, លោកអ្នកពេលកំពុងអង្គុយសមាធិឬក៏ពេលយល់សប្តិលេចឡើងប្រភេទកាលៈទេសៈនេះ, មិនមែនសុបិន្ត, គឺវិញ្ញាណដើមឃ្លាតពីរាងកាយ, នេះគឺខុសគ្នាឆ្ងាយពីសុបិន្ត។ យល់សប្តិនឹងមើលមិនឃើញច្បាស់លាស់ដូច្នោះ, លំអិតដូច្នោះ។ វិញ្ញាណដើមឃ្លាតពីរាងកាយ, លោកអ្នកមើលឃើញអ្វីមួយចំនួន, សូម្បីតែអណ្តែតឡើងដូចម្តេច, លោកអ្នកនឹងមើលឃើញពិតណាស់, ចងចាំបានច្បាស់ណាស់។

*សិស្ស៖ បន្ទាប់ពីហ្វាលូនខូចទ្រង់ទ្រាយនឹងមានផលវិបាកមិនល្អអ្វី?*

គ្រូ៖ ពន្យល់ថាគាត់ដើរគម្លាតហើយ, ហ្វាលូនជាក់ស្ដែងនឹងបាត់ប្រសិទ្ធភាព, លើសពីនេះទៀតនៅនាំមកឱ្យលោកអ្នករឿងរំខានជាច្រើននៅក្នុងការបួសហាត់, ដូចជាផ្លូវធំនេះលោកអ្នកមិនដើរ, ហើយដើរផ្លូវបំបែកវង្វេងផ្លូវ, រកផ្លូវចេញមិនបាន, នឹងជួបប្រទះរឿងរំខាន។ រឿងទាំងនេះនឹងឆ្លុះបញ្ចាំងនៅក្នុងស្ថានភាពរស់នៅរបស់មនុស្សសាមញ្ញ។

*សិស្ស៖ មនុស្សម្នាក់ហាត់គង់, បរិយាកាសនៅក្នុងផ្ទះដោះស្រាយដូចម្ដេច? តើនៅក្នុងផ្ទះអាចមានហ្វាលូនទេ?*

គ្រូ៖ អង្គុយនៅទីនេះ, ធ្លាប់មានមនុស្សជាច្រើនបានមើលឃើញនៅក្នុងផ្ទះមានហ្វាលូនស្ថិតនៅ, មនុស្សនៅក្នុងផ្ទះក៏ធ្លាប់ចាប់ផ្ដើមទទួលអត្ថប្រយោជន៍។ ពួកយើងធ្លាប់បានសម្ដែង, ក្នុងពេលតែមួយកន្លែងតែមួយមានដ៏ច្រើនអវកាសស្ថិតនៅ, ក្នុងផ្ទះរបស់លោកអ្នកក៏គ្មានករណីលើកលែងដែរ, ចាំបាច់ត្រូវតែដោះស្រាយ។ វិធីសាស្ត្រដោះស្រាយ, ជាធម្មតាគឺកម្ចាត់ចោលអ្វីដែលមិនល្អ, បន្ទាប់មកដាក់គម្របមួយ, អ្វីដែលមិនល្អក៏ចូលទៅក្នុងមិនបាន។

*សិស្ស៖ ខណៈពេលហាត់គង់ឈើសម្រុកចូលកន្លែងមានជំងឺ, មានអារម្មណ៍ឈឺនិងហើមគឺជារឿងដូចម្ដេច?*

គ្រូ៖ ជំងឺគឺជាមួយប្រភេទនៃក្រុមថាមពលពណ៌ខ្មៅ។ នៅថ្នាក់បង្រៀនដំណាក់កាលដំបូងបន្ទាប់ពីវាយបំបែកវា, នឹងមានអារម្មណ៍ថាទីតាំងដែលមានជំងឺហើមឡើង, ទោះយ៉ាងណាក៏ដោយវាបានបាត់បង់ឫសរួចហើយ, កំពុងបង្វែរទៅខាងក្រៅ, យ៉ាងឆាប់រហ័សនឹងបណ្ដេញចេញ, ជំងឺជាក់ស្ដែងមិនស្ថិតនៅទៀត។

*សិស្ស៖ ជំងឺដែលធ្លាប់មានពីមុនចូលរួមថ្នាក់បង្រៀនពីរបីថ្ងៃបានរលាយបាត់អស់, ប៉ុន្ដែឆ្លងបានប៉ុន្មានថ្ងៃស្រាប់តែលេចឡើងម្ដងទៀត, នេះគឺជារឿងដូចម្ដេច?*

គ្រូ៖ ដោយសារតែគង់នេះជាន់ថ្នាក់កើនឡើងឆាប់រហ័សខ្លាំងណាស់, មួយជាន់ថ្នាក់ក្នុងរយៈពេលដ៏ខ្លីកន្លងផុតទៅរួចហើយ, លោកអ្នកសុទ្ធតែមិនពិនិត្យបាន, តាមពិតជំងឺបានជាសះស្បើយរួចហើយ។ រោគសញ្ញានៅពេលក្រោយគឺជា "គ្រោះមហន្តរាយ" ដែលខ្ញុំធ្លាប់សម្ដែងបានមកដល់, លោកអ្នកពិនិត្យដោយប្រុងប្រយ័ត្នបន្តិច, គឺមិនដូចគ្នាជាមួយនឹងរោគសញ្ញាដែលលោកអ្នកធ្លាប់មានពីមុន។ លោកអ្នកទៅរកគ្រូឈីគង់ផ្សេងមកកែសំរួល, គាត់ក៏ប៉ះមិនបានដែរ, គឺជាប្រតិកម្មរបស់អំណាចកម្មនៅពេលបង្កើនគង់។

*សិស្ស៖ តើហាត់គង់នៅចាំបាច់លេបថ្នាំឬទេ?*

គ្រូ៖ បញ្ហាមួយនេះភ្ញាក់ដឹងដោយខ្លួនឯង, ហាត់គង់តែលេបថ្នាំជាក់ស្ដែងគឺមិនជឿថាហាត់គង់អាចព្យាបាលជំងឺ, ជឿហើយលោកអ្នកនៅលេបថ្នាំអ្វីទៀត។ ប៉ុន្ដែលោកអ្នកមិនយោងតាមបរមាណីយចិត្ដគំនិតដើម្បីតម្រូវខ្លួនឯង, លេចឡើងបញ្ហាហើយលោកអ្នកនឹង

និយាយថាលីហ៊ុងជីមិនឱ្យលេបថ្នាំ, ប៉ុន្តែលីហ៊ុងជីនៅហៅលោកអ្នកតឹងរឹងតម្រូវចិត្តគំនិតរបស់លោកអ្នក, តើលោកអ្នកធ្វើបានឬទេ? មនុស្សដែលពិតជាប្ញសហាត់មហាធម៌, ដែលនាំជាមួយនៅលើរាងកាយសុទ្ធតែមិនមែនជាអ្វីរបស់មនុស្សសាមញ្ញ, ជំងឺដែលមនុស្សសាមញ្ញកើតមានសុទ្ធតែមិនត្រូវបានអនុញ្ញាតឱ្យកើតឡើងនៅលើរាងកាយរបស់លោកអ្នក។ ចិត្តរបស់លោកអ្នកប្រសិនបើដាក់ឱ្យបានត្រឹមត្រូវ, ជឿថាហាត់គង់អាចហាត់បានល្អ, បញ្ឈប់ថ្នាំ, មិនទៅកង្វល់, មិនទៅព្យាបាល, គឺមានមនុស្សព្យាបាលឱ្យលោកអ្នករួចហើយ។ អ្នករាល់គ្នានៅទីនេះកាន់តែប្រសើរឡើងជារៀងរាល់ថ្ងៃ, កាន់តែមានផាសុខភាពជារៀងរាល់ថ្ងៃ, គឺជារឿងដូចម្ដេច? មនុស្សជាច្រើនលើរាងកាយមានបរមីរបស់ខ្ញុំបន្តចូលចេញ, រវល់ជាប្រចាំ, ជាក់ស្តែងគឺកំពុងជួយលោកអ្នកធ្វើរឿងទាំងនេះ។ ប្រសិនបើខ្លួនឯងក្នុងចិត្តមិនស្ថិតស្ថេរ, ហាត់គង់ផង, ជ្រើប្រើអាកប្បកិរិយាមិនជឿឬក៏សាកល្បងមើលផង, ដូច្នោះលោកអ្នកនឹងមិនទទួលបានអ្វីទាំងអស់។ លោកអ្នកជឿឬក៏មិនជឿព្រះពុទ្ធ, គឺដោយសារតែការភ្ញាក់ដឹង, និស្ស័យរបស់លោកអ្នកកំណត់។ ប្រសិនបើព្រះពុទ្ធបង្ហាញចេញមក, ជាក់ស្តែងនៅទីនេះអាចប្រើភ្នែកសាច់មើលឃើញយ៉ាងច្បាស់លាស់, នោះមនុស្សទាំងអស់សុទ្ធតែទៅរៀនព្រះពុទ្ធ, ជាក់ស្តែងមិនស្ថិតនៅបញ្ហាផ្លាស់ប្តូរមនោគតិទៀត។ លោកអ្នកត្រូវតែជឿមុនសិន, ក្រោយមកទើបអាចមើលឃើញបាន។

*សិស្ស៖ មនុស្សមួយចំនួនចង់អញ្ជើញលោកគ្រូនិងសិស្សរបស់លោកគ្រូពិនិត្យជំងឺ, តើអាចបានឬទេ?*

គ្រូ៖ គោលបំណងដែលខ្ញុំចេញមកសាធារណៈគឺមិនមែនដើម្បីព្យាបាលជំងឺ។ មនុស្សខ្លះជាក់ស្តែងគួរតែមានជំងឺ។ ពាក្យដែលខ្ញុំសម្តែងមនុស្សមួយចំនួនជាក់ស្តែងគឺមិនយល់, ខ្ញុំមិនពន្យល់បន្ថែមទៀត។ គង់ហ្វាពុទ្ធវង្សគឺប្រោសសត្វលោកទាំងឡាយ, ពិនិត្យជំងឺឱ្យមនុស្សដទៃគឺអាចបាន។ ពួកយើងពិនិត្យជំងឺឱ្យមនុស្សដទៃ, គឺមានការរៀបចំ, នាំការឃោសនាជាមួយ។ ដោយសារតែខ្ញុំទើបចេញមកសាធារណៈ, ប្រជាប្រិយភាពទាប, មនុស្សដទៃមិនស្គាល់, នៅពេលបង្រៀនគង់អាចគ្មានមនុស្សមកស្តាប់, តាមរយៈការប្រឹក្សា(ព្យាបាលជំងឺ)សម្រាប់អ្នករាល់គ្នាមើលឃើញ, ប្រសិទ្ធភាពជាក់ស្តែងល្អណាស់, ធ្វើការឃោសនា, មិនមែនជំនាញដើម្បីព្យាបាលជំងឺ។ ប្រើគង់(ជាន់)ខ្ពស់ដើម្បីព្យាបាលជំងឺពេញម៉ោងគឺមិនអនុញ្ញាត, ប្រើផុតពីលោកីយ៍ធម៌ជំនួសឱ្យលោកីយ៍ធម៌គឺមិនបានទេ, មិនមែនប្រភេទស្ថានភាពនេះ, ពេលខ្លះប្រសិទ្ធភាពព្យាបាលជំងឺមិនល្អ។ ដើម្បីទទួលខុសត្រូវចំពោះសិក្ខាកាមហាត់គង់, ជាក់ស្តែងត្រូវតែកែសំរួលរាងកាយរបស់លោកអ្នករហូតដល់គ្មានជំងឺ, ទើបអាចបួសឡើងលើជាន់ថ្នាក់ខ្ពស់។ ប្រសិនបើលោកអ្នកតែងតែគិតដល់ជំងឺរបស់លោកអ្នក, ជាមូលដ្ឋានជាក់ស្តែងមិនគិតដល់ហាត់គង់, ទោះមិនបាននិយាយក៏ដោយ, ប៉ុន្តែផ្នត់គំនិតរបស់លោកអ្នកបរមីរបស់ខ្ញុំដឹងច្បាស់លាស់ទាំងអស់, នៅទីបញ្ចប់

លោកអ្នកនឹងមិនទទួលបានអ្វីទាំងអស់។ ពួកយើងនៅលើថ្នាក់បង្រៀនបានកែសំរួលរាងកាយឱ្យអ្នករាល់គ្នារួចហើយ, ពិតប្រាកដណាស់លោកអ្នកមុនដំបូងត្រូវតែជាមនុស្សហាត់គង់។ ប្រសិនបើខ្ញុំព្យាបាលជំងឺឱ្យអ្នករាល់គ្នាពាក់កណ្ដាលបន្ទាប់មកប្រមូលប្រាក់ម្ដងទៀត, រឿងបែបនេះពួកយើងមិនធ្វើទេ។ ប្រសិនបើជំងឺរបស់លោកអ្នកមិនជា, នោះនៅតែជាបញ្ហាភ្ជាក់ដឹង។ ពិតប្រាកដណាស់ក៏មិនបដិសេធថាបុគ្គលខ្លះជំងឺធ្ងន់ធ្ងរណាស់, អាចនៅលើរាងកាយលោកអ្នកខ្លះបញ្ចាំងមិនបង្ហាញច្បាស់, ប៉ុន្តែតាមពិតទៅធំណាស់ៗ។ មួយដងអាចកែសំរួលមិនអស់, តែពួកយើងបានធ្វើអស់ពីកម្លាំងរួចហើយ, មិនមែនមិនទទួលខុសត្រូវចំពោះលោកអ្នក, ពិតជាជំងឺធំខ្លាំងពេក, លោកអ្នកត្រឡប់ទៅវិញហាត់គង់នៅតែនឹងព្យាបាលឱ្យលោកអ្នកជានិច្ច, រហូតដល់ជំងឺរបស់លោកអ្នកជាសះស្បើយទើបឈប់, កាលៈទេសៈប្រភេទនេះគឺជាភាគតិច។

*សិស្ស៖ នៅពេលហាត់គង់ធ្វើម្ដេចទើបអាចចូលទៅក្នុងស្ងប់, តើនៅពេលហាត់គង់គិតដល់បញ្ហាពិបាកក្នុងការងារគឺបានរាប់ជាការប្រកាន់ដែរឬទេ?*

គ្រូ៖ មើលស្រាលរឿងនៃផលប្រយោជន៍, ជាធម្មតាគឺរក្សាបេះដូងមួយស្ងប់ស្ងាត់។ ប្រសិនបើលោកអ្នកមានការប្រុងប្រៀប, គ្រោះមហន្តរាយមកដល់ពេលណា, គឺជាយ៉ាងម៉េច, ពេលនោះនឹងមិនមែនជាគ្រោះមហន្តរាយទេ។ ជាទូទៅសុទ្ធតែមកដល់ភ្លាមៗ, លោកអ្នកដាក់ចិត្តចុះពិតជាអាចឆ្លងផុតបាន, បែបនេះទើបអាច

មើលចេញចិត្តគំនិតរបស់លោកអ្នកខ្ពស់ប៉ុណ្ណា។ ចិត្តប្រកាន់របស់លោកអ្នកកម្ចាត់ចោលរួចហើយ, ចិត្តគំនិតលើកកម្ពស់រួចហើយ, ការប្រជែងប្រយុទ្ធ, អាក់អន់ចិត្តជាដើមជាមួយនឹងមនុស្សសុទ្ធតែបោះបង់ចោលបាន, មនោគតិមិនរញ៉េរញ៉ៃទៀត, នៅពេលនេះចូរនិយាយអំពីកម្លាំងរម្ងាប់។ ប្រសិនបើនៅតែស្ងប់ចុះមិនបាន, លោកអ្នកខ្លួនឯងធ្វើដូចជាអ្នកទីពីរ, សន្មតថាមនោគតិគឺមិនមែនរបស់លោកអ្នក, ស្រេចតែវាគិតបង្វែរទន្លេទៅសមុទ្រយ៉ាងណា, លោកអ្នកលោតចេញក្រៅ, ស្រេចតែវាទៅគិតបានហើយ។ នៅតែមានមនុស្សនិយាយថាសូត្រពុទ្ធនាម, ឬក៏រាប់លេខ, នេះសុទ្ធតែជាវិធីសាស្ត្រផ្សេងៗនៃការហាត់គង់។ ពួកយើងហាត់គង់មិនតម្រូវផ្តោតគំនិត, ប៉ុន្តែលោកអ្នកត្រូវតែដឹងថាខ្លួនឯងកំពុងហាត់គង់។ បណ្តារឿងលំបាកក្នុងការងារ, មិនជារបស់ផលប្រយោជន៍ឯកជន, មិនមែនចិត្តប្រកាន់, គឺជារឿងល្អ។ ខ្ញុំស្គាល់ព្រះសង្ឃមួយអង្គ, គាត់ដឹងពីអ្វីបួសហាត់នៃទិដ្ឋភាពនេះ។ គាត់នៅក្នុងវត្តធ្វើព្រះចៅអធិការ, រឿងរ៉ាវច្រើនណាស់, ប៉ុន្តែដរាបណាគាត់អង្គុយសមាធិទីនោះជាក់ស្តែងផ្តាច់ចេញជាមួយនឹងពួកវា, ធានាមិនគិត, នេះក៏ជាគង់ផងដែរ។ ភាពពិតនៅពេលពិតជាហាត់គង់, ក្នុងខួរក្បាលអ្វីក៏មិនគិតទាំងអស់, គ្មានបន្តិចគំនិតអាត្មានិយម។ រឿងក្នុងការងារមិនលាយបញ្ចូលអ្វីនៃឯកជន, លោកអ្នកនៅតែអាចធ្វើបានល្អ។

*សិស្ស៖ នៅពេលហាត់គង់ក្នុងមនោគតិមានអ្វីមិនល្អតើធ្វើដូចម្តេច?*

គ្រូ៖ ក្នុងពេលហាត់គង់ពេលខ្លះនឹងលេចឡើងជាច្រើនអ្វីមិនល្អ , អ្នករាល់គ្នាទើបតែហាត់គង់, មិនអាចភ្លាមៗឈានដល់កម្រិតដ៏ខ្ពស់, ឥឡូវនេះក៏នឹងមិនតម្រូវលោកអ្នកខ្ពស់ពេកផងដែរ, ហៅលោកអ្នកក្នុងមនោគតិអ្វីអាក្រក់បន្តិចក៏មិនទៅគិត, នេះគឺមិនមែនជាការពិត។ ជាបណ្ដើរ, ពេលដំបូងអាចបាន, ប៉ុន្ដែលោកអ្នកមិនបានបន្ធូរខ្លួនឯង, រង់ចាំពេលវេលាយូរទៅ, មនោគតិរបស់លោកអ្នកថ្កើងឡើងរួចហើយ, សម្រាប់ខ្លួនឯងត្រូវតែមានតម្រូវខ្ពស់, ដោយសារតែលោកអ្នកបានបួសហាត់មហាធម៌រួចហើយ, បន្ទាប់ពីចាកចេញពីថ្នាក់នេះលែងនៅជាមនុស្សសាមញ្ញទៀតហើយ, អ្វីដែលនាំជាមួយលើរាងកាយពិសេសណាស់រួចហើយ, ដូច្នេះតម្រូវចិត្តគំនិតសម្រាប់លោកអ្នកជាក់ស្ដែងត្រូវតែតឹងរឹង។

*សិស្ស៖ នៅពេលហាត់គង់មានអារម្មណ៍ថាក្បាលនិងពោះទាបកំពុងបង្វិល, អារម្មណ៍តំបន់ទ្រូងពិបាកទ្រាំ?*

គ្រូ៖ នេះគឺជាពេលដំបូងហ្វាលូនកំពុងវិល, ចាប់ពីពេលនេះទៅមិនប្រាកដថាមានរោគសញ្ញាប្រភេទនេះទៀត។

*សិស្ស៖ នៅពេលហាត់គង់ទាក់ទាញសត្វល្អិតមកតើធ្វើដូចម្ដេច?*

គ្រូ៖ ហាត់គង់អ្វីក៏សុទ្ធតែទាក់ទាញសត្វល្អិតមកដែរ, កុំខ្វល់នឹងវាគឺបានហើយ។ ដោយសារតែនៅក្នុងវាលថាមពលដែលល្អ, ជាពិសេសគឺគង់ពុទ្ធវង្ស, ក្នុងគង់ស្ថិតនៅកត្តាប្រោសសត្វលោកទាំងឡាយ។ ហ្វាលូនរបស់ពួកយើងនៅពេលបង្វិលតាមទ្រនិចនាឡិកា

ប្រោសខ្លួនឯង; នៅពេលបង្វិលច្រាសទ្រនិចនាឡិកាប្រោសសត្វលោកទាំងឡាយ។ បន្ទាប់មករង្វិលជុំត្រឡប់មកវិញ, ដូច្នេះអ្វីៗគ្រប់យ៉ាងដែលនៅជុំវិញយើងសុទ្ធតែទទួលបានអត្ថប្រយោជន៍។

*សិស្ស៖ លំហាត់ស្រោចស្រឡះពីរប៉ូលតើដៃមួយដងឡើងនិងមួយដងចុះរាប់ថាម្តងមែនទេ? នៅពេលលំហាត់ព្រះពុទ្ធបង្ហាញដៃមួយពាន់, មុនពេលដៃលាតសន្ធឹងចេញតើត្រូវគិតថាខ្លួនឯងខ្ពស់ធំណាស់មែនទេ?*

គ្រូ៖ ដៃទាំងពីរនីមួយៗធ្វើមួយដងរាប់ថាម្តង។ នៅពេលធ្វើលំហាត់ព្រះពុទ្ធបង្ហាញដៃមួយពាន់, លោកអ្នកមិនគិតអំពីខ្លួនឯង, ក៏នឹងមានអារម្មណ៍ខ្ពស់ធំផងដែរ។ លោកអ្នកគ្រាន់តែមានគំនិតប្រភេទនេះមានអារម្មណ៍ថា ‵ខ្ញុំតែមួយគត់ឈរកណ្តាលមេឃនិងដីទៅទីនោះឈរ′ គឺបានហើយ, កុំរមែងគំនិតស្វែងរក, នោះជាក់ស្តែងគឺជាអ្វីនៃការប្រកាន់។

*សិស្ស៖ អង្គុយសមាធិហាត់គង់, បត់ប្រសព្វជើងឡើងមិនបានតើធ្វើដូចម្តេច?*

គ្រូ៖ បត់ប្រសព្វឡើងមិនបានអាចអង្គុយនៅលើគែមកៅអីដើម្បីហាត់, ក៏នឹងទទួលបានប្រសិទ្ធភាពដូចគ្នា។ ប៉ុន្តែលោកអ្នកគឺជាមនុស្សហាត់គង់, ជាក់ស្តែងត្រូវតែហាត់ជើងទាំងទ្វេរបស់លោកអ្នក, ចាំបាច់ត្រូវតែបត់ប្រសព្វឡើងបាន។ អង្គុយនៅលើគែមកៅអីបន្តិចម្តងៗហាត់ជើងរបស់លោកអ្នក, ទីបំផុតត្រូវតែបត់ប្រសព្វឡើងបាន។

*សិស្ស៖ ប្រសិនបើមនុស្សក្នុងផ្ទះធ្វើរឿងមិនល្អ, មិនសមស្រប "សច្ចៈ-ករុណា-ខន្តី", តើធ្វើដូចម្ដេច?*

គ្រូ៖ មនុស្សក្នុងផ្ទះរបស់លោកអ្នកមិនមែនហាត់ហ្វាលូនគង់, បញ្ហានេះគ្មានទាក់ទងទេ, ចម្បងគឺបួសហាត់ខ្លួនឯង។ លោកអ្នកខ្លួនឯងទៅបួស, កុំគិតស្មុគស្មាញពេក, នៅត្រូវតែងាយស្រួលបន្តិច, ដាក់ជំនាញលើខ្លួនឯងច្រើនជាង។

*សិស្ស៖ ក្នុងជីវិតប្រចាំថ្ងៃពេលខ្លះធ្វើរឿងខុសឆ្គងស្ដាយក្រោយណាស់, ប៉ុន្តែម្ដងហើយម្ដងទៀត, តើចិត្តគំនិតទាបណាស់មែនទេ?*

គ្រូ៖ លោកអ្នកអាចសរសេរចេញមក, បញ្ជាក់ថាចិត្តគំនិតរបស់លោកអ្នកបានលើកកម្ពស់រួចហើយ, អាចដឹងបានចំណុចមួយនេះ។ មនុស្សសាមញ្ញធ្វើរឿងខុសឆ្គងក៏សុទ្ធតែមិនដឹង, ពន្យល់ថាលោកអ្នកបានលើសផុតពីមនុស្សសាមញ្ញរួចហើយ។ លើកទីមួយធ្វើខុស, ចិត្តគំនិតរក្សាមិនជាប់, នេះគឺមានមួយដំណើរការ, លើកបន្ទាប់ម្ដងទៀតជួបប្រទះបញ្ហា, ម្ដងទៀតលើកកម្ពស់។

*សិស្ស៖ មនុស្សដែលអាយុ៤០, ៥០ឆ្នាំតើអាចសម្រេចបាន "ផ្កាបីប្រមូលផ្ដុំនៅកំពូល" ឬទេ?*

គ្រូ៖ ដោយសារតែពួកយើងគឺជាគង់ហ្វាចិត្តជីវិតបួសទាំងទ្វេ, មិនខ្វល់ពីអាយុធំឬតូច, ដរាបណាលោកអ្នកចិត្តតែមួយទៅហាត់, អាចយោងទៅតាមចិត្តគំនិតដែលខ្ញុំនិយាយដើម្បីតម្រូវខ្លួនឯង, នឹងលេចឡើងបាតុភូតបន្តហាត់គង់បន្តពន្យាជីវិត, តើពេលវេលាហាត់គង់របស់លោកអ្នកមិនគ្រប់គ្រាន់ទេឬ? ប៉ុន្តែមានចំណុចមួយ

, ជាពិសេសគឺគង់ហ្វាចិត្តជីវិតបួសទាំងទ្វេ, នៅពេលដែលជីវិតរបស់លោកអ្នកត្រូវពន្យាបានមកដល់, ប្រសិនបើចិត្តគំនិតលេចឡើងបញ្ហា, ភ្លាមៗនោះគឺនឹងលេចឡើងគ្រោះថ្នាក់ដល់ជីវិត, ដោយសារតែគឺដើម្បីហាត់គង់ទើបពន្យាជីវិតរបស់លោកអ្នក, ដូច្នេះចិត្តគំនិតដរាបណាដើរគម្លាត, ភ្លាមៗនោះជាក់ស្តែងនឹងលេចឡើងគ្រោះថ្នាក់ដល់ជីវិត។

*សិស្ស៖ តើធ្វើដូចម្តេចធ្វើជាម្ចាស់នៃបញ្ហាភាពខ្លាំង "ក្នុងទន់មានរឹង"?*

គ្រូ៖ រឿងនេះលោកអ្នកត្រូវតែស្វែងយល់ខ្លួនឯង, ឧទាហរណ៍និយាយ, នៅពេលពួកយើងវាយក្បាច់ដៃធំ, ដៃមើលទៅទន់ណាស់, ប៉ុន្តែធ្វើចេញមកវាតាមពិតគឺប្រើកម្លាំង, ភាពខ្លាំងនៃកំភួនដៃនិងកដៃ, រវាងម្រាមដៃនេះគឺធំណាស់។ ប៉ុន្តែមើលទៅដូចជាទន់ណាស់, តាមពិតទៅភាពខ្លាំងគឺធំខ្លាំងណាស់, នេះជាក់ស្តែងគឺជា "ក្នុងទន់មានរឹង"។ នៅពេលខ្ញុំវាយក្បាច់ដៃធំឱ្យអ្នករាល់គ្នា, ប្រការនេះបានផ្តល់ឱ្យលោកអ្នករួចហើយ, លោកអ្នកបន្តិចម្តងៗនៅក្នុងហាត់គង់ពិនិត្យបាន។

*សិស្ស៖ រឿងរវាងបុរសនិងស្ត្រីមិនចាំបាច់ទៀតឬ, តើកំលោះក្រមុំចាំបាច់ត្រូវលែងលះគ្នា?*

គ្រូ៖ នៅលើបញ្ហាកាមគុណពីមុនបានសម្តែងរួចហើយ, នៅលើជាន់ថ្នាក់ដែលលោកអ្នកមានពេលនេះ, មិនហៅលោកអ្នកធ្វើជាព្រះសង្ឃ, សមណី, គឺលោកអ្នកខ្លួនឯងចង់ធ្វើជាសមណី, ព្រះ

សង្ឃ។ សំខាន់គឺហៅលោកអ្នកលះបង់ចិត្តមួយនេះ! យកចិត្តដែលលោកអ្នកលះបង់មិនបានលះបង់ទាំងអស់។ ធ្វើជាមនុស្សសាមញ្ញនេះគឺជាមួយប្រភេទនៃតណ្ហា, នៅពួកយើងជាក់ស្តែងត្រូវតែលះបង់, មើលឱ្យស្រាល។ មនុស្សខ្លះជាក់ស្តែងស្វែងរកប្រការនេះ, ខួងចូលទៅក្នុងខួរក្បាល, ធ្វើមនុស្សសាមញ្ញក៏ហួសកម្រិតហើយ។ ធ្វើជាមនុស្សហាត់គង់កាន់តែមិនគួរ។ ដោយសារតែលោកអ្នកហាត់គង់, មនុស្សក្នុងផ្ទះមិនហាត់គង់, រស់នៅប្រចាំថ្ងៃដំណាក់កាលបច្ចុប្បន្នគឺបានអនុញ្ញាត, បន្ទាប់ពីមកដល់ជាន់ថ្នាក់ខ្ពស់រួចហើយ, លោកអ្នកខ្លួនឯងនឹងដឹងគួរតែធ្វើដូចម្តេច?

*សិស្ស៖ តើពេលអង្គុយសមាធិគេងលក់បានឬទេ? ដោះស្រាយដូចម្តេច? ពេលខ្លះសន្លប់រហូតដល់៣នាទី, មិនដឹងរឿងអ្វីទៀត?*

គ្រូ៖ គេងលក់មិនបានទេ, តើហាត់គង់អាចគេងលក់បានឬ? គេងលក់នៅពេលអង្គុយសមាធិក៏ជាមួយប្រភេទនៃខ្មោចផងដែរ។ លោកអ្នកនិយាយថាសន្លប់ប្រភេទបាតុភូតនេះមិនអាចលេចឡើង, តើសរសេរមិនច្បាស់ទេឬ? ៣នាទីដោយគ្មានស្មារតីមិនរាប់ជាអ្វីទេ, មនុស្សដែលមានកម្លាំងរម្ងាប់ដ៏ខ្ពស់ជាធម្មតាលេចឡើងស្ថានភាពបាត់បង់ស្មារតី, វេលាយូរអង្វែងបែបនេះជាក់ស្តែងមិនបានទេ។

*សិស្ស៖ តើមនុស្សដែលមានការប្តេជ្ញាចិត្តបួសសម្រេចមគ្គផលខ្ពស់បំផុតសុទ្ធតែអាចសម្រេចមគ្គផលខ្ពស់បំផុត? តើនិស្ស័យទាប*

*បន្ទិចធ្វើដូចម្ដេច?*

គ្រូ៖ ជាក់ស្ដែងសង្កេតមើលលោកអ្នកមានឬក៏គ្មានការប្ដេជ្ញាចិត្តមួយនេះ, សំខាន់គឺការប្ដេជ្ញាចិត្តនេះមានធំប៉ុណ្ណា។ មនុស្សដែលនិស្ស័យទាបបន្តិច, គឺនៅតែសង្កេតមើលការប្ដេជ្ញាចិត្តនិងភ្ញាក់ដឹងរបស់លោកអ្នក។

*សិស្ស៖ តើផ្កាសសាយឬគ្រុនក្ដៅអាចហាត់គង់បានឬទេ?*

គ្រូ៖ ខ្ញុំនិយាយថាលោកអ្នកបន្ទាប់ពីចាកចេញពីថ្នាក់តទៅសុទ្ធតែគ្មានជំងឺ, លោកអ្នកប្រហែលជាមិនជឿ, សិស្សរបស់ខ្ញុំពេលខ្លះដូចជាផ្កាសសាយ, គ្រុនក្ដៅគឺជារឿងដូចម្ដេច, នោះគឺជាប្រតិកម្មនៃការឆ្លងកាត់ទ្វារ, ឆ្លងកាត់ទុក្ខ, គួរលើកកម្ពស់ជាន់ថ្នាក់។ ពួកគាត់ខ្លួនឯងសុទ្ធតែយល់ច្បាស់, មិនខ្វល់ពីវាខ្លួនឯងអាចឆ្លងផុតបាន។

*សិស្ស៖ ស្ត្រីដែលមានផ្ទៃពោះអាចហាត់ហ្វាលូនគង់បានឬទេ?*

គ្រូ៖ គ្មានបញ្ហាទេ, ដោយសារតែហ្វាលូនដំឡើងនៅអវកាសមួយផ្សេង, គង់ហ្វារបស់ពួកយើងមិនមានធ្វើចលនាខ្លាំងក្លា, សម្រាប់ស្ត្រីមានផ្ទៃពោះគ្មានឥទ្ធិពលអាក្រក់, សម្រាប់រាងកាយរបស់គាត់គឺនៅមានអត្ថប្រយោជន៍។

*សិស្ស៖ លោកគ្រូបានចាកចេញពីពួកកូន, តើមានចម្ងាយនៃអវកាសទេ?*

គ្រូ៖ មនុស្សជាច្រើនសុទ្ធតែមានគំនិតរបៀបនេះ៖ លោកគ្រូ

លោកមិននៅប៉េកាំងទៀត, តើពួកកូនធ្វើដូចម្ដេច? លោកអ្នកហាត់គង់ហ្វាដទៃក៏ដូចគ្នាផងដែរ, លោកគ្រូក៏មិនអាចមើលថែរាល់ថ្ងៃ។ ធម៌, ខ្ញុំបានបង្រៀនឱ្យអ្នករាល់គ្នារួចហើយ, គោលសីលធម៌, បានបង្រៀនឱ្យអ្នករាល់គ្នារួចហើយ, សំណុំគង់នេះបានបង្រៀនឱ្យអ្នករាល់គ្នារួចហើយ; មួយសំណុំអ្វីពេញលេញសុទ្ធតែបានផ្ដល់ឱ្យលោកអ្នករួចហើយ, ជាក់ស្ដែងសង្កេតមើលលោកអ្នកខ្លួនឯងបួសដូចម្ដេច។ លោកអ្នកមិនអាចនិយាយថានៅក្បែរខ្លួនខ្ញុំនឹងមានការធានា, មិននៅក្បែរខ្លួនខ្ញុំនឹងគ្មានការធានា។ ពួកយើងលើកឧទាហរណ៍មួយ, និយាយថាសិស្សពុទ្ធសាសនា, សក្យមុនីមិននៅលើលោកជាង២០០០ឆ្នាំរួចហើយ, តើមិនមែនពួកគាត់កំពុងបន្តហាត់រៀងមក, ចិត្តមួយគ្មានពីរឬ? ដូច្នេះហាត់ឬមិនហាត់គឺជាបញ្ហាខ្លួនឯង។

*សិស្ស៖ តើហាត់ហ្វាលូនគង់នឹងតមអាហារ "ប៊ីគូ" ឬទេ?*

គ្រូ៖ នឹងមិន, ដោយសារតែប្រភេទវិធីសាស្ត្រប៊ីគូនេះគឺនៅមុនពេលដែលពុទ្ធនិងតាវមិនទាន់ស្ថិតនៅបានស្ថិតនៅការបួសហាត់មហាតាវរួចមកហើយ, នៅមុនពេលមិនទាន់បង្កើតសាសនាបានមានរួចមកហើយ, ជាធម្មតាប្រភេទវិធីសាស្ត្រនេះសុទ្ធតែជារបស់បួសហាត់ឯកតា។ ដោយសារតែនាពេលនោះពុំទាន់មានប្រព័ន្ធវត្តអារាម, គ្រាន់តែអាចនៅលើពាក់កណ្ដាលជួរភ្នំ, គ្មានមនុស្សបំរើម្ហូបអាហារ, នៅពេលបួសហាត់ចាំបាច់បិទទ្វារ, ចាំបាច់រយៈពេលកន្លះឆ្នាំមួយឆ្នាំអចលនា, ដូច្នេះជ្រើសប្រើប្រភេទវិធីសាស្ត្រនេះ។ ពួក

យើងបួសហាត់សព្វថ្ងៃនេះ, មិនចាំបាច់បែបនេះ, ដោយសារតែនោះគឺជាមួយប្រភេទវិធីសាស្ត្រដែលបានជ្រើសប្រើក្នុងបរិយាកាសជាក់លាក់, និងមិនមែនជាសីលគង់អ្វីទេ។ មនុស្សខ្លះបង្រៀនរឿងនេះ, ខ្ញុំនិយាយថាមនុស្សនៃពិភពលោកទាំងមូលសុទ្ធតែមិនបរិភោគទៀត, នេះគឺបានបំផ្លាញស្ថានភាពសង្គមមនុស្សសាមញ្ញ, នោះនឹងក្លាយជាបញ្ហា, មនុស្សទាំងអស់សុទ្ធតែមិនបរិភោគទៀត, តើនោះគឺជាសង្គមរបស់មនុស្សមែនទេ? នោះមិនបានទេ, មិនមែនបែបនោះទេ។

*សិស្ស៖ តើ៥សំណុំគង់ហ្វានេះអាចហាត់ដល់ជាន់ថ្នាក់ណា?*

គ្រូ៖ ៥សំណុំគង់ហ្វានេះបានគ្រប់គ្រាន់អាចឱ្យលោកអ្នកហាត់ដល់ជាន់ថ្នាក់យ៉ាងខ្ពស់បំផុតៗរួចហើយ។ ជាការពិតលោកអ្នកចង់ហាត់ដល់ជាន់ថ្នាក់មួយណា, ដល់ពេលនោះលោកអ្នកនឹងដឹងដោយខ្លួនឯង។ ពីព្រោះគង់គ្មានទីបញ្ចប់, លោកអ្នកពិតជាដល់ជំហាននោះរួចហើយ, ជាក់ស្តែងមានវាសនានោះ, នៅអាចទទួលបានមហាធម៌នៃជាន់ថ្នាក់ខ្ពស់ជាងទៀត។

*សិស្ស៖ ធម៌ហាត់មនុស្ស, ហ្វាលូនបង្វិលជាប្រចាំតើអាចមិនហាត់គង់ទៀតទេ?*

គ្រូ៖ ហាត់គង់និងបួសធម៌ក្នុងវត្តអារាមមិនដូចគ្នាទេ។ តាមពិតក្នុងវត្តអារាមក្នុងចិត្តចង់បួស, ជាក់ស្តែងក៏ត្រូវតែអង្គុយសមាធិ, ភាពជំនាញការនោះគឺត្រូវតែហាត់, មិនអាចគ្រាន់តែនិយាយបង្កើនគង់ហើយមិនហាត់អ្វីទាំងអស់, គ្រាន់តែនិយាយហើយនៅលើ

ក្បាលមានគង់, ខ្ញុំនិយាយថានោះគឺមិនមែនជាមនុស្សហាត់គង់ត្រូវ ឬអត់? មួយសំណុំជំនាញណាមួយសុទ្ធតែមានស្នងបង្រៀនមួយ សំណុំអ្វីៗ, គឺត្រូវតែយកមួយសំណុំអ្វីៗនេះហាត់ចេញមក។

*សិស្ស៖ មនុស្សដែលហាត់គង់ដទៃនិយាយថា៖ គង់ដែលគ្មានគំនិតមិនមែនគង់ហ្វា, ត្រូវឬអត់?*

គ្រូ៖ សេចក្ដីថ្លែងការណ៍នេះសេចក្ដីថ្លែងការណ៍នោះច្រើនណាស់, ប៉ុន្តែគ្មាននរណាដូចខ្ញុំយកមហាធម៌បែបនេះប្រាប់លោកអ្នកទេ។ ពុទ្ធវង្សសម្ដែងថាធម៌ដោយចេតនានឹងមិនខ្ពស់ពេក, ធម៌ដោយចេតនាមិនមែនសំដៅទៅលើចលនា, គាត់អង្គុយសមាធិ, ភ្ជាប់ត្រាក៏ជាចលនា, ដូច្នេះមិនមែននៅចលនាធំឬតូច។ ដោយចេតនាឬដោយអចេតនាស្ថិតនៅក្នុងគំនិតរបស់លោកអ្នក, នៅលើការស្វែងរក, មានគំនិត, មានការស្វែងរក, ជាក់ស្ដែងគឺជាការប្រកាន់, ជាក់ស្ដែងគឺជាដោយចេតនា, ដែលសំដៅទៅលើគឺជាអ្វីទាំងនេះ។

*សិស្ស៖ ចិត្តគំនិតនិងគុណធម៌មិនស្មើគ្នា, គាត់និយាយថាគុណធម៌ច្រើនឬតិចកំណត់ជាន់ថ្នាក់, ហើយនិយាយទៀតថាចិត្តគំនិតខ្ពស់ប៉ុណ្ណាគង់ខ្ពស់ប៉ុណ្ណោះ, តើរឿងទាំងពីរមិនមែនផ្ទុយគ្នាទេឬ?*

គ្រូ៖ លោកអ្នកអាចមិនស្ដាប់បានច្បាស់លាស់។ ចិត្តគំនិតគ្របដណ្ដប់ទូលាយណាស់, គុណធម៌គឺជាមួយផ្នែកក្នុងនោះ; នៅគ្របដណ្ដប់ទាំង "ខន្តី", សមត្ថភាពរងទុក្ខ, ភ្ញាក់ដឹង, ដោះស្រាយទំនាស់ជាដើម, ទាំងអស់នេះសុទ្ធតែជារបស់បញ្ហាចិត្តគំនិត, ក្នុង

នោះនៅគ្រប់ដណ្ដប់ទាំងការវិវត្តន៍របស់គង់, ការវិវត្តន៍របស់គុណធម៌, គឺជាអ្វីមួយដែលមានអត្ថន័យទូលំទូលាយ។ គុណធម៌មានច្រើនឬក៏តិចមិនមែននិយាយថាគង់របស់លោកអ្នកខ្ពស់ប៉ុណ្ណា, វាគឺនិយាយថាលោកអ្នកអនាគតបង្កើនគង់បានប៉ុណ្ណា។ គុណធម៌នៅត្រូវតែឆ្លងកាត់ហ្វឹកហាត់លើកកម្ពស់ចិត្តគំនិតបន្ទាប់មក, វាទើបអាចបំលែងទៅជាគង់។

*សិស្ស៖ មួយផ្ទះមនុស្សពីរបីនាក់ហាត់មិនមែនប្រភេទគង់តែមួយ, តើនឹងប៉ះពាល់ដល់គ្នាទៅវិញទៅមកឬទេ?*

គ្រូ៖ នឹងមិន។ ប៉ុន្តែ, រវាងពួកគាត់នឹងប៉ះពាល់ដល់គ្នាទៅវិញទៅមកឬទេខ្ញុំមិនដឹង។ ក្នុងនាមជាហ្វាលូនគង់ពួកយើងនរណាក៏ជ្រៀតជ្រែកមិនបានផងដែរ, លើសពីនេះទៀតលោកអ្នកនៅមានកន្លែងល្អសម្រាប់ពួកគាត់, ពីព្រោះពួកយើងគឺបួសហាត់សុចរិតធម៌, នឹងមិនលេចឡើងគម្លាត។

*សិស្ស៖ ឥឡូវនេះក្នុងសង្គមចែកចាយសេចក្ដីថ្លែងការណ៍ជាច្រើន, ឧបមាសំបុត្រជាខ្សែសង្វាក់, តើដោះស្រាយដូចម្ដេច?*

គ្រូ៖ ខ្ញុំប្រាប់អ្នករាល់គ្នា, អ្វីទាំងនេះសុទ្ធសាធគឺបំភាន់មនុស្ស, លោកអ្នកមិនចាំបាច់ឆ្លើយតបសំបុត្រទៅគាត់, ពិតជាអត់ន័យ, លោកអ្នកអាចមិនអើពើនឹងវា។ លោកអ្នកមើលគាត់អ្វីទាំងនេះសុចរិតឬក៏មិនសុចរិត, មើលភ្លាមជាក់ស្ដែងអាចមើលចេញបាន, ធម៌នេះរបស់ពួកយើងតម្រូវតឹងរឹងបួសចិត្តគំនិត។ មានគ្រូឈីគង់មួយចំនួនខ្ញុំហៅគាត់ថាឈ្មួញឈីគង់, យកឈីគង់ធ្វើជាមួយ

ប្រភេទនៃទំនិញ, ក្លាយជាដើមទុនសម្រាប់ប្តូរយកប្រាក់, មនុស្សបែបនេះបង្រៀនគង់ក៏បង្រៀនមិនចេញមកបានអ្វីដែរ, មានអ្វីបន្តិចនោះក៏នឹងមិនខ្ពស់ផងដែរ, នៅមានទាំងអ្វីជាទុចរិតទៀតផង។

*សិស្ស៖ សិក្ខាកាមហ្វាលូនគង់នៅក្នុងវត្តសាងភ្នួសរួចហើយតើធ្វើដូចម្តេច? តើគួរសឹកចេញវិញដែរទេ?*

គ្រូ៖ វាគ្មានទាក់ទងអ្វីជាមួយនឹងពួកយើង, ទោះបីលោកអ្នកបានសាងភ្នួសរួចហើយក៏ដោយ, នោះគឺជាអ្វីនៃទម្រង់ប៉ុណ្ណោះ។

*សិស្ស៖ ពួកកូនពីរបីនាក់បន្ទាប់ពីថ្នាក់បង្រៀនមកមានអារម្មណ៍ក្បាលហើមនិងធឹងធោង?*

គ្រូ៖ នេះអាចជាសិក្ខាកាមថ្មីចូលមក, រាងកាយនៅមិនទាន់កែសំរួលបានល្អ, ថាមពលដែលខ្ញុំវាយចេញធំណាស់, ឈឺជំងឺបញ្ចេញទៅខាងក្រៅនឹងមានអារម្មណ៍ក្បាលហើម, ក្បាលហើមគឺបំបាត់ជំងឺនៅលើក្បាលឱ្យលោកអ្នក, គឺជារឿងល្អ, ប៉ុន្តែបំបាត់ខ្លាំងក្លាពេកប្រតិកម្មនឹងធំ។ យើងខ្ញុំបើកថ្នាក់បង្រៀនរយៈពេល៧ថ្ងៃមនុស្សខ្លះទ្រាំមិនបាន, ពេលវេលាខ្លីជាងទៀតអាចនឹងលេចឡើងបញ្ហា, ថាមពលដែលវាយចេញធំ, ប្រតិកម្មខ្លាំងក្លាខ្លាំងណាស់, ក្បាលហើមទ្រាំមិនបាន, មើលទៅថ្នាក់បង្រៀនរយៈពេល១០ថ្ងៃមានស្ថេរភាពជាង, មនុស្សចូលមកក្រោយប្រតិកម្មនឹងធំជាងមុន។

*សិស្ស៖ តើហាត់គង់អាចជក់បារី, ផឹកស្រាបានឬទេ? ដោយសារតែការងារពិសេសចាំបាច់ផឹកស្រាតើធ្វើដូចម្តេច?*

គ្រូ៖ សម្រាប់បញ្ហានេះខ្ញុំមើលឃើញបែបនេះ, ពួកយើងហាត់ពុទ្ធវង្សគង់គឺត្រូវតែហាមឃាត់សុរា, ពេលវេលាយូរលោកអ្នកអាចនៅតែគិតដល់, បន្តិចម្តងៗហាមឃាត់បាន។ ប៉ុន្តែពេលវេលាកុំយូរពេក, យូរពេកហើយនឹងទទួលទណ្ឌកម្ម! សម្រាប់ជក់បារី, ខ្ញុំគិតថាគឺជាបញ្ហានៃឆន្ទៈ, ដរាបណាលោកអ្នកចង់ហាមឃាត់នឹងហាមឃាត់បាន។ មនុស្សសាមញ្ញច្រើនតែគិតថា៖ "ថ្ងៃនេះខ្ញុំហាមឃាត់បារីបានហើយ"។ ឆ្លងបានប៉ុន្មានថ្ងៃក៏ព្យាយាមមិនបានទៀត។ ឆ្លងបានពីរថ្ងៃក៏គិតដល់ម្តងទៀត, ចោលម្តងទៀត, ជាក់ស្តែងបែបនេះ, គាត់តែងតែហាមឃាត់មិនបាន។ មនុស្សសាមញ្ញរស់នៅលើលោកីយ៍, រវាងមនុស្សនៅលើលោកីយ៍ប្រាស្រ័យទាក់ទងគ្នាជៀសមិនរួចទំនាក់ទំនងទាំងនេះ, ប៉ុន្តែ, លោកអ្នកត្រូវតែគិតដល់លោកអ្នកលែងនៅជាមនុស្សសាមញ្ញម្នាក់ទៀតហើយ, បានចាប់ផ្តើមបួសហាត់រួចហើយ។ មានឆន្ទៈ, ជាក់ស្តែងអាចសម្រេចបានគោលបំណង។ ជាការពិត, កូនសិស្សរបស់ខ្ញុំក៏នៅមានជក់បារី, គាត់ខ្លួនឯងក៏អាចហាមឃាត់បាន, ប៉ុន្តែដរាបណាអ្នកដទៃឱ្យគាត់, គាត់គួរសមពិបាកក្នុងការបដិសេធ, ចង់ជក់ម្តងទៀត, ពីរថ្ងៃមិនជក់នៅតែពិបាកទ្រាំ, ហើយជក់ឡើងវិញក៏ពិបាកទ្រាំផងដែរ។ ខ្លួនឯងជាក់លាក់ត្រូវតែឃុំគ្រងជាប់! មនុស្សមួយចំនួនគឺធ្វើទំនាក់ទំនងសង្គម, ជាធម្មតាត្រូវតែផឹកស្រាជាមួយភ្ញៀវ, បញ្ហានេះពិបាកដោះស្រាយណាស់។ ផឹកតិចបំផុតតាមដែលអាចធ្វើទៅបាន, ឬក៏លោកអ្នកគិតរកដំណោះស្រាយ។

*សិស្ស៖ នៅពេលដែលនៅមិនទាន់អាចមើលឃើញហ្វាលូនបង្វិល, ប្រសិនបើផ្ដល់គំនិតតាមទ្រនិចនាឡិកា, តើនឹងមានឥទ្ធិពលដល់ហ្វាលូនកំពុងបង្វិលច្រាសទ្រនិចនាឡិកាឬទេ?*

គ្រូ៖ ហ្វាលូនគឺបង្វិលដោយស្វ័យប្រវត្តិ, មិនចាំបាច់គំនិតលោកអ្នកដឹកនាំទេ។ សង្កត់ធ្ងន់ម្ដងទៀត, មិនបានប្រើគំនិត, គំនិតក៏ឃុំគ្រងគាត់មិនបានដែរ។ មិនបានយកគំនិតរបស់លោកអ្នកដើម្បីឃុំគ្រងធ្វើឱ្យគាត់បង្វិលតាមទិសផ្ទុយមកវិញ។ ហ្វាលូននៅទីតាំងពោះទាបគឺមិនទទួលរងការឃុំគ្រងរបស់គំនិត។ ហ្វាលូននៅខាងក្រៅដែលកែសំរួលរាងកាយ, លោកអ្នកទុកឱ្យគាត់បង្វិល, អាចនឹងទទួលរងសកម្មភាពគិតរបស់លោកអ្នក, អាចនឹងបង្កើតប្រភេទអារម្មណ៍នេះ។ ខ្ញុំសម្ដែងឱ្យលោកអ្នក៖ លោកអ្នកមិនបានធ្វើ, មិនអាចទៅហាត់ដោយចេតនា។ ដោយចេតនាទៅហាត់តើមិនមែននៅតែជាមនុស្សហាត់គង់ទេឬ, គឺជាហ្វាលូនទៅហាត់, គឺជាធម៌ហាត់មនុស្ស។ ហេតុអ្វីតែងតែមិនបោះបង់នូវអ្វីដែលជាគំនិតរបស់លោកអ្នក? គង់ហ្វាណាមួយពេលដល់ជាន់ថ្នាក់ខ្ពស់, ទោះបីជាគង់ហ្វាតាវវង្សក៏ដោយ, សុទ្ធតែគ្មានគំនិតដឹកនាំ។

*សិស្ស៖ តើហាត់ហ្វាលូនគង់ពេលវេលា, ទីកន្លែង, ទិសដៅណាប្រសិទ្ធភាពល្អបំផុត? ហាត់ប៉ុន្មានដងសមល្មម? តើមុននិងក្រោយពេលបរិភោគហាត់(គង់)មានបញ្ហាឬទេ?*

គ្រូ៖ ដោយសារតែហ្វាលូនគឺមូល, គឺជារូបភាពបង្រួមតូចនៃចក្រវាលនេះរបស់ពួកយើង, ដែលហាត់នោះគឺជាគោលសីលធម៌

នៃចក្រវាល, លើសពីនេះទៀតចក្រវាលគឺធ្វើចលនា, ផ្ទុយមកវិញជាក់ស្ដែងគឺធម៌ហាត់មនុស្ស។ លោកអ្នកមិនហាត់គង់, គាត់ហាត់លោកអ្នក, ខុសជាមួយនឹងទ្រឹស្ដីនៃគង់ហ្វាទាំងអស់ដែលបានបង្រៀនចេញ, (គង់ហ្វា)នេះរបស់ខ្ញុំគឺជា "ធម៌ហាត់មនុស្ស" តែមួយគត់។ គង់ហ្វាដទៃទាំងអស់សុទ្ធតែនិកាយមួយនេះដើរតានតាវ, ហាត់គង់ដោយចេតនា, ផ្ទុកតាន, ពួកយើងមិនត្រូវការ។ គង់មួយនេះរបស់ពួកយើងពេលវេលាណាក៏អាចហាត់បាន, លោកអ្នកមិនហាត់គង់គង់ហាត់លោកអ្នក, មិនចាំបាច់ជ្រើសរើសពេលវេលា, មានពេលច្រើនគឺហាត់ច្រើន, មានពេលតិចគឺហាត់តិច។ គង់ហ្វាមួយនេះរបស់ពួកយើងតម្រូវមិនតឹងរឹងពិសេសទេ, ប៉ុន្តែពួកយើងតម្រូវសម្រាប់ចិត្តគំនិតគឺតឹងខ្លាំងណាស់។ គង់ហ្វារបស់ពួកយើងក៏មិនសម្ដែងអំពីទិសដៅ, ឈរនៅទិសដៅណាមួយក៏អាចបាន។ ពីព្រោះចក្រវាលគឺបង្វិល, កំពុងផ្លាស់ប្ដូរ, លោកអ្នកឈរនៅខាងលិចក៏មិនប្រាកដគឺជាខាងលិច, លោកអ្នកឈរនៅខាងកើតក៏មិនប្រាកដគឺជាខាងកើត។ ខ្ញុំតម្រូវឱ្យកូនសិស្សហាត់គង់ឈរបែរមុខទៅខាងលិច, គ្រាន់តែជាការគោរពប៉ុណ្ណោះ, តាមពិតទៅវាគ្មានផលប៉ះពាល់អ្វីទេ។ ហាត់គង់នៅកន្លែងណាក៏អាចហាត់បាន, ក្នុងផ្ទះខាងក្រៅបានទាំងអស់។ ប៉ុន្តែខ្ញុំនៅតែគិតថារកកន្លែងមួយ, បរិស្ថាន, ខ្យល់អាកាសល្អជាងបន្តិច, ជាពិសេសគឺត្រូវឃ្លាតឆ្ងាយអ្វីសំអុយ, ដូចជាធុងសំរាម, បន្ទប់ទឹកជាដើម, អ្វីផ្សេងទៀតគ្មានបញ្ហាទេ។ បួសហាត់មហាធម៌មិនសម្ដែងពេលវេលា, ទីកន្លែងនិង

ទិសដៅ។ មុននិងក្រោយពេលបរិភោគអាចហាត់បានទាំងអស់, ប៉ុន្តែប្រសិនបើលោកអ្នកញាំឆ្អែតពេក, ភ្លាមៗហាត់ក៏ពិបាកទ្រាំដែរ, ល្អបំផុតនៅតែឈប់សម្រាកមួយរយៈ។ នៅពេលដែលក្រពះឃ្លានលាន់សូរសន្ធឹកក៏ពិបាកចូលទៅក្នុងស្ងប់ផងដែរ, អ្នករាល់គ្នាផ្អែកលើកាលៈទេសៈខ្លួនឯងដើម្បីរៀបចំ។

*សិស្ស៖ បន្ទាប់ពីហាត់គង់ចប់មានតម្រូវអ្វីទេ? តើត្រូវការត្រដុសមុខទេ?*

គ្រូ៖ ពួកយើងបន្ទាប់ពីហាត់គង់ចប់មិនខ្លាចទឹកត្រជាក់អ្វីទេ, ក៏មិនចាំបាច់ត្រដុសមុខ, ត្រដុសដៃ, នេះសុទ្ធតែជាអ្វីដែលប្រើនៅដំណាក់កាលដំបូងដើម្បីវាយបើកចំណុចចាក់ម្ជុលវិទ្យាសាស្ត្រនិងខ្សែវណ្ណនៃរាងកាយមនុស្ស។ ពួកយើងគឺជាបួសហាត់មហាធម៌, សុទ្ធតែគ្មានអ្វីទាំងនេះ, ឥឡូវនេះលែងនៅជាស្ថានភាពទើបតែចាប់ផ្តើមផ្លាស់ប្តូររាងកាយមនុស្សទៀតហើយ។ មនុស្សសាមញ្ញដើរឆ្ពោះទៅមនុស្សហាត់គង់ហាក់ដូចជាពិបាកណាស់ៗ, លើសពីនេះទៀតគង់ហ្វាមួយចំនួននៅតែមិនអាចផ្លាស់ប្តូររាងកាយមនុស្សដោយផ្ទាល់បាន, បើនិយាយពីវាមានតម្រូវមួយចំនួនស្មុគស្មាញណាស់, ពួកយើងនៅទីនេះសុទ្ធតែគ្មាន, ក៏គ្មានគំនិតទាំងនេះផងដែរ។ ដែលខ្ញុំមិនសម្តែងដល់លោកអ្នកមិនចាំបាច់ទៅកង្វល់, គ្រាន់តែកង្វល់ដើម្បីហាត់ប៉ុណ្ណោះ។ ដោយសារតែពួកយើងគឺបួសហាត់មហាធម៌, រាងកាយរបស់លោកអ្នកនៅក្នុងស្ថានភាពបឋមខ្លាចនេះខ្លាចនោះ, ឬក៏ដំណើរការដែលតម្រូវនេះតម្រូវនោះ, ក្នុង

រយៈពេលប៉ុន្មានថ្ងៃសុទ្ធតែឆ្លងផុតអស់។ ខ្ញុំមិននិយាយគង់ហ្វាទាបដទៃទៀតដែលមានជំនាញពីរបីឆ្នាំ, ប៉ុន្តែក៏មិនខុសពីគ្នាប៉ុន្មានដែរ។ អ្វីនៃជាន់ថ្នាក់ទាប, ទិសដៅនេះ, ខ្សែវណ្ណនោះ, ជាដើមទាំងនេះខ្ញុំសុទ្ធតែមិនសម្តែង, ពួកយើងសម្តែងអំពីអ្វីនៅជាន់ថ្នាក់ខ្ពស់។ ឬសហាត់មហាធម៌, ពិតជាហាត់គង់, គឺជាអក្សរ "炼", ប៉ុន្តែមិនមែនជាអក្សរ "练"។

*សិស្ស៖ តើបន្ទាប់ពីហាត់គង់អាចបត់ជើងធំឬបត់ជើងតូចភ្លាមបានឬទេ? នៅក្នុងទឹកនោមមានច្រើនពពុះ, តើឈើនឹងលេចធ្លាយឬទេ?*

គ្រូ៖ គ្មានបញ្ហាទេ។ មនុស្សហាត់គង់ពួកយើងនៅលើជាន់ថ្នាក់ខ្ពស់, បត់ជើងធំឬក៏បត់ជើងតូចជាការពិតមានថាមពលនាំចេញ, ប៉ុន្តែថាមពលបន្តិចនោះមិនរាប់ជាអ្វីទេ, អ្វីក៏មិនប៉ះពាល់ដែរ។ ហាត់មហាធម៌នៅត្រូវតែប្រោសសត្វលោកទាំងឡាយ, នៅចំណុចនេះមិនចាំបាច់យកចិត្តទុកដាក់, ដែលពួកយើងទទួលបាននៅច្រើនជាងទៅទៀត។ បើកថ្នាក់នេះ, ថាមពលដែលខ្ញុំវាយចេញខ្លាំងក្លាណាស់, លើជញ្ជាំងសុទ្ធតែបន្សល់ទុកជាច្រើនអ្វីៗ។

*សិស្ស៖ តើអាចផ្សព្វផ្សាយហ្វាលូនគង់បានឬទេ? តើអាចបង្រៀនឱ្យមនុស្សដែលមិនទាន់ចូលរួមថ្នាក់ស្តាប់សម្តែងធម៌ហាត់ហ្វាលូនគង់បានដែរទេ? (មនុស្ស)ដែលមិនទាន់ចូលរួមថ្នាក់ស្តាប់សម្តែងធម៌តើអាចនៅទីតាំងជំនួយហាត់គង់បានឬទេ? តើផ្ញើខ្សែអាត់និងសៀវភៅទៅសាច់ញាតិនិងមិត្តភក្តិនៅក្រៅទីក្រុងបាន*

*ឬទេ?*

គ្រូ៖ ធ្វើឱ្យជាសកលគង់ហ្វារបស់ពួកយើង, ធ្វើឱ្យមនុស្សកាន់តែច្រើនទទួលបានអត្ថប្រយោជន៍, នឹងមិនលេចឡើងគម្លាត។ ខ្ញុំសម្ដែងចេញឱ្យលោកអ្នកធម៌ជាច្រើន, ជាក់ស្ដែងគឺអនុញ្ញាតឱ្យលោកអ្នកដឹងពីធម៌, យល់ច្បាស់ពីអ្វីនៃជាន់ថ្នាក់ខ្ពស់, មើលឃើញនូវអ្វីនៃជាន់ថ្នាក់ខ្ពស់។ សម្ដែងចេញមុនគឺខ្លាចចាំដល់ពេលលោកអ្នកមើលឃើញឬក៏ជួបប្រទះរួចហើយមិនយល់។ លោកអ្នកអាចបង្រៀនមនុស្សដទៃហាត់គង់, ប៉ុន្ដែលោកអ្នកដំឡើងហ្វាលូននោះមិនបានទេ។ តើធ្វើដូចម្ដេចទៅ? ខ្ញុំបានសម្ដែងរួចហើយ, ប្រសិនបើលោកអ្នកមិនឧស្សាហ៍ព្យាយាមហាត់គង់, បរមីរបស់ខ្ញុំជាក់ស្ដែងនឹងឃ្លាតចេញពីលោកអ្នក។ ប្រសិនបើលោកអ្នកពិតជាហាត់គង់, បរមីជាក់ស្ដែងនឹងគ្រប់គ្រងលោកអ្នក។ ដូច្នេះនៅពេលលោកអ្នកបង្រៀនគង់ឱ្យគាត់, ជាក់ស្ដែងនាំព័ត៌មានដែលខ្ញុំបានបង្រៀនជាមួយ, ជាក់ស្ដែងមាននាំយន្ដការឈើដែលបង្កើតហ្វាលូនជាមួយ។ មនុស្សដែលលោកអ្នកបង្រៀនមានចិត្តទៅហាត់, ជាក់ស្ដែងអាចបង្កើតហ្វាលូន។ មានវាសនា, ដែលនិស្ស័យល្អ, នៅពេលនោះជាក់ស្ដែងអាចទទួលបានហ្វាលូន។ សៀវភៅរបស់ពួកយើងសរសេរលម្អិតណាស់, គ្មានមនុស្សបង្រៀន, ក៏អាចហាត់បានល្អផងដែរ។

*សិស្ស៖ ហាត់ហ្វាលូនគង់សម្ដែងឬក៏មិនសម្ដែងដកដង្ហើម? ធ្វើដូចម្ដេចសំរួលដង្ហើម?*

គ្រូ៖ ហាត់ហ្វាលូនគង់, មិនចាំបាច់សំរួលដង្ហើម, ក៏មិនសម្តែងដកដង្ហើម, នោះគឺជាអ្វីដែលរៀននៅគង់ហ្វាបឋម, នៅកន្លែងពួកយើងនេះមិនត្រូវការទេ។ ដោយសារតែសំរួលដង្ហើមដកដង្ហើមគឺដើម្បីហាត់តាន, ថែមខ្យល់, បន្ថែមភ្លើង។ ដកដង្ហើមបញ្ច្រាស, ដកដង្ហើមបណ្តោយ, លេបទឹកមាត់សុទ្ធតែគឺដើម្បីហាត់តាន, ពួកយើងមិនហាត់អ្វីទាំងនេះ។ អ្វីគ្រប់យ៉ាងដែលលោកអ្នកត្រូវការបានបង្គ្រប់ដោយហ្វាលូន។ មានរបស់មួយចំនួនដែលខ្ពស់ជាងពិបាកជាង, ដោយសារបរមីរបស់លោកគ្រូមកបង្គ្រប់។ និកាយណាមួយ, ជាពិសេសគឺតាវវង្សសម្តែងលម្អិតជាងទៀត, ប៉ុន្តែមិនមែនបានហាត់ចេញដោយចេតនា។ តាមពិតទៅគឺជាគ្រូខាងលើនៃនិកាយនោះរបស់គាត់កំពុងវិវត្តនិងផ្លាស់ប្តូរឱ្យគាត់, កំពុងផ្តល់ឱ្យគាត់, គាត់គ្រាន់តែមិនបានដឹងប៉ុណ្ណោះ។ ខ្លួនឯងដោយចេតនាធ្វើមិនបានទេ, មានតែមនុស្សដែលបើកការត្រាស់ដឹងរួចហើយ, បើកគង់រួចហើយទើបអាចធ្វើបាន។

*សិស្ស៖ តើហាត់គង់មានផ្តោតអារម្មណ៍ឬទេ? គំនិតនៃគង់ហ្វានៅកន្លែងណា?*

គ្រូ៖ ពួកយើងទីនេះគ្មានការផ្តោតអារម្មណ៍ទេ, រមែងគ្មានហៅអ្នករាល់គ្នាផ្តោតអារម្មណ៍, ទុកឱ្យលោកអ្នកលះបង់ការប្រកាន់, មិនតម្រូវគំនិតអ្វីទេ។ សំណុំគង់ហ្វាទី៣, បាតដៃទាំងពីរនាំឈីជាមួយស្រោចស្រឡះពីរប៉ូល, គិតភ្លាមនឹងទទួលបាន, លំហាត់ដទៃមិនចាំបាច់គិត។

*សិស្ស៖ តើប្រមូលថាមពលគឺដូចគ្នានឹងប្រមូលឈើមែនទេ?*

គ្រូ៖ ពួកយើងប្រមូលឈើធ្វើអ្វី? ដែលពួកយើងបួសហាត់គឺមហាធម៌, អនាគតនឹងមិនអាចសូម្បីតែឈើក៏បញ្ចេញមិនបាន។ ដែលពួកយើងហាត់មិនមែនឈើនៃជាន់ថ្នាក់ទាប, ប៉ុន្តែដែលបានបញ្ចេញមកគឺជាពន្លឺ។ ការប្រមូលថាមពល, ប្រើហ្វាលូនដើម្បីធ្វើ, មិនចាំបាច់ពួកយើងធ្វើដោយខ្លួនឯង។ ប៉ុន្តែឧបមាលំហាត់ស្រោចស្រឡះពីរប៉ូល, គាត់មិនមែនការប្រមូលឈើ, តាមពិតទៅគឺស្រោចស្រឡះរាងកាយ, ក៏ដើរតួនាទីក្នុងការប្រមូលថាមពលផងដែរ, ប៉ុន្តែចម្បងមិនមែនសម្រាប់គោលបំណងនេះ។ ចង់និយាយប្រមូលឈើតើប្រមូលដូចម្ដេច? បួសហាត់មហាធម៌, នៅពេលគ្រវីដៃកំពូលក្បាលនឹងមានអារម្មណ៍សម្ពាធធំណាស់, ភ្លាមៗនោះនឹងមកដល់ច្រើនខ្លាំងណាស់, ប៉ុន្តែចង់បានឈើសម្រាប់ធ្វើអ្វី? ថាមពលក៏មិនចាំបាច់ទៅប្រមូលដោយចេតនាផងដែរ។

*សិស្ស៖ តើហ្វាលូនគង់មានការកសាងមូលដ្ឋានរយៈពេលមួយរយថ្ងៃនិងដង្ហើមគភ៌ឬទេ?*

គ្រូ៖ ទាំងអស់នោះគឺជាអ្វីដែលទាប, ពួកយើងមិនហាត់។ ពួកយើងបានដើរឆ្លងដំណាក់កាលដំបូងនៃអស្មេរភាពតាំងពីយូរមកហើយ។

*សិស្ស៖ តើហ្វាលូនគង់មានតុល្យភាពអវិជ្ជមាននិងវិជ្ជមានឬទេ?*

គ្រូ៖ ទាំងនេះសុទ្ធតែជារបស់ការហាត់ឈើ, គឺជាអ្វីនៃជាន់ថ្នាក់

ទាប, ពេលដែលលោកអ្នកលោតចេញពីជាន់ថ្នាក់របស់ឈើរួចហើយ, រាងកាយរបស់លោកអ្នកមិនស្ថិតនៅបញ្ហាតុល្យភាពអវិជ្ជមាននិងវិជ្ជមានទៀត។ មិនថាលោកអ្នកហាត់គង់ហ្វាណាមួយ, ដរាបណាលោកអ្នកពិតជាទទួលបានការបង្រៀនពិតប្រាកដរបស់លោកគ្រូ, ធានាថាពេលដែលលោកអ្នកដើរចេញផុតពីជាន់ថ្នាក់ទាប, ជាក់ស្តែងត្រូវបោះចោលទាំងអស់អ្វីដែលលោកអ្នកធ្លាប់បានហាត់ពីមុន, ដូចគ្នាសុទ្ធតែមិនត្រូវការទៀត! នៅជាន់ថ្នាក់ថ្មីម្តងទៀតហាត់អ្វីមួយសំណុំថ្មី, បន្ទាប់មកឆ្លងកាត់មួយជាន់, ម្តងទៀតហាត់អ្វីមួយសំណុំថ្មី, ជាក់ស្តែងគឺជាបែបនេះ។

*សិស្ស៖ ពេលផ្គររន្ទះអាចហាត់គង់បានឬទេ? តើហាត់ហ្វាលូនគង់ភ័យខ្លាចសូរសម្លេងដែរទេ?*

គ្រូ៖ ខ្ញុំផ្តល់ឱ្យអ្នករាល់គ្នាឧទាហរណ៍មួយ, អតីតកាលខ្ញុំបានបង្រៀនសិស្សនៅក្នុងបរិវេណអាគារមួយធំនៅប៉េកាំង, នៅពេលនោះមេឃជិតភ្លៀង, ផ្គរលាន់ខ្លាំងណាស់។ នៅពេលនោះគង់ដែលពួកគាត់ហាត់គឺជាគង់ដែលខ្ញុំបង្រៀនឱ្យសិស្ស, ពេលដែលហាត់ត្រូវការឈរហាត់ផងធ្វើដំណើរលើហ្វាលូនផង។ ខ្ញុំឃើញភ្លៀងមកហើយ, គង់របស់ពួកគាត់នៅមិនទាន់ហាត់ចប់, ប៉ុន្តែ, នៅពេលនេះភ្លៀងធំជាមូលដ្ឋានធ្លាក់ចុះមកមិនបាន។ ពពកទាបណាស់, ពពកវិលបក់នៅពីលើអាគារ, ផ្គររន្ទះបាញ់ខ្លាំងណាស់, មេឃងងឹតណាស់, នៅពេលនោះរន្ទះបាញ់នៅខាងលើរង្វង់ហ្វាលូន, ប៉ុន្តែគ្មានបង្កគ្រោះថ្នាក់បន្តិចសោះសម្រាប់ពួកខ្ញុំ។ កាលៈទេសៈដែល

រន្ទះបាញ់ចុះនៅលើដីមើលឃើញយ៉ាងច្បាស់, ក៏មិនបង្កគ្រោះថ្នាក់ដល់ពួកយើង។ នេះពន្យល់ថាគង់នេះរបស់ពួកយើងគឺមានការពារ។ ធម្មតាខ្ញុំហាត់គង់មិនបែងចែកអាកាសធាតុអ្វីទេ, ចង់ហាត់គឺហាត់, មានពេលវេលាគឺហាត់, ក៏មិនខ្លាចសម្លេងផងដែរ។ គង់ដទៃទៀតសុទ្ធតែខ្លាចសម្លេង, ដោយសារតែលោកអ្នកនៅក្នុងពេលដ៏ស្ងាត់ៗស្រាប់តែស្ដាប់ឮសំឡេងដ៏ខ្លាំងមួយ, លោកអ្នកនឹងមានប្រភេទអារម្មណ៍, ស្ទើរតែឈើទាំងអស់នៃខាងលើខាងក្រោមពាសពេញរាងកាយជាក់ស្ដែងដូចជាការបំផ្ទុះ, បញ្ចេញពន្លឺទៅខាងក្រៅរាងកាយ។ ប៉ុន្តែកុំបារម្ភ, គង់របស់ពួកយើងមិនលេចឡើងគម្លាតទេ។ ជាការពិតណាស់ព្យាយាមរកកន្លែងមួយស្ងប់ស្ងាត់ដើម្បីហាត់នៅតែល្អជាង។

*សិស្ស៖ តើចាំបាច់ស្រមៃដល់រូបភាពរបស់លោកគ្រូទេ?*

គ្រូ៖ មិនចាំបាច់ស្រមៃទេ, បញ្ញាញាណរបស់លោកអ្នកបើករួចហើយជាក់ស្ដែងអាចមើលឃើញបរមីរបស់ខ្ញុំនៅក្បែរខ្លួន។

*សិស្ស៖ នៅពេលហាត់៥សំណុំលំហាត់នេះមានតម្រូវអ្វីទេ? តើត្រូវការហាត់ទាំងអស់តែម្ដងទេ? តម្រូវឱ្យហាត់៩ដងតើរាប់ក្នុងចិត្តបានដែរទេ? លើសពី៩ដងឬក៏ចងចាំងចលនាខុសតើនឹងផ្ដល់ផលអាក្រក់ដែរឬទេ?*

គ្រូ៖ ៥សំណុំគង់ហ្វាអាចហាត់សំណុំណាមួយក៏បាន, ខ្ញុំគិតថានៅមុនពេលលោកអ្នកហាត់គង់ល្អបំផុតហាត់សំណុំលំហាត់ទីមួយ, ដោយសារតែគាត់នឹងបើកសកម្មភាពនៃរាងកាយទាំងមូល,

លោកអ្នកហាត់មុនមួយដង, រាងកាយបើកការធ្វើចលនាពេញលេញរួចហើយ, បន្ទាប់មកហាត់លំហាត់ដទៃទៀតប្រសិទ្ធភាពល្អជាង។ ពេលវេលាច្រើនគឺហាត់ច្រើន, ពេលវេលាតិចគឺហាត់តិច, ឬក៏ជ្រើសសំណុំគង់ហ្វាមួយក្នុងនោះដើម្បីហាត់ក៏បានផងដែរ។ សំណុំលំហាត់ទី៣, ៤នីមួយៗហាត់៩ដង, ក្នុងសៀវភៅសរសេរថារាប់ក្នុងចិត្ត, លោកអ្នកត្រឡប់ទៅវិញអាចសាកមើល, ហៅកូនរបស់លោកអ្នកនៅក្បែរខ្លួនរាប់, ហើយលោកអ្នកធ្វើ។ បន្ទាប់ពីធ្វើ៩ដងរួចហើយរកយន្តការឈើទៀតក៏រកមិនបានដែរ, ដោយសារតែអ្វីរបស់ខ្ញុំនេះជាក់ស្តែងគឺបែបនេះឯង, ចាប់ផ្តើមត្រូវតែប្រើផ្នត់គំនិតរាប់បន្តិច, បន្ទាប់ពីទម្លាប់ហើយជាធម្មតានឹងឈប់។ ចងចាំខុសចលនាឬក៏ធ្វើច្រើនធ្វើតិចជាង, កែតម្រូវវិញគឺបានហើយ។

*សិស្ស៖ ហេតុអ្វីបានជាដកឥរិយាបថមិនដកគង់?*

គ្រូ៖ ហ្វាលូនបង្វិលដោយស្វ័យប្រវត្តិ, គាត់ភ្លាមៗនោះដឹងថាលោកអ្នកមិនហាត់គង់ទៀត។ ថាមពលរបស់គាត់ធំណាស់, ភ្លាមៗអាចដកមកវិញនូវអ្វីដែលបញ្ចេញទៅបាត់, យ៉ាងណាក៏ល្អជាងលោកអ្នកដកមកវិញដោយចេតនាផងដែរ។ នេះក៏មិនមែនដកគង់, គ្រាន់តែយកថាមពលមកវិញប៉ុណ្ណោះ។ គង់ហ្វាដទៃទៀតថាឈប់នឹងឈប់។ គង់ហ្វារបស់ពួកយើងនេះរមែងកំពុងហាត់, ឈប់ហើយក៏កំពុងហាត់, ដូច្នេះគឺមិនអាចដកបញ្ឈប់បាន។ ប្រសិនបើចង់ឱ្យហ្វាលូនឈប់, លោកអ្នកក៏បញ្ឈប់មិនបានផងដែរ។ និយាយស៊ីជម្រៅលោកអ្នកយល់មិនបាន, ប្រសិនបើលោក

អ្នកអាចបញ្ឈប់គាត់បាន, ខ្ញុំនៅទីនេះក៏ត្រូវតែឈប់ផងដែរ, តើលោកអ្នកអាចធ្វើឱ្យខ្ញុំនៅទីនេះក៏បញ្ឈប់បានដែរទេ?

*សិស្ស៖ តើភ្ជាប់ត្រា, ដៃពីររួមដប់អាចមើលដូចជាឈរគំនរដើម្បីហាត់បានទេ?*

គ្រូ៖ សំណុំគង់ហ្វាទី១-ព្រះពុទ្ធបង្ហាញដៃមួយពាន់មិនអាចមើលដូចជាឈរគំនរដើម្បីហាត់, សន្ទឹងកម្លាំងខ្លាំង, នឹងសន្ទឹងចេញជាជំងឺមិនខាន។

*សិស្ស៖ នៅពេលហាត់គង់ខាងក្រោមក្លៀកតើតម្រូវមានចន្លោះទេ? តើនៅពេលហាត់លើកទី១មានអារម្មណ៍ថាតឹងខាងក្រោមក្លៀកគឺជារឿងដូចម្តេច?*

គ្រូ៖ តើលោកអ្នកមានជំងឺទេឬ? នៅស្ថានភាពដំណាក់កាលដំបូង, នៅពេលផ្លាស់ប្តូររាងកាយរបស់លោកអ្នក, រកឃើញបាតុភូតនេះនោះ, នឹងមានរោគសញ្ញាមួយចំនួន, ប៉ុន្តែមិនមែនគង់នាំមកជាមួយ។

*សិស្ស៖ មនុស្សដែលមិនធ្លាប់ចូលរួមថ្នាក់ស្តាប់លោកគ្រូលើបង្រៀន, តើអាចនៅឧទ្យានហាត់គង់ជាមួយនឹងសិក្ខាកាមបានដែរទេ?*

គ្រូ៖ អាចបាន។ សិក្ខាកាមសុទ្ធតែអាចបង្រៀនឱ្យមនុស្សដទៃហាត់គង់។ សិក្ខាកាមបង្រៀនមនុស្សដទៃហាត់គង់មិនដូចខ្ញុំបង្រៀន, ខ្ញុំនឹងផ្លាស់ប្តូររាងកាយអោយអ្នករាល់គ្នាដោយផ្ទាល់,

ប៉ុន្តែក៏មានមនុស្សខ្លះដរាបណាហាត់គឺបង្កើតបានហ្វាលូន, ដោយសារតែខាងក្រោយរាងកាយសិក្ខាកាមសុទ្ធតែមានបរមីរបស់ខ្ញុំ, គាត់អាចទៅដោះស្រាយដោយផ្ទាល់។ នេះជាក់ស្ដែងត្រូវតែមើលវាសនា, វាសនាធំ, ពេលនោះនឹងអាចទទួលបានហ្វាលូន; វាសនាមិនធំ, ត្រូវតែឆ្លងកាត់ការហាត់គង់ដំណាក់កាលយូរ, ខ្លួនឯងបន្តិចម្ដងៗនឹងបង្កើតប្រភេទយន្តការបង្វិលនេះ។ ហាត់គង់បន្តទៀតធ្វើឱ្យយន្តការបង្វិលបង្កើតជាហ្វាលូន។

*សិស្ស៖ ឋិតិវន្តគង់ "ពង្រឹងទេពអំណាច" អត្ថន័យនៃចលនាក្បាច់ដៃគឺជាអ្វី?*

គ្រូ៖ នេះមិនអាចពន្យល់បានជាភាសារបស់ពួកយើងទេ, ចលនានីមួយៗគ្របដណ្ដប់អត្ថន័យច្រើនណាស់, ជាទូទៅជាក់ស្ដែងគឺ៖ 'ខ្ញុំបម្រុងហាត់គង់, បម្រុងហាត់ធម៌ព្រះពុទ្ធ, សំរួលល្អរាងកាយ, ចូលទៅក្នុងស្ថានភាពហាត់គង់'។

*សិស្ស៖ នៅពេលហាត់សម្រេចរាងកាយសដូចទឹកដោះ, តើរន្ធញើសធំតូចសុទ្ធតែវាយបើក, បង្កើតជារាងកាយដង្ហើមមែនទេ?*

គ្រូ៖ អ្នករាល់គ្នាពិសោធសាកមើល, លោកអ្នកធ្លាប់បានដើរឆ្លងកាត់ជាន់ថ្នាក់នេះរួចហើយ, ដោយសារតែខ្ញុំចង់សំរួលរាងកាយលោកអ្នកដល់ស្ថានភាពសដូចទឹកដោះ, ត្រូវការសម្ដែងធម៌ច្រើនជាង១០ម៉ោង, មិនអាចកាត់ខ្លីបានទៀត។ លោកអ្នកនៅក្នុងគង់ហ្វាដទៃត្រូវតែហាត់ជាងដប់ឆ្នាំរាប់ទសវត្សរ៍ឬក៏ពេលវេលាកាន់តែយូរជាងទៀត, ពួកយើងនៅទីនេះភ្លាមៗនឹងនាំលោកអ្នកដល់

ជំហានមួយនេះ។ ដោយសារតែជំហាននេះគ្មានតម្រូវនៃចិត្តគំនិត, យោងទៅតាមសមត្ថភាពរបស់គ្រូដើម្បីធ្វើ, ពេលលោកអ្នកនៅតែមិនទាន់ដឹងបានផង, ជាន់ថ្នាក់មួយនេះបានកន្លងផុតរួចហើយ, ប្រហែលជាមានតែពីរឬក៏បីម៉ោងប៉ុណ្ណោះ។ មានថ្ងៃមួយនោះ, លោកអ្នកមានអារម្មណ៍ឆាប់រសើបណាស់, បន្ទាប់ពីមួយរយៈលែងឆាប់រសើបទៀត, តាមពិតទៅជាក់ស្ដែងគឺមួយជាន់ថ្នាក់ធំកន្លងផុតរួចហើយ, ប៉ុន្តែនៅក្នុងគង់ហ្វាដទៃត្រូវតែរក្សាប្រភេទស្ថានភាពនេះមួយឆ្នាំឬក៏រាប់ឆ្នាំ, ទាំងអស់នេះ, តាមពិតសុទ្ធតែជាអ្វីនៃជាន់ថ្នាក់ទាប។

*សិស្ស៖ ពេលនៅលើឡានក្រុងឬក៏រង់ចាំនៅផ្លូវ, តើគិតអំពីឥរិយាបថរបស់ហ្វាលូនគង់បានឬទេ?*

គ្រូ៖ គង់របស់ពួកយើងគឺមិនមែនប្រើគំនិត, ក៏មិនតម្រូវរាល់ថ្ងៃត្រូវតែហាត់រយៈពេលយូរប៉ុណ្ណា, ជាការពិតពេលវេលាដែលហាត់កាន់តែយូរកាន់តែល្អ។ ពេលដែលលោកអ្នកមិនហាត់, ផ្ទុយមកវិញវាហាត់លោកអ្នក។ ប៉ុន្តែនៅពេលលោកអ្នកហាត់គង់ដំណាក់កាលដំបូងនៅតែត្រូវហាត់ឱ្យបានច្រើន, ពង្រឹងវា។ មានសិក្ខាកាមមួយចំនួនធ្លាប់លេចឡើងកាលៈទេសៈបែបនេះ, ធ្វើដំណើរអាជីវកម្មរយៈពេលមួយឬពីរខែ, ក្នុងមួយឬពីរខែនេះរវល់នឹងកិច្ចការជំនួញ, មិនហាត់គង់, បន្ទាប់ពីត្រឡប់មកវិញមិនត្រូវប៉ះពាល់ទាល់តែសោះ, ហ្វាលូននៅតែកំពុងបង្វិល, ដោយសារតែគាត់មិនបញ្ឈប់។ ក្នុងខួរក្បាលលោកអ្នកគិតថាលោកអ្នកគឺជាមនុស្សហាត់

គង់, ចិត្តគំនិតរក្សាជាប់, គាត់នឹងដំណើរការ។ មានតែមួយចំណុច, លោកអ្នកមិនហាត់គង់, ថែមទាំងមើលខ្លួនឯងលាយឡំនឹងមនុស្សសាមញ្ញទៀត, គាត់ជាក់ស្តែងនឹងរលាយបាត់ទៅ។

*សិស្ស៖ ហ្វាលូនគង់អាចហាត់រួមជាមួយនឹងនិកាយមីចុងបានទេ?*

គ្រូ៖ និកាយមីចុងក៏ជាហ្វាលូនផងដែរ, មិនអាចហាត់រួមជាមួយនឹងគង់របស់ពួកយើងបានទេ។ ប្រសិនបើលោកអ្នកហាត់និកាយមីចុងនិងហ្វាលូនបានបង្កើតរួចហើយ, លោកអ្នកអាចហាត់និកាយមីចុង, ដោយសារតែនិកាយមីចុងក៏ជាសុចរិតធម៌, ប៉ុន្តែហាត់ក្នុងពេលដំណាលគ្នាមិនបានទេ។ ហ្វាលូនរបស់មីចុងគឺប្ញសខ្សែវណ្ណកណ្តាល, បង្វិលផ្តេក, ហ្វាលូនរបស់វាខុសពីពួកយើង, លើកង់របស់វាមានមន្តគាថា។ ហ្វាលូនរបស់យើងគឺនៅទីតាំងពោះទាបដាក់បញ្ឈរ, មុខរាបបែរចេញក្រៅ, ពោះទាបគឺធំតែប៉ុណ្ណឹង, កង់របស់ខ្ញុំមួយគឺកាន់កាប់ពេញរួចហើយ, ដាក់មួយទៀតជាក់ស្តែងលាយបញ្ចូលគ្នាខូចបាត់។

*សិស្ស៖ ហាត់ហ្វាលូនគង់ហើយអាចហាត់គង់ហ្វាពុទ្ធវង្សដទៃទៀតបានឬទេ? ខ្សែអាត់ព្រះពោធិសត្វអាចស្តាប់បានឬទេ? តើឧបាសកឧបាសិកានៅផ្ទះបន្ទាប់ពីរៀនគង់រួចហើយអាចសូត្រគម្ពីរបានឬទេ? តើអាចក្នុងពេលដំណាលគ្នាហាត់គង់ហ្វាដទៃទៀតបានដែរទេ?*

គ្រូ៖ បញ្ហាមួយនេះខ្ញុំគិតថាមិនអាច។ ធម្មក្ខន្ធនីមួយៗសុទ្ធតែ

ជាមួយប្រភេទនៃវិធីសាស្រ្តប្ញូសហាត់, ពិតជាប្ញូសហាត់មិនមែនព្យាបាលជំងឺកាយសម្បទា, ជាក់ស្តែងចាំបាច់ត្រូវតែឯកទេសតែមួយគត់, នេះគឺជាបញ្ហាតឹងរឹង។ ប្ញូសហាត់ឡើងជាន់ថ្នាក់ខ្ពស់គឺត្រូវតែកាន់ជាប់ធម្មក្ខន្ធមួយប្ញូសឡើងទៅលើ, នេះគឺជាសច្ចៈធម៌ដាច់ខាត។ ប៉ុន្តែរាល់ធម្មក្ខន្ធនៃពុទ្ធវង្សក៏មិនអាចលាយបញ្ចូលផងដែរ។ គង់ហ្វាមួយនេះដែលពួកយើងសម្តែងគឺជាជាន់ថ្នាក់ខ្ពស់, គឺបានឆ្លងកាត់ជំនាន់យូរអង្វែងផ្ទេរចម្លងមក, ពឹងផ្អែកលើអារម្មណ៍របស់លោកអ្នកមិនបានទេ។ ពីអវកាសផ្សេងសង្កេតមើលដំណើរការវិវត្តន៍របស់គាត់, សុទ្ធតែជាអាថ៌កំបាំងបំផុត, ស្មុគស្មាញបំផុត។ ប្រដូចជាឧបករណ៍ភាពជាក់លាក់មួយ, ប្រសិនបើលោកអ្នកយកគ្រឿងប្រដាប់មួយរបស់វាចេញ, ប្តូរមួយផ្សេងដាក់ចូល, ភ្លាមៗនោះនឹងខូចជាមិនខាន។ គង់ហ្វាក៏ដូចគ្នាផងដែរ, អ្វីក៏ដោយសុទ្ធតែមិនអាចលាយបញ្ចូលបាន, លាយបញ្ចូលទៅក្នុងធានាលេចឡើងគម្លាត។ រាល់គង់ហ្វាសុទ្ធតែដូច្នោះ, លោកអ្នកចង់ហាត់ជាក់ស្តែងប្រាកដត្រូវតែឯកទេសតែមួយគត់។ លោកអ្នកមិនឯកទេសតែមួយគត់ជាមូលដ្ឋានជាក់ស្តែងប្ញូសមិនបាន, ការនិយាយថា៖ "យកភាពខ្លាំងរបស់មនុស្សគ្រប់គ្នា", គឺជាការនិយាយនៃជាន់ថ្នាក់ព្យាបាលជំងឺកាយសម្បទាមួយនេះ, គាត់មិនអាចនាំលោកអ្នកឡើងលើជាន់ថ្នាក់ខ្ពស់បានទេ។

*សិស្ស៖ ហាត់គង់រួមគ្នា(មួយកន្លែង)ជាមួយមនុស្សហាត់គង់ហ្វាដទៃ, តើមានប៉ះពាល់គ្នាទៅវិញទៅមកដែរទេ?*

គ្រូ៖ មិនថាគាត់ហាត់គង់អ្វី, តាវវង្សគង់ក៏បាន, អាទិទេពគង់ក៏បាន, ពុទ្ធវង្សគង់ក៏បាន, ដរាបណាគឺជាសុចរិតធម៌, សម្រាប់ពួកយើងគ្មានជ្រៀតជ្រែកអ្វីទេ, លោកអ្នកសម្រាប់គាត់ក៏មិនជ្រៀតជ្រែកផងដែរ។ គាត់ហាត់នៅក្បែរលោកអ្នកសម្រាប់គាត់មានកន្លែងល្អ, ដោយសារតែហ្វាលូនគឺជារាងកាយវិញ្ញាណ, មិនមែនហាត់តាន, គាត់អាចជួយដោយស្វ័យប្រវត្តិ។

*សិស្ស៖ តើអាចហៅគ្រូឈីគង់ដទៃកែសំរួលរាងកាយបានឬទេ? ស្ដាប់របាយការណ៍របស់គ្រូឈីគង់ដទៃតើមានឥទ្ធិពលឬទេ?*

គ្រូ៖ ខ្ញុំគិតថាបន្ទាប់ពីចាកចេញថ្នាក់បង្រៀននេះ, អ្នករាល់គ្នានឹងដឹងបានថារាងកាយរបស់លោកអ្នកយ៉ាងម៉េចរួចហើយ, ឆ្លងកាត់មួយដំណាក់កាលពេលវេលានឹងមិនអនុញ្ញាតឱ្យលោកអ្នកមានជំងឺទៀត។ ជំងឺម្ដងទៀត, អាចដូចជាផ្ដាសាយ, ក៏អាចដូចជាឈឺពោះ, តាមពិតទៅលែងនៅជាអ្វីនេះទៀតហើយ។ ប៉ុន្តែគឺជាគ្រោះមហន្តរាយ, គឺជាការឆ្លងទ្វារ។ លោកអ្នករកគ្រូឈីគង់ដទៃដើម្បីកែសំរួល, គឺលោកអ្នកមិនភ្ញាក់ដឹង, មិនជឿពាក្យដែលខ្ញុំនិយាយ, ឱបយកមនោគតិចំណង់, ជាក់ស្ដែងនឹងទាក់ទាញមកព័ត៌មានមិនល្អជ្រៀតជ្រែកលោកអ្នកបួសហាត់, គ្រូឈីគង់នោះគឺជាគង់របស់រាងកាយភ្ជាប់, លោកអ្នកក៏អាចទាក់ទាញមករបស់ទាំងនោះផងដែរ។ ស្ដាប់របាយការណ៍ក៏ដូចគ្នាផងដែរ, ចង់ស្ដាប់តើមិនមែនទៅចំណង់ឬ? បញ្ហាមួយនេះលោកអ្នកភ្ញាក់ដឹងដោយ

ខ្លួនឯង។ នេះគឺជាបញ្ហាចិត្តគំនិត, ខ្ញុំមិនគ្រប់គ្រង។ ប្រសិនបើដែលគាត់សម្តែងគឺជាធម៌ដ៏ខ្ពស់, សម្តែងអំពីបញ្ហាចិត្តគំនិតក៏បានដែរ។ លោកអ្នកចូលរួមក្នុងថ្នាក់របស់ខ្ញុំ, រាងកាយរបស់លោកអ្នកបានកែសំរួលកន្លងមកគឺមិនងាយស្រួលបន្តិចណាទេ, ដើមឡើយព័ត៌មានដែលរាងកាយលោកអ្នកហាត់ច្របូកច្របល់ណាស់, លើរាងកាយរញ៉េរញ៉ៃ, ឥឡូវនេះសុទ្ធតែកែសំរួលសមស្របរួចហើយ, របស់អាក្រក់កម្ចាត់ចោល, របស់ល្អរក្សាទុក។ ជាការពិតខ្ញុំមិនប្រឆាំងរៀនគង់ដទៃ, លោកអ្នកមានអារម្មណ៍ថាហ្វាលូនគង់មិនល្អអាចរៀនគង់ផ្សេងទៀតបាន, ប៉ុន្តែខ្ញុំគិតថាប្រសិនបើរៀនច្របូកច្របល់ពេកក៏មិនបានផងដែរ។ លោកអ្នកបានបួសមហាធម៌រួចហើយ, បរមីជាក់ស្តែងនៅក្បែររាងកាយលោកអ្នក, ទទួលបានរបស់ខ្ពស់រួចហើយនៅត្រឡប់មកស្វែងរកទៀតឬ!

*សិស្ស៖ តើហាត់ហ្វាលូនគង់អាចរៀនគង់ហ្វាដទៃទៀតបានទេ? ដូចជាម៉ាស្សា, ក្បាច់គុនការពារខ្លួន, សមាធិម្រាមដៃមួយ, ថៃជីជាដើម, មិនហាត់បណ្តាគង់នោះប៉ុន្តែអានសៀវភៅនៃទិដ្ឋភាពនេះតើមានបញ្ហាឬទេ?*

គ្រូ៖ សិក្សាម៉ាស្សា, ការពារខ្លួនអាចបាន, ប៉ុន្តែមានពេលខ្លះនៅពេលបញ្ចេញចិត្តឃោរឃៅនឹងមានអារម្មណ៍មិនស្រណុកកាយ។ សមាធិម្រាមដៃមួយ, ថៃជីជារបស់ឈីគង់, ហាត់ហើយនោះ, នឹងបន្ថែមអ្វីចូលទៅខាងក្នុង។ អ្វីរបស់ខ្ញុំនៅលើរាងកាយលោកអ្នកនឹងមិនបរិសុទ្ធទៀត។ មើលសៀវភៅសម្តែងអំពីចិត្ត

គំនិតនៅអាចបាន។ ប៉ុន្តែមានសៀវភៅមួយចំនួនអ្នកនិពន្ធខ្លួនគាត់ផ្ទាល់នៅមិនទាន់យល់ច្បាស់, បានឈានដល់ការសន្និដ្ឋាន, ដែលនឹងធ្វើឱ្យច្របូកច្របល់មនោគតិរបស់លោកអ្នក។

*សិស្ស៖ "ឱបកង់ខាងមុខក្បាល" ពេលខ្លះដៃនឹងប៉ះគ្នា, មានបញ្ហាអ្វីទេ?*

គ្រូ៖ មិនប៉ះបាន, ពួកយើងតម្រូវគឺគម្លាតចេញ, ប៉ះហើយ, ថាមពលដែលនៅលើដៃនឹងត្រឡប់មកវិញ។

*សិស្ស៖ នៅពេលហាត់សំណុំគង់ហ្វាទី២ដៃខំព្យាយាមមិនបាន, ដាក់ចុះមកហើយហាត់ម្តងទៀតបានឬទេ?*

គ្រូ៖ ហាត់គង់គឺលំបាកណាស់, នៅពេលណាចុករោយក៏ដាក់ចុះភ្លាមស្មើនឹងគ្មានប្រសិទ្ធភាព, តម្រូវពេលវេលាកាន់តែយូរកាន់តែល្អ, ប៉ុន្តែត្រូវប៉ាន់ស្មានកម្លាំងដើម្បីធ្វើ។

*សិស្ស៖ នៅពេលអង្គុយបត់ប្រសព្វជើងហេតុអ្វីស្ត្រីជើងឆ្វេងនៅខាងក្រោម, ជើងស្តាំនៅខាងលើ?*

គ្រូ៖ ដោយសារតែពួកយើងហាត់គង់សម្តែងអំពីចំណុចមូលដ្ឋាន, រាងកាយស្ត្រីនិងបុរសមិនដូចគ្នា, ដូច្នេះចង់រាងកាយរបស់គាត់ទៅផ្លាស់ប្តូរខ្លួនឯង, ជាក់ស្តែងត្រូវតែស្របតាមសរីរវិទ្យានៃលក្ខណៈស្ត្រីទើបមានប្រសិទ្ធភាព, ស្ត្រីជាធម្មតាគឺជើងឆ្វេងទ្រជើងស្តាំ, ស្របតាមស្ថានភាពផ្ទាល់ខ្លួន, បុរសផ្ទុយមកវិញ, ចំណុចមូលដ្ឋានមិនដូចគ្នា។

*សិស្ស៖ តើស្តាប់ខ្សែអាត់ឬក៏ស្តាប់ចម្រៀងឬក៏សូត្រវគ្គហាត់គង់បានឬទេ?*

គ្រូ៖ ប្រសិនបើមានចម្រៀងល្អរបស់ពុទ្ធវង្សអាចស្តាប់បាន, ប៉ុន្តែពិតជាហាត់គង់ចម្រៀងអ្វីសុទ្ធតែមិនត្រូវការ, ដោយសារតែតម្រូវកម្លាំងរម្ងាប់, ស្តាប់ខ្សែអាត់ដើម្បីគំនិតមួយតំណាងរាប់ម៉ឺនគំនិត។

*សិស្ស៖ តើលំហាត់ស្រោចស្រឡះពីរប៉ូលគឺសម្រាក, ឬក៏តម្រូវប្រើកម្លាំង?*

គ្រូ៖ លំហាត់ស្រោចស្រឡះពីរប៉ូលតម្រូវឈរត្រង់តាមធម្មតា, សម្រាក, មិនតម្រូវដូចសំណុំគង់ហ្វាទីមួយបែបនោះទេ, លំហាត់ដទៃទៀតរបស់ពួកយើងសុទ្ធតែមិនដូចសំណុំគង់ហ្វាទីមួយ, សុទ្ធតែត្រូវសម្រាក។

## III. បួសហាត់ចិត្តគំនិត

*សិស្ស៖ កូនចង់ធ្វើបាន "សច្ចៈ-ករុណា-ខន្តី", ប៉ុន្តែម្សិលមិញយល់សប្តិឈ្លោះប្រកែកជាមួយនឹងមនុស្សដទៃ, ឈ្លោះគ្នាសាហាវណាស់, កូនចង់ខន្តី, តែខន្តីមិនបានសោះ, តើនេះគឺកំពុងជួយកូនលើកកម្ពស់ចិត្តគំនិតមែនទេ?*

គ្រូ៖ ពិតប្រាកដណាស់។ សុបិន្តគឺជារឿងដូចម្តេចពួកយើងបានសម្តែងរួចហើយ, អ្នករាល់គ្នាខ្លួនឯងទៅភ្ញាក់ដឹង។ រឿងដែលលើកកម្ពស់ចិត្តគំនិតមកដល់ភ្លាមៗណាស់, មិនមែនរង់ចាំលោក

អ្នកធ្វើល្អត្រៀមមនោគតិដើម្បីស្វាគមន៍វាទើបវាមកដល់។ សង្កេតមើលមនុស្សម្នាក់គឺជាល្អឬក៏ជាអាក្រក់, មានតែនៅក្នុងកាលៈទេសៈដែលមិនមានការត្រៀមមនោគតិទើបអាចសាកល្បងចេញមកបាន។

*សិស្ស៖ "ខន្តី" ក្នុង "សច្ចៈ-ករុណា-ខន្តី" នៃហ្វាលូនគង់, តើរឿងរ៉ាវទាំងអស់សុទ្ធតែចាំបាច់ខន្តី, មិនថាត្រឹមត្រូវឬក៏អត់?*

គ្រូ៖ "ខន្តី" ដែលខ្ញុំសម្ដែង, គឺសំដៅទៅលើបញ្ហាដែលទាក់ទងដល់ផលប្រយោជន៍ឯកជនរបស់លោកអ្នក, លើអ្វីទាំងនេះដែលលោកអ្នកប្រកាន់និងលះបង់មិនបានដើម្បីលើកកម្ពស់ចិត្តគំនិតរបស់លោកអ្នក។ តាមពិតទៅ "ខន្តី" មិនមែនរឿងអាក្រក់, ជាក់ស្តែងគឺសម្រាប់មនុស្សសាមញ្ញក៏មិនអាក្រក់ផងដែរ។ ពួកយើងនិទានរឿងមួយ៖ ហានស៊ីនគឺជាឧត្តមសេនីយ៍យោធាម្នាក់, តាំងពីកុមារភាពគឺពូកែក្បាច់គុន, មនុស្សហាត់ក្បាច់គុននាពេលនោះជាក់ស្តែងចូលចិត្តកាន់ដាវ។ ហានស៊ីនដើរតាមផ្លូវ, ជនពាលម្នាក់បានចូលមកហើយនិយាយថា៖ "ឯងកាន់ដាវនេះទុកធ្វើអ្វី? ឯងហ៊ានសម្លាប់មនុស្សទេ? ឯងហ៊ានសម្លាប់មនុស្សសម្លាប់អាញ់មុនមក។" ខណៈពេលនិយាយកក៏លាតចេញ៖ "ប្រសិនបើមិនហ៊ាន, គឺលូនកាត់ក្រោមក្រលៀនរបស់អាញ់!" ហានស៊ីនក៏លូនឆ្លងកាត់, សមត្ថភាព "ខន្តី" របស់គាត់ធំណាស់។ មានមនុស្សមើលខន្តីក្លាយជាទន់ខ្សោយងាយត្រូវសម្លុត, តាមពិតមនុស្សដែលអាចខន្តីឆន្ទៈគឺរឹងមាំណាស់។ សម្រាប់រឿងរ៉ាវត្រឹមត្រូវឬអត់, ត្រូវតែសង្កេតមើលវាគឺ

ពិតជាស្របតាមគោលសីលធម៌នៃចក្រវាលឬអត់។ លោកអ្នកសន្មតថារឿងមួយមិនមែនកំហុសរបស់លោកអ្នក, គឺមនុស្សដទៃធ្វើឱ្យលោកអ្នកខឹង, តាមពិតលោកអ្នកមិនដឹងទីបំផុតហេតុអ្វី? លោកអ្នកនិយាយថា៖ "ខ្ញុំដឹងតើ, ជាក់ស្តែងគឺព្រោះតែរឿងរ៉ាវតូចមួយ។" អ្វីដែលខ្ញុំនិយាយគឺជាគោលសីលធម៌មួយផ្សេង, មិនមែនអ្វីដែលមើលឃើញបាននៃអវកាសសារធាតុរបស់យើងនេះ។

និយាយកំប្លែងមួយនេះ, ប្រហែលលោកអ្នកជាតិមុនជំពាក់គេ, លោកអ្នកធ្វើម្តេចអាចវិនិច្ឆ័យវាត្រឹមត្រូវឬខុសឆ្គង? ពួកយើងជាក់ស្តែងត្រូវតែខន្តី។ តើមានឯណាមកធ្វើឱ្យមនុស្សដទៃខឹងមុនហើយវិលទៅខន្តីវិញ? សម្រាប់មនុស្សដែលពិតជាធ្វើឱ្យលោកអ្នកខឹង, លោកអ្នកមិនត្រឹមតែត្រូវខន្តីប៉ុណ្ណោះទេ, នៅត្រូវតែអរគុណដល់គាត់ទៀតផង។ គាត់ស្តីបន្ទោសលោកអ្នករួចហើយ, ទៅរកលោកគ្រូដើម្បីប្តឹងលោកអ្នកទៀត, លោកអ្នកវិលមកក្នុងចិត្តនៅត្រូវតែនិយាយអរគុណ។ លោកអ្នកនិយាយថា៖ "តើនោះមិនក្លាយជាអា-Q ហើយឬ?" នោះគឺជាការគិតរបស់លោកអ្នក។ តាមរយៈរឿងនេះ, ប្រសិនបើលោកអ្នកប្រព្រឹត្តចំពោះគាត់មិនដូច(គាត់ប្រព្រឹត្តចំពោះលោកអ្នក), ចិត្តគំនិតរបស់លោកអ្នកជាក់ស្តែងលើកកម្ពស់រួចហើយ។ នៅអវកាសសារធាតុនេះគាត់កាន់កាប់បានហើយ, តើនៅខាងនោះមិនមែនគាត់ផ្តល់ឱ្យលោកអ្នកអ្វីមួយទេឬ? ចិត្តគំនិតរបស់លោកអ្នកលើកកម្ពស់រួចហើយ, សារធាតុពណ៌ខ្មៅបានផ្លាស់ប្តូររួចហើយ, កាយវិការមួយទទួលបានបី, ហេតុអ្វីមិនអរគុណគេ?

ឈរនៅលើទស្សនៈរបស់មនុស្សសាមញ្ញមិនងាយស្រួលពន្យល់។ ខ្ញុំមិនមែនកំពុងសម្ដែងឱ្យមនុស្សសាមញ្ញ, ប៉ុន្តែគឺកំពុងសម្ដែងសម្រាប់មនុស្សហាត់គង់។

*សិស្ស៖ មនុស្សដែលគ្មានរាងកាយភ្ជាប់លើកកម្ពស់ចិត្តគំនិតអាចជៀសវាងរាងកាយភ្ជាប់, មនុស្សដែលមានរាងកាយភ្ជាប់តើធ្វើដូចម្ដេចទើបអាចកម្ចាត់បាន?*

គ្រូ៖ សុចរិតមួយសង្កត់រាប់រយទុចរិត។ លោកអ្នកថ្ងៃនេះទទួលបានធម៌នេះ, បន្ទាប់មកទោះបីជាវាផ្ដល់ឱ្យលោកអ្នកនាំមក "កន្លែងល្អ" លោកអ្នកសុទ្ធតែមិនចង់បាន។ ប្រសិនបើនៅពេលអ្វីនោះផ្ដល់ឱ្យលោកអ្នកនាំមកនូវប្រាក់, កិត្តិនាម, ផលប្រយោជន៍, ក្នុងចិត្តលោកអ្នកសប្បាយរីករាយ, "មើលតើខ្ញុំមានសមត្ថភាពប៉ុណ្ណា", បង្ហាញនៅចំពោះមុខមនុស្សបន្តិច។ នៅពេលលោកអ្នកពិបាកទ្រាំលោកអ្នកមិនចង់បានទៀត, ចង់រកលោកគ្រូព្យាបាលឱ្យលោកអ្នក, នៅពេលវាផ្ដល់ឱ្យលោកអ្នក "កន្លែងល្អ" លោកអ្នកធ្វើដូចម្ដេច? នោះគឺមិនអាចគ្រប់គ្រងបានទេ, ដោយសារតែវាផ្ដល់ឱ្យលោកអ្នក "កន្លែងល្អ" លោកអ្នកទទួលយករួចហើយ, លោកអ្នកចង់បានតែកន្លែងល្អនោះមិនបានទេ។ មានតែចិត្តលោកអ្នកខ្លួនឯងមិនចង់បាន, នាំមកកន្លែងល្អក៏មិនចង់បាន, ជាក់ស្ដែងគឺយោងទៅតាមវិធីសាស្ត្រដែលលោកគ្រូនិយាយដើម្បីប្ដូសហាត់។ មនុស្សលោកអ្នកឱ្យតែសុចរិត, ចិត្តឱ្យតែព្យាយាមនិងរឹងមាំ, វាបានភ័យរន្ធត់រួចហើយ, ឱ្យលោកអ្នកកន្លែងល្អលោកអ្នកក៏មិនចង់បាន, វា

ជាក់ស្តែងគួរតែទៅហើយ។ ប្រសិនបើមិនទៅទៀតជាក់ស្តែងគឺជាធ្វើរឿងអាក្រក់, នៅពេលនោះខ្ញុំជាក់ស្តែងអាចគ្រប់គ្រងវាហើយ, គ្រវីដៃមួយភ្លាមវានឹងបាត់ស្រមោល។ ប៉ុន្តែមានកន្លែងល្អប្រសិនបើលោកអ្នកចង់បានជាក់ស្តែងមិនបានទេ។

*សិស្ស៖ តើនៅក្នុងខ្ទៀនហាត់គង់នឹងមានរាងកាយភ្ជាប់ឬទេ?*

គ្រូ៖ ខ្ញុំបានសម្តែងឱ្យអ្នករាល់គ្នាច្រើនដងរួចហើយ, ពួកយើងគឺជាបួសហាត់សុចរិតធម៌, ចិត្តសុចរិតសង្កត់រាប់រយទុចរិត! បួសហាត់សុចរិតធម៌, ចិត្តបរិសុទ្ធណាស់, អ្វីមួយក៏ឡើងមកមិនបានដែរ។ ប៉ុន្តែហ្វាលូនគឺជាអ្វីមួយពិតជាអស្ចារ្យណាស់, អ្វីដែលមិនល្អមិនត្រឹមតែឡើងមកមិនបានប៉ុណ្ណោះទេ, មកដល់ចំពោះមុខវាសុទ្ធតែភ័យខ្លាច។ លោកអ្នកមិនជឿទៅដល់កន្លែងផ្សេងហាត់គង់, វាសុទ្ធតែខ្លាចលោកអ្នក។ ខ្ញុំនិយាយចេញតួលេខ, អ្នករាល់គ្នាសុទ្ធតែមានអារម្មណ៍គួរឱ្យខ្លាច, មនុស្សជាច្រើនគឺមានរាងកាយភ្ជាប់។ សម្រេចបានគោលបំណងព្យាបាលជំងឺកាយសម្បទារួចហើយនៅតែបន្តហាត់, តើលោកអ្នកចង់ទទួលបានអ្វី? ចិត្តមិនសុចរិតជាក់ស្តែងនាំមកនូវបញ្ហាទាំងនេះ។ ប៉ុន្តែក៏មិនបន្ទោសមនុស្សទាំងនោះ, គាត់មិនដឹងគោលសីលធម៌ទាំងនេះ, គោលបំណងដែលខ្ញុំចេញមកសាធារណៈក្នុងនោះក៏រួមមានរឿងនេះផងដែរ, ដើម្បីកែតម្រូវអ្វីដែលខុសឆ្គងទាំងនេះឱ្យអ្នករាល់គ្នា។

*សិស្ស៖ អនាគតនឹងលេចឡើងសីលគង់អ្វី?*

គ្រូ៖ ខ្ញុំមិនចង់សម្តែង, ដោយសារតែកាលៈទេសៈរបស់មនុស្សម្នាក់ៗមិនដូចគ្នា, ដូច្នេះពិបាកនិយាយណាស់។ នៅលើជាន់ថ្នាក់នេះបញ្ចេញមួយនេះ, លើជាន់ថ្នាក់នោះបញ្ចេញមួយនោះ, សំខាន់គឺនូវចិត្តគំនិតរបស់លោកអ្នកនៅក្នុងជាន់ថ្នាក់នីមួយៗ។ ចិត្តប្រកាន់អាចនៅទិដ្ឋភាពនេះកម្ចាត់បានហើយ, ទិដ្ឋភាពនេះលេចឡើងសីលគង់, ប៉ុន្តែសីលគង់ដែលលោកអ្នកលេចឡើងត្រូវតែគឺនៅអំឡុងពេលដំបូង, នឹងមិនខ្ពស់ណាស់ទេ។ នៅពេលដែលចិត្តគំនិតមិនទាន់ឈានដល់ខ្ពស់ណាស់, សីលគង់ក៏មិនអាចផ្តល់ឱ្យលោកអ្នកបានផងដែរ។ ប៉ុន្តែលើថ្នាក់បង្រៀនរបស់ពួកយើងមនុស្សខ្លះនិស្ស័យល្អណាស់, បានលេចឡើងសីលគង់បាទជើងព្រះរួចហើយ, មេឃភ្លៀងមិនទទឹក, ក៏មានលេចឡើងផ្ទេរជញ្ជូនផងដែរ។

*សិស្ស៖ បួសចិត្តគំនិត, កម្ចាត់ទាំងអស់ចិត្តប្រកាន់, តើគឺសំដៅទៅលើសម្រេចបាន "ទទេ" នៃពុទ្ធវង្ស, "គ្មាន" នៃតាវវង្ស មែនទេ?*

គ្រូ៖ ចិត្តគំនិតឬក៏គឺជា "គុណធម៌" ដែលពួកយើងនិយាយ, សុទ្ធតែមិនមែនបានបញ្ចូលក្នុង "ទទេ" របស់ពុទ្ធវង្ស, "គ្មាន" របស់តាវវង្ស, ផ្ទុយមកវិញ, ទាំងនោះរបស់ពួកគាត់សុទ្ធតែរួមបញ្ចូលនៅក្នុងចិត្តគំនិតរបស់ពួកយើង។

*សិស្ស៖ តើព្រះពុទ្ធជានិច្ចគឺជាព្រះពុទ្ធមែនទេ?*

គ្រូ៖ អ្នកបួសហាត់សម្រេចធម៌, បន្ទាប់ពីត្រាស់ដឹង, លោក

អ្នកជាក់ស្ដែងរាប់ថាជាអង្គមហាត្រាស់ដឹង, ក៏ជាក់ស្ដែងគឺជាជីវិតកម្រិតខ្ពស់, ប៉ុន្តែមិនអាចធានាថាលោកអ្នកជានិច្ចមិនធ្វើរឿងអាក្រក់។ ជាការពិតតាមធម្មតានៅជាន់ថ្នាក់នោះលោកអ្នកនឹងមិនធ្វើរឿងអាក្រក់, ដោយសារតែមើលឃើញសេចក្ដីពិតរួចហើយ, ប៉ុន្តែប្រសិនបើធ្វើរឿងអាក្រក់, នៅតែធ្លាក់ចុះ។ ជានិច្ចធ្វើរឿងល្អជាក់ស្ដែងជានិច្ចនៅទីនោះ។

*សិស្ស៖ អ្វីគឺជាមនុស្សមហានិស្ស័យ?*

គ្រូ៖ នេះដោយកត្តានៃប៉ុន្មានទិដ្ឋភាពអាចកំណត់បាន៖ ១▪និស្ស័យរបស់គាត់ល្អណាស់; ២▪ភ្ញាក់ដឹងខ្ពស់ណាស់; ៣▪ការស៊ូទ្រាំខ្លាំងណាស់; ៤▪ចិត្តប្រកាន់តូច, សម្រាប់អ្វីៗនៃលោកីយ៍មើលស្រាលណាស់, នេះជាក់ស្ដែងគឺជាមហានិស្ស័យ។ មនុស្សមហានិស្ស័យពិបាកជួបបានណាស់។

*សិស្ស៖ តើអ្នកដែលមិនមែនមហានិស្ស័យហាត់ហ្វាលូនគង់អាចបញ្ចេញគង់ឬទេ?*

គ្រូ៖ មិនមែនអ្នកមហានិស្ស័យក៏អាចបញ្ចេញគង់បានផងដែរ, ដោយសារតែមនុស្សម្នាក់ៗសុទ្ធតែនាំតាមបរិមាណគុណធម៌ជាមួយ។ គ្មានបរិមាណគុណធម៌បន្តិចណាសោះគឺមិនអាចទេ, គ្មានមនុស្សបែបនេះទេ។ ប្រសិនបើលើរាងកាយលោកអ្នកគ្មានសារធាតុដែលមានពណ៌ស, ក៏នៅតែមានសារធាតុដែលមានពណ៌ខ្មៅផងដែរ, សារធាតុដែលមានពណ៌ខ្មៅតាមរយៈការហាត់គង់អាចបំលែងទៅជាសារធាតុដែលមានពណ៌ស, គ្រាន់តែបន្ថែមនីតិវិធីមួយ

ប៉ុណ្ណោះ។ នៅក្នុងការហាត់គង់លោកអ្នករងទុក្ខលំបាករួចហើយ, លើកកម្ពស់ចិត្តគំនិតរួចហើយ, មានចំណាយរួចហើយ, ក៏ជាក់ស្តែងមានគង់រួចហើយ, ហាត់គឺជាលក្ខខណ្ឌជាមុន, ក្រោយមកដោយសារបរមីរបស់លោកគ្រូប្រែក្លាយវាទៅជាគង់។

*សិស្ស៖ នៅពេលមនុស្សម្នាក់កើតមក, មួយជីវិតរបស់គាត់ជាក់ស្តែងបានកំណត់រួចហើយ, ដូច្នេះតាមរយៈការតស៊ូអាចផ្លាស់ប្តូរបានឬទេ?*

គ្រូ៖ ជាការពិតអាចផ្លាស់ប្តូរបាន, ការតស៊ូរបស់លោកអ្នកក៏បានរៀបចំរួចហើយ, មិនតស៊ូក៏មិនបានដែរ, លោកអ្នកគឺជាមនុស្សសាមញ្ញ, ប៉ុន្តែអ្វីដែលធំផ្លាស់ប្តូរមិនបានទេ។

*សិស្ស៖ ក្នុងកាលៈទេសៈដែលបញ្ញាញាណមិនទាន់បើក, តើធ្វើដូចម្តេចដើម្បីសម្គាល់ព័ត៌មានដែលទទួលបានគឺជាល្អឬក៏ជាអាក្រក់?*

គ្រូ៖ លោកអ្នកខ្លួនឯងមិនងាយស្រួលសម្គាល់បានទេ, នៅក្នុងការហាត់គង់របស់លោកអ្នក, ស្ថិតនៅជាច្រើនបញ្ហាដែលសាកល្បងចិត្តគំនិតរបស់លោកអ្នក។ បរមីការពារលោកអ្នកគឺមិនទុកឱ្យលោកអ្នកកើតមានគ្រោះថ្នាក់ដល់ជីវិត, ប៉ុន្តែមានរឿងមួយចំនួនលេចឡើងគាត់មិនប្រាកដថានឹងគ្រប់គ្រង, ចាំបាច់លោកអ្នកខ្លួនឯងទៅឆ្លងកាត់, ខ្លួនឯងទៅដោះស្រាយ, ខ្លួនឯងទៅភ្ញាក់ដឹង។ ពេលខ្លះព័ត៌មានអាក្រក់មកដល់, វាប្រាប់លោកអ្នកថ្ងៃនេះឆ្នោតគឺលេខប៉ុន្មាន, ប្រហែលជាត្រូវ, ប្រហែលជាមិនត្រូវ, ឬក៏ប្រាប់លោក

អ្នករឿងផ្សេង, ជាក់ស្តែងសង្កេតមើលលោកអ្នកធ្វើដូចម្តេច។ ចិត្តសុចរិតអំពើអាក្រក់មិនលុកលុយ។ ដរាបណាលោកអ្នករក្សាជាប់ចិត្តគំនិតជាក់ស្តែងគ្មានបញ្ហាទេ។

*សិស្ស៖ នៅពេលអារម្មណ៍, មនោសញ្ចេតនាមិនស្ថិតស្ថេរតើអាចហាត់គង់បានឬទេ?*

គ្រូ៖ នៅពេលអារម្មណ៍មិនសូវល្អលោកអ្នកអង្គុយនៅទីនោះក៏ស្ងប់ចុះមិនបានផងដែរ, គំនិតរមែងគិតតែរឿងមិនល្អ, ហាត់គង់គឺមានព័ត៌មានស្ថិតនៅ, ក្នុងខួរក្បាលគិតអ្វីដែលមិនល្អ, លោកអ្នកហាត់គង់ជាក់ស្តែងហាត់ចូលទៅក្នុងរួចហើយ, ដោយចេតនាហាត់ទុចរិតធម៌។ គង់ដែលលោកអ្នកហាត់ប្រហែលជាគឺគ្រូល្បីល្បាញបង្រៀនលោកអ្នក, ក៏ប្រហែលជាគឺគ្រូខាងលើណាមួយបង្រៀនលោកអ្នក, ឬក៏គឺជាព្រះពុទ្ធរស់បង្រៀន, ប៉ុន្តែលោកអ្នកមិនតឹងរឹងយោងទៅតាមចិត្តគំនិតដែលពួកគាត់តម្រូវដើម្បីតម្រូវជាក់ស្តែងគឺមិនមែនគង់នោះរបស់គាត់ទេ, បើទោះបីជាបានគាត់បង្រៀនក៏ដោយ។ អ្នករាល់គ្នាពួកយើងទាំងអស់គិតសាកមើល, ឧបមាលោកអ្នកនៅទីនោះហាត់ឈរគំនររោយណាស់ទៅហើយ, ប៉ុន្តែក្នុងខួរក្បាលសកម្មណាស់ ‵តើនរណាៗក្នុងអង្គភាពរបស់ពួកយើងម្តេចក៏អាក្រក់យ៉ាងនេះន៎? តើគាត់ប្តឹងខ្ញុំយ៉ាងម៉េច?′ ‵ឡើងប្រាក់ខែតើគិតវិធីអ្វីអាចឡើងបាន?′ ‵តម្លៃទីផ្សារឥឡូវនេះកំពុងកើនឡើង, ខ្ញុំត្រូវតែទិញច្រើនបន្តិច′។ តើនោះមិនមែនលោកអ្នកកំពុងហាត់ទុចរិតធម៌ដោយចេតនា, ដោយអឌ្ឍសម្បជញ្ញៈ, ដោយមិន

ដឹងខ្លួនទេឬ? ដូច្នេះនៅពេលអារម្មណ៍មិនល្អព្យាយាមកុំហាត់តាមដែលអាចធ្វើទៅបាន។

*សិស្ស៖ បរមាណីយនៃ "ចិត្តគំនិតយ៉ាងខ្ពស់បំផុត" គឺជាអ្វី?*

គ្រូ៖ ចិត្តគំនិតគឺជាប្អូសហាត់, គ្មានបរមាណីយអ្វី, ទាំងស្រុងពឹងផ្អែកលើលោកអ្នកខ្លួនឯងដើម្បីភ្ញាក់ដឹង។ ប្រសិនបើត្រូវនិយាយថាមានបរមាណីយ, ជាក់ស្តែងនៅពេលជួបប្រទះរឿងលោកអ្នកគិតសាកមើល៖ 'ប្រសិនបើអង្គត្រាស់ដឹងតើគាត់គួរធ្វើដូចម្តេច?' អ្នកជឿនលឿនជាការពិតគឺលេចធ្លោខ្លាំងណាស់, ប៉ុន្តែគាត់គ្រាន់តែជាគំរូនៃមនុស្សសាមញ្ញប៉ុណ្ណោះ។

*សិស្ស៖ សម្រាប់របាយការណ៍, កថានៃបណ្តាគ្រូឈីគង់មិនអាចឱបយកអាកប្បកិរិយាសង្ស័យ, ប៉ុន្តែជួបប្រទះ(គ្រូឈីគង់) បញ្ឆោតមនុស្សបញ្ឆោតលុយតើធ្វើដូចម្តេច?*

គ្រូ៖ នោះមិនកំណត់ទេ, មុនដំបូងលោកអ្នកចង់មើលសម្តែងគឺជាអ្វី។ ជួបប្រទះជនបញ្ឆោតមនុស្ស, លោកអ្នកទៅសម្គាល់ខ្លួនឯង។ មើលគ្រូឈីគង់ម្នាក់ល្អឬក៏អាក្រក់, អាចមើលចិត្តគំនិតរបស់គាត់, ចិត្តគំនិតខ្ពស់ប៉ុណ្ណា, គង់នឹងខ្ពស់ប៉ុណ្ណោះ។

*សិស្ស៖ ធ្វើដូចម្តេចបំបាត់អំណាចកម្ម, នោះគឺបំបាត់កម្មផលដែលបានសម្តែងក្នុងពុទ្ធសាសនាមែនទេ?*

គ្រូ៖ ហាត់គង់ខ្លួនវាគឺរំលាយកម្ម។ ល្អបំផុតគឺលើកកម្ពស់ចិត្តគំនិតខ្លួនឯង, អាចធ្វើឱ្យសារធាតុពណ៌ខ្មៅផ្លាស់ប្តូរទៅជាអ្វីដែល

មានពណ៌ស, នោះគឺសារធាតុនៃ "គុណធម៌", បំលែង 'គុណធម៌' ក្លាយទៅជា 'គង់'។

*សិស្ស៖ ហាត់ហ្វាលូនគង់មានវិន័យអ្វីទេ?*

គ្រូ៖ ក្នុងពុទ្ធសាសនាតម្រូវរាល់វិន័យ, ពួកយើងភាគច្រើនសុទ្ធតែវិន័យ។ ប៉ុន្តែទស្សនៈមិនដូចគ្នា, ពួកយើងមិនមែនព្រះសង្ឃ, ត្រូវរស់នៅក្នុងមនុស្សសាមញ្ញ, ដូច្នេះគឺមិនដូចគ្នា។ មានរឿងខ្លះមើលវាឱ្យស្រាល, គឺបានហើយ។ ជាការពិត, ជាមួយនឹងអំណាចគង់បន្តលើកកម្ពស់, នៅពេលសម្រេចបានជាន់ថ្នាក់យ៉ាងខ្ពស់បំផុត, តម្រូវសម្រាប់ចិត្តគំនិតរបស់លោកអ្នកក៏ជាយ៉ាងខ្ពស់បំផុតផងដែរ។

## IV. បញ្ញាញាណ

*សិស្ស៖ នៅពេលលោកគ្រូសម្តែងធម៌មើលឃើញរង្វង់ពន្លឺពណ៌មាសខ្ពស់៣ម៉ែត្រពីខាងលើក្បាលរបស់លោកគ្រូ, ខាងក្រោយខ្នងមានជាច្រើនរង្វង់ពន្លឺពណ៌មាសប្រហាក់ប្រហែលក្បាលមនុស្ស។*

គ្រូ៖ ជាន់ថ្នាក់បញ្ញាញាណរបស់មនុស្សម្នាក់នេះលែងនៅទាបទៀតហើយ។

*សិស្ស៖ មើលឃើញនៅពេលសិស្សរបស់លោកគ្រូព្យាបាលជំងឺឱ្យអ្នកដទៃប្រើស្រាបាញ់ចេញនាំតាមពន្លឺពណ៌មាស។*

គ្រូ៖ ខ្ញុំនិយាយថាមនុស្សម្នាក់នេះហាត់បានល្អណាស់, មើល

ឃើញទាំងសីលគង់ដែលវាយចេញ។

*សិស្ស៖ តើកុមារបើកបញ្ញាញាណគឺមានប៉ះពាល់ដល់គាត់ឬទេ? តើបញ្ញាញាណបើករួចហើយគឺកំពុងបញ្ចេញថាមពលមែនទេ?*

គ្រូ៖ កុមារអាយុក្រោម៦ឆ្នាំងាយស្រួលបើកបញ្ញាញាណណាស់, កុមារមិនហាត់គង់, បើកបញ្ញាញាណជាក់ស្តែងគឺថាមពលបណ្តេញចេញក្រៅ, ប៉ុន្តែក្នុងផ្ទះជាក់លាក់ត្រូវមានមនុស្សហាត់គង់។ ល្អបំផុតគឺហៅគាត់រាល់ថ្ងៃមើលបានមួយដង, រក្សាមិនបិទមកវិញ, ក្នុងពេលដំណាលគ្នាមិនបណ្តេញចេញក្រៅច្រើនពេក។ កុមារល្អបំផុតហាត់គង់ដោយខ្លួនឯង។ ប្រើការច្រើនថាមពលបណ្តេញចេញច្រើន, ដែលវាមានឥទ្ធិពលគឺមិនមែនរាងកាយសាច់របស់ពួកគាត់ទេ, ប៉ុន្តែគឺជាអ្វីដែលជាមូលដ្ឋានបំផុត។ ប៉ុន្តែប្រសិនបើរក្សាបានល្អ, នឹងគ្មានឥទ្ធិពលទេ។ ដែលខ្ញុំទើបតែសម្តែងគឺអំពីកុមារ, មិនមែនមនុស្សធំ។ បញ្ញាញាណមនុស្សមួយចំនួនមិនមែនពេលណាបើកនឹងខ្លាចបញ្ចេញថាមពលនោះទេ, វាគឺបើកទូលាយ, មិនខ្លាចបញ្ចេញថាមពល, ប៉ុន្តែមើលមិនឃើញអ្វីនៃជាន់ថ្នាក់ខ្ពស់ណាស់ទេ។ ក៏មាន(មនុស្ស)ខ្លះអាចមើលឃើញជាន់ថ្នាក់ខ្ពស់, នៅពេលមើល, បរមីឬក៏គ្រូខាងលើផ្តល់ថាមពលឱ្យ, នេះគ្មានបញ្ហាទេ។

*សិស្ស៖ មើលឃើញលើរាងកាយលោកគ្រូលេចឡើងពន្លឺសន្ទៅពណ៌មាស, នៅមានទាំងស្រមោលរបស់លោកគ្រូទៀត,*

*ពព្រិចភ្នែកក៏គ្មានទៀត, តើគឺជារឿងដូចម្ដេច?*

គ្រូ៖ នេះជាក់ស្ដែងគឺជាបរមីរបស់ខ្ញុំ, ខ្ញុំកំពុងសម្ដែងធម៌, កំពូលក្បាលមានសសរគង់, នៅជាន់ថ្នាក់នេះរបស់ខ្ញុំជាក់ស្ដែងគឺជាបែបនេះ។ មួយពព្រិចភ្នែកក៏គ្មានទៀត, គឺលោកអ្នកនៅតែមិនទាន់ចេះប្រើបញ្ញាញាណ, បានប្រើភ្នែកដើម្បីមើលរួចហើយ។

*សិស្ស៖ តើសីលគង់ពិសេសអាចប្រើបានយ៉ាងដូចម្ដេច?*

គ្រូ៖ ប្រើសីលគង់ពិសេសនៅលើវិទ្យាសាស្ត្រយោធាឬក៏បច្ចេកវិទ្យាខ្ពស់ផ្សេងទៀត, ឬក៏ប្រើក្នុងចារកម្ម, ខ្ញុំគិតថានៅទីនេះមានបញ្ហា។ ចក្រវាលនេះរបស់ពួកយើងគឺមានលក្ខណៈពិសេស, ដរាបណាវាសមស្របតាមលក្ខណៈពិសេសនេះ, វាជាក់ស្ដែងស័ក្តិសិទ្ធ; មិនសមស្របតាមលក្ខណៈពិសេសនេះ, វាជាក់ស្ដែងប្រើមិនបាន។ ទោះបីហៅគាត់ធ្វើរឿងល្អ, គាត់ក៏ធ្វើមិនបានអ្វីនៅលើជាន់ថ្នាក់ខ្ពស់ផងដែរ, គ្រាន់តែដឹងឬមានអារម្មណ៍តិចតួចប៉ុណ្ណោះ។ ធ្វើបច្ចេកទេសតូចមួយចំនួនសម្រាប់ការអភិវឌ្ឍន៍ធម្មតានៃសង្គមមិនបង្កគ្រោះថ្នាក់ច្រើនទេ។ ប្រសិនបើគាត់គឺចង់ផ្លាស់ប្ដូរអ្វីមួយ, ចង់ធ្វើរឿងដ៏ធំណាមួយ, ចាំបាច់ឬក៏មិនចាំបាច់គាត់ធ្វើ, គាត់សម្រេចមិនបានទេ, ដោយសារតែការអភិវឌ្ឍន៍នៃសង្គមគឺមិនយោងទៅតាមឆន្ទៈរបស់មនុស្សហើយបង្វែរបានទេ។ គាត់ចង់សម្រេចបានកម្រិតណា, រឿងនេះនរណាក៏ធ្វើម្ចាស់មិនបានដែរ។

*សិស្ស៖ សតិរបស់មនុស្សគឺចូលចេញដូចម្ដេច?*

គ្រូ៖ សតិដែលពួកយើងសម្ដែង, ជាធម្មតាគឺចេញទៅពីលើ

កំពូលក្បាល។ ជាការពិត, មិនកំណត់ត្រឹមនេះទេ, វាអាចចេញទៅពីកន្លែងណាមួយ។ មិនដូចជាមានគង់ហ្វាមួយចំនួនសង្កត់ធ្ងន់ថាជាក់លាក់ចេញទៅពីលើកំពូលក្បាល, កន្លែងណាមួយសុទ្ធតែអាចឃ្លាតចេញពីរាងកាយបាន។ ចូលទៅក៏ដូចគ្នាផងដែរ។

*សិស្ស៖ តំបន់បញ្ញាញាណមានពន្លឺក្រហម, ចំកណ្ដាលគឺជាប្រហោងខ្មៅ, វិកយ៉ាងឆាប់រហ័សមួយជាន់ៗ, តើកំពុងបើកបញ្ញាញាណមែនទេ? ពេលខ្លះនៅមានពន្លឺផ្កាយ, ផ្លេកបន្ទោរ?*

គ្រូ៖ នៅពេលដែលលោកអ្នកបើកដល់មានពន្លឺផ្កាយជាក់ស្ដែងបើកជិតរួចរាល់ហើយ, មានផ្លេកបន្ទោរតាមពិតទៅជិតបើកធ្លាយស្រឡះហើយ។

*សិស្ស៖ មើលឃើញលើក្បាលលើខ្លួនលោកគ្រូមានរង្វង់ពន្លឺពណ៌ក្រហម, ពណ៌បៃតង, ប៉ុន្តែបិទភ្នែកវិញអ្វីក៏មើលមិនឃើញទៀត, តើបានប្រើពន្លឺដែលនៅសល់ដើម្បីមើលមែនទេ?*

គ្រូ៖ គឺមិនមែនប្រើពន្លឺដែលនៅសល់មើលទេ, លោកអ្នកគ្រាន់តែមិនដឹងមើលខណៈពេលបិទភ្នែក, គឺមើលដោយបើកភ្នែក។ ជាធម្មតាមនុស្សដែលបើកបញ្ញាញាណរួចហើយនឹងមិនដឹងប្រើ, ពេលខ្លះខណៈពេលបើកភ្នែកដោយអចេតនាអាចមើលឃើញបាន, ប៉ុន្តែប្រសិនបើលោកអ្នកចង់មើលឱ្យបានលម្អិត, តាមពិតទៅគឺប្រើភ្នែករួចហើយ, ម្ដងទៀតមើលមិនឃើញ, នៅពេលដែលលោកអ្នកមិនចាប់អារម្មណ៍ម្ដងទៀតមើលឃើញ។

*សិស្ស៖ កូនស្រីរបស់កូនបានឃើញរង្វង់មួយចំនួននៅលើ*

*អាកាស, នាងនិយាយមិនច្បាស់, ស្មើឱ្យនាងមើលនិមិត្តរូបហ្វាលូន , នាងប្រាប់ថាជាក់ស្ដែងនេះគឺជាវា, តើនាងពិតជាបើកបញ្ញាញាណរួចហើយមែនទេ?*

គ្រូ៖ និមិត្តរូបហ្វាលូនរបស់ពួកយើង, កុមារអាយុពី៦ឆ្នាំចុះក្រោមមើលឃើញពេលណាបញ្ញាញាណនឹងបើក, ប៉ុន្តែលោកអ្នកកុំទៅធ្វើ, កុមារគឺអាចមើលឃើញបាន។

*សិស្ស៖ បញ្ញាញាណបើករួចហើយមិនដឹងប្រើ, សូមសួរឱ្យគ្រូឆ្លើយ?*

គ្រូ៖ នៅពេលដែលបញ្ញាញាណបើកស្រឡះអស់ហើយ, មិនដឹងប្រើក៏នឹងដឹងប្រើ; នៅពេលភ្លឺខ្លាំង, ងាយស្រួលប្រើណាស់, មិនដឹងប្រើក៏នឹងដឹងប្រើ។ ប្រើបញ្ញាញាណមើលអ្វីមួយគឺនៅក្នុងស្ថានភាពដោយអចេតនាហើយមើលឃើញ, នៅពេលចង់មើលលម្អិត, ដោយអចេតនាប៉ះដល់ភ្នែករួចហើយ, ដើរឆ្លងសរសៃប្រសាទនៃភ្នែករួចហើយ, ដូច្នេះជាក់ស្ដែងមើលមិនឃើញទៀត។

*សិស្ស៖ តើបន្ទាប់ពីបើកបញ្ញាញាណដែលមើលឃើញគឺជាអ្វីនៃអវកាសចក្រវាលទាំងមូលមែនទេ?*

គ្រូ៖ ពួកយើងបើកបញ្ញាញាណគឺបែងចែកជាន់ថ្នាក់, ក៏ដូចជានិយាយថាលោកអ្នកមើលឃើញសេចក្ដីពិតបានប៉ុណ្ណា, គឺដោយបែងចែកជាន់ថ្នាក់កំណត់។ បើកបញ្ញាញាណមិនមែនមើលឃើញទាំងអស់នៅក្នុងចក្រវាល, ប៉ុន្តែគឺនៅក្នុងការហាត់គង់ពេលអនាគតបន្តិចម្ដងៗលើកកម្ពស់ជាន់ថ្នាក់របស់លោកអ្នក, ចុង

ក្រោយសម្រេចបានត្រាស់ដឹង, លោកអ្នកទើបអាចមើលឃើញជាន់ថ្នាក់ច្រើនជាង, នោះក៏មិនធានាថាដែលលោកអ្នកមើលឃើញគឺជាសេចក្ដីពិតនៃចក្រវាលទាំងមូល។ ដោយសារតែសក្យមុនីនាគ្រានោះនៅពេលគាត់សម្ដែងធម៌នាបណ្ដាឆ្នាំនៅមានជីវិត, ក៏បានបន្តលើកកម្ពស់, រាល់ពេលដែលលើកកម្ពស់មួយជាន់ថ្នាក់, គាត់បានរកឃើញថាអ្វីដែលបានសម្ដែងពីមុនម្ដងទៀតមិនស្ថិតស្ថេរ, ឡើងខ្ពស់ទៀតហើយមើលចុះមើលឃើញមិនត្រូវទៀត, ដូច្នេះគាត់ចុងក្រោយសម្ដែងថា "ធម៌មិនកំណត់ធម៌", មួយជាន់ថ្នាក់មួយគោលសីលធម៌។ គាត់ក៏មិនអាចមើលឃើញទាំងស្រុងសច្ចៈធម៌នៃចក្រវាលទាំងមូល។ នៅមនុស្សធម្មតាពួកយើងមើលមក, លោកីយ៍បួសហាត់សម្រេចបានជាន់ថ្នាក់យូឡាយនឹងគិតថាជារឿងមិនគួរឱ្យជឿហើយ, ដោយសារតែគាត់គ្រាន់តែដឹងអំពីជាន់ថ្នាក់យូឡាយមួយនេះ។ អ្វីដែលខ្ពស់ជាងទៀតគាត់ក៏មិនដឹង, ជាក់ស្ដែងទទួលយកមិនបាន, យូឡាយគឺជាជាន់ថ្នាក់តូចៗមួយនៅក្នុងធម៌ព្រះពុទ្ធ, មហាធម៌គ្មានដែន, ជាក់ស្ដែងមានអត្ថន័យដូច្នេះ។

*សិស្ស៖ អ្វីដែលពួកកូនបានមើលឃើញលើរាងកាយរបស់ទ្រង់តើពិតជាស្ថិតនៅមែនទេ?*

គ្រូ៖ ជាការពិតគឺពិតជាស្ថិតនៅ, អវកាសទាំងអស់សុទ្ធតែជាសារធាតុបង្កើតឡើង, គ្រាន់តែថារចនាសម្ព័ន្ធខុសគ្នាជាមួយនឹងពួកយើង។

*សិស្ស៖ អារម្មណ៍ព្យាករណ៍របស់កូនតែងតែស្របនឹងរឿងរ៉ាវ*

*ដែលបានកើតឡើង?*

គ្រូ៖ នេះជាក់ស្តែងគឺជាសីលគង់ព្យាករណ៍ដែលពួកយើងនិយាយ, តាមពិតទៅជាក់ស្តែងគឺជាដំណាក់កាលជាន់ថ្នាក់ទាបនៃ(សីលគង់)ដឹងពីជោគវាសនា។ គង់ដែលពួកយើងហាត់សុទ្ធតែនៅក្នុងអវកាសផ្សេង, នៅក្នុងអវកាសនោះគ្មានទស្សនាទានវេលា-អវកាសទេ, មិនថាឃ្លាតឆ្ងាយយ៉ាងណាគឺសុទ្ធតែដូចគ្នា។

*សិស្ស៖ ក្នុងអំឡុងពេលហាត់គង់លេចឡើងមនុស្សមានពណ៌, ផ្ទៃមេឃមានពណ៌, រូបភាព?*

គ្រូ៖ បញ្ញាញាណរបស់លោកអ្នកបើករួចហើយ, អ្វីដែលលោកអ្នកមើលឃើញគឺជាអវកាសផ្សេង។ អវកាសផ្សេងគឺបែងចែកជាន់ថ្នាក់, ដែលលោកអ្នកមើលឃើញអាចគឺជាមួយជាន់ថ្នាក់ក្នុងនោះ, វាជាក់ស្តែងគឺស្អាតបែបនេះឯង។

*សិស្ស៖ ក្នុងអំឡុងពេលពេលហាត់គង់ស្រាប់តែសម្លេងមួយរំពង, មានអារម្មណ៍រាងកាយត្រូវបានប្រញាប់បើកចេញ, មានរឿងជាច្រើនបានយល់ភ្លាមៗ?*

គ្រូ៖ មនុស្សមួយចំនួនហាត់គង់ងាយស្រួលលេចឡើងប្រភេទកាលៈទេសៈនេះ, ផ្ទុះបើកមួយផ្នែកនៃរាងកាយ, ត្រាស់ដឹងទិដ្ឋភាពណាមួយ, គឺជារបស់កាលៈទេសៈត្រាស់ដឹងបន្តិចម្តងៗ។ នៅពេលដែលលោកអ្នកបួសហាត់ដើរបញ្ចប់មួយជាន់ថ្នាក់, នឹងផ្ទុះបើកមួយផ្នែក, នេះសុទ្ធតែជាការធម្មតា។

*សិស្ស៖ ពេលខ្លះមានអារម្មណ៍កម្រើកមិនបាន, តើមូលហេតុអ្វី?*

គ្រូ៖ ហាត់គង់ដំណាក់កាលដំបូង, លោកអ្នកអាចនឹងមានអារម្មណ៍ប្រភេទនេះ, ភ្លាមៗដៃឬក៏ផ្នែកណាមួយកម្រើកមិនបាន, ហេតុអ្វី? ដោយសារតែលោកអ្នកមានប្រភេទសីលគង់មួយរួចហើយ, ហៅថាគង់ឈប់ស្ងៀម។ នេះគឺជាមួយប្រភេទសីលគង់ដែលរាងកាយលោកអ្នកស្ថិតនៅ។ សីលគង់នេះសមត្ថភាពធំណាស់, នៅពេលដែលមនុស្សម្នាក់ប្រព្រឹត្តរឿងអាក្រក់ហើយកំពុងរត់, លោកអ្នកនិយាយ "ឈប់ស្ងៀម", ពេលនោះគាត់ជាក់ស្ដែងកម្រើកមិនបានទៀត។

*សិស្ស៖ ពេលណាអាចពិនិត្យជំងឺ, ពីមុនកូនពិនិត្យជំងឺឱ្យគេមានប្រសិទ្ធភាពខ្លះៗ, បន្ទាប់ពីសិក្សាហ្វាលូនគង់, មានមនុស្សរកកូនពិនិត្យជំងឺ, តើកូនអាចពិនិត្យឱ្យគេបានឬទេ?*

គ្រូ៖ ខ្ញុំឃើញមនុស្សនៅលើថ្នាក់នេះ, មិនថាលោកអ្នកពីមុនធ្លាប់បានរៀនគង់ហ្វានៃវង្សណាមួយ, ហាត់រយៈពេលយូរប៉ុណ្ណា, អាចសម្រេចបានកម្រិតពិនិត្យជំងឺឬអត់, នៅជាន់ថ្នាក់ទាប, មិនចង់ហៅអ្នករាល់គ្នាពិនិត្យជំងឺ, ដោយសារតែលោកអ្នកខ្លួនឯងក៏មិនដឹងថាខ្លួនឯងគឺជាស្ថានភាពអ្វី។ លោកអ្នកគឺធ្លាប់ពិនិត្យជំងឺឱ្យមនុស្សដទៃរួចហើយ, អាចថាគឺដោយសារតែលោកអ្នកគ្រានោះចិត្តសុចរិត, មានប្រសិទ្ធភាព, ក៏អាចថាគឺលោកគ្រូដែលឆ្លងកាត់ណាមួយជួយលោកអ្នកបន្តិច, ដោយសារតែលោកអ្នកកំពុងធ្វើ

រឿងល្អតើ។ បើទោះបីជាថាមពលបន្តិចនោះដែលលោកអ្នកហាត់មានប្រសិទ្ធភាពក៏ដោយ, ក៏ការពារមិនបានលោកអ្នកខ្លួនឯងផងដែរ។ នៅពេលលោកអ្នកពិនិត្យជំងឺ, ជាមួយនឹងអ្នកជំងឺនៅក្នុងវាលតែមួយ, យូរៗទៅ, ឈើខ្មៅនៅលើរាងកាយ, លោកអ្នកឈឺប្រៀបនឹងអ្នកជំងឺនៅធ្ងន់ធ្ងរជាង។ សួរអ្នកជំងឺ៖ ‵បានជាសះស្បើយឬនៅ?′ គាត់និយាយថា ‶ស្រួលជាងបន្តិចហើយ″, នោះហៅថាពិនិត្យជំងឺរបៀបអ្វី? គ្រូឈីគង់ខ្លះសម្តែងថា៖ ‵ថ្ងៃស្អែកមកម្តងទៀត, ខានស្អែកមកម្តងទៀត, ខ្ញុំពិនិត្យឱ្យលោកអ្នកមួយវគ្គព្យាបាល′។ គាត់ក៏សម្តែង ‶វគ្គព្យាបាល″, តើនេះមិនមែនជាការបញ្ឆោតមនុស្សទេឬ? ចាំលោកអ្នកមកដល់លើជាន់ថ្នាក់ខ្ពស់រួចហើយពិនិត្យល្អប៉ុណ្ណា? ពិនិត្យម្នាក់ជាសះស្បើយម្នាក់, ឆាប់រហ័សណាស់! ប្រសិនបើលោកអ្នកបញ្ចេញគង់រួចហើយ, ថែមទៀតក៏មិនទាប, នៅពេលពិតជាចាំបាច់ពិនិត្យជំងឺ, ខ្ញុំនឹងបើកដៃអោយលោកអ្នក, ខ្ញុំអាចយកសីលគង់ពិនិត្យជំងឺរបស់លោកអ្នកយកចេញមកឱ្យលោកអ្នក។ ប៉ុន្តែលោកអ្នកបួសឡើងលើជាន់ថ្នាក់ខ្ពស់, ខ្ញុំគិតថាល្អបំផុតនៅតែកុំធ្វើរឿងប្រភេទនេះ។ ដើម្បីផ្សព្វផ្សាយមហាធម៌ និងចូលរួមសកម្មភាពសង្គម, សិស្សរបស់ខ្ញុំមានមួយផ្នែកកំពុងពិនិត្យជំងឺ, ដោយសារតែគាត់នៅក្បែរខ្លួនខ្ញុំ, ខ្ញុំនាំគាត់តាមជាមួយ, គាត់មានការធានា, ដូច្នេះគ្មានបញ្ហាអ្វី។

*សិស្ស៖ បញ្ចេញសីលគង់រួចហើយអាចនិយាយជាមួយនឹងមនុស្សដទៃបានឬទេ?*

គ្រូ៖ បញ្ចេញសីលគង់រួចហើយនិយាយជាមួយនឹងមនុស្ស ដែលហាត់ហ្វាលូនគង់, ចូរបន្ទាបខ្លួនបន្តិច, គ្មានបញ្ហាអ្វីទេ។ ហៅអ្នករាល់គ្នាប្រមូលផ្តុំមកហាត់គង់ជាក់ស្តែងគឺដើម្បីអ្នករាល់គ្នាអាចផ្លោះប្តូរ។ ជាការពិតណាស់, នៅខាងក្រៅជួបប្រទះមនុស្សដែលមានសីលគង់អាចនិយាយជាមួយនឹងគាត់, មិនសំខាន់ទេ, គ្រាន់តែមិនបានអំនួត, ប្រសិនបើចង់អំនួតបន្តិចថាខ្ញុំមានសមត្ថភាពជាក់ស្តែងមិនបានទេ, នៅពេលអំនួតយូរទៅ, របស់នោះនឹងគ្មានទៀត។ ប្រសិនបើចង់សម្តែងអំពីបាតុភូតឈីគង់, ពិភាក្សាបន្តិច, គ្មានបន្តិចគំនិតច្របូកច្របល់នៃឯកជន, ខ្ញុំនិយាយថាគឺគ្មានបញ្ហាអ្វីទេ។

*សិស្ស៖ ពុទ្ធវង្សសម្តែង "ទទេ" តាវវង្សសម្តែង "គ្មាន", តើពួកយើងសម្តែងអ្វី?*

គ្រូ៖ "ទទេ" នៃពុទ្ធវង្ស, "គ្មាន" នៃតាវវង្សគឺជាអ្វីដែលពិសេសមានតែក្នុងគង់របស់វា, ជាការពិតពួកយើងនៅទីនេះក៏ចាំបាច់ឈានដល់លំដាប់ប្រភេទនេះ។ ពួកយើងសម្តែងចេតនាហាត់គង់អចេតនាទទួលបានគង់។ បួសចិត្តគំនិត, កម្ចាត់ចិត្តប្រកាន់, ដូច្នេះនៅតែជា 'ទទេ' 'គ្មាន', ប៉ុន្តែពួកយើងមិនពិសេសសង្កត់ធ្ងន់លើវាទេ។ ដោយសារតែលោកអ្នករស់នៅក្នុងពិភពសារធាតុ, លោកអ្នកត្រូវការធ្វើការ, លោកអ្នកត្រូវការការងារ, ជៀសមិនរួចត្រូវធ្វើរាល់រឿង។ ធ្វើរាល់រឿងជាក់ស្តែងជៀសមិនរួចនាំមកនូវបញ្ហារឿងមួយល្អ, អាក្រក់, តើធ្វើដូចម្តេច? ដែលពួកយើងបួសគឺជាចិត្តគំនិត, នេះ

គឺជាអ្វីដែលលេចធ្លោបំផុតក្នុងគង់នេះរបស់ពួកយើង, ដរាបណាចិត្តលោកអ្នកសុចរិត, រឿងដែលធ្វើចេញមកសមស្របនឹងតម្រូវរបស់ពួកយើង, ចិត្តគំនិតជាក់ស្តែងគ្មានបញ្ហាអ្វីទេ។

*សិស្ស៖ ពួកកូនពេលធម្មតាធ្វើដូចម្តេចទើបអាចដឹងបានការកើនឡើងរបស់សីលគង់?*

គ្រូ៖ នៅដំណាក់កាលដំបូងលោកអ្នកហាត់គង់, ប្រសិនបើបញ្ចេញសីលគង់រួចហើយនឹងដឹងចេញមកបាន។ ប្រសិនបើមិនបញ្ចេញសីលគង់ប៉ុន្តែរាងកាយឆាប់រសើប, អាចដឹងចេញមកបាន។ ប្រសិនបើទាំងពីរយ៉ាងសុទ្ធតែមិនត្រូវ, ជាក់ស្តែងគ្មានផ្លូវទទួលដឹងបានទេ, មានតែបិទភ្នែកដើម្បីហាត់។ សិក្ខាកាមពួកយើងមាន៦០ភាគរយដល់៧០ភាគរយគឺបើកបញ្ញាញាណរួចហើយ, អាចមើលឃើញបាន, ខ្ញុំដឹងទាំងអស់។ លោកអ្នកមិនស្រដីគ្រាន់តែចំហភ្នែកសម្លឹងមើល, ហេតុអ្វីហៅអ្នករាល់គ្នាហាត់គង់ជាមួយគ្នា? គឺចង់លោកអ្នកផ្ទៃក្នុងក្រុមតូចអាចទំនាក់ទំនងផ្តោះប្តូរទៅវិញទៅមក។ ប៉ុន្តែមានការទទួលខុសត្រូវចំពោះគង់ហ្វា, ដល់ខាងក្រៅមិនបាននិយាយមិនសមហេតុមិនសមផល, ទំនាក់ទំនង, លើកកម្ពស់ទៅវិញទៅមករវាងផ្ទៃក្នុងជាមួយគ្នាបានហើយ។

*សិស្ស៖ តើបរមីមានរាងដូចអ្វី? តើខ្លួនកូនមានបរមីឬទេ?*

គ្រូ៖ បរមីមានលក្ខណៈដូចគ្នានឹងមនុស្សរូបនោះឯង។ លោកអ្នកបច្ចុប្បន្នគ្មានបរមីទេ, ចាំពេលហាត់ដល់កម្រិតជាក់លាក់, ដើរចេញផុតពីលោកកីយ៍ធម៌, បួសហាត់ចូលទៅក្នុងកម្រិតយ៉ាងខ្ពស់

បំផុត, ទើបអាចបញ្ចេញបរមី។

*សិស្ស៖ បន្ទាប់ពីថ្នាក់បង្រៀនបញ្ចប់, បរមីរបស់លោកគ្រូអាចនៅតាមយូរដល់ណា?*

គ្រូ៖ សិក្ខាកាមម្នាក់ភ្លាមៗនោះហាត់អ្វីដែលនៅលើជាន់ថ្នាក់ខ្ពស់, សម្រាប់គាត់ដើម្បីនិយាយជាក់ស្តែងគឺជាការផ្លាស់ប្តូរមួយដ៏ធំ, មិនមែនសំដៅទៅលើការផ្លាស់ប្តូរគំនិតទេ, ប៉ុន្តែគឺសំដៅទៅលើការផ្លាស់ប្តូរនៃឯកជនទាំងមូលរបស់លោកអ្នក។ ដោយសារតែមនុស្សសាមញ្ញម្នាក់ភ្លាមៗទទួលបានអ្វីដែលមនុស្សសាមញ្ញម្នាក់ដូចគាត់មិនគួរទទួលបាន, នោះគឺជាគ្រោះថ្នាក់, ជីវិតជាក់ស្តែងនឹងត្រូវទទួលនូវគំរាមកំហែង, បរមីរបស់ខ្ញុំចាំបាច់ត្រូវតែការពារគាត់។ ប្រសិនបើខ្ញុំធ្វើមិនបានចំណុចមួយនេះ, ហើយនៅទីនេះបង្រៀនធម៌, ជាក់ស្តែងគឺបង្កគ្រោះថ្នាក់ដល់មនុស្ស។ ជាច្រើនគ្រូឈីគង់មិនហ៊ានធ្វើ, មិនហ៊ានបង្រៀន, ជាក់ស្តែងគឺដោយសារតែគាត់ទ្រទ្រង់មិនបានការទទួលខុសត្រូវនេះ។ បរមីរបស់ខ្ញុំនឹងជានិច្ចការពារលោកអ្នក, រហូតដល់លោកអ្នកបួសសម្រេច។ ពាក់កណ្តាលផ្លូវលោកអ្នកមិនបួសទៀត, បរមីខ្លួនឯងនឹងចេញទៅ។

*សិស្ស៖ លោកគ្រូនិយាយថា៖ មនុស្សសាមញ្ញបួសរៀនមិនមែនពឹងផ្អែកលើការហាត់គង់, ប៉ុន្តែគឺពឹងផ្អែកលើចិត្តគំនិត។ តើអាចនិយាយថា, ដរាបណាចិត្តគំនិតខ្ពស់មិនចាំបាច់ហាត់គង់ក៏អាចបួសសម្រេចមគ្គផលខ្ពស់បំផុត?*

គ្រូ៖ យោងទៅតាមគោលសីលធម៌គឺបែបនេះ, ដរាបណា

លោកអ្នកបួសចិត្តគំនិត, គុណធម៌ជាក់ស្ដែងអាចបំលែងក្លាយជាគង់។ ប៉ុន្តែ, លោកអ្នកត្រូវតែចាត់ទុកលោកអ្នកធ្វើជាមនុស្សហាត់គង់។ លោកអ្នកមិនធ្វើជាមនុស្សហាត់គង់, គ្រាន់តែអាចសន្សំគុណធម៌ៗ, លោកអ្នកអាចសន្សំគុណធម៌បានច្រើនណាស់, គ្រាន់តែធ្វើជាមនុស្សល្អដើម្បីសន្សំគុណធម៌, ទោះបីជាចាត់ទុកខ្លួនឯងធ្វើជាមនុស្សហាត់គង់ក៏មិនបាន, លោកអ្នកនៅតែមិនទាន់ទទួលបានធម៌ដែលនៅលើជាន់ថ្នាក់ខ្ពស់។ អ្នករាល់គ្នាដឹងថា, ខ្ញុំសម្ដែងចេញមកច្រើនប្រការណាស់, គ្មានលោកគ្រូការពារលោកអ្នក, លោកអ្នកគឺពិបាកបួសឡើងទៅលើណាស់, លោកអ្នកសូម្បីតែមួយថ្ងៃក៏មិនអាចហាត់គង់នៅលើជាន់ថ្នាក់ខ្ពស់បានផងដែរ។ ដូច្នេះចង់បួសសម្រេចមគ្គផលខ្ពស់បំផុតមិនមែនងាយស្រួលនោះទេ។ ប៉ុន្តែ, បន្ទាប់ពីចិត្តគំនិតបានលើកកម្ពស់, ជ្រួតជ្រាបជាមួយនឹងលក្ខណៈពិសេសនៃចក្រវាល។

*សិស្ស៖ គោលសីលធម៌នៃការព្យាបាលពីចម្ងាយគឺជាអ្វី?*

គ្រូ៖ គោលសីលធម៌សាមញ្ញណាស់, ចក្រវាលអាចធំអាចតូច, សីលគង់បញ្ចេញទៅក៏អាចធំអាចតូចផងដែរ។ ខ្ញុំនៅទីតាំងដើមគ្មានកម្រើក, ប៉ុន្តែសីលគង់បញ្ចេញទៅអាចប៉ះដល់អ្នកជំងឺដែលឆ្ងាយដូចនៅប្រទេសអាមេរិក។ អាចយកគង់វាយឆ្លងកាត់ទៅ, ក៏អាចបញ្ជាវិញ្ញាណដើមរបស់គាត់មកទីនេះ។ នេះជាក់ស្ដែងគឺជាគោលសីលធម៌នៃការព្យាបាលពីចម្ងាយ។

*សិស្ស៖ តើអាចដឹងថានឹងបញ្ចេញបានប៉ុន្មានប្រភេទសីលគង់?*

គ្រូ៖ សីលគង់មានច្រើនជាងមួយម៉ឺនប្រភេទ, ដឹងបានជាក់លាក់ប៉ុន្មានសុទ្ធតែមិនសំខាន់, ដឹងបានគោលសីលធម៌នេះ, ធម៌នេះគឺបានហើយ, ដែលនៅសល់ខ្លួនឯងទៅហាត់។ ក៏មិនចាំបាច់ដឹងអ្វីច្រើននោះទេ, សម្រាប់លោកអ្នកក៏គ្មានកន្លែងល្អ។ គ្រូស្វែងរកកូនសិស្ស, ទទួលកូនសិស្ស, កូនសិស្សនោះអ្វីក៏មិនដឹងទាំងអស់, ក៏មិនប្រាប់គាត់, ពឹងផ្អែកទាំងស្រុងលើខ្លួនឯងដើម្បីភ្ញាក់ដឹង។

*សិស្ស៖ កូននៅលើថ្នាក់បិទភ្នែកអាចមើលឃើញទ្រង់នៅខាងលើសម្ដែងធម៌, រាងកាយផ្នែកខាងលើគឺជាពណ៌ខ្មៅ, តុក៏ជាពណ៌ខ្មៅ, ក្រណាត់ខាងក្រោយគឺជាពណ៌ផ្កាឈូក, ពេលខ្លះជុំវិញទ្រង់គឺជាមួយផ្ទាំងពន្លឺពណ៌បៃតង, នេះគឺជារឿងដូចម្ដេច?*

គ្រូ៖ នេះគឺជាបញ្ហាជាន់ថ្នាក់របស់លោកអ្នក។ ដោយសារតែនៅពេលបញ្ញាញាណទើបតែបើកនឹងមើលពណ៌សទៅជាពណ៌ខ្មៅ, មើលពណ៌ខ្មៅទៅជាពណ៌ស, បន្ទាប់ពីលើកកម្ពស់ជាន់ថ្នាក់បន្តិច, មើលឃើញទាំងអស់សុទ្ធតែជាពណ៌ស, បន្ទាប់ពីលើកកម្ពស់ជាន់ថ្នាក់ថែមទៀត, ពណ៌នឹងបំបែកចេញបាន។

## V. ទុក្ខវេទនា

*សិស្ស៖ តើទុក្ខវេទនាគឺជាការសាកល្បងដែលលោកគ្រូរៀបចំសម្រាប់សិស្សមែនទេ?*

គ្រូ៖ អាចថាគឺជាបែបនេះឯង។ នេះគឺដើម្បីលើកកម្ពស់ចិត្តគំនិតរបស់អ្នករាល់គ្នាហើយរៀបចំ។ ឧបមានិយាយថា, ចិត្តគំនិតលោកអ្នកមិនទាន់ឈានដល់ខ្ពស់ដូច្នោះប៉ុន្តែទុកឱ្យលោកអ្នកបួសឡើងទៅលើតើអាចបានដែរទេ? ជាក់ស្តែងប្រៀបដូចសិស្សសាលាបឋមម្នាក់, តើជូនគាត់ទៅក្នុងមហាវិទ្យាល័យបានឬទេ? ខ្ញុំគិតថាមិនបានទេ! ចិត្តគំនិតរបស់លោកអ្នកមិនទាន់សម្រេចបានការលើកកម្ពស់ពិតប្រាកដ, នៅពេលដែលអ្វីៗគ្រប់យ៉ាងមិនអាចមើលស្រាល, មិនអាចបោះបង់បាន, ឧបមាទុកឱ្យលោកអ្នកបួសឡើងទៅលើ, លោកអ្នកអាចព្រោះតែរឿងតូចមួយហើយធ្វើឈ្លោះអឺងកងជាមួយនឹងបណ្តាអង្គត្រាស់ដឹង, មិនបានទេ! ហេតុអ្វីបានជាមើលចិត្តគំនិតសំខាន់ដូច្នេះ, ជាក់ស្តែងគឺជាគោលសីលធម៌នេះ។

*សិស្ស៖ ទុក្ខវេទនារបស់មនុស្សហាត់គង់និងមនុស្សសាមញ្ញមានអ្វីខុសគ្នា?*

គ្រូ៖ មនុស្សហាត់គង់ពួកយើងនិងមនុស្សសាមញ្ញគ្មានអ្វីខុសគ្នាទេ។ ទុក្ខវេទនារបស់លោកអ្នកគឺតាមផ្លូវរបស់មនុស្សហាត់គង់រៀបចំឱ្យលោកអ្នក, មនុស្សសាមញ្ញគឺកំពុងសងកម្មរបស់មនុស្សសាមញ្ញ, សុទ្ធតែមានទុក្ខវេទនា, មិនមែននិយាយថាលោកអ្នកហាត់គង់នឹងមាន, មនុស្សសាមញ្ញនឹងគ្មាន, សុទ្ធតែនឹងមានដូចគ្នា។ គ្រាន់តែទុក្ខវេទនានេះរបស់លោកអ្នកគឺដើម្បីលើកកម្ពស់ចិត្តគំនិតរបស់លោកអ្នកហើយកំណត់; ទុក្ខវេទនានោះរបស់គាត់គឺដើម្បីសងជ្រះកម្មរបស់គាត់ហើយកំណត់។ តាមពិតទុក្ខវេទនាគឺ

ជាអំណាចកម្មរបស់ខ្លួនឯង, ខ្ញុំបានឆ្លៀតប្រើបន្តិចដើម្បីលើកកម្ពស់ចិត្តគំនិតរបស់សិស្ស។

*សិស្ស៖ តើទុក្ខវេទនាគឺដូចជាលំបាក៨១ដងនោះនៃ(រឿង)ទទួលគម្ពីរមេឃខាងលិចដែរឬទេ?*

គ្រូ៖ មានប្រហាក់ប្រហែលបន្តិច។ មួយជីវិតរបស់មនុស្សហាត់គង់បានរៀបចំស្រេចរួចហើយ, នឹងមិនច្រើន, ក៏នឹងមិនតិច។ ប៉ុន្តែមិនជាក់លាក់គឺជា៨១គ្រោះ(លំបាក)។ នេះត្រូវសង្កេតមើលនិស្ស័យរបស់លោកអ្នកអាចប្ដូសបានខ្ពស់ប៉ុណ្ណា, គឺពឹងផ្អែកលើកម្រិតដែលលោកអ្នកអាចឈានដល់ហើយរៀបចំ។ អ្វីទាំងនោះដែលមនុស្សសាមញ្ញមានប៉ុន្តែមនុស្សហាត់គង់គួរកម្ចាត់, សុទ្ធតែត្រូវឆ្លងកាត់ក្នុងមួយដង, ពិតហើយគឺពិបាកណាស់។ អ្វីដែលលោកអ្នកបោះបង់មិនបានសុទ្ធតែត្រូវគិតរកវិធីទុកឱ្យលោកអ្នកបោះបង់បាន, តាមរយៈការហ្វឹកហាត់ដើម្បីលើកកម្ពស់ចិត្តគំនិតរបស់លោកអ្នក។

*សិស្ស៖ នៅពេលហាត់គង់មានមនុស្សបំផ្លាញតើធ្វើដូចម្ដេច?*

គ្រូ៖ ហាត់ហ្វាលូនគង់មិនខ្លាចមនុស្សដទៃបំផ្លាញ។ នៅដំណាក់កាលដំបូង, មានបរមីរបស់ខ្ញុំការពារលោកអ្នក, ប៉ុន្តែលោកអ្នកមិនមែនដាច់ខាតសុទ្ធតែមិនជួបរឿងអ្វីទាំងអស់។ ពេញមួយថ្ងៃអង្គុយនៅលើសាឡុង, ផឹកទឹកតែនឹងបង្កើនគង់, មិនមែនបែបនេះទេ! ពេលខ្លះលោកអ្នកជួបប្រទះទុក្ខវេទនា, ស្រែកហៅឈ្មោះរបស់ខ្ញុំ, មើលឃើញខ្ញុំនៅចំពោះមុខលោកអ្នក, ប្រហែលជាមិនជួយ

លោកអ្នក, នោះគឺដោយសារតែមួយទ្វារដែលលោកអ្នកគួរតែឆ្លងកាត់។ ប៉ុន្តែនៅពេលលោកអ្នកពិតជាជួបប្រទះគ្រោះថ្នាក់គឺនឹងគ្រប់គ្រងលោកអ្នក។ ប៉ុន្តែ, ជាធម្មតាគ្រោះថ្នាក់ពិតប្រាកដប្រភេទនេះក៏នឹងមិនស្ថិតនៅ, ដោយសារតែផ្លូវដើរនោះរបស់លោកអ្នកបានកែប្រែរួចហើយ, មិនអនុញ្ញាតអ្វីដែលដោយចេតនាខាងក្រៅដោតចូលបាន។

*សិស្ស៖ តើដោះស្រាយទុក្ខវេទនាដូចម្ដេច?*

គ្រូ៖ ខ្ញុំបានសង្កត់ធ្ងន់ម្ដងហើយម្ដងទៀត, រក្សាជាប់ចិត្តគំនិតរបស់លោកអ្នក! រឿងដែលធ្វើចេញលោកអ្នកគិតថាមិនធ្វើអាក្រក់ជាក់ស្ដែងល្អណាស់។ ពិសេសគឺដោយសារតែរឿងប្រភេទអ្វីមួយនៅពេលដែលមនុស្សដទៃរំលោភលើផលប្រយោជន៍របស់លោកអ្នក, លោកអ្នកក៏ដូចគ្នានឹងមនុស្សសាមញ្ញប្រយុទ្ធជាមួយនឹងគាត់, នោះលោកអ្នកក៏ជាក់ស្ដែងគឺជាមនុស្សសាមញ្ញផងដែរ។ ដោយសារតែលោកអ្នកគឺជាមនុស្សហាត់គង់, ជាក់ស្ដែងមិនអាចទៅដោះស្រាយបែបនោះ។ លោកអ្នកជួបប្រទះរឿងរ៉ាវដែលជ្រៀតជ្រែកចិត្តគំនិតរបស់លោកអ្នក, គឺសុទ្ធតែកំពុងលើកកម្ពស់ចិត្តគំនិតរបស់លោកអ្នក, ជាក់ស្ដែងសង្កេតមើលលោកអ្នកដោះស្រាយដូចម្ដេច, មើលលោកអ្នកអាចឬក៏មិនអាចរក្សាជាប់, មើលថាតើលោកអ្នកនៅក្នុងរឿងនេះអាចឬក៏មិនអាចលើកកម្ពស់ចិត្តគំនិតរបស់លោកអ្នក។

## VI. អវកាសនិងមនុស្សជាតិ

*សិស្ស៖ តើចក្រវាលមានប៉ុន្មានជាន់ថ្នាក់អវកាស?*

គ្រូ៖ តាមដែលខ្ញុំដឹង, ក្នុងចក្រវាលមានរាប់មិនអស់ជាន់ថ្នាក់អវកាស, សម្រាប់ការស្ថិតនៅនៃជាន់ថ្នាក់អវកាសបន្ថែមទៀត, ក៏ដូចជាក្នុងអវកាសទាំងនោះមានអ្វី, នរណានៅក្នុងនោះ? ប្រើវិធីសាស្ត្រនៃវិទ្យាសាស្ត្របច្ចុប្បន្នគឺពិបាកដឹងបានណាស់, វិទ្យាសាស្ត្រទំនើបនៅតែមិនអាចធ្វើចេញភស្តុតាងជាក់ស្តែង។ ប៉ុន្តែគ្រូឈីគង់ពួកយើងមួយចំនួននិងអ្នកដែលមានសីលគង់ពិសេសអាចមើលឃើញអវកាសដទៃបាន, ដោយសារតែមើលអវកាសដទៃគ្រាន់តែអាចប្រើបញ្ញាញាណដើម្បីមើលប៉ុណ្ណោះ, ប៉ុន្តែមិនអាចប្រើភ្នែកដើម្បីមើលបាន។

*សិស្ស៖ បណ្តាអវកាសសុទ្ធតែរួមបញ្ចូលលក្ខណៈពិសេស "សច្ចៈ-ករុណា-ខន្តី" មែនទេ?*

គ្រូ៖ ត្រូវ, អវកាសនីមួយៗសុទ្ធតែរួមបញ្ចូលលក្ខណៈពិសេសនៃ "សច្ចៈ-ករុណា-ខន្តី"។ មនុស្សដែលអនុលោមតាមប្រភេទលក្ខណៈពិសេសនេះ, ជាក់ស្តែងគឺជាមនុស្សល្អ; ទៅផ្លូវផ្ទុយមកវិញ, ជាក់ស្តែងគឺជាមនុស្សអាក្រក់; ដែលជ្រួតជ្រាបជាមួយនឹងគាត់ជាក់ស្តែងគឺជាអង្គត្រាស់ដឹង។

*សិស្ស៖ តើមនុស្សជាតិដំបូងគឺមកពីទីណា?*

គ្រូ៖ ចក្រវាលដំបូងគ្មានជាន់ថ្នាក់តាមខ្សែបណ្តោយច្រើនដូច្នេះ

ទេ, ក៏គ្មានជាន់ថ្នាក់តាមខ្សែផ្តេកច្រើនដូច្នេះផងដែរ, វាគឺយ៉ាងឯកតាណាស់។ នៅក្នុងដំណើរការអភិវឌ្ឍន៍និងប្រតិបត្តិការរបស់វាបានផ្តល់កំណើតដល់ជីវិត, ក៏ជាក់ស្តែងគឺជាជីវិតដំបូងបំផុតដែលពួកយើងនិយាយ, គាត់និងចក្រវាលគឺជ្រួតជ្រាបជាមួយគ្នា, គ្មានអ្វីដែលមិនល្អស្ថិតនៅ។ ជ្រួតជ្រាបនឹងចក្រវាល, ជាក់ស្តែងគឺដូចគ្នាជាមួយនឹងចក្រវាល, សីលគង់ទាំងអស់ក្នុងចក្រវាលគាត់សុទ្ធតែមាន។ ជាមួយនឹងការអភិវឌ្ឍន៍, វិវត្តន៍នៃចក្រវាល, ម្តងទៀតបានលេចឡើងឋានសួគ៌មួយចំនួន។ ក្រោយមក, លេចឡើងជីវិតកាន់តែច្រើនឡើងៗ, នៅជាន់ថ្នាក់ទាបរបស់ពួកយើងដើម្បីសម្តែង, ជាក់ស្តែងគឺបានបង្កើតឡើងក្រុមសង្គម, មានការទំនាក់ទំនងរវាងពួកគេជាមួយគ្នា។ នៅក្នុងដំណើរការវិវត្តន៍នេះ, មនុស្សមួយចំនួនបានកើតឡើងការផ្លាស់ប្តូរ, គម្លាតចេញពីចរិតពិសេសនៃចក្រវាលកាន់តែឆ្ងាយទៅៗ, ផ្លាស់ប្តូរមិនសូវល្អទៀត, ទេពអំណាចក៏នឹងតូចទៅ។ ដូច្នេះមនុស្សហាត់គង់ត្រូវតែសម្តែង "ត្រឡប់មកសច្ចៈ", ជាក់ស្តែងគឺវិលត្រឡប់មកស្ថានភាពដើម, ជាន់ថ្នាក់កាន់តែខ្ពស់, ជាក់ស្តែងកាន់តែជ្រួតជ្រាបនឹងចក្រវាល, សមត្ថភាពជាក់ស្តែងកាន់តែធំ។ ពេលនេះនៅក្នុងការវិវត្តន៍របស់ចក្រវាលជីវិតមួយចំនួនផ្លាស់ប្តូរទៅជាមិនល្អ, ក៏មិនអាចបំផ្លាញគាត់, បានគិតរកវិធីដើម្បីឱ្យគាត់ម្តងទៀតលើកកម្ពស់ឡើងជ្រួតជ្រាបជាមួយនឹងចក្រវាល, ទុកឱ្យគាត់ទៅជាន់ថ្នាក់មួយដែលទាបជាង, រងទុក្ខបន្តិច, លើកកម្ពស់ៗ។ ក្រោយមកបន្តមានមនុស្សមកដល់ជាន់ថ្នាក់

នេះ។ បន្ទាប់មកនៅក្នុងជាន់ថ្នាក់នេះម្តងទៀតកើតឡើងការបែងចែក, មនុស្សដែលចិត្តគំនិតផ្លាស់ប្តូរកាន់តែមិនល្អ, ជាន់ថ្នាក់នេះក៏រក្សាមិនជាប់ទៀត, ដូច្នេះបានបង្កើតថែមជាន់ថ្នាក់មួយទៀត។ ជាក់ស្តែងបែបនេះ, កាន់តែចុះទាប, បន្តិចម្តងៗបែងចែក, រហូតដល់ថ្ងៃនេះ, បានបង្កើតចេញជាន់ថ្នាក់មួយនេះដែលមនុស្សជាតិពួកយើងកំពុងរស់នៅ។ នេះជាក់ស្តែងគឺជាប្រភពដើមរបស់មនុស្សជាតិ។

## បទានុក្រម

ពន្យល់ពាក្យទាំងអស់ដោយបានអ្នកបកប្រែសរសេរតាមការយល់ឃើញរបស់ខ្លួនឯង, ដូច្នេះវាគ្រាន់តែសម្រាប់ជាឯកសារយោងតែប៉ុណ្ណោះ។

សម្រាប់រាល់ពាក្យទូទៅនៅពេលបង្ហាញគំនិតក្នុងពិភពបួសហាត់និយាយរួមនិងនៅក្នុងធម្មក្ខន្ធហ្វាលូនដាហ្វានិយាយដោយខ្មែរ។ ឧទាហរណ៍៖ វង់សកល, ភ្ជាប់ត្រា,...។ នៅចំណុចនេះអ្នកបកប្រែគ្រាន់តែខំប្រឹងបកស្រាយន័យខាងលើផ្ទៃតែមិនប៉ះពាល់ដល់អត្ថន័យខាងក្នុង។ សូមប្រិយមិត្តតាមរយៈការសិក្សាមហាធម៌, ការផ្តោះប្តូរក្នុងសិក្ខាសាលាចិត្តយល់ដឹងដើម្បីភ្ញាក់ដឹងអត្ថន័យរបស់ធម៌។

ពាក្យនិងឃ្លាពិបាកបកប្រែបានគ្បោះក្បាយណាស់, ធម្មតាជាពាក្យដែលទាក់ទងស្អិតល្មួតដល់វប្បធម៌ប្រទេសចិនឬក៏ជាប់ទាក់ទងក្នុងរចនាសម្ព័ន្ធភាសាចិន, ដូច្នេះក្នុងវចនានុក្រម, អក្សរខ្មែរគ្មានពាក្យស្មើ, ឬក៏ប្រសិនបើបកប្រែនឹងពិបាកចម្លងបានកម្លាំងនៃភាសា។ ឧទាហរណ៍៖ ជីវជួនជីនតានស៊ូ, តានតាវ, ជីនកាង,...។ ប៉ុន្តែដោយខ្មែរពាក្យដែលមានប្រភពអក្សរបាលៃ, សំស្ក្រឹត, អ្នកបកប្រែសូមសរសេរតាមប្រភពដើម។ ឧទាហរណ៍៖ បរមី,...។ ពាក្យដែលមានប្រភពពីបរទេសដែលមិនមែនជាភាសាចិន, អ្នកបកប្រែសូមសរសេរជាអក្សរអង់គ្លេស, ឧទាហរណ៍៖ Tom, Darwin, Galileo,...

មានពាក្យមួយចំនួនបានដាក់ក្នុងវង់ក្រចក () គឺជាពាក្យបន្ទាប់បន្សំដើម្បីអានបានរឿយ។ សញ្ញាសម្រង់ដោយសារអ្នកបកប្រែដាក់ចូលគឺជាសញ្ញាសម្រង់ទោល ‵ ′ ដើម្បីកុំឱ្យច្រឡំជាមួយសញ្ញាសម្រង់ទ្វេ ‶ ″ របស់អត្ថបទដើម។

**ក្រពេញស្រល់៖** ឬក៏ក្រពេញpinealគឺជាក្រពេញរាងស្រល់ស្រទាប់នៃប្រព័ន្ធendocrine។ វាស្ថិតនៅចន្លោះអឌ្ឍគោលខួរក្បាលនៃខួរក្បាល។

**ខ្សែវណ្ណ៖** (ឱសថបុរាណចិន) ផ្លូវណាមួយនៅលើដងខ្លួនដែលថាមពលសំខាន់ត្រូវបានគិតថានឹងហូរ, ហើយដូច្នោះចំណុចចាក់ម្ជុលវិទ្យាសាស្ត្រត្រូវបានចែកចាយ។

**គម្ពីរ៖** (ន)សាស្ត្រា, ច្បាប់, ធម្មវិន័យដែលរួបរួមដោយពួក, ដោយប៉ែក, ដោយផ្នែក។

**ចក្ខុ៖** (ន) អាយតនៈសម្រាប់មើល, សម្រាប់ឃើញរូបផ្សេងៗ (ភ្នែក)។

**ចរន្ត៖** (ន) ដំណើររត់ឬហូរ។

**ឈរគំនរ៖** ធ្វើលំហាត់ក្នុងឥរិយាបថឈរ។ លំហាត់បានពិពណ៌នានៅក្នុងលំហាត់ឈរឱបហ្វាលូន។

**ឈ្មោះរបស់ចលនា៖** Jieyin ភ្ជាប់ត្រា, Mi le shen yao មីឡឹកសន្ទឹងខ្នង, Rulai guan ding យូឡាយស្រោចកំពូល, Heshi រួមដប់, Zhang zhi qiankun បាតដៃចង្អុលមេឃនិងដី, Jin hou

fenshen ស្វាមាសបំបែកកាយ, Shuanglong xiahai គូនាគចុះសមុទ្រ, Pusa fu lian ព្រះពោធិសត្វកាន់ផ្កាឈូក, Luohan beishan អរហន្តលីភ្នំ, Jin gang pai shan ជិនកាងរុញភ្នំ, Die kou xiaofu ដៃពីត្រួតគ្នានៅពោះទាប, Tou qian baolun ឱបកង់ខាងមុខក្បាល, Fu qian baolun ឱបកង់ខាងមុខពោះ, Tou ding baolun ឱបកង់ខាងលើកបាល, Liang ce baolun ឱបកង់សងខាង, Danshou chongguan ដៃមួយលើកឡើងដាក់ចុះ, Tongshi chongguan លើកឡើងដាក់ចុះដំណាលគ្នា, Shuang shou tuidong falun ដៃទាំងពីររុញបង្វិលហ្វាលូន, Da shouyin ក្បាច់ដៃធំ, Shouyin zhi yi, er, san, ក្បាច់ដៃទីមួយ, ពីរ, បី, បួន , Jiachiពង្រឹង, Jiachi qiu zhuang Shentong ពង្រឹងទេពអំណាចរាងមូល, Jiachi zhu zhuang shentong ពង្រឹងទេពអំណាចរាងសសរ.

**ដង្ហើមគភ៌៖** នោះគឺមិនប្រើច្រមុះនិងមាត់ដើម្បីដកដង្ហើមទេប៉ុន្តែដកដង្ហើមដោយផ្ចិតដូចជាទារក។ មានន័យថាមិនដកដង្ហើមតាមច្រមុះនិងមាត់ទេប៉ុន្តែដូចជាទារក។

**ទ្វារ៖** ច្រកទ្វារ, ព្រំដែន។ ជាធម្មតាមានន័យថាជាការពិសោធន៍; បញ្ហាប្រឈម។

**ទិព្វ៖**(គុ) ដែលជារបស់ទេវតា, ដែលទាក់ទងពួកទេវតា, ដែលមានក្នុងទេវតា, ដូចជាត្រចៀកទិព្វ, ថ្នាំទិព្វ។

**ទូរវេទន៍៖**(បា សំ) នៈអារម្មណ៍ឆ្ងាយ, ដឹងពីចម្ងាយ។

**ទស្សនាទានវេលា-អវកាស៖** វេលា–អវកាសគឺជាគំរូគណិតវិទ្យាដែលរួមបញ្ចូលអវកាសវិមាត្របីជាមួយនឹងពេលវេលាវិមាត្រមួយដើម្បីបង្កើតរចនាសម្ព័ន្ធបង្រួបបង្រួមដែលហៅថាពេលវេលា–អវកាសបន្ត។

**តាវវត្តី**៖ សម័យបុរាណអាចសំដៅទៅលើអ្នកប្រាជ្ញនិងអ្នកអនុវត្តលទ្ធិតាវ; ជាពាក្យទូទៅសម្រាប់អ្នកដែលរៀនតាវ;

**ឋិតិវន្តគង់៖** ហាត់គង់ក្នុងស្ថានភាពឋិតិវន្ត, ស្ងប់, ឥរិយាបថថេរ។ ផ្ទុយមកវិញគឺជាថាមវន្តគង់។

**ថាយយ៉ាង៖** (1)ចំណុចចាក់ម្ជុលវិទ្យាសាស្ត្រនៅសងខាង, ពីកន្ទុយភ្នែកខិតមកក្រោយពីសុន, (2) ព្រះអាទិត្យ

**នីវ៉ាន, នីវ៉ានគុង(វិមាននីវ៉ាន)៖** ពាក្យថាខាងតាវវង្សសំដៅលើកន្លែងមួយនៅក្នុងរាងកាយ, ស្របគ្នាជាមួយនឹងទីតាំងក្រពេញស្រល់(pineal endocrine)។

**ណឺរូន**៖ កោសិកាប្រសាទ(កោសិកាខួរក្បាល)។

**ដើរតានតាវ៖** ដើរតាមវិធីហាត់តាន។

**បរមាណើយ៖** ស្តង់ដារ; លក្ខណៈវិន្និច្ឆ័យ; គំរូ។

**បង្រៀនឯកតា**៖ ការផ្ទេរបង្រៀនទៅសិស្សម្នាក់។

**បាតដៃផ្កាឈូក**៖ ដៃឈូក, ដៃត្រូវលាតសន្ធឹងតាមបែបធម្មជាតិដោយម្រាមដៃកណ្តាលចូលបន្តិច, ម្រាមដៃមិននៅជាប់គ្នាទេ,

ចាំបាច់ត្រូវមើលរូបថតនិងវីដេអូឱ្យបានដិតដល់ដើម្បីធ្វើឱ្យបានត្រឹមត្រូវ។

**ប្រាកដនិយម**៖ ភាពពិត, ភាពជាក់ស្តែង, ដែលពិត, ពិតប្រាកដ។

**បាំងជញ្ជាំងមើលវត្ថុ**៖ ការមើលឃើញវត្ថុឆ្លងកាត់ជញ្ជាំង, មើលឃើញឆ្លងកាត់វត្ថុជារបាំង (ន័យលើផ្ទៃ)

**ប៉ាយហួយ**៖ បៃហួយគឺជាកន្លែងដែលមានទីតាំងស្ថិតនៅចំកណ្តាលនៃមកុដនៃក្បាល។

**ពង្រឹង**៖ ធ្វើឱ្យកាន់តែរឹងមាំ។

**ពោះទាប**៖ គឺជាតំបន់ទាបបំផុតនៃពោះខាងក្រោមផ្ចិតឬតំបន់អាងត្រគាក។

**មហិមា**៖(គុ) ធំសម្បើម, អស្ចារ្យ។

**មាគ៌ា**៖ ផ្លូវ។

**យ័ន**៖ អង្គភាពមូលដ្ឋាននៃប្រាក់នៅក្នុងប្រទេសចិន។

**រាងកាយវិញ្ញាណ**៖ ទម្រង់ជីវិតខាងវិញ្ញាញ។

**រ៉ឺន-ទូ**៖ ឈ្មោះនៃខ្សែវណ្ណពីររត់នៅក្រោមស្បែក, មួយនៅខាងមុខតាមបណ្តោយពាក់កណ្តាលនៃរាងកាយ, មួយនៅពីក្រោយតាមបណ្តោយពាក់កណ្តាលរាងកាយ។

**លោកីយ៍**៖(គុ) ដែលមានក្នុងលោក, ដែលជាប់ទាក់ទងដោយលោក, សម្រាប់លោក។

**វគ្គ**៖ ជាពាក្យបង្រៀនសម្រាប់ងាយចាំនិងសូត្រ។ ក្នុងសៀវភៅនេះ វគ្គត្រូវសូត្រម្តងមុនពេលធ្វើលំហាត់នីមួយៗ។ សិក្ខាកាមត្រូវស្តាប់នូវការបញ្ចេញសំឡេងចិនក៏ដូចជាសូត្រឡើងវិញតាមសំឡេងចិន (មាននៅក្នុងខ្សែអាត់តន្ត្រីនៃលំហាត់)។

**វត្តី**៖ ការកោតសសើរចំពោះមនុស្សម្នាក់ដែលមានគុណសម្បត្តិឬទេពកោសល្យបុគ្គល។

**វង្ស**៖(ន)ពូជ, ត្រកូល, អំបូរ។

**វប្បធម៌**៖(ន) ការផ្សាំបណ្តុះចំណេះវិជ្ជាឱ្យបានលូតលាស់ចំរើន។

**វិវត្តន៍**៖(បា)(ន) ការប្រែប្រួល, ការផ្លាស់ប្តូរ, បម្រែបម្រួល។

**វាយមិនសងដៃ, ជេរមិនតមាត់**៖ ត្រូវគេវាយដំមិនវាយសងវិញ, ត្រូវបានគេស្តីបន្ទោសនិងជេរប្រមាថមិននិយាយតបវិញ។

**សមកាលកម្ម**៖ ដើម្បីនាំឱ្យមានលក្ខណៈឬការអនុលោមមួយ; ដើម្បីបង្កឱ្យមានភាពដូចគ្នារវាង; ដើម្បីក្លាយជាស្រដៀងគ្នា។

**សានកិន**៖ ចំណុចចាក់ម្ជុលវិទ្យាសាស្ត្រនៅគល់ច្រមុះ, ក្រោមចិញ្ចើម។

**សច្ចៈ-ករុណា-ខន្តី**៖ សច្ចៈ→ សច្ចៈធម៌, សេចក្តីពិត, ស្មោះត្រង់; ករុណា→ ការអាណិតអាសូរ, ចិត្តមេត្តា,សុភាពរាបសា; ខន្តី→ ការអត់ធ្មត់, បន្ទាបខ្លួន(នេះគ្រាន់តែជាការបង្ហាញលើផ្ទៃនៃពាក្យនីមួយៗបុណ្ណោះ)។

**សាវនដ្ឋាន**៖ បន្ទប់ធំសម្រាប់ការប្រជុំសាធារណៈឬការសម្តែង។

**សុជីវធម៌៖** សំ(ន) ការរស់នៅដែលល្អ គឺចំណេះ, សណ្ដាប់ធ្នាប់គួរសមក្នុងកិច្ចការប្រាស្រ័យជាមួយនឹងអ្នកដទៃ។

**ហ្វាលូន៖** កង់ធម៌ឬក៏ធម្មចក្រ។

**ហួយយីន៖** ចំណុចហ៊ុយយិនស្ថិតនៅចន្លោះរន្ធគូថនិងប្រដាប់ភេទ។ ការប្រមូលផ្ដុំមានន័យថាការប្រមូលផ្ដុំ។ យិនមានន័យថាប្រដាប់ភេទនិងរន្ធគូថ។ ការប្រមូលផ្ដុំនេះត្រូវបានគេចាត់ទុកថាជាផ្នែកយិននៃរាងកាយហើយវាក៏ជាទីតាំងចាប់ផ្ដើមនៃសៀគ្វីញ៉ាម, ជីពចរនិងដុក។

**អឌ្ឍសម្បជញ្ញៈ៖** គ្មានសម្បជញ្ញៈ។

**អតិសុខុមប្រាណ៖** អតិ៖ បា, សំ(និ) កន្លង, ក្រៃ, ពេក, ក្រៃពេក, ពន់ពេក, ក្រៃលែង, លើស, លើសលែង, ហួស, ហួសពេក, ផុត, បំផុត, ណាស់។ សុខុម៖ បា,សំ(គុ) ល្អិត, ឆ្មារ, ម៉ដ្ឋ, ប៉ផូរ, ផូរផង់, ល្វន់តូចណាស់, ចង្អៀតក្រយល់, ឈ្លាសវៃ។ ប្រាណ៖ បា, សំ(ន) សត្វ, ជីវិត, ខ្យល់ដកដង្ហើម, កម្លាំង។

**អតិអារម្មណ៍៖** លើសពីជួរនៃអ្វីដែលអាចដឹងដោយអង្គញាណ; មិនមែនស្ថិតក្នុងពិភពសារធាតុដែលអាចពិសោធន៍បាន។

**អនុវរភាព៖** ការកើនឡើងនៃទំហំនៃសំយោលនៃប្រពន្ធមួយដែលស្ថិតនៅក្រោមឥទ្ធិពលនៃកម្លាំងតាមកាលកំណត់ដែលហ្វ្រេកង់ស៍គឺជិតនឹងហ្វ្រេកង់ស៍ធម្មជាតិ។

**អរិយធម៌៖**(បា)(ន) ភាពនាំឱ្យមានសេចក្ដីសុខចំរើនសំបូររុងរឿង។

**អា-Q៖** ឈ្មោះតួអង្គនៅក្នុងរឿងចិន "រឿងពិតរបស់អា-Q", ជាញឹកញាប់ត្រូវបានគេយល់ថាជាគំរូល្ងីល្ងើ។

1. Fo zhan qian shou fa លំហាត់ព្រះពុទ្ធបង្ហាញដៃមួយពាន់, Shenshen heyi (កាយនិងវិញ្ញាណរួបរួមជាមួយ), Dongjing suiji (ចលនាបណ្ដោយតាមយន្តការឈើ), Dingtian duzun (ខ្ពស់ធំដូចកំពូលមេឃថ្លៃថ្នូរតែមួយ), Qianshou Fo li (ព្រះពុទ្ធបញ្ចេញដៃមួយពាន់)។

2. Falun zhuangfa លំហាត់ឈរឱបហ្វាលូន Sheng hui zeng li (បង្កើតបញ្ញាបង្កើនកម្លាំង), Rong xin qing ti (ចិត្តគ្របដណ្ដប់រាងកាយស្រាល), Si miao si wu (ដូចជាអាថ៌កំបាំងដូចជាភ្ញាក់ដឹង), Falun chu qi (ហ្វាលូនចាប់ផ្ដើមដំណើរការ)។

3. Quantong liangji fa ស្រោចស្រពឡះពីរប៉ូល: Jinghua benti (បន្សុទ្ធរាងកាយ), Fa kai ding di (ធម៌បើកលើកំពូលនិងក្រោមបាត), Xin ci yi meng (ចិត្តមេត្តាគំនិតខ្លាំងក្លា), Tongtian che di (ធ្លាយឈានដល់មេឃនិងចុះដល់បាតដី)។

4. Falun Zhou tian fa លំហាត់វង់សកលហ្វាលូន, Xuanfa zhi xu (បង្វិលធម៌រហូតដល់គ្មាន), Xin qing si yu (ចិត្តថ្លាដូចត្បូង), Fan ben guizhen (ត្រឡប់កាយមកសច្ចៈ), Youyou shi qi (ជាបណ្ដើរលើកឡើង)។

5. Shentong jiachi fa លំហាត់ពង្រឹងទេពអំណាច៖ Youyi wuyi (គំនិតដូចជាមានដូចជាគ្មាន), Yin suiji qi (ភ្ជាប់ត្រាបណ្ដោយតាមយន្តការឈើ), Si kong fei kong (ដូចជាគ្មានដូចមិនត្រូវជាគ្មាន), Dongjing ru yi (ចលនាយ៉ាណាដូចបំណង)។

**Copyright © by Li Hongzhi**

http://falundafa.org
http://kh.falundafa.org

Translated in khmer November 19, 2020.